# បរមត្ថទីបនី

# អដ្ឋកថាព្រះអភិធម្មបិដក

## តតិយភាគ

## ៩

រចនាដោយព្រះពុទ្ធឃោសាចារ្យ

ផ្ដើមប្រែរៀបរៀងដោយខ្ញុំព្រះករុណា ខ្ញុំបាទ សុន្ទរ៍-សារៈមឿន

ព. ស. ២៥៥៧ គ. ស. ២០១៣

# បរមត្ថទីបនី

## តតិយភាគ

៩

ព. ស.

២៥៥៧

គ. ស.

២០១៣

# បរមត្ថទីបនី

# អដ្ឋកថាព្រះអភិធម្មបិដក

# ឈ្មោះថា  បញ្ចបករណ៍

## ( ធាតុកថា -បុគ្គលបញ្ញត្តិ -កថាវត្ថុ)

## តតិយភាគ

## ៩


រចនាដោយព្រះពុទ្ធឃោសាចារ្យ

ផ្តើមប្រែរៀបរៀងដោយលោក

កល្យាណធម្មោ  សុន្ទរ៍-សារមៀន



ព. ស. ២៥៤៨ គ. ស. ២០១៣

# សេចក្តីបញ្ជាក់

គម្ពីរ **អដ្ឋកថាព្រះអភិធម្ម** ជាពាក្យអធិប្បាយសេចក្តីក្នុងព្រះអភិ-ធម្មបិដក ចាត់ជាភាគធំៗ មាន ៣ ភាគ គឺ

**១.បឋមភាគ** ឈ្មោះ **អដ្ឋសាលិនី** អធិប្បាយគម្ពីរ ***ធម្មសង្គណី***

**២.ទុតិយភាគ** ឈ្មោះ **សម្មោហវិនោទនី** អធិប្បាយគម្ពីរ ***វិភង្គ***

**៣.តតិយភាគ** ឈ្មោះ **បរមត្ថទីបនី** អធិប្បាយគម្ពីរ ***បញ្ចបករណ៍*** តាំងពី ***ធាតុកថា*** រហូតដល់ចប់គម្ពីរ ***បដ្ឋាន*** ទាំងអស់ ។

បើចាត់ជាភាគតូចៗ មាន ១២ ភាគ ដោយបែងចែកចេញពីភាគធំៗ ទាំង ៣ ខាងលើនេះ ក្នុងមួយភាគៗ មាន ៤ លេខ ខុសគ្នាទៅនឹងការបោះពុម្ពមុនៗ ។ ឯសៀវភៅដែលលោកអ្នកកំពុងអាននេះ ជាគម្ពីរអដ្ឋ-កថា ***អភិធម្មបិដក តតិយភាគ ៩*** កើតឡើងដោយស្នាព្រះហស្តនៃ ***ព្រះពុទ្ធឃោសាចារ្យ*** ជាជនជាតិឥណ្ឌា បានរចនានៅឯប្រទេសសិរីលង្កា ក្រោយការបរិនិព្វានរបស់ព្រះពុទ្ធជាង ៩០០ឆ្នាំ ។ ឯរូបខ្ញុំផ្ទាល់វិញ គ្រាន់តែជាអ្នកផ្តើមប្រែសម្រួលរៀបរៀង ជាបណ្តោះអាសន្ន សម្រាប់អ្នកដែលត្រូវការសិក្សារៀនសូត្រតែប៉ុណ្ណោះ ព្រោះហេតុដូច្នេះ ខ្ញុំ***សូមបញ្ជាក់*** និងសូមទោសជាមុន ចំពោះអ្នកអាន និងអ្នកសិក្សាជាទីគោរពថា ខ្ញុំពុំមានសមត្ថភាពនៃការចេះដឹងគ្រប់គ្រាន់ ដូចសេចក្តីនៃធម៌ដែលមាននៅក្នុងសៀវភៅនេះទេ ថែមទាំងសមត្ថភាពនៃការប្រែសម្រួល និងរៀបរៀង

នេះទៀត មិនអាចគេចផុតពីការខុសឆ្គាំឆ្គងបានឡើយ ។ ការខុសឆ្គាំឆ្គងទាំងនុ៎ះ មានដោយអចេតនាខ្លះ ដោយការចេះមិនដល់ខ្លះ តែខ្ញុំយល់ឃើញថា **មានប្រសើរជាងគ្មាន** ព្រោះសៀវភៅដែលរេនូវព្រះអភិធម្មបិដកបែបនេះ មិនទាន់ដែលមានគ្រប់គ្រាន់ក្នុងប្រទេសយើងទេ ដូច្នេះយើងក៏អាចឧទាហរណ៍បានថា ៖

* សម័យណា ដែលមានភាពអន្ធការ សូម្បីតែពន្លឺអំពិលអំពែក ក៏អាចភ្លឺបានដែរ ។

* សម័យណា គ្មានដើមឈើ គេក៏អាចយកដើមល្ហុង ធ្វើជាដើមឈើបានដែរ ។ ល ។ (ស្រីហិតោបទេស) ។

ព្រោះហេតុដូច្នេះ ខ្ញុំសូមផ្ញើនូវគម្ពីរនេះ ដល់លោកអ្នកសិក្សា និងវិញ្ញូជនទាំងឡាយ ជួយកែសម្រួល សម្រាប់សិក្សាតរៀងទៅ ។ ដើម្បីសម្រួលដល់ការបូកសរុបមតិកែតម្រូវ ក្នុងអត្ថបទនេះ សូមមេត្តាជ្រាបដូចតទៅ ៖

១-សូមសរសេរឈ្មោះ ទីកន្លែង និងថ្ងៃ ខែ ឆ្នាំ ដែលកែសម្រេចនៅលើក្រដាសដែលផ្ញើមក ។

២-ចុះលេខទំព័រ បន្ទាត់ ក្នុងតារាងលេខ ១ និងលេខ ២ ។ ចំពោះសេចក្ដី ពាក្យ ឃ្លា ឬអក្ខរាវិរុទ្ធត្រង់ណា ដែលយល់ថា មិនទាន់ត្រឹមត្រូវ សូមសរសេរចុះក្នុងតារាងលេខ ៣ ។ ចំណែកពាក្យដែលយល់ថា គួរកែមកជាយ៉ាងណាវិញនោះ សូមសរសេរចុះក្នុងតារាងលេខ ៤ ។

៣-ប្រសិនបើ ការកែតម្រូវនោះ មានឯកសារបញ្ជាក់ សូមចុះឈ្មោះឯកសារនោះ ក្នុងតារាងលេខ ៥ ។

៤-នៅក្នុងតារាងលេខ ៦ សម្រាប់បញ្ជាក់បន្ថែម ចំពោះករណីពិសេសណា ដែលប្រាថ្នាចង់បញ្ជាក់បន្ថែម ។

៥-សូមផ្ញើកំណែមកខ្ញុំ ដោយការទាក់ទង តាមទូរសព្ទដែលមាននៅក្នុងសៀវភៅនេះស្រាប់ ។

* ប្រសិនបើ នៅក្នុងសៀវភៅនេះ មានការខុសទំព័រលេខរៀង អក្សរដាច់ ឬមើលមិនសូវច្បាស់ជាដើម នុ៎ះពុំមែនជាកំហុសនៃសំណៅដើមរបស់ខ្ញុំឡើយ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣

**ខ្ញុំព្រះករុណា ខ្ញុំបាទ *សុន្ទរ៍ សាមឿន***

សូមអរព្រះគុណ និងអរគុណ

# តារាងកែតម្រូវ “ ឲ ”

# នាមឈ្មោះអ្នកជួយពិនិត្យផ្ទៀងផ្ទាត់កែសម្រួល

## អដ្ឋកថាតតិយភាគ ៩ នេះ មាន ៖

-ភិក្ខុសាមណេរជាពហូសូតក្នុង **វត្តធុតង្គ** (ចម្ការដូង) មាន ៩រូប

-ភិក្ខុសាមណេរជាពហូសូតក្នុង **វត្តនិរោធារាមមង្គលវ័ន** មាន ៦ រូប

-ភិក្ខុខន្តិជាតិកោ **វ៉ៃ ភិរក្ស** -ធម្មាចារ្យ ធម្មានន្ទោ **សួង សឿ**

-ភិក្ខុធម្មរក្ខិតោ **គង់ ថន** -ភិក្ខុជោតញ្ញាណោ **វ៉ែត សុផាន់**

-ឧបាសក **ពុង ស៊ីម** -ឧបាសក **ដាំ កុយ**

-ឧបាសក **សំរ៉ែង ចំណ្ណា** -ឧបាសក **វឿង សិរីសុគន្ធ**

-អ្នកគ្រូ **ធី សុធី** -ឧបាសក **ង៉ូចសុខុម**

-ឧបាសក **វៀម រដ្ឋា** ។

## អ្នកមានឧបការៈក្នុងការងារធម្មទាននេះ

-ភិក្ខុបញ្ញាបទីបោ **ព្រឿង ប៊ុនធឿន** -ភិក្ខុខន្តិជាតិកោ **វ៉ៃ ភិរក្ស**

-ឧបាសក **ថោង ល្អសាន្ត** -ឧបាសិកា **លី ស៊ីវង្ស** ជាដើម

-ឧបាសិកា **ងុន ស៊ូគី** ជាដើម -លោក **បាន សុផាន** និងភរិយា

-ក្រុមទ្រទ្រង់ព្រះត្រៃបិដក មានលោក **សួន ឱសថ** ជាដើម

-ភិក្ខុសាមណេរ **វត្តគីរីមង្គលចាស់** ជាដើម

-លោក **ហោង សុវណ្ណរ៉ា** និងក្រុមគ្រួសារ

-ឧបាសក **ស្រុង ចាន់ណា** និងក្រុមគ្រួសារ

-ឧបាសក **ម៉ៅ ផុន** ហៅ **ពុយ** និងសហការី ។

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអនុមោទនា ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសន្ដានចិត្តដ៏ល្អរបស់គុណម្ចាស់ ញាតិញោមជាពុទ្ធបរិស័ទទាំងក្នុង និងក្រៅប្រទេស ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ជួយពិនិត្យកែសម្រួល ព្រមទាំងចំណាយរូបិយវត្ថុជាដើម ដើម្បីជំរុញឲ្យអត្ថបទនៃគម្ពីរនេះ ចេញជារូបរាងឡើង ។

បន្ទាប់ពីតតិយភាគ ៩ នេះទៅ ខ្ញុំនឹងដំណើរការបោះពុម្ពនូវតតិយភាគ ១០ ជាបន្តទៀត ។

អាស្រ័យហេតុនេះ បើព្រះគុណម្ចាស់ ញាតិញោមត្រូវការចូលប្រាក់ដើម្បីថតចម្លងជាធម្មទាន ឬយកផ្ទាល់ខ្លួន ឬក៏យកទៅតម្កល់តាមវត្តនានា សូមមេត្តាទាក់ទងតាមរយៈទូរសព្ទដូចខាងក្រោមនេះ ៖

០៩២ ៩០ ៨២ ៦៥

០៩៧ ២៣ ៣០ ២១៥

០១៦ ៨៦ ៥២ ៣៨

# ឧទ្ទិសកថា

ខ្ញុំសូមផ្សាយនូវមហាកុសលធម្មទាននេះ ប្រគេន ថ្វាយ ជូន ចំពោះ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ, ព្រះថេរានុត្ថេរៈគ្រប់រូប ទាំងក្នុង ទាំងក្រៅ ប្រទេស, **អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រក្នុងបច្ចុប្បន្ន** រាជរដ្ឋាភិបាល ដែលមានសម្តេចតេជោ **ហ៊ុន សែន** ជាប្រមុខ និងមន្ត្រីរាជការគ្រប់ៗ ស្ថាប័ន, ព្រមទាំងពុទ្ធបរិស័ទទាំងក្នុងប្រទេស ទាំងក្រៅប្រទេស មានលោក គ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាដើម មួយអន្លើដោយសព្វសត្វទាំងអស់ សូម ទ្រង់ត្រេកអរ និងត្រេកអរ អនុមោទនា យកចំណែកបុណ្យធម្មទាននេះ គ្រប់ៗ រូប គ្រប់ៗ អង្គ គ្រប់ៗ គ្នា កុំបីខានឡើយ ។

**ដោយអំណាចនៃមហាកុសលផលធម្មទាននេះ សូមឱ្យ ៖**

**-សត្វទាំងឡាយ កុំមានពៀរនឹងគ្នា មានតែសេចក្តីសុខ កុំមានទុក្ខ**

**-សត្វទាំងឡាយ កុំព្យាបាទគ្នា កុំមានការចង្អៀតចង្អល់នឹងគ្នា**

**-សត្វទាំងឡាយ មានអាយុវែង សម្រេចដោយសម្បត្តិទាំងឡាយ**

**-សត្វទាំងឡាយ រក្សានូវខ្លួន ឱ្យបានជាសុខតរៀងទៅ ៕**

..........................................................................................................................................................................................

**តារាងកែតម្រូវ** ថ្ងៃទី ....... ខែ ..... ឆ្នាំ ...

**តតិយភាគ ៩** ឈ្មោះ .........................

សម្រាប់បោះពុម្ពលើកទី ៣ អាសយដ្ឋាន ..................

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ | ឯកសារយោង | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|
| | | | | | |

# បរមត្ថទីបនី

## អដ្ឋកថាព្រះអភិធម្មបិដក

## តតិយភាគ ៩

## ធាតុកថាបករណ៍

មាតិកាធម៌ ទំព័រ


អារម្ភកថា ..... ..... ..... ..... ..... ..... ..... ..... ..... ..... ... ១


### ១.អដ្ឋកថាមាតិកា

### ២.អដ្ឋកថានិទ្ទេសវារៈ

### ១.ពណ៌នាអំពីសង្គហាសង្គហបទនិទ្ទេស


១.ពណ៌នាអំពីខន្ធបទនិទ្ទេស ..... ..... ..... ..... ..... ..... ..... . ៨

២. ,, អាយតនបទនិទ្ទេស ..... ..... ..... ..... ..... ..... . ១១

៣. ,, សច្ចនិទ្ទេស ..... ..... ..... ..... ..... ..... ..... .. ១៣

៤. ,, ឥន្ទ្រិយនិទ្ទេស ..... ..... ..... ..... ..... ..... ..... ១៣

៥. ,, បដិច្ចសមុប្បាទនិទ្ទេស ..... ..... ..... ..... ..... ... ១៤

២. ,, សង្គហិតេន អសង្គហិតបទនិទ្ទេស ..... ..... ..... .. ១៨

៣. ,, អសង្គហិតេន សង្គហិតបទនិទ្ទេស ..... ..... ..... .. ២៦

៤. ,, សង្គហិតេន សង្គហិតបទនិទ្ទេស ..... ..... ..... ..... ៣១

## អដ្ឋកថាព្រះអភិធម្មបិដក

មាតិកាធម៌ ទំព័រ


៥.ពណ៌នាអំពី អសង្គហិតេន អសង្គហិតបទនិទ្ទេស ..... ..... ..... . ៣៣

៦. ,, សម្បយោគវិប្បយោគបទនិទ្ទេស ..... ..... ..... ..... ៣៨

៧. ,, សម្បយុត្តេន វិប្បយុត្តបទនិទ្ទេស ..... ..... ..... .... ៤៧

៨. ,, វិប្បយុត្តេន សម្បយុត្តបទនិទ្ទេស ..... ..... ..... ... ៥០

៩. ,, សម្បយុត្តេន សម្បយុត្តបទនិទ្ទេស ..... ..... ..... . ៥១

១០. ,, វិប្បយុត្តេន វិប្បយុត្តបទនិទ្ទេស ..... ..... ..... .... ៥៣

១១. ,, សង្គហិតេន សម្បយុត្តវិប្បយុត្តបទនិទ្ទេស ..... ..... . ៥៤

១២. ,, សម្បយុត្តេន សង្គហិតាសង្គហិតបទនិទ្ទេស ..... ..... ៥៦

១៣. ,, អសង្គហិតេន សម្បយុត្តវិប្បយុត្តបទនិទ្ទេស ..... .... ៥៧

១៤. ,, វិប្បយុត្តេន សង្គហិតាសង្គហិតបទនិទ្ទេស ..... ...... ៥៨

ពាក្យនិគម (ធាតុកថា) ..... ..... ..... ..... ..... ..... ..... ..... ៦០


## អដ្ឋកថានៃបុគ្គលបញ្ញត្តិបករណ៍


អារម្ភកថា ..... ..... ..... ..... ..... ..... ..... ..... ..... ..... . ៦១

១.ពណ៌នាអំពីមាតិកាឧទ្ទេសវារៈ ..... ..... ..... ..... ..... ..... ៦២

បញ្ញត្តិ ៦ ក្រៅពីព្រះបាលី (បិដក) ..... ..... ..... ..... ..... ..... . ៦៣

បញ្ញត្តិ ៦ តាមន័យរបស់អាចារ្យ ..... ..... ..... ..... ..... ..... .. ៦៦

# បរមត្ថទីបនី


មាតិកាធម៌ ទំព័រ

ឧបនិធាបញ្ញត្តិ ..... ..... ..... ..... ..... ..... ..... ..... ..... .... ៦៨

ន័យម្យ៉ាងទៀត បញ្ញត្តិ ៦ របស់អាចារ្យ .... ..... ..... ..... .... .... ៦៩

២.អដ្ឋកថានិទ្ទេសវារៈ ..... ..... ..... ..... ..... ..... ..... .. ៧៥

## ១.អដ្ឋកថាឯកកនិទ្ទេស អធិប្បាយបុគ្គល ១ ជំពូក

ពណ៌នាអំពី សមយវិមុត្តបុគ្គល ..... ..... ..... ..... ..... ..... .... ៧៥

,, អសមយវិមុត្តបុគ្គល ..... ..... ..... ..... ..... ..... . ៨០

,, កុប្បធម្មបុគ្គល ..... ..... ..... ..... ..... ..... ..... . ៨២

,, អកុប្បធម្មបុគ្គល ..... ..... ..... ..... ..... ..... ..... ៨៦

,, បរិហានធម្មបុគ្គល និងអបរិហានធម្មបុគ្គល ..... ..... . ៨៧

,, ចេតនាភព្វបុគ្គល ..... ..... ..... ..... ..... ..... .... ៨៨

,, អនុរក្ខនាភព្វបុគ្គល ..... ..... ..... ..... ..... ..... ... ៨៨

,, បុថុជ្ជនបុគ្គល ..... ..... ..... ..... ..... ..... ..... .. ៩១

,, គោត្រភូបុគ្គល ..... ..... ..... ..... ..... ..... ..... . ៩២

,, ភយូបរតបុគ្គល និងអភយូបរតបុគ្គល ..... ..... ..... . ៩២

,, អភព្វាគមនបុគ្គល និងភព្វាគមនបុគ្គល ..... ..... ..... ៩៥

,, និយតបុគ្គល និងអនិយតបុគ្គល ..... ..... ..... ..... . ៩៧

,, បដិបន្នកបុគ្គល ..... ..... ..... ..... ..... ..... ..... . ៩៨

មាតិកាធម៌ ទំព័រ

ពណ៌នាអំពីសមសីសីបុគ្គល ..... ..... ..... ..... ..... ..... ..... ៩៩
,, ឋិតកប្បីបុគ្គល ..... ..... ..... ..... ..... ..... ..... . ១០២
,, អរិយបុគ្គល ..... ..... ..... ..... ..... ..... ..... ... ១០៦
,, សេក្ខបុគ្គល និងអសេក្ខបុគ្គល ..... ..... ..... ..... . ១០៦
,, តេវិជ្ជបុគ្គល និងឆឡភិញ្ញបុគ្គល ..... ..... ..... ..... ១០៧
,, សម្មាសម្ពុទ្ធបុគ្គល ..... ..... ..... ..... ..... ..... .. ១១០
,, បច្ចេកសម្ពុទ្ធបុគ្គល ..... ..... ..... ..... ..... ..... . ១១២
,, ឧភតោភាគវិមុត្តបុគ្គល ..... ..... ..... ..... ..... ... ១១១
,, បញ្ញាវិមុត្តបុគ្គល ..... ..... ..... ..... ..... ..... .... ១១៤
,, កាយសក្ខីបុគ្គល ..... ..... ..... ..... ..... ..... ..... ១១៥
,, ទិដ្ឋិប្បត្តបុគ្គល ..... ..... ..... ..... ..... ..... ..... . ១១៥
,, សទ្ធាវិមុត្តបុគ្គល ..... ..... ..... ..... ..... ..... .... ១១៨
,, ធម្មានុសារីបុគ្គល ..... ..... ..... ..... ..... ..... ... ១២១
,, សទ្ធានុសារីបុគ្គល ..... ..... ..... ..... ..... ..... .. ១២២
,, សត្តក្ខត្តុំបរមបុគ្គល ..... ..... ..... ..... ..... ..... . ១២៧
,, កោលំកោលបុគ្គល ..... ..... ..... ..... ..... ..... . ១២៩

# បរមត្ថទីបនី


| មាតិកាធម៌ | ទំព័រ |
| --- | --- |
| ពណ៌នាអំពីឯកពីជីបុគ្គល ..... ..... ..... ..... ..... ..... ..... . | ១៣០ |
| ,, សកទាគាមីបុគ្គល ..... ..... ..... ..... ..... ..... .. | ១៣៤ |
| ,, អនាគាមីបុគ្គល ..... ..... ..... ..... ..... ..... .... | ១៣៧ |
| ,, អន្តរាបរិនិព្វាយីបុគ្គល ..... ..... ..... ..... ..... .... | ១៣៩ |
| ,, ឧបហច្ចបរិនិព្វាយីបុគ្គល ..... ..... ..... ..... ..... . | ១៣៩ |
| ,, អសង្ខារបរិនិព្វាយី និងសសង្ខារបរិនិព្វាយីបុគ្គល ..... | ១៣៩ |
| ,, ឧទ្ធំសោតោអកនិដ្ឋគាមីបុគ្គល ..... ..... ..... ..... . | ១៤០ |


**២.អដ្ឋកថាទុកនិទ្ទេស** អធិប្បាយបុគ្គល ២ ជំពូក


| | |
| --- | --- |
| ពណ៌នាអំពីបុគ្គលចូលចិត្តក្រោធជាដើម ..... ..... ..... ..... .... | ១៥១ |
| ,, អហិរិកបុគ្គល គឺអ្នកមិនមានហិរិជាដើម ..... ..... .... | ១៥២ |
| ,, អក្កោធនបុគ្គល គឺបុគ្គលអ្នកមិនក្រោធ .... ..... ...... | ១៥៤ |
| ,, បុគ្គលរកបានដោយលំបាក ២ ជំពូក ..... ..... ..... .. | ១៥៤ |
| ,, បុគ្គលឱ្យឆ្អែតបានដោយលំបាក ២ ជំពូក ..... ..... ... | ១៥៧ |
| ,, បុគ្គលឱ្យឆ្អែតបានដោយងាយ ២ ជំពូក ..... ..... ... | ១៥៨ |


**៣.អដ្ឋកថាតិកនិទ្ទេស** អធិប្បាយបុគ្គល ៣ ជំពូក


| | |
| --- | --- |
| ពណ៌នាអំពីបុគ្គលមិនមានសេចក្ដីសង្ឃឹមជាដើម ..... ..... ..... . | ១៦៣ |
| ,, គិលានូបមបុគ្គលជាដើម ..... ..... ..... ..... ..... . | ១៦៨ |

មាតិកាធម៌ ទំព័រ

ពណ៌នាអំពីកាយសក្ខីបុគ្គលជាដើម ..... ..... ..... ..... ..... .. ១៧២
,, គូថភាណីបុគ្គលជាដើម ..... ..... ..... ..... ..... .. ១៧៣
,, អរុក្ខូបមចិត្តបុគ្គលជាដើម ..... ..... ..... ..... ..... ១៧៧
,, អន្ធបុគ្គល គឺបុគ្គលដែលខ្វាក់ជាដើម ..... ..... ..... . ១៨២
,, បុគ្គលដែលមានបញ្ញាប្រៀបដូចភាជនៈផ្កាប់ជាដើម ... ១៨៣
,, បុគ្គលមានរាគៈមិនទាន់ទៅប្រាសហើយជាដើម ..... . ១៨៨
,, បុគ្គលអ្នកប្រៀបដូចគំនូសលើថ្មជាដើម ..... ..... .... ១៩០
,, បុគ្គលប្រៀបដូចសំពត់សម្បកឈើ ៣ ប្រភេទ ..... ... ១៩៣
,, ,, ,, សំពត់ដែនកាសី ៣ ប្រភេទ ..... ..... ១៩៦
,, បុគ្គលដែលប្រមាណបានដោយងាយជាដើម ..... ..... ១៩៧
,, បុគ្គលមិនគួរសេពគប់ជាដើម ..... ..... ..... ..... .. ២០០
,, បុគ្គលដែលគួររង្កៀសជាដើម ..... ..... ..... ..... .. ២០២
,, បុគ្គលមានប្រក្រតីធ្វើឱ្យបរិបូណ៌ក្នុងសីលជាដើម ..... . ២០៥
,, សាស្តា ៣ ជំពូក ..... ..... ..... ..... ..... ..... .... ២០៨

**៩.អដ្ឋកថាចតុក្កនិទ្ទេស** អធិប្បាយបុគ្គល ៤ ជំពូក

ពណ៌នាអំពីបុគ្គលជាអសប្បុរសជាដើម ..... ..... ..... ..... .... ២១០
,, បុគ្គលដែលលាមកជាដើម ..... ..... ..... ..... ..... ២១២

# បរមត្ថទីបនី


| មាតិកាធម៌ | ទំព័រ |
|---|---|
| ពណ៌នាអំពីបុគ្គលមានធម៌លាមកជាដើម ..... ..... ..... ..... .. | ២១៣ |
| ,, បុគ្គលមានទោសជាដើម ..... ..... ..... ..... ..... . | ២១៣ |
| ,, ឧគ្ឃដិតញ្ញូបុគ្គលជាដើម ..... ..... ..... ..... ..... . | ២១៦ |
| វិគ្រោះសព្ទថា នេយ្យបុគ្គល ..... ..... ..... ..... ..... ..... .... | ២១៧ |
| ,, ,, បទបរមបុគ្គល ..... ..... ..... ..... ..... ..... . | ២១៧ |
| ពណ៌នាអំពីបុគ្គលឆ្លើយបានត្រឹមត្រូវ តែមិនរហ័សរហួនជាដើម ... | ២១៨ |
| ,, បុគ្គលជាធម្មកថិក ៤ ជំពូក ..... ..... ..... ..... .... | ២២០ |
| ,, បុគ្គលប្រៀបដូចវលាហកៈ (ពពក) ៤ យ៉ាង ..... ..... | ២២១ |
| ,, ,, ,, កណ្ដុរ ៤ ជំពូក ..... ..... ..... .... | ២២៣ |
| ,, ,, ,, ផ្លែស្វាយ ៤ ប្រភេទ ..... ..... ..... | ២២៥ |
| ,, ,, ,, ក្អម ៤ ប្រភេទ ..... ..... ..... ..... | ២២៥ |
| ,, ,, ,, អន្លង់ទឹក ៤ កន្លែង ..... ..... ..... .. | ២២៦ |
| ,, ,, ,, គោបម្រើ ៤ ពួក ..... ..... ..... ... | ២២៧ |
| ,, បុគ្គលប្រៀបដូចអាសិរពិស ៤ ពួក ..... ..... ..... ... | ២២៧ |
| ,, បុគ្គលពោលតិះដៀលមនុស្សដែលគួរតិះដៀល ត្រឹមត្រូវតាមកាល ។ល។ ជាដើម ..... ..... ..... ..... ..... . | ២២៨ |
| ពណ៌នាអំពីបុគ្គលចិញ្ចឹមជីវិតដោយផលនៃសេចក្ដីព្យាយាម | |

មាតិកាធម៌ ទំព័រ


។ល។ ជាដើម ..... ..... ..... ..... ..... ..... ..... ..... ... ២២៩

ពណ៌នាអំពីបុគ្គលមកងងឹត ទៅងងឹតជាដើម ..... ..... ..... .... ២៣០

,, បុគ្គលប្រៀបដូចដើមឈើ ៤ ពួក ..... ..... ..... ... ២៣៧

,, បុគ្គលកាន់យករូបជាប្រមាណ ហើយជ្រះថ្លាក្នុងរូបជាដើម ២៣៧

,, បុគ្គលបដិបត្តិដើម្បីប្រយោជន៍ខ្លួនឯងជាដើម ..... .... ២៤១

,, បុគ្គលធ្វើខ្លួនឱ្យក្តៅក្រហាយជាដើម ..... ..... ..... . ២៤២

,, ,, ខ្លួនឱ្យលំបាកលំបិនជាដើម ..... ..... ..... . ២៥៨

,, បុគ្គលមានរាគៈជាដើម ..... ..... ..... ..... ..... .. ២៨៦

,, បុគ្គលបានចេតោសមថៈខាងក្នុង ។ល។ ជាដើម .... ២៨៦

,, បុគ្គលទៅតាមក្រសែជាដើម ..... ..... ..... ..... ... ២៨៦

,, បុគ្គលមានសុតៈតិចជាដើម ..... ..... ..... ..... ... ២៨៩

,, បុគ្គលជាសមណៈមិនកម្រើកញាប់ញ័រជាដើម ..... .. ២៨៩


**៥.អដ្ឋកថាបញ្ចកនិទ្ទេស** អធិប្បាយបុគ្គល ៥ ជំពូក


ពណ៌នាអំពីបុគ្គលឱ្យហើយមើលងាយជាដើម ..... ..... ..... ... ២៩៦

,, បុគ្គលប្រៀបដូចអ្នកចម្បាំងជាអាជីព ៥ ជំពូក ..... ... ២៩៩

,, ភិក្ខុកាន់បិណ្ឌបាតជាវត្ត ៥ ជំពូក ..... ..... ..... .... ៣០២

,, ភិក្ខុកាន់ការហាមភត្ត ដែលគេនាំមកប្រគេនខាងក្រោយ

## បរមត្ថទីបនី

មាតិកាធម៌ ទំព័រ

ជាវត្តជាដើម ..... ..... ..... ..... ..... ..... ..... ..... ..... . ៣០៤

**៦.អដ្ឋកថាឆក្កនិទ្ទេស** អធិប្បាយបុគ្គល ៦ ជំពូក

**៧.អដ្ឋកថាសត្តកនិទ្ទេស** អធិប្បាយបុគ្គល ៧ ជំពូក

**៨.អដ្ឋកថាអដ្ឋកនិទ្ទេស និងនវកនិទ្ទេស** អធិប្បាយបុគ្គល ៨ និង ៩ ជំពូក

**១០.អដ្ឋកថាទសកនិទ្ទេស** អធិប្បាយបុគ្គល ១០ ជំពូក

និគមគាថា ..... ..... ..... ..... ..... ..... ..... ..... ..... ... ៣១៣

**កថាវត្ថុបករណ៍**

អារម្ភកថា ..... ..... ..... ..... ..... ..... ..... ..... ..... .... ៣១៤

និទានកថា ..... ..... ..... ..... ..... ..... ..... ..... ..... .... ៣១៥

ព្រះរាជាទ្រទ្រង់ធម៌ ..... ..... ..... ..... ..... ..... ..... ..... ៣២៥

កុសលោបាយជ្រើសរើសយកលទ្ធិដែលជាធម្មវាទី ..... ..... ..... ៣២៧

ព្រះមោគ្គល្លីបុត្តតិស្សត្ថេរសម្តែងកថាវត្ថុ ..... ..... ..... ..... .. ៣៣១

**១.បុគ្គលកថា**

**១.សុទ្ធសច្ចិកត្ថ**

ពណ៌នាអំពីអនុលោមបញ្ចក: *(និគ្គហៈទី ១)* ..... ..... ..... ..... ៣៣៣

## អដ្ឋកថាព្រះអភិធម្មបិដក


| មាតិកាធម៌ | | ទំព័រ |
|---|---|---|
| **ពណ៌នាអំពីបដិកម្មចតុក្កៈ** | *ពួក ៤ នៃការធ្វើតប ..... ..... .....* | **៣៤៣** |
| ,, **និគ្គហចតុក្កៈ** | *ពួក ៤ នៃការសង្កត់សង្កិន ..... .....* | **៣៤៤** |
| ,, **ឧបនយនចតុក្កៈ** | *,, ,, បង្អោនទៅ ..... ..... .* | **៣៤៦** |
| ,, **និគ្គមចតុក្កៈ** | *,, នៃនិគ្គម គឺសរុបនិគ្គហៈពី ១-៨* | **៣៤៨** |


## ២.ឱកាសសច្ចិកត្ថ


| | | |
|---|---|---|
| **ពណ៌នាអំពីបច្ចនីកបញ្ចកៈ** | *ពួក ៥ នៃបច្ចនីកៈ (និគ្គហៈទី ២) ...* | **៣៤៩** |

# អក្សរសង្ខេប
## ដែលប្រើក្នុងអដ្ឋកថាតតិយភាគ ៩ នេះ

ម. មូ.  = មជ្ឈិមនិកាយ មូលបណ្ណាសកៈ

ម. មូ. ២២ /២៩៣ = មជ្ឈិមនិកាយ មូលបណ្ណាសកៈ តតិយភាគ ២២ ទំព័រ ២៩៣

អំ. តិក. ៤១ / ៣២៤ = អង្គុត្តរនិកាយ តិកនិបាត ទុតិយភាគ ៤១ ទំព័រ ៣២៤

# បរមត្ថទីបនី

# អដ្ឋកថាព្រះអភិធម្មបិដក

# ឈ្មោះ បញ្ចបករណ៍

# តតិយភាគ ៩

ព. ស. ២៥៥៧

# បរមត្ថទីបនី

# អដ្ឋកថាព្រះអភិធម្មបិដក

## ឈ្មោះ បញ្ចបករណ៍

## តតិយភាគ

## ធាតុកថាបករណ៍

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

### អារម្ភកថា *

*ព្រះមហាវីរបុរសជាម្ចាស់ព្រះអង្គទ្រង់ឈ្នះមារ លុះទ្រង់សម្ដែងនូវវិភង្គប្បករណ៍ទាំង ១៨ វិភង្គចប់រួចហើយ កាលនឹងទ្រង់ប្រកាសសេចក្ដីផ្សេងគ្នានៃធាតុ ទើបបានត្រាស់ធាតុកថាបករណ៍ទុកក្នុងលំដាប់នៃវិភង្គប្បករណ៍នោះឯង, ខ្ញុំ (ព្រះពុទ្ធឃោសាចារ្យ) នឹងសម្ដែងសេចក្ដីនៃធាតុកថាបករណ៍នោះ, សូមសាធុជនទាំងឡាយ មានចិត្តតាំងមាំស្ដាប់នូវព្រះធម៌នោះចុះ៕*

ចប់អារម្ភកថា

---

* *ជាកថារបស់អ្នករចនាដើម គឺព្រះពុទ្ធឃោសាចារ្យ ។*

# ១.អដ្ឋកថាមាតិកា

## នយមាតិកា ១៤ ន័យ

ព្រះធម្មសង្គាហកាចារ្យបានពោលទុកថា “បករណ៍នេះ ព្រះមានព្រះភាគទ្រង់ចែកទុក ១៤ ន័យ” ដោយអំណាចនៃពាក្យថា **“សង្គហោ អសង្គហោ”** ជាដើម; សូម្បីពាក្យទាំងអស់នោះ លោកតាំងទុក ២ យ៉ាង គឺដោយឧទ្ទេស និងនិទ្ទេស ។ ឧទ្ទេសនៃធម៌មានខន្ធជាដើម ឈ្មោះថា **មាតិកា** ។

មាតិកានេះ ព្រះមានព្រះភាគទ្រង់តាំងទុក ៥ យ៉ាង គឺ

**១-នយមាតិកា** មាតិការបស់ន័យ

**២-អព្ភន្តរមាតិកា** មាតិកាខាងក្នុង

**៣-នយមុខមាតិកា** មាតិកាជាប្រធានរបស់ន័យ

**៤-លក្ខណមាតិកា** មាតិកាសម្ដែងនូវលក្ខណៈ

**៥-ពាហិរមាតិកា** មាតិកាខាងក្រៅ ។

បណ្ដាមាតិកាទាំងនោះ មាតិកាដែលទ្រង់តាំងទុក ១៤ បទ មានពាក្យថា **“សង្គហោ អសង្គហោ ។ ល ។ វិប្បយុត្តេន សង្គហិតំ អសង្គហិតំ”** ដូច្នេះ នេះឈ្មោះថា **នយមាតិកា** ។ ពិតមែន មាតិកានេះព្រះអង្គត្រាស់ហៅថា **នយមាតិកា** ព្រោះសេចក្ដីនៃមាតិកានេះ ព្រះអង្គទ្រង់តាំងទុក

ដើម្បីសម្តែងថា "ធម៌ទាំងឡាយក្នុងធាតុកថាដែលព្រះអង្គទ្រង់ចែកទុកហើយដោយន័យដែលសង្គ្រោះចូលគ្នាបានជាដើមនេះ" ។ នយមាតិកានេះ សូម្បីនឹងហៅថា **"មូលមាតិកា"** ក៏បាន ព្រោះសេចក្តីនៃមាតិកានោះជាមូលនៃបទទាំងឡាយប៉ុណ្ណោះ ។

មាតិកាដែលទ្រង់តាំងទុក ១២៥ បទថា **"បញ្ចក្ខន្ធា ។ល។ មនសិការោ"** នេះឈ្មោះថា **អព្ភន្តរមាតិកា** ។

ពិតមែន មាតិកានេះ លោកហៅថា **អព្ភន្តរមាតិកា** ព្រោះសេចក្តីនៃមាតិកានេះ ព្រះអង្គមិនត្រាស់ទុកយ៉ាងនេះថា "សូម្បីធម្មសង្គណីទាំងអស់ ជាមាតិកាក្នុងធាតុកថា" ដូច្នេះទេ, តែទ្រង់សម្តែងធម៌មានខន្ធជាដើមដែលគួរចែកដោយន័យ មានការសង្គ្រោះចូលគ្នាបានជាដើម ទុកដោយសង្ខេបហើយតាំងទុកក្នុងធាតុកថាប៉ុណ្ណោះ ។ មាតិកានេះ សូម្បីនឹងហៅថា "ជាបកិណ្ណកមាតិកា" ដូច្នេះ ក៏បាន ព្រោះសេចក្តីនៃបទទាំងឡាយ មានខន្ធជាដើម មិនបានសង្គ្រោះទុកក្នុងធម្មសង្គណីមាតិកាទេ ។ មាតិកាដែលទ្រង់តាំងទុកដោយបទទាំងឡាយ ៤ បទ គឺ **"តីហិ សង្គហោ, តីហិ អសង្គហោ, ចតូហិ សម្បយោគោ, ចតូហិ វិប្បយោគោ"** នេះឈ្មោះថា **នយមុខមាតិកា** ។ ពិតណាស់ ធម៌ដែលសង្គ្រោះចូលគ្នាបាន និងសង្គ្រោះ

ចូលគ្នាមិនបាននេះ ព្រះមានព្រះភាគទ្រង់ប្រកបទុកក្នុងធម៌ទាំងឡាយ មាន បញ្ចក្ខន្ធជាដើម សូម្បីទាំងអស់ និងក្នុងធម៌នៃមាតិកាទាំងឡាយ មាន កុសលត្តិកមាតិកាជាដើម ដោយបទនៃខន្ធ អាយតនៈ និងធាតុទាំង ៣ ប៉ុណ្ណោះ ។ ដោយទំនងដូចគ្នានេះ ***សម្បយោគត្តី វិប្បយោគត្តី*** ក៏ទ្រង់ប្រកបទុក ដោយអរូបក្ខន្ធទាំង ៤ ។ មាតិកានេះ ហៅថា **នយមុខមាតិកា** ព្រោះ សេចក្តីនៃមាតិកានេះ ទ្រង់តាំងទុកដើម្បីសម្តែងថា បទទាំង ៤ នេះ ជាប្រធាន របស់ន័យទាំងឡាយ មានន័យថា ធម៌ដែលសង្គ្រោះចូលគ្នាបាន និងមិន សង្គ្រោះចូលគ្នាបានជាដើមនេះ ។ មាតិកាដែលទ្រង់តាំងទុក ដោយបទ ទាំង ២ គឺ**សភាគោ និងវិសភាគោ** ឈ្មោះថា **លក្ខណមាតិកា** ។ ពិតមែន ន័យរបស់ធម៌ដែលសង្គ្រោះចូលគ្នាបាន ព្រះមានព្រះភាគទ្រង់ប្រកបទុក ដោយធម៌ទាំងឡាយ ដែលមានលក្ខណៈស្មើគ្នា, ន័យរបស់ធម៌ដែលសង្គ្រោះ ចូលគ្នាមិនបាន ទ្រង់ប្រកបទុកដោយធម៌ទាំងឡាយ ដែលមានលក្ខណៈ មិនស្មើគ្នា, ន័យរបស់ ***សម្បយោគ*** និង ***វិប្បយោគ*** ក៏ដូចគ្នាដែរ ។ មាតិកា នេះ ព្រះមានព្រះភាគត្រាស់ហៅថា **លក្ខណមាតិកា** ព្រោះសេចក្តីនៃបទ ទាំងនោះ ព្រះអង្គទ្រង់តាំងទុកដើម្បីសម្តែងលក្ខណៈនៃធម៌ដែលសង្គ្រោះ ចូលគ្នាបានជាដើម ដោយអំណាចនៃលក្ខណៈដែលជាសភាគ និងវិសភាគ ។ មាតិកាដែលទ្រង់សង្ខេបតាំងបទតិកៈ ៦៦ និងបទទុកៈ ២០០ ថា "សូម្បី

ធម្មសង្គណីទាំងអស់ ជាមាតិកាក្នុងធាតុកថា" នេះឈ្មោះថា **ពាហិរមាតិកា** ។

ពិតមែន មាតិកានេះ ហៅថា **"ពាហិរមាតិកា"** ព្រោះសេចក្ដីនៃមាតិកានេះ ព្រះមានព្រះភាគមិនត្រាស់ទុកខាងក្នុងធាតុកថា យ៉ាងនេះថា **"បញ្ចក្ខន្ធា ។ល។ មនសិការោ"** ដូច្នេះទេ, តែទ្រង់តាំងទុកខាងក្រៅអំពីមាតិកានៃធាតុកថា យ៉ាងនេះថា "សូម្បីធម្មសង្គណីទាំងពួង ជាមាតិកា" ដូច្នេះ បណ្ឌិតគប្បីជ្រាបនូវសេចក្ដីនៃមាតិកា ជាសភាវៈដែលព្រះមានព្រះភាគត្រាស់ទុក ៥ យ៉ាង ដោយប្រការដូច្នេះឯង; ឥឡូវនេះ គប្បីជ្រាបធម៌ដែលសង្គ្រោះចូលគ្នាបាន ៤ យ៉ាង ក្នុងពាក្យទាំងឡាយ មានពាក្យថា **"សង្គហោ អសង្គហោ"** ជាដើម ដោយអំណាចនៃ ***ជាតិ សញ្ជាតិ កិរិយា*** និង ***គណនសង្គហៈ*** ជាមុនសិន ។

បណ្ដាសង្គហៈ (គឺធម៌ដែលសង្គ្រោះចូលគ្នាបាន) ទាំងនោះ ការសង្គ្រោះដែលពោលថា "ពួកក្សត្រទាំងពួង ចូរមក, ពួកព្រាហ្មណ៍ទាំងពួង ចូរមក, ពួកគហបតីទាំងពួង ចូរមក, ពួកសូទ្រៈទាំងពួង ចូរមក; ម្នាលវិសាខៈមានអាយុ ធម៌ទាំងនេះ គឺសម្មាវាចាណា, សម្មាកម្មន្តៈណា, សម្មាអាជីវៈណា ព្រះមានព្រះភាគទ្រង់សង្គ្រោះចូលក្នុងសីលក្ខន្ធ"[១] នេះឈ្មោះថា

---

[១] ម. មូ.។

**ជាតិសង្គហៈ** *(សង្គ្រោះចូលគ្នាបានដោយជាតិ) ព្រោះថា ក្នុងអធិការនេះ សូម្បីធម៌ទាំងពួង ដល់នូវការសង្គ្រោះជាមួយគ្នាដោយជាតិ ដូចក្នុងឋាន ដែលលោកពោលហើយថា "ជនទាំងឡាយអ្នកមានជាតិតែមួយ ចូរមក"* ។

*ការសង្គ្រោះដែលពោលថា "អ្នកកោសលទាំងពួង ចូរមក, ជនអ្នកមគធៈទាំងពួង ចូរមក, ជនអ្នកភារុកច្ឆកៈទាំងពួង ចូរមក, ម្នាលវិសាខៈមានអាយុ ធម៌ទាំងនេះ គឺសម្មាវាយាមៈណា, សម្មាសតិណា, សម្មាសមាធិណា ព្រះមានព្រះភាគ ទ្រង់សង្គ្រោះចូលក្នុងសមាធិក្ខន្ធ"*[២] នេះឈ្មោះថា **សញ្ជាតិសង្គហៈ** *(សង្គ្រោះចូលដោយសញ្ជាតិ)* ។ *ពិតមែន ក្នុងទីនេះ ជនទាំងអស់ ដល់ហើយនូវការសង្គ្រោះដូចគ្នាដោយស្ថានទីកើត គឺដោយឱកាសទីអាស្រ័យនៅ ហាក់ដូចក្នុងទីដែលលោកពោលហើយថា "ជនទាំងឡាយអ្នកទាក់ទងគ្នាដោយជាតិ ចូរមក"* ។

*ការសង្គ្រោះដែលពោលថា "ពួកទាហានដំរី (នាយហ្មដំរី) ចូរមក, ពួកទាហានសេះ ចូរមក, ពួកទាហានរថ ចូរមក, ម្នាលវិសាខៈមានអាយុ ធម៌ទាំងនេះ គឺសម្មាទិដ្ឋិណា, សម្មាសង្កប្បៈណា, ព្រះមានព្រះភាគ ទ្រង់សង្គ្រោះទុកក្នុងបញ្ញាខន្ធ*[៣] នេះឈ្មោះថា **កិរិយាសង្គហៈ** *(គឺការសង្គ្រោះ*

---

[២] ម. មូ. ។

[៣] ម. មូ. ២២ / ២៩៣ ។

*ចូលគ្នាបានដោយការធ្វើ) ។ ព្រោះជនទាំងអស់នោះ ដល់ហើយនូវការសង្គ្រោះចូលជាមួយគ្នាដោយអំពើរបស់ខ្លួន ។*

***សួរថា* ចក្ខាយតនៈ** *រមែងដល់នូវការរាប់ (គណនា) ថា ជាខន្ធអ្វី ?*

*ឆ្លើយថា* **ចក្ខាយតនៈ** *រមែងដល់ការរាប់ថាជា* **រូបក្ខន្ធ** *។ ការសង្គ្រោះ ដែលពោលថា* **“***បើចក្ខាយតនៈដល់នូវការរាប់ថា ជារូបក្ខន្ធមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះឯង អ្នកគប្បីពោលថា ចក្ខាយតនៈសង្គ្រោះចូលដោយរូបក្ខន្ធ***”** *នេះ ឈ្មោះថា* **គណានសង្គហៈ** *(គឺការសង្គ្រោះចូលដោយការរាប់ ឬហៅថា ការរាប់សង្គ្រោះ) ។ គណនសង្គហៈនេះលោកបំណងយកក្នុងទីនេះឯង ។ បណ្ឌិតគប្បីជ្រាបនូវធម៌ ដែលរាប់សង្គ្រោះចូលគ្នាមិនបាន ព្រោះជាបដិបក្ខចំពោះធម៌នោះ ។ គប្បីជ្រាបនូវបទថា* **“សង្គហិតេន អសង្គហិតំ”** *ជាដើម ដោយការកំណត់នូវធម៌ទាំងនោះ ។ គប្បីជ្រាបនូវសម្បយោគធម៌ ដោយអំណាចនៃភាពជា* ***ឯកុប្បាទៈ ឯកនិរោធៈ ឯកវត្ថុកៈ និងឯការម្មណៈ*** *។ គប្បីជ្រាបនូវវិប្បយោគដោយធម៌ជាបដិបក្ខ ចំពោះសម្បយោគនោះ ។ គប្បីជ្រាបថា* **“សម្បយុត្តេន វិប្បយុត្តំ”** *ជាដើម ដោយការកំណត់នូវធម៌ទាំងនោះ ។ គប្បីជ្រាបថា* **“សង្គហិតេន សម្បយុត្តំ វិប្បយុត្តំ”** *ជាដើម ដោយការកំណត់នូវធម៌ដែល*

*ទាក់ទងគ្នាទាំង ២ បទ ។ ក៏ពាក្យថា* **“បញ្ចក្ខន្ធា”** *ជាដើម គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងខន្ធវិភង្គជាដើមនុ៎ះឯង ។ តែធម៌ទាំងឡាយ មានផស្សៈជាដើម ក្នុងទីនេះ គប្បីជ្រាបថា លោកបានពោលដោយការកើតឡើងនៃសព្វចិត្តសាធារណៈ តាមដែលពោលហើយ ដោយអំណាចនៃការសន្និដ្ឋានបទដូច្នេះឯង ៕*

ចប់មាតិកា

## ២.អដ្ឋកថានិទ្ទេសវារៈ

## ១.ពណ៌នាអំពីសង្គហាសង្គហបទនិទ្ទេស

## ១.ពណ៌នាអំពីខន្ធបទនិទ្ទេស

*ឥឡូវនេះ ដើម្បីនឹងសម្ដែងមាតិកាតាមដែលព្រះភគវាទ្រង់តាំងទុកដោយអំណាចនៃបញ្ចក្ខន្ធជាដើម ប្រកបជាមួយបទ**នយមាតិកា**ទាំងឡាយ មានពាក្យជាអាទិ៍ថា* **“សង្គហោ អសង្គហោ”** *ព្រះមានព្រះភាគទ្រង់ផ្ដើមនិទ្ទេសវារៈដោយន័យថា* **“រូបក្ខន្ធោ កតីហិ ខន្ធេហិ”** *ជាដើម ។ បណ្ដាមាតិកាទាំងនោះ នយមុខមាតិកាព្រះមានព្រះភាគទ្រង់តាំងទុកថា* **“គតីហិ សង្គហោ** *= ការសង្គ្រោះដោយធម៌ ៣ គឺខន្ធ, អាយតនៈ និងធាតុ;* **គតីហិ**

**អសង្គហោ** = គឺការសង្គ្រោះមិនបាន ដោយធម៌ទាំង ៣" ព្រោះនយមាតិកាថា **"សង្គហោ អសង្គហោ"** ជាដើម ដើម្បីសម្ដែងការរាប់សង្គ្រោះរូបក្ខន្ធជាដើម ទើបលោកលើកបទទាំង ៣ គឺខន្ធ, អាយតនៈ និងធាតុនុ៎ះឯងឡើងសម្ដែងថា "ធម៌ទាំងនេះ រាប់សង្គ្រោះបានដោយខន្ធប៉ុន្មាន ? ដោយអាយតនៈប៉ុន្មាន ? ដោយធាតុប៉ុន្មាន ?" ។ បណ្ដាធម៌ទាំងឡាយ មានសច្ចៈ ៤ ជាដើម សូម្បីតែមួយ៉ាង ក៏មិនជាបរាមដ្ឋៈ (គឺមិនជាអារម្មណ៍របស់បរាមាស) ឡើយ ។

ក៏លក្ខណមាតិកា ព្រះមានព្រះភាគទ្រង់តាំងទុកយ៉ាងនេះថា **"សភាគោ វិសភាគោ"** ដូច្នេះ ព្រោះហេតុដូច្នោះ ក្នុងការវិសជ្ជនាបញ្ហានេះ ទើបទ្រង់ត្រាស់ថា "រូបក្ខន្ធ រាប់សង្គ្រោះបានដោយខន្ធមួយ" ជាដើម ។ ព្រោះថាធម៌មានខន្ធជាដើមនេះ ជាសភាគរបស់លក្ខណមាតិកានោះ, បណ្ដាបទទាំងនោះ ពីរបទថា **"ឯកេន ខន្ធេន"** បានដល់ (រាប់សង្គ្រោះបាន) ដោយរូបក្ខន្ធតែប៉ុណ្ណោះ ។

ពិតមែន រូបយ៉ាងណានីមួយ រមែងដល់នូវការរាប់សង្គ្រោះថា ជារូបក្ខន្ធតែមួយ៉ាង ព្រោះជាធម៌ស្មើគ្នានឹងរូបក្ខន្ធ ។ ព្រោះហេតុដូច្នោះ ***រូប*** ទើបលោកសង្គ្រោះដោយរូបក្ខន្ធនោះឯង និងកំណត់យកដោយរូបក្ខន្ធ

តែប៉ុណ្ណោះ ។ ពីរបទថា **"ឯកាទសហិ អាយតនេហិ"** បានដល់ វៀរចាកមនាយតនៈ ។ ព្រោះសុម្បីរូបក្ខន្ធទាំងអស់ ជាអាយតនៈ ១០ និងជាចំណែកមួយនៃធម្មាយតនៈ; ព្រោះហេតុដូច្នោះ រូបក្ខន្ធនោះ ទើបលោករាប់យកហើយ កំណត់យកហើយ ដោយអាយតនៈ ១១ ។ ពីរបទថា **"ឯកាទសហិ ធាតូហិ"** បានដល់ ដោយធាតុ ១១ វៀរចាកវិញ្ញាណធាតុ ៧ ។ ព្រោះឈ្មោះថា រូបដែលមិនបានរាប់បញ្ចូលក្នុងធាតុទាំងនោះ រមែងមិនមាន ។ ក្នុងនិទ្ទេសនៃអសង្គហន័យ ទ្រង់ធ្វើពាក្យសួរដោយសង្ខេបទុកថា **"កតីហិ អសង្គហិតោ"** , តែក្នុងការវិសជ្ជនានៃបញ្ហានោះ អរូបក្ខន្ធ ៤ មនាយតនៈ ១ វិញ្ញាណធាតុ ៧ ជាវិសភាគរបស់រូបក្ខន្ធ, ព្រោះហេតុដូច្នោះ ទើបត្រាស់ថា **"ចតូហិ ខន្ធេហិ"** ជាដើម ។ បណ្ឌិតគប្បីជ្រាបនូវបទថា **"សង្គហោ អសង្គហោ"** ក្នុងបទទាំងពួងដោយន័យនេះចុះ ។

មួយទៀត ក្នុងពាក្យថា **"រូបក្ខន្ធោ កតីហិ ខន្ធេហិ"** ជាដើម ក្នុងខន្ធនិទ្ទេសនេះ ទ្រង់សម្ដែងពាក្យបុច្ឆា ៥ និងវិសជ្ជនា ៥ ក្នុងសង្គហន័យ ដែលជាឯកមូលទុកដោយសង្ខេបប៉ុណ្ណោះ ។ ក្នុងអសង្គហន័យ ក៏សម្ដែងពាក្យបុច្ឆា ៥ និងវិសជ្ជនា ៥ ដោយសង្ខេបដែរ ។

សុម្បីក្នុងមូលទាំងឡាយ មាន***ទុកមូល***ជាដើម បណ្ឌិតគប្បីជ្រាបនូវពាក្យបុច្ឆា និងពាក្យវិសជ្ជនាទាំងឡាយដោយឧបាយនេះចុះ ។ ក៏ក្នុង

*ខន្ធបទនិទ្ទេសនេះ ព្រះមានព្រះភាគទ្រង់សម្ដែងទុកៈ តិកៈ និងចតុក្កមូលទុកក្នុងរូបក្ខន្ធមូលប៉ុណ្ណោះ ។ តែក្នុងបញ្ចកមូល ទ្រង់ធ្វើបុច្ឆា និងវិសជ្ជនាទុក ២ យ៉ាង គឺ* ***ភេទៈ*** *(សំដៅដល់ការបែក) យ៉ាងនេះថា* **"រូបក្ខន្ធោ ច ។បេ ។ វិញ្ញាណក្ខន្ធោ ច"** *និង* ***អភេទៈ*** *(ការមិនបែក) យ៉ាងនេះថា* **"បញ្ចក្ខន្ធា កតីហិ ខន្ធេហិ"** *។ បណ្ឌិតគប្បីជ្រាបន័យរបស់ព្រះបាលី ដូចបានពណ៌នាមកដូច្នេះឯង ៕*

ចប់ខន្ធបទនិទ្ទេស

## ២.ពណ៌នាអំពីអាយតនបទនិទ្ទេស

*ក្នុងនិទ្ទេសទាំងឡាយ មានអាយតនបទនិទ្ទេសជាដើម គប្បីជ្រាប* ***អាយតនបទនិទ្ទេស*** *សិន ៖*

*ពាក្យថា* **"ចក្ខាយតនំ ឯកេន ខន្ធេន"** *សេចក្ដីថា ចក្ខាយតនៈគប្បីជ្រាបថា រាប់សង្គ្រោះបានដោយរូបក្ខន្ធ ១ ដោយចក្ខាយតនៈ ១ និងដោយចក្ខុធាតុ ១ ។ សូម្បីក្នុងសោតាយតនៈជាដើម ក៏គប្បីជ្រាបការរាប់សង្គ្រោះបាន និងសង្គ្រោះមិនបានដោយន័យនេះចុះ ។ តែក្នុងពាក្យថា* **"អសង្ខតំ ខន្ធតោ ឋបេត្វា"** *ព្រោះអសង្ខតៈ គឺនិព្វាន ឈ្មោះថា ធម្មាយតនៈ, ក៏*

*ធម្មាយតនៈ គឺនិព្វាននោះ មិនដល់នូវការរាប់សង្គ្រោះថាជាខន្ធ, ព្រោះហេតុដូច្នោះ ទើបត្រាស់ថា* **“ខន្ធតោ ឋបេត្វា** *= លើកលែងដោយសេចក្តីជាខន្ធ”* ។ *ពីរបទថា* **“ចតូហិ ខន្ធេហិ”** *បានដល់ សង្គ្រោះបានដោយខន្ធ ៤ គឺរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ និងសង្ខារក្ខន្ធ ។ ព្រោះថា ធម្មាយតនៈ វៀរនិព្វានហើយ រាប់សង្គ្រោះបានដោយខន្ធទាំងឡាយ មានរូបក្ខន្ធជាដើមនេះ ។ ចំណែកអាយតនៈនោះ វៀរធម្មាយតនៈ និងធម្មធាតុហើយ រាប់សង្គ្រោះមិនបានដោយវិញ្ញាណក្ខន្ធ អាយតនៈ និងធាតុដ៏សេស ។ ដោយហេតុនោះ ទើបត្រាស់ទុកថា “ធម្មាយតនៈ រាប់សង្គ្រោះ មិនបានដោយខន្ធ ១ (គឺវិញ្ញាណក្ខន្ធ), ដោយអាយតនៈ ១១ (គឺឱឡារិកាយតនៈ ១០ និងមនាយតនៈ ១), ដោយធាតុ ១៧ (គឺឱឡារិកធាតុ ១០ និងវិញ្ញាណធាតុ ៧)”* ។ *ក៏ន័យទាំងឡាយ មានរូបក្ខន្ធជាមូល ក្នុងខាងក្រោយយ៉ាងណា គប្បីជ្រាបន័យទាំងឡាយដែលមានចក្ខាយតនៈជាមូល សូម្បីក្នុងទីនេះ ក៏យ៉ាងនោះដែរ ។ ក៏ព្រះមានព្រះភាគ លុះទ្រង់សម្តែងបាលីទុកៈ (គឺភេទសុទ្ធ និងភេទឯកមូលាទិ) សមគួរហើយ ទើបធ្វើពាក្យបុច្ឆា និងវិសជ្ជនា ដោយ* ***អភេទ****ថា* **“ទ្វាទសាយតនានិ”** *ដូច្នេះ សូម្បីក្នុងធាតុនិទ្ទេស ក៏ន័យនេះដែរ ។*

## ចប់អាយតនបទនិទ្ទេស

## ៣.ពណ៌នាអំពីសច្ចនិទ្ទេស

ក្នុង ***សច្ចនិទ្ទេស*** សូម្បីទុកៈ តិកៈ និងចតុក្កៈទាំងអស់ ទ្រង់សម្ដែងទុកច្បាស់ហើយក្នុងព្រះបាលី (បិដក) ។ តែព្រោះពាក្យវិសជ្ជនា សូម្បីក្នុងមគ្គសច្ចត្រង់ទុកៈ និងតិកៈទាំងឡាយ ក៏ដូចនឹងសមុទយសច្ចដែរ, ព្រោះហេតុដូច្នោះ ទើបត្រាស់មគ្គសច្ចនោះ ក្នុងលំដាប់នៃសមុទយសច្ច ៕

ចប់សច្ចនិទ្ទេស

---

## ៤.ពណ៌នាអំពីឥន្ទ្រិយនិទ្ទេស

ក្នុង ***និទ្ទេសនៃឥន្ទ្រិយ*** ពាក្យថា **"ជីវិតិន្ទ្រិយំ ទ្វីហិ ខន្ធេហិ"** សេចក្ដីថា រូបជីវិតិន្ទ្រិយ រាប់សង្គ្រោះបានដោយរូបក្ខន្ធ, អរូបជីវិតិន្ទ្រិយ រាប់សង្គ្រោះបាន ដោយសង្ខារក្ខន្ធ ។ គប្បីជ្រាបនូវឥន្ទ្រិយដ៏សេស ដោយទំនងតាមន័យដែលពោលហើយនុ៎ះឯង ។ ចំណែកការកំណត់ព្រះបាលីក្នុងនិទ្ទេសនេះ ដូចគ្នានឹងអាយតននិទ្ទេស និងធាតុនិទ្ទេសដែរ ៕

ចប់ឥន្ទ្រិយនិទ្ទេស

---

## ៥.ពណ៌នាអំពីបដិច្ចសមុប្បាទនិទ្ទេស

ក្នុង ***បដិច្ចសមុប្បាទនិទ្ទេស*** ព្រះមានព្រះភាគទ្រង់មិនបានផ្ដើមពាក្យបុច្ឆាថា **"អទិដ្ឋា កតីហិ ខន្ធេហិ"** ទេ, តែទ្រង់សម្ដែងពាក្យវិសជ្ជនាយ៉ាងនេះ ពិតប្រាកដថា **"អវិជ្ជាបច្ចយា សង្ខារា ឯកេន ខន្ធេន"** ជាដើម ។ ក្នុងបទទាំងនោះ ពាក្យថា **"សង្ខារបច្ចយា វិញ្ញាណំ"** អធិប្បាយថា កាលបើបដិសន្ធិប្រព្រឹត្តទៅហើយ សូម្បីវិបាកវិញ្ញាណទាំងពួង ក៏ប្រព្រឹត្តទៅដែរ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **"សត្តហិ ធាតូហិ សង្គហិតំ"** ។ សូម្បីក្នុងនាមរូប ក៏គប្បីជ្រាបដោយអំណាចនៃការប្រព្រឹត្តរបស់បដិសន្ធិដែរ ។ ព្រោះហេតុនេះ ព្រះអង្គទ្រង់រួបរួមសូម្បីនូវសឡាយតនៈ ហើយ សម្ដែងការរាប់សង្គ្រោះទុកដោយអាយតនៈ ១១ ក្នុងបដិច្ចសមុប្បាទនិទ្ទេសនេះ ។

គប្បីជ្រាបនូវខន្ធភេទ (គឺការបែកខន្ធ) ក្នុងធម៌ទាំងឡាយ មានផស្សៈជាដើម ។ ពិតមែនហើយ ***ផស្សៈ*** រាប់សង្គ្រោះបានដោយខន្ធ ១, វេទនាខន្ធ ក៏រាប់សង្គ្រោះបានដោយខន្ធ ១ ទៀត ។ ចំពោះ ***តណ្ហា ឧបាទាន កម្ម*** និង ***ភព*** រាប់សង្គ្រោះបានដោយសង្ខារក្ខន្ធតែប៉ុណ្ណោះ ។ ម្យ៉ាងទៀត បទនៃភពទ្រង់បែកចេញជា ១១ យ៉ាង ដោយអំណាចនៃកម្មភពជាដើម

ទុកក្នុងនិទ្ទេសនេះ ។ បណ្ដាភពទាំងនោះ ***កម្មភព*** ទ្រង់សម្ដែងរួមនឹងភពទាំងនោះ ព្រោះសេចក្ដីជាពាក្យវិសជ្ជនាដូចផស្សៈជាដើមដែរ ។ ***ឧប្បត្តិភព កាមភព សញ្ញាភព និងបញ្ចវោការភព*** ទ្រង់សម្ដែងរួមគ្នា ព្រោះសេចក្ដីជាពាក្យវិសជ្ជនាហាក់បីដូចជារបស់គ្នានឹងគ្នាដែរ ។ តែព្រោះសភាវធម៌ដែលកម្មចូលទៅរួបរឹតទុកដោយសេចក្ដីជាផលពិតប្រាកដ ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា **"ឯកាទសហាយតនេហិ សត្តរសហិ ធាតូហិ"** ដូច្នេះ; ពិតណាស់ សឡាយតនៈដែលកម្មមិនបានប្រកាន់ទុកដោយសេចក្ដីជាផល (គឺមិនមែនជាកម្មជរូប) សឡាយតនៈនោះទើបព្រះអង្គទ្រង់មិនបានកាន់យកក្នុងទីនេះឡើយ ។

ក្នុង ***រូបភវនិទ្ទេស*** ពីរបទថា **"បញ្ចហិ អាយតនេហិ"** បានដល់ដោយចក្ខាយតនៈ សោតាយតនៈ មនាយតនៈ រូបាយតនៈ និងធម្មាយតនៈ ។

ពីរបទថា **"អដ្ឋហិ ធាតូហិ"** បានដល់ ធាតុ ៨ គឺចក្ខុធាតុ សោតធាតុ ចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ រូបធាតុ ធម្មធាតុ មនោធាតុ និងមនោវិញ្ញាណធាតុ ។ សូម្បីភពទាំង ៣ មានអរូបភពជាដើម ទ្រង់សម្ដែងរួមគ្នា ព្រោះសេចក្ដីជាពាក្យវិសជ្ជនាមានទំនងដូចគ្នា ។ អសញ្ញីភព ឯកវោការភព ក៏ដូច្នោះដែរ ។

បណ្ដាពាក្យទាំងនោះ ពាក្យថា **“ទ្វីហិ អាយតនេហិ”** បានដល់ អាយតនៈពីរ គឺរូបាយតនៈ និងធម្មាយតនៈ ។ សូម្បីក្នុងធាតុទាំងឡាយ ក៏មានន័យដូចគ្នានេះដែរ ។

មយ៉ាងទៀត ក្នុងនិទ្ទេសនោះ ព្រះមានព្រះភាគទ្រង់លើកយក រូបាយតនៈឡើងមកសម្ដែង ព្រោះភាវៈនៃរូបាយតនៈរបស់ព្រហ្មនោះ ជាអារម្មណ៍ដល់ព្រហ្មទាំងឡាយដ៏សេស អ្នកនៅក្នុងផ្ទៃពិភពជាមួយគ្នា ព្រោះការកើតឡើងនៃចក្ខុ ។

ពាក្យថា **“ជាតិ ទ្វីហិ ខន្ធេហិ”** បានដល់ រូបជាតិ រាប់សង្គ្រោះបានដោយរូបក្ខន្ធ, អរូបជាតិ រាប់សង្គ្រោះបានដោយសង្ខារក្ខន្ធ ។ សូម្បីក្នុងជរា និងមរណៈ ក៏មានន័យដូចគ្នានេះដែរ ។ ពាក្យថា **“ឯកេន ខន្ធេន”** សូម្បីក្នុងធម៌ទាំងឡាយ មានសោកៈជាដើម បណ្ឌិតគប្បីជ្រាបខន្ធដែលប្លែកគ្នាយ៉ាងនេះថា ៖

***សោក ទុក្ខ ទោមនស្ស រាប់សង្គ្រោះបាន ដោយ វេទនាខន្ធ, បរិទេវៈ រាប់សង្គ្រោះបានដោយរូបក្ខន្ធ ឧបាយាស ជាដើម រាប់សង្គ្រោះបានដោយសង្ខារក្ខន្ធ ។***

ពាក្យថា **“ឥទ្ធិបាទោ ទ្វីហិ ខន្ធេហិ”** ជាដើម បានដល់ រាប់សង្គ្រោះដោយសង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ ១, ដោយមនាយតនៈ និងធម្មាយតនៈ ១

ដោយធម្មធាតុ និងមនោវិញ្ញាណធាតុ ១ ។

ពាក្យថា **“ឈានំ ទ្វីហិ ខន្ធេហិ”** បានដល់ ដោយវេទនាខន្ធ និងសង្ខារក្ខន្ធ ។ ធម៌ទាំងឡាយ មាន ***អប្បមញ្ញា*** ជាដើម អធិប្បាយទុករួមគ្នា ព្រោះសេចក្ដីជាពាក្យវិសជ្ជនាមានទំនងដូចគ្នា ។ តែបិត្តសូម្បីតាំងទុកក្នុងលំដាប់នៃចេតនា ក៏ទ្រង់សម្ដែងក្នុងខាងក្រោយ ព្រោះមានពាក្យវិសជ្ជនាមិនដូចគ្នា ។

បណ្ដាបទទាំងឡាយ មានបទថា ***អប្បមញ្ញា*** ជាដើម ពាក្យថា **“ឯកេន ខន្ធេន”** បានដល់ វេទនារាប់សង្គ្រោះបានដោយវេទនាខន្ធ, សញ្ញារាប់សង្គ្រោះបានដោយសញ្ញាខន្ធ, ធម៌ដ៏សេស រាប់សង្គ្រោះបានដោយសង្ខារក្ខន្ធ; ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបខន្ធដែលប្លែកគ្នា ដោយប្រការដូច្នេះ ។

ព្រះមានព្រះភាគ លុះទ្រង់សម្ដែងសង្គហាសង្គហបទក្នុងអព្ភន្តរមាតិកាយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់សម្ដែង **ពាហិរមាតិកា** ទើបផ្ដើមពាក្យថា **“កុសលា ធម្មា”** ជាអាទិ៍ ។ បណ្ដាមាតិកាទាំងនោះ ក្នុងវេទនាត្តិកៈ ពាក្យថា **“តីហិ ធាតូហិ”** បានដល់ ដោយកាយវិញ្ញាណធាតុ មនោវិញ្ញាណធាតុ និងធម្មធាតុ ។ ពាក្យថា **“សត្តហិ ធាតូហិ”** បានដល់ ដោយធាតុ ៧ គឺចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជិវ្ហា-

*វិញ្ញាណធាតុ មនោធាតុ ធម្មធាតុ និងមនោវិញ្ញាណធាតុ ។ ក្នុង* ***វិបាកត្តិកៈ*** *ពាក្យថា* **“អដ្ឋហិ ធាតូហិ”** *បានដល់ដោយធាតុទាំង ៧ នោះឯង និងដោយកាយវិញ្ញាណធាតុ ១ ទៀត ។ តែវិបាកធម្មធម្មាកាន់យករួមគ្នា ព្រោះពាក្យវិសជ្ជនា ដូចគ្នានឹងសង្កិលិដ្ឋសង្កិលេសិកៈទាំងឡាយ ។ ក៏ឯនិទ្ទេសទាំងនោះ សម្តែងទុកយ៉ាងណាក្នុងបទតិកៈ និងទុកៈទាំងពួង (ក្នុងពាហិរ-មាតិកានេះ) ក៏ដូច្នោះដែរ គឺថា បទណា ៗ ជាពាក្យវិសជ្ជនារួមគ្នា បទនោះ ៗ សូម្បីមិនប្រព្រឹត្តទៅតាមលំដាប់ លោកក៏កាន់យកពាក្យវិសជ្ជនាព្រមគ្នាដោយបទនោះ ៗ ។ សង្គហាសង្គហន័យក្នុងទីនេះ គប្បីជ្រាបដោយទំនងដែលខ្ញុំពោលហើយនុ៎ះឯង ។*

ចប់សង្គហាសង្គហបទនិទ្ទេស

---

## ២.ពណ៌នាអំពីសង្គហិតេន អសង្គហិតបទនិទ្ទេស

*ឥឡូវនេះ ដើម្បីចែក* ***សង្គហិតេន អសង្គហិតបទ*** *ទើបព្រះមាន-ព្រះភាគទ្រង់ផ្តើមពាក្យថា* **“ចក្ខាយតនេន”** *ជាដើម ។ ក្នុងបទនេះ គប្បីជ្រាបលក្ខណៈដូចតទៅនេះ ៖*

*ក៏ក្នុងវារៈនេះ បទណា (សំដៅដល់រូប ២៧ វៀរចក្ខាយតនៈ) រាប់សង្គ្រោះបាន ដោយបទនៃខន្ធ តែរាប់សង្គ្រោះមិនបាន ដោយបទនៃ*

អាយតនៈ និងធាតុ ឬថា បទណា (វិញ្ញាណធាតុ ៧ វៀរចក្ខុវិញ្ញាណធាតុ) រាប់សង្គ្រោះបានដោយបទនៃខន្ធ និងអាយតនៈ តែរាប់សង្គ្រោះមិនបានដោយបទនៃធាតុ ទើបព្រះមានព្រះភាគទ្រង់ធ្វើបុច្ឆា និងវិសជ្ជនានូវបទ ដែលសង្គ្រោះមិនបានដោយខន្ធនៃបទនោះ ក៏បទ (ដែលសង្គ្រោះមិនបាន) នោះ រមែងមិនប្រកបក្នុងធម៌ទាំងឡាយ មានរូបក្ខន្ធជាដើមទេ ។ ព្រោះថា រូបក្ខន្ធសង្គ្រោះបានដោយរូបក្ខន្ធប៉ុណ្ណោះ, តែរូបក្ខន្ធនោះ ឈ្មោះថារាប់សង្គ្រោះមិនបានដោយអាយតនៈ និងធាតុដប់មួយកន្លះ ក៏មិនមាន, ដូចវេទនា រាប់សង្គ្រោះបានដោយវេទនាខន្ធប៉ុណ្ណោះ, សូម្បីវេទនាខន្ធនោះ ឈ្មោះថា រាប់សង្គ្រោះមិនបានដោយធម្មាយតនៈ និងធម្មធាតុទាំងឡាយ ក៏មិនមែន ។ កាលមិនមាន ព្រោះធម៌ទាំងនេះ សង្គ្រោះមិនបានយ៉ាងនេះ បទទាំងឡាយដទៃនោះ និងបទ មានមនាយតនៈ និងធម្មាយតនៈជាដើម មានសភាពយ៉ាងនេះ ព្រះមានព្រះភាគ ក៏ទ្រង់មិនសង្គ្រោះទុកក្នុងវារៈនេះទេ ។ តែបទឯណា រមែងបំភ្លឺដល់ឯកទេសនៃរូប ដែលមិនលាយឡំដោយអរូប និងឯកទេសនៃវិញ្ញាណដែលមិនលាយឡំដោយធម៌ដទៃ បទទាំងនោះ ព្រះមានព្រះភាគទ្រង់សង្គ្រោះទុកក្នុងនិទ្ទេសនៃបទនេះ ។ ក្នុងទីបំផុត ទ្រង់សម្តែងធម៌ទាំងនោះ ទុកក្នុងឧទានគាថាយ៉ាងនេះថា ៖

**“ទសាយតនា សត្តរស ធាតុយោ**

**សត្តិន្ទ្រិយា អសញ្ញាភវោ ឯកវោការភវោ**
**បរិទេវោ សនិទស្សនសប្បដិឃំ**
**អនិទស្សនំ បុនរេវ សប្បដិឃំ ឧបាទា"**

*និទ្ទេសនេះ មាន ៤២ បទ គឺ*

*- ទ្វារិកាយតនៈ ១០ បទ*

*- ធាតុ ១៧ បទ (វៀរធម្មធាតុចេញ)*

*- រូបឥន្ទ្រិយ ៧ បទ (គឺចក្ខុន្ទ្រិយជាដើម រហូតដល់បុរិសិន្ទ្រិយជាទីបំផុត) ។*

*- អសញ្ញីភព ១ បទ*

*- ឯកវោការភព ១ បទ*

*- បរិទេវៈ ១ បទ*

*- សនិទស្សនសប្បដិឃៈ ១ បទ*

*- អនិទស្សនសប្បដិឃៈ ១ បទ*

*- សនិស្សនៈ ១ បទ*

*- សប្បដិឃៈ ១ បទ*

*- ឧបាទានធម្ម ១ បទ ។*

*ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបការរាប់សង្គ្រោះធម៌ដែលបាន និងមិនបានដោយអំណាចនៃបទទាំងនោះឯង ។ ក៏ពោលដោយអំណាចនៃបញ្ហា*

ក្នុងវារៈនេះ ទ្រង់ធ្វើទុក ៨ បញ្ហា គឺ

-បញ្ហា ១ ធ្វើទុក ***ព្រោះរូបរូមធម៌ ២០*** ដោយអំណាចនៃអាយតនៈ (ទ្វារិកាយតនៈ ១០) និងធាតុ (ទ្វារិកធាតុ ១០) ទុកក្នុងពាក្យវិស្សជ្ជនា ដែលមានទំនងដូចគ្នា ។

-បញ្ហា ១ ធ្វើទុក ព្រោះរូបរូមវិញ្ញាណធាតុ ៧

-បញ្ហា ១ ធ្វើទុក ព្រោះរូបរូមឥន្ទ្រិយ ៧ (មានចក្ខុន្ទ្រិយជាដើម)

-បញ្ហា ១ ធ្វើទុក ព្រោះរូបរូមភពទាំង ២

-បញ្ហា ១ ធ្វើទុកដោយបរិទេវបទ និងសនិទស្សនសប្បដិឃបទ

-បញ្ហា ១ ធ្វើទុកដោយសនិទស្សនបទទាំងឡាយ

-បញ្ហា ១ ធ្វើដោយសប្បដិឃបទ និងឧបាទាធម៌ទាំងឡាយ ។

បណ្ដាបញ្ហាទាំងនោះ គប្បីជ្រាបការចែកខន្ធជាដើមយ៉ាងនេះ គឺ

## បញ្ហា ៨ យ៉ាង

***-ក្នុងបញ្ហាទី ១*** សិន ៖ ពីរបទថា **"ចក្ខុហិ ខន្ធេហិ"** បានដល់ សង្គ្រោះមិនបានដោយអរូបក្ខន្ធ ៤ ។ ពីរបទថា **"ទ្វីហិ អាយតនេហិ"** បានដល់ សង្គ្រោះមិនបានដោយមនាយតនៈ ១ ជាមួយនឹងអាយតនៈទាំងឡាយ មានចក្ខាយតនៈជាដើម អាយតនៈណាមួយ ។ ពីរបទថា **"អដ្ឋហិ ធាតូហិ"** បានដល់ សង្គ្រោះមិនបានដោយធាតុ ៨ គឺដោយ

វិញ្ញាណធាតុ ៧ ជាមួយនឹងបណ្ដាធាតុទាំងឡាយ មានចក្ខុធាតុជាដើម ធាតុណាមួយ ក្នុងនិទ្ទេសនេះ ។ គប្បីជ្រាបន័យដូច្នេះថា ចក្ខាយតនៈ សង្គ្រោះដោយសេចក្ដីជារូបក្ខន្ធបាន, កាលបើចក្ខាយតនៈនោះ សង្គ្រោះដោយសេចក្ដីជាខន្ធហើយ ចក្ខាយតនៈមួយប៉ុណ្ណោះ ក៏សង្គ្រោះបាន ដោយការសង្គ្រោះជាអាយតនៈ ។ ចំណែកអាយតនៈ ១០ ដ៏សេស រាប់សង្គ្រោះមិនបានទេ ។ សូម្បីការសង្គ្រោះដោយធាតុ ចក្ខុធាតុមួយប៉ុណ្ណោះ រាប់សង្គ្រោះដោយធាតុបាន ។ ធាតុ ១០ ដ៏សេស រាប់សង្គ្រោះមិនបានទេ ។ ព្រោះហេតុនេះ អាយតនៈឯណា ១០ រាប់សង្គ្រោះមិនបាន ដោយចក្ខាយតនៈនោះ អាយតនៈទាំងនោះ មិនរាប់សង្គ្រោះដោយអាយតនៈ ២ គឺ **ចក្ខាយតនៈ** និង **មនាយតនៈ** ទេ; សូម្បី ***ធាតុឯណា ១០*** រាប់សង្គ្រោះចូលមិនបាន ធាតុទាំងនោះ ក៏រាប់សង្គ្រោះមិនបានដោយចក្ខុធាតុ និង វិញ្ញាណធាតុ ៧ ដូច្នេះឡើយ ។ សូម្បីក្នុងរូបាយតនៈជាដើម ក៏មានន័យដូចគ្នានេះដែរ ។

***-ក្នុងបញ្ហាទី ២*** វិញ្ញាណក្ខន្ធ លោកសង្គ្រោះបានដោយវិញ្ញាណធាតុយ៉ាងណានីមួយ វិញ្ញាណក្ខន្ធនោះ ឈ្មោះថា សង្គ្រោះមិនបានដោយមនា-យតនៈ មិនមានឡើយ ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ទុកថា **"អាយតនសង្គហេន សង្គហិតា"** ។ ក៏ក្នុងការវិសជ្ជនាបញ្ហាទីពីរនេះ

ពីរបទថា **"ចតូហិ ខន្ធេហិ"** បានដល់ ដោយខន្ធ ៤ មានរូបក្ខន្ធ ជាដើម ។ ពីរបទថា **"ឯកាទសហិ អាយតនេហិ"** បានដល់ សង្គ្រោះ មិនបានដោយអាយតនៈ ១១ វៀរមនាយតនៈចេញ; ពីរបទថា **"ទ្វាទសហិ ធាតូហិ"** បានដល់ សង្គ្រោះមិនបានដោយធាតុ ១២ ដ៏សេស ដោយនាំវិញ្ញាណធាតុ ៦ ចេញតាមសមគួរ ។ ព្រោះថា ចក្ខុវិញ្ញាណធាតុរាប់សង្គ្រោះបានដោយចក្ខុវិញ្ញាណធាតុហ្នឹងឯង, ធាតុក្រៅពីនេះ សង្គ្រោះមិនបានឡើយ ។ សូម្បីក្នុងសោតវិញ្ញាណធាតុជាដើម ក៏មានន័យដូចគ្នានេះដែរ ។

*-ក្នុងបញ្ហាទី ៣* ការវិសជ្ជនាចក្ខុន្ទ្រិយជាដើម ដូចនឹងចក្ខ្វាយតនៈជាដើមនុ៎ះដែរ ។ តែក្នុងឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ គប្បីជ្រាបអាយតនៈ ២ គឺ ***មនាយតនៈ*** និង ***ធម្មាយតនៈ***, ឯ ***ធាតុ ៨*** គឺ ***វិញ្ញាណធាតុ ៧*** និង ***ធម្មធាតុ ១*** (រាប់សង្គ្រោះចូលដោយឥន្ទ្រិយទាំង ២ នេះ មិនបានទេ) ។

*-ក្នុងបញ្ហាទី ៤* បទថា **"តីហិ អាយតនេហិ"** បានដល់ (រាប់សង្គ្រោះមិនបាន) ដោយ ***រូបាយតនៈ ធម្មាយតនៈ*** និង ***មនាយតនៈ*** ។ ព្រោះថា ក្នុងភពទាំងនោះ ពោលដោយអំណាចនៃ ***រូបាយតនៈ*** និង ***ធម្មាយតនៈ*** បាន ***អាយតនៈ ២ ប៉ុណ្ណោះ*** សង្គ្រោះមិនបានដោយអាយតនៈ ៣ គឺដោយអាយតនៈ ២ (រូបាយតនៈ និងធម្មាយតនៈ) ទាំងនោះឯង និងមនា-

យតនៈ ១ ។ ពីរបទថា **“នវហិ ធាតូហិ”** បានដល់ ដោយធាតុ ៩ គឺ ***វិញ្ញាណធាតុ ៧, រូបធាតុ*** និង ***ធម្មធាតុ*** ។

***-ក្នុងបញ្ហាទី ៥*** បទថា **“ទ្វីហិ អាយតនេហិ”** សំដៅយកបទទី ១ (គឺបរិទេវធម៌) ដែលរាប់សង្គ្រោះមិនបានដោយ ***សទ្ទាយតនៈ*** និង ***មនាយតនៈ*** ។ សំដៅយកបទទី ២ (គឺសនិទស្សនសប្បដិឃធម៌) ដែលរាប់សង្គ្រោះមិនបានដោយ ***រូបាយតនៈ*** និង ***មនាយតនៈ*** ។ សូម្បីធាតុទាំងឡាយ ក៏គប្បីជ្រាបថា វិញ្ញាណធាតុ ៧ និងអាយតនៈម្យ៉ាង ៗ ក្នុងបណ្ដាអាយតនៈទាំងនោះឯង ។

***-ក្នុងបញ្ហាទី ៦*** ពីរបទថា **“ទសហិ អាយតនេហិ”** បានដល់អាយតនៈ ១០ វៀររូបាយតនៈ និងធម្មាយតនៈចេញ ។ ពីរបទថា **“សោឡសហិ ធាតូហិ”** បានដល់ ធាតុ ១៦ វៀររូបធាតុ និងធម្មធាតុចេញ ។ ***សួរថា*** សេចក្ដីនេះ មានអធិប្បាយយ៉ាងណា ? ឆ្លើយថា ក៏ព្រោះឱឡារិកាយតនៈ ៩ ឈ្មោះថា អនិទស្សនសប្បដិឃធម៌ កាលបើអាយតនៈទាំងនោះ សង្គ្រោះចូលក្នុងរូបក្ខន្ធដោយខន្ធសង្គហៈហើយ អាយតនៈទាំងនោះឯង ក៏សង្គ្រោះបានដោយអាយតនៈ, តែសង្គ្រោះមិនបាន ដោយ ***រូបាយតនៈ*** និង ***ធម្មាយតនៈ***; សូម្បីពោលដោយធាតុសង្គហៈ ក៏ឱឡារិកធាតុ ៩ សង្គ្រោះចូលគ្នាបានដែរ, តែរូបធាតុ និងធម្មធាតុ រាប់សង្គ្រោះចូលគ្នា

មិនបាន ដោយអាយតនៈនុ៎ះទេ ។ ដោយហេតុនេះ ការរាប់សង្គ្រោះមិនបាន ដោយអាយតនៈទាំងនោះ, ចំណែកអាយតនៈទាំងនោះ អាយតនៈណា ២ គប្បីជ្រាបថា រាប់សង្គ្រោះមិនបានដោយអាយតនៈ ១០ គឺ ***ឱឡារិកាយតនៈ ៩*** និង ***មនាយតនៈ ១ វៀររូបាយតនៈ*** និង ***ធម្មាយតនៈ*** ចេញ ។ សូម្បីធាតុទាំងពីរឯណា ដែលរាប់សង្គ្រោះមិនបានដោយធម៌ទាំងនោះ ធាតុទាំងនោះ គប្បីជ្រាបថា រាប់សង្គ្រោះមិនបានដោយធាតុ ១៦ គឺឱឡារិកធាតុ ៩ និងវិញ្ញាណធាតុ ៧ វៀររូបធាតុ និងធម្មធាតុចេញ ។

***-ក្នុងបញ្ហាទី ៧*** ពីរបទថា **"ទ្វីហិ អាយតនេហិ"** បានដល់ ដោយអាយតនៈ ២ គឺរូបាយតនៈ និងមនាយតនៈ ។ ពីរបទថា **"អដ្ឋហិ ធាតូហិ"** បានដល់ ដោយធាតុ ៨ គឺដោយរូបធាតុ និងវិញ្ញាណធាតុ ៧ ។

***-ក្នុងបញ្ហាទី ៨*** ពីរបទថា **"ឯកាទសហិ អាយតនេហិ"** សំដៅយកសប្បដិឃធម៌ទាំងឡាយ វៀរធម្មាយតនៈ និងសំដៅយកឧបាទានធម៌ទាំង-ឡាយ វៀរផោដ្ឋព្វាយតនៈចេញ ។ សូម្បីក្នុងធាតុទាំងឡាយ ក៏មានន័យដូចគ្នានេះដែរ ក៏ការប្រកបសេចក្ដីក្នុងនិទ្ទេសនៃបទនេះ បណ្ឌិតគប្បីជ្រាបតាមន័យដែលខ្ញុំពោលហើយ ក្នុងខាងក្រោយនុ៎ះចុះ ៚

ចប់សង្គហិតេន អសង្គហិតបទនិទ្ទេស

## ៣.ពណ៌នាអំពីអសង្គហិតេន សង្គហិតបទនិទ្ទេស

*ឥឡូវនេះ ដើម្បីចែក* ***អសង្គហិតេន សង្គហិតបទ*** *ព្រះមានព្រះភាគទើបផ្ដើមពាក្យថា* **“ខេធនាខន្ធេន”** *ជាអាទិ៍ ។ ក្នុងបទនេះ គប្បីជ្រាបលក្ខណៈដូច្នេះ ៖*

*ក្នុងវារៈនេះ បទណារាប់សង្គ្រោះចូលគ្នាមិនបានដោយខន្ធ, តែរាប់សង្គ្រោះចូលគ្នាបានដោយបទនៃអាយតនៈ និងធាតុទាំងឡាយ ព្រះមាន-ព្រះភាគទ្រង់ធ្វើបុច្ឆា និងវិសជ្ជនាការរាប់សង្គ្រោះនូវបទទាំងនោះ ដោយខន្ធជាដើម ។ តែថា បទ (អសង្គហិតេនសង្គហិត) នោះ រមែងមិនប្រកបក្នុងបទទាំងឡាយ មានរូបក្ខន្ធ វិញ្ញាណក្ខន្ធ និងចក្ខាយតនៈជាដើម ។ ព្រោះថារូបក្ខន្ធ រាប់សង្គ្រោះចូលក្នុងនាមក្ខន្ធ ៤ ដោយខន្ធសង្គហៈមិនបានឡើយ ។ បណ្ដាធម៌ទាំងនោះ សូម្បីធម៌ ១ ឈ្មោះថា រាប់សង្គ្រោះបាន ដោយអាយតនៈ និងធាតុទាំងឡាយប៉ុណ្ណោះ ក៏រមែងមិនមាន ។ កាលមានពាក្យសួរថា វេទនាជាដើម រាប់សង្គ្រោះចូលគ្នាបានដោយធម្មាយតនៈ មិនមែនឬ ? ឆ្លើយថា វេទនាជាដើម ដែលរាប់សង្គ្រោះចូលគ្នា ដោយធម្មាយតនៈបាន, តែមិនមែនធម្មាយតនៈ គឺរូបក្ខន្ធទេ, ព្រោះទ្រង់ចែកធម្មាយតនៈ*

ត្រឹមតែជាសុខុមរូប ដោយសេចក្ដីជារូបក្ខន្ធ ព្រោះហេតុដូច្នោះ ធម៌ណា ដែលរាប់សង្គ្រោះចូលគ្នាបានដោយធម្មាយតនៈ, ធម៌ទាំងនោះ មិនបាន ឈ្មោះថា រាប់សង្គ្រោះចូលគ្នាបានដោយរូបក្ខន្ធទេ ។ ខន្ធ ៤ ក្រៅអំពីនេះ ក៏សង្គ្រោះចូលគ្នាមិនបាន សូម្បីជាមួយវិញ្ញាណក្ខន្ធ ។ បណ្ដាធម៌ទាំងនោះ សូម្បីធម៌ ១ ឈ្មោះថា រាប់សង្គ្រោះចូលគ្នាបាន ដោយអាយតនៈ និង ធាតុទាំងនោះ ក៏រមែងមិនមាន ។ ព្រោះសេចក្ដីនៃបទទាំងនេះ រាប់ សង្គ្រោះចូលគ្នាយ៉ាងនេះ មិនមានបទទាំងឡាយក្រៅអំពីនេះក្ដី ទើបរាប់ សង្គ្រោះចូលគ្នាមិនបានក្នុងវារៈនេះ ។ ចំណែកបទណា រមែងបំភ្លឺដល់ ឯកទេសនៃធម្មាយតនៈ ដែលមិនលាយច្រឡំដោយវិញ្ញាណ ឬឱឡារិករូប, បទនោះប៉ុណ្ណោះ ព្រះមានព្រះភាគទ្រង់កាន់យកក្នុងទីនេះ ។ គប្បីជ្រាប ឧទាននៃបទទាំងនោះដូច្នេះ ៖

**“តយោ ខន្ធា តថា សច្ចា　ឥន្ទ្រិយានិ ច សោឡស**
**បទានិ បច្ចយាការេ　ចុទ្ទសូបរិ ចុទ្ទស ។**
**សមត្តឹស បទា ហោន្តិ　គោច្ឆកេសុ ទសស្វថ**
**ទុវេ ចូឡន្តរទុកា　អដ្ឋ ហោន្តិ មហន្តរា**

ខន្ធ ៣ គឺ (ចេតសិកខន្ធ ៣), សច្ចៈ ៣ (គឺសមុទ័យ និរោធ និង មគ្គ), ឥន្ទ្រិយ ១៦ (គឺវៀរបសាទិន្ទ្រិយ ៥ និងមនិន្ទ្រិយចេញ),

បច្ចយាការ ១៨ (គឺបដិច្ចសមុប្បាទ ១៨ វៀរវិញ្ញាណ នាមរូប សឡាយតនៈ ឧប្បត្តិភព និងបរិទេវៈ) បទដែលតមកអំពីបច្ចយាការ ១៨ បទទៀត (គឺបទសតិបដ្ឋានជាដើម វៀរឥទ្ធិបាទចេញ) បទទាំងឡាយ ៣០ បទ ដែលមានក្នុងគោច្ឆកៈ ១០ ចូឡន្តរទុកៈ ២ បទ (គឺអប្បច្ចយបទ និងអសង្ខតបទ) មហន្តរទុកៈ ៨ បទ (រួមត្រូវជា ៩០ បទ) ។

ក៏បណ្ដាបទទាំងនោះ ព្រះមានព្រះភាគត្រាស់បញ្ហាទាំងអស់ទុក ១២ បទ ដោយរួមបទ ៦ ដែលជាពាក្យវិសជ្ជនាដូចគ្នាតែម្យ៉ាង ។ បណ្ឌិតគប្បីជ្រាបនូវការបែកខន្ធក្នុងបទទាំងនោះ យ៉ាងនេះ ។ តែក្នុងអាយតនៈ និងធាតុទាំងឡាយ មិនមានសេចក្ដីផ្សេងគ្នាឡើយ ។

## បញ្ហា ៧ យ៉ាង

***-ក្នុងបញ្ហាទី ១*** មុន ពីរបទថា **“តីហិ ខន្ធេហិ”** បានដល់ (រាប់សង្គ្រោះបាន) ដោយខន្ធ ៣ គឺ ***រូបក្ខន្ធ សញ្ញាខន្ធ*** និង ***សង្ខារក្ខន្ធ*** ។

ចំណែកអាយតនៈ និងធាតុ គប្បីជ្រាបការរាប់សង្គ្រោះបាន ដោយអំណាចនៃធម្មាយតនៈ និងធម្មធាតុ ។ ក្នុងនិទ្ទេសនេះ គប្បីជ្រាបន័យដូច្នេះថា ***និព្វាន សុខុមរូប សញ្ញា*** និង ***សង្ខារក្ខន្ធ*** មិនរាប់សង្គ្រោះដោយខន្ធសង្គហៈជាមួយវេទនាខន្ធឡើយ, តែជាធម៌ដែលរាប់សង្គ្រោះបាន ដោយអាយតនៈ (គឺធម្មាយតនៈ) និងធាតុ (គឺធម្មធាតុ) ។ បណ្ដាធម៌ទាំងនោះ

និព្វានមិនដល់ការរាប់ថាជាខន្ធទេ ។ ធម៌ដ៏សេសរមែងដល់ការសង្គ្រោះបាន ដោយរូបក្ខន្ធ សញ្ញាខន្ធ និងសង្ខារក្ខន្ធ សូម្បីនិព្វាន ក៏រមែងដល់ការរាប់សង្គ្រោះថា ជាអាយតនៈ និងធាតុមែនពិត ។ ដោយហេតុនេះ ទើបព្រះមានព្រះភាគត្រាស់ថា **"អសង្ខតំ ខន្ធតោ ឋបេត្វា តីហិ ខន្ធេហិ ឯកេនាយតនេន ឯកាយ ធាតុយា សង្គហិតា"** ដូច្នេះ ។ តែសញ្ញាខន្ធក្នុងទីនេះ នាំសញ្ញាខន្ធចេញហើយ គប្បីជ្រាបថា ជាខន្ធ ៣ ជាមួយនឹងវេទនាខន្ធ ។ ក្នុងសង្ខារក្ខន្ធជាដើម នាំសង្ខារក្ខន្ធចេញហើយ គប្បីជ្រាបថា ជាខន្ធ ៣ ដោយអំណាចនៃរូបក្ខន្ធ វេទនាខន្ធ និងសញ្ញាខន្ធ ។

*-**ក្នុងបញ្ហាទី ២*** ពីរបទថា **"ចតូហិ ខន្ធេហិ"** បានដល់ ខន្ធ ៤ វៀរវិញ្ញាណក្ខន្ធចេញ ។ ព្រោះថា ធម៌ទាំងនោះរាប់សង្គ្រោះដោយនិរោធជាខន្ធសង្គហៈមិនបានទេ, តែរាប់សង្គ្រោះបានដោយអាយតនៈ និងធាតុ ។

*-**ក្នុងបញ្ហាទី ៣*** ពាក្យថា **"ទ្វីហិ"** បានដល់ (រាប់សង្គ្រោះបាន) ដោយខន្ធ ២ គឺ ***វេទនាខន្ធ*** និង ***សញ្ញាខន្ធ***; ព្រោះថា ***វេទនាខន្ធ សញ្ញាខន្ធ*** និង ***វិញ្ញាណក្ខន្ធ*** រាប់សង្គ្រោះបានដោយជាខន្ធ សង្គ្រោះមិនបានដោយជារូបឥន្ទ្រិយ និងអរូបឥន្ទ្រិយ ។ តែក្នុងធម៌ទាំងនោះ ***វេទនា*** និង ***សញ្ញា*** រាប់សង្គ្រោះបានដោយជាអាយតនៈ និងធាតុ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **"វេទនាសញ្ញាខន្ធេហិ"** ដូច្នេះ បណ្ឌិតគប្បីជ្រាប

*សេចក្ដីផ្សេងគ្នានៃខន្ធក្នុងបទទាំងពួង ដោយឧបាយនេះចុះ តទៅនេះ ខ្ញុំនឹងពោលឈ្មោះរបស់ខន្ធទាំងឡាយដ៏ល្មមសមគួរប៉ុណ្ណោះ ។*

***-ក្នុងបញ្ហាទី ៤*** *ពីរបទថា* ***“តីហិ ខន្ធេហិ”*** *បានដល់ ក្នុង* ***ឥត្ថិន្ទ្រិយ*** *និង* ***បុរិសិន្ទ្រិយ*** *គប្បីជ្រាបការសង្គ្រោះបានដោយខន្ធ ៣ គឺ* ***វេទនាខន្ធ សញ្ញាខន្ធ*** *និង* ***សង្ខារក្ខន្ធ*** *។ ក្នុងពួក ៥ នៃវេទនា គប្បីជ្រាបដោយ* ***រូបក្ខន្ធ សញ្ញាខន្ធ*** *និង* ***សង្ខារក្ខន្ធ*** *។ ក្នុងសទ្ធិន្ទ្រិយជាខាងដើម មានផស្សៈជាទីបំផុត គប្បីជ្រាបថា សង្គ្រោះមិនបានដោយ* ***រូបក្ខន្ធ វេទនាខន្ធ*** *និង* ***សញ្ញាខន្ធ*** *ទេ ។ គប្បីជ្រាបក្នុងវេទនា ដូចនឹងវេទនាខន្ធនុ៎ះដែរ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងតណ្ហា ឧបាទាន និងកម្មភពទាំងឡាយ ដូចនឹងសង្ខារក្ខន្ធដែរ ។*

***-ក្នុងបញ្ហាទី ៥*** *គប្បីជ្រាបការវិនិច្ឆ័យក្នុងជាតិ ជរា និងមរណៈ ដូចនឹងជីវិតិន្ទ្រិយដែរ ព្រោះនិព្វាន សុខុមរូប សញ្ញា ជាមួយនឹងឈានរាប់សង្គ្រោះដោយខន្ធសង្គហៈមិនបាន, តែរាប់សង្គ្រោះចូលដោយជាអាយតនៈ និងធាតុបាន; ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់សំដៅយកធម៌នោះ រាប់សង្គ្រោះដោយខន្ធ ២ គឺរូបក្ខន្ធ និងសញ្ញាខន្ធ ។*

***-ក្នុងបញ្ហាទី ៦*** *គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ៣ នៃសោកៈជាដើម រាប់សង្គ្រោះជាមួយនឹងវេទនាខន្ធ គប្បីជ្រាបក្នុងឧបាយាសៈជាដើម ដូចនឹងសង្ខារក្ខន្ធ ។ គប្បីជ្រាបក្នុងវេទនាម្ដងទៀត ដូចនឹងវេទនាខន្ធដែរ ។*

*គប្បីជ្រាបក្នុងសញ្ញា ដូចនឹងសញ្ញាខន្ធដែរ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងចេតនាជាដើម ដូចនឹងសង្ខារក្ខន្ធ ។*

***-សូម្បីក្នុងបញ្ហាទី ៧*** *ជាដើម ក៏គប្បីជ្រាបធម៌ដែលរាប់សង្គ្រោះបាន និងមិនបាន ដោយឧបាយនេះចុះ ៕*

ចប់អសង្គហិតេន សង្គហិតបទនិទ្ទេស

---

## ៤.ពណ៌នាអំពីសង្គហិតេន សង្គហិតបទនិទ្ទេស

*ឥឡូវនេះ ដើម្បីចែក* ***សង្គហិតេន សង្គហិតបទ*** *ទើបព្រះមានព្រះភាគទ្រង់ផ្ដើមពាក្យថា* **“សមុទយសច្ចេន”** *ជាដើម ។ ក្នុងនិទ្ទេសនោះ បទណា រាប់សង្គ្រោះបានដោយអំណាចនៃខន្ធសង្គហៈជាដើម ដោយធម៌មានខន្ធជាដើម ព្រះមានព្រះភាគទ្រង់ធ្វើបុច្ឆា និងវិសជ្ជនានូវការសង្គ្រោះបទនោះឯង ដោយខន្ធជាដើមទៀត ។ បទនោះ សូម្បីតែមួយបទ មិនបានប្រកបក្នុងបទទាំងឡាយ ដែលលោកកាន់យកចំណែកទាំងអស់ តាំងទុកក្នុងខន្ធ អាយតនៈ និងធាតុដែរ ។ ព្រោះថា បទដទៃ ឈ្មោះថា សង្គ្រោះ ហើយដោយអំណាចនៃខន្ធជាដើម ដោយបទនៃខន្ធជាដើមទាំងអស់ ។ បទណា រួមបទដែលសង្គ្រោះបានដល់ខន្ធ, បទនោះ គប្បីដល់ការរាប់សង្គ្រោះ ដោយអំណាចនៃខន្ធជាដើមនោះឯងទៀត; ព្រោះហេតុដូច្នោះ បទទាំងឡាយនោះ*

ព្រះមានព្រះភាគទ្រង់មិនបានកាន់យកក្នុងវារៈនេះទេ ។ ចំណែកបទណា រមែងបំភ្លឺដល់ឯកទេសនៃសង្ខារក្ខន្ធដែលមិនលាយដោយបទដទៃ ឬរមែងបំភ្លឺដល់វេទនាខន្ធ ឬថាសុខុមរូប ឬក៏ឯកទេសនៃសច្ចៈដែលមិនលាយដោយបទដទៃ, បទទាំងនោះ ព្រះអង្គទ្រង់កាន់យកក្នុងវារៈនេះ ។ គប្បីជ្រាបឧទាននៃបទទាំងនោះ ដូច្នេះ ៖

**"ទ្វេ សច្ចា បណ្ណរសិន្ទ្រិយា ឯកាទស បដិច្ចបទា**
**ឧទ្ធំ បន ឯកាទស គោច្ឆកបទមេត្ថ តឹសទិធា**

សច្ចៈ ២ (គឺសមុទយសច្ច និងមគ្គសច្ច) ឥន្ទ្រិយ ១៥ (គឺវៀរបសាទិន្ទ្រិយ ៥ ជីវិតិន្ទ្រិយ ១ និងមនិន្ទ្រិយ ១ ចេញ) បដិច្ចសមុប្បាទ ១១ បទ (គឺវៀរវិញ្ញាណ នាមរូប សឡាយតនៈ វេទនា ឧប្បត្តិភព ជាតិ ជរា និងមរណៈ) បទដែលតពីបដិច្ចសមុប្បាទទៅទៀត មាន ១១ បទ (គឺសតិបដ្ឋាន សម្មប្បធាន អប្បមញ្ញា បញ្ចិន្ទ្រិយ ពលៈ ពោជ្ឈង្គៈ មគ្គង្គៈ ផស្សៈ ចេតនា អធិមោក្ខ និងមនសិការ) បទដែលនៅក្នុងគោច្ឆកៈ ៣០ បទ (រួមត្រូវជា ៦៩ បទ)" ។

## បញ្ហា ២ យ៉ាង

ក៏ក្នុងនិទ្ទេសនៃបទនេះ មាន ២ បញ្ហាប៉ុណ្ណោះ ។ ក្នុងបញ្ហាទាំងនោះ បទណាដែលព្រះមានព្រះភាគទ្រង់អារាធនាឡើងដើម្បីបុច្ឆា, បទនោះ

នុ៎ះឯង រាប់សង្គ្រោះបានដោយអំណាចនៃខន្ធជាដើម ដោយធម៌ណា, ទ្រង់សំដៅយកធម៌ទាំងនោះ ទើបត្រាស់ថា **"ឯកេន ខន្ធេន"** ជាដើម ទុកក្នុងទីទាំងពួង ។ ក្នុងបញ្ហានោះ គប្បីជ្រាបន័យដូច្នេះថា ក៏សង្ខារទាំងឡាយវៀរតណ្ហាចេញហើយ រាប់សង្គ្រោះបានដោយខន្ធសង្គហៈជាដើមបាន ដោយសមុទយសច្ច តណ្ហានោះឯង ក៏នៅសង្គ្រោះចូលគ្នាបាន ដោយធម៌ទាំងនោះទៀត ។ តណ្ហានោះ ទើបឈ្មោះថា រាប់សង្គ្រោះបានដោយខន្ធសង្គហៈជាដើម ដោយសង្ខារទាំងឡាយនោះឯងទៀត ។ ក្នុងបទទាំងពួង ក៏មានន័យដូចគ្នានេះដែរ ។ តែក្នុងបុច្ឆានៃរូបធម៌ទាំងឡាយ ក្នុងទីនេះ ឈ្មោះថា មានខន្ធមួយ គឺសង្ខារក្ខន្ធ ឬវេទនាខន្ធ ។ ក្នុងបុច្ឆានៃធម៌ ឈ្មោះថា មានខន្ធមួយ គឺរូបក្ខន្ធ ។ ក្នុងបុច្ឆានៃបទបរិទេវៈ ឈ្មោះថា មានអាយតនៈ ១ គឺសទ្ទាយតនៈ, ឈ្មោះថា មានធាតុមួយ គឺសទ្ទធាតុនោះឯង, បណ្ឌិតគប្បីជ្រាបសេចក្តីក្នុងបទដ៏សេស ដោយអំណាចនៃធម្មាយតនៈ និងធម្មធាតុដូច្នេះឯង ៕

ចប់សង្គហិតេន សង្គហិតបទនិទ្ទេស

---

## ៥.ពណ៌នាអំពីអសង្គហិតេន អសង្គហិតបទនិទ្ទេស

ឥឡូវនេះ ដើម្បីចែក ***អសង្គហិតេន អសង្គហិតបទ*** ទើបព្រះមាន-

ព្រះភាគទ្រង់ផ្ដើមពាក្យថា **“រូបក្ខន្ធេន”** ជាដើម ។ ក្នុងនិទ្ទេសនៃបទទាំងនោះ បទណារាប់សង្គ្រោះមិនបានដោយអំណាចនៃខន្ធជាដើម ដោយបទដែលសង្គ្រោះមិនបាន ដោយខន្ធជាដើម ព្រះមានព្រះភាគទ្រង់ធ្វើបុច្ឆា និងវិសជ្ជនានូវការសង្គ្រោះបទនោះឯង ដោយខន្ធជាដើមម្ដងទៀត ។ បទថា **“អសង្គហិតេន អសង្គហិតៈ”** នោះ រមែងមិនប្រកបក្នុងបទទាំងឡាយ មានទុក្ខសច្ចជាដើម ដែលប្រព្រឹត្តទៅដោយខន្ធ ៥ និងក្នុងបទទាំងឡាយដែលមានអនិទស្សនាបដិឃៈជាដើម ដែលប្រព្រឹត្តទៅដោយសុខុមរូបជាមួយនឹងវិញ្ញាណ ។ ព្រោះព្រះនិព្វានមិនគប្បីសង្គ្រោះចូលជាខន្ធបាន ដោយបទដូច្នោះទេ ។ ចំណែកបទដ៏សេស ឈ្មោះថា ជាធម៌ដែលសង្គ្រោះចូលមិនបានដោយខន្ធជាដើម រមែងមិនមាន ព្រោះហេតុដូច្នោះ បទទាំងឡាយដែលមានសភាពយ៉ាងនេះ ព្រះមានព្រះភាគទ្រង់មិនកាន់យកក្នុងវារៈនេះឡើយ ។ ក៏ប៉ុន្តែ បទឯណាមិនសម្ដែងវិញ្ញាណក្នុងខន្ធ ៥ ដោយរួមជាមួយនឹងសុខុមរូប, បទទាំងនោះ ព្រះអង្គទ្រង់កាន់យកក្នុងទីនេះ ។ បណ្ឌិតគប្បីជ្រាបបទឧទាននៃបទទាំងនោះដូច្នេះ ៖

**“សព្វេ ខន្ធា តថាយតន- ធាតុយោ សច្ចតោ តយោ**
**ឥន្ទ្រិយានិបិ សព្វានិ តេវីសតិ បដិច្ចតោ ។**

**បរតោ សោឡសបទា គេចត្តាឡីសកត្តិកេ**
**គោច្ឆកេ សត្តតិ ទ្វេ ច សត្ត ចូឡន្តរេ បទា ។**
**មហន្តរេ បទា ទុក្កា អដ្ឋារស តតោ បរំ**
**អដ្ឋារសេវ ញាតព្វា សេសា ឥធ ន ភាសិតា ។**

*ខន្ធទាំងអស់ អាយតនៈទាំងអស់ ធាតុទាំងអស់ សច្ចៈ ៣ (គឺសមុទយសច្ច និរោធសច្ច និងមគ្គសច្ច) ឥន្ទ្រិយទាំងអស់ បដិច្ចសមុប្បាទ ២៣ (វៀរឧប្បត្តិភព កាមភព រូបភព សញ្ញី-ភព និងបញ្ចវោការភព) តពីបដិច្ចសមុប្បាទទៅទៀត ១៦ បទ (គឺសតិបដ្ឋានជាដើម រហូតដល់មនសិការជាទីបំផុត) ក្នុងតិកៈ ៤៣ បទ ក្នុងគោច្ឆកៈ ៧២ បទ ក្នុងចូឡន្តរទុកៈ ៧ បទ ក្នុងមហន្តរទុកៈ ១៨ បទ និងខាងមុខនេះ ១៨ បទទៀត (គឺបិដ្ឋិទុកៈ) រួមទាំងអស់ ២៥៧, បទដ៏សេស ព្រះមានព្រះភាគទ្រង់មិនសម្ដែងទុកក្នុងនិទ្ទេសនេះទេ ។*

## បញ្ហា ៣៤ យ៉ាង

*ក៏ក្នុងនិទ្ទេសនេះ សូម្បីបញ្ហាទាំងអស់ មាន ៣៤ ព្រមជាមួយបទដែលទ្រង់រួបរួមទុក ដោយអំណាចនៃពាក្យវិសជ្ជនាមានទំនងដូចគ្នា ក្នុងនិទ្ទេសនៃបទទាំងនោះ បទណា ព្រះមានព្រះភាគទ្រង់លើកឡើងសម្ដែងដើម្បីបុច្ឆាបទនោះឯង សង្គ្រោះមិនបានដោយធម៌ឯណា មានខន្ធជាដើម ទ្រង់សំដៅ*

យកធម៌ទាំងនោះ ទើបត្រាស់ថា **“ឯកេន ខន្ធេន”** ជាអាទិ៍ ។ ក្នុងសេចក្ដីនេះ គប្បីជ្រាបន័យដូច្នេះថា ៖

ខន្ធ ៤ និងនិព្វាន ១ រាប់សង្គ្រោះមិនបានដោយរូបក្ខន្ធ ដោយខន្ធសង្គហៈ វៀរវិញ្ញាណចេញហើយ ធម៌ដ៏សេសរាប់សង្គ្រោះបានដោយការសង្គ្រោះជាអាយតនៈ និងធាតុ ព្រោះហេតុនោះ វិញ្ញាណនោះឯងឈ្មោះថា សង្គ្រោះចូលមិនបាន សូម្បីដោយសង្គហៈទាំង ៣ មានខន្ធសង្គហៈជាដើម ។ ខន្ធ ៤ ក៏រាប់សង្គ្រោះមិនបានដោយនិព្វាន ដោយវិញ្ញាណនិងដោយការសង្គ្រោះចូលក្នុងខន្ធជាដើម ។ សូម្បីធម៌ទាំងអស់ សង្គ្រោះមិនបាន ដោយវិញ្ញាណនោះឯង ដោយខន្ធសង្គហៈជាដើមទៀត ព្រោះហេតុនោះ ធម៌ទាំងនោះ ទើបឈ្មោះថា រាប់សង្គ្រោះមិនបាន ដោយខន្ធ ១ អាយតនៈ ១ និងធាតុ ៧ ។ ន័យមួយទៀត វិញ្ញាណនោះៗ ឯង រាប់សង្គ្រោះមិនបានដោយរូបក្ខន្ធ ដោយសង្គហៈទាំង ៣ មានខន្ធសង្គហៈជាដើម រូបធម៌ទាំងនោះមានពិត ក៏សង្គ្រោះមិនបានដោយវិញ្ញាណធម៌សូម្បីដោយសង្គហៈទាំង ៣ នោះ ។ ឯរូបធម៌ទាំងនោះ ក៏រាប់សង្គ្រោះមិនបានដោយវិញ្ញាណ ដោយសង្គហៈទាំង ៣ ទៀត ។ ព្រោះថា វិញ្ញាណ កាលពោលដោយខន្ធ ជាវិញ្ញាណក្ខន្ធ ១, កាលពោលដោយអាយតនៈ ជាមនាយតនៈ, បើពោលដោយធាតុ ជាវិញ្ញាណធាតុ ៧ ព្រោះហេតុនោះ ទើបព្រះមាន

*ព្រះភាគត្រាស់ថា* **“ឯកេន ខន្ធេន”** *ជាដើម ។ ដោយឧបាយនេះ ក្នុងបទទាំងពួង បទណាព្រះមានព្រះភាគទ្រង់លើកឡើងសម្ដែងដើម្បីបុច្ឆា, បទនោះឯង រាប់សង្គ្រោះមិនបាន ដោយធម៌ពួកណា ដោយអំណាចនៃខន្ធជាដើម បណ្ឌិតគប្បីជ្រាបខន្ធជាដើម ដែលសង្គ្រោះមិនបាន ដោយអំណាចនៃធម៌ទាំងនោះ ។*

*ក្នុងនិទ្ទេសនោះ* ***បញ្ហាទី ២*** *គប្បីជ្រាបដោយអំណាចនៃរូប និងវិញ្ញាណមុន, ព្រោះថា វេទនាជាដើម រាប់សង្គ្រោះមិនបានដោយរូប និងវិញ្ញាណឡើយ ដោយការសង្គ្រោះក្នុងខន្ធជាដើម ។ ព្រោះថា ខន្ធទាំង ២ នោះ ជាអាយតនៈ ១១ និងជាធាតុ ១៧ ។*

*ក្នុងបញ្ហាទី ៣ វិញ្ញាណរាប់សង្គ្រោះមិនបានដោយខន្ធ ៤ មានរូបក្ខន្ធជាដើម ព្រោះហេតុដូច្នេះ បណ្ឌិតគប្បីជ្រាបធម៌ទាំងឡាយ មានខន្ធជាដើម ដោយអំណាចនៃធម៌ទាំងនោះ ។*

*ក្នុងបញ្ហាទី ៤ គប្បីជ្រាបធម៌ទាំងឡាយ មានខន្ធជាដើម ក្នុងបញ្ហាទាំងពួង ដោយន័យនេះថា* ***“ចក្ខាយតនៈរាប់សង្គ្រោះមិនបានដោយខន្ធ ៤ មានវេទនាខន្ធជាដើម”*** *។ ក្នុងបរិយោសាន ធម៌ដែលព្រះមានព្រះភាគទ្រង់សម្ដែងទុកក្នុងឧទានគាថានោះឯងថា* **“រូបំ ធម្មាយតនំ”** *ជាដើម ជាការសម្ដែងសង្ខេបទុក ដោយអាការដទៃដូច្នេះឯង ៕*

ចប់អសង្គហិតេន អសង្គហិតបទនិទ្ទេស

## ៦.ពណ៌នាអំពីសម្បយោគវិប្បយោគបទនិទ្ទេស

*ឥឡូវនេះ ដើម្បីចែកបទ **សម្បយោគវិប្បយោគ** ទើបព្រះមានព្រះភាគទ្រង់ផ្ដើមពាក្យថា* **“រូបក្ខន្ធោ”** *ជាដើម ។ ក្នុងនិទ្ទេសនោះ បទណារមែងបាន, បទណារមែងមិនបាន, បទទាំងអស់នោះ ព្រះមានព្រះភាគទ្រង់កាន់យកដើម្បីបុច្ឆា ។ តែក្នុងការវិសជ្ជនា បទណារមែងមិនបាន, បទនោះព្រះអង្គទ្រង់បដិសេធថា* **“នត្ថិ** *= មិនមាន***”** *ដូច្នេះ ។ ការប្រកបនូវគ្នានឹងគ្នា របស់រូបក្ខន្ធទាំងឡាយនោះឯង ដែលកើតឡើងក្នុងសន្ដានមួយ ក្នុងខណៈមួយ ដែលមានចំណែកស្មើដោយអរូបក្ខន្ធ ៤ នោះឯង រមែងបានពីព្រះបាលីនុ៎ះថា* **“ចតូហិ សម្បយោគោ, ចតូហិ វិប្បយោគោ, សភាគោ វិសភាគោ”** *ដូច្នេះ ។ ក៏ឈ្មោះថា **សម្បយោគ** (គឺការប្រកប) របស់រូបទាំងឡាយ មួយអន្លើដោយរូប ឬដោយនិព្វាន និងសម្បយោគ របស់និព្វានមួយអន្លើដោយរូប រមែងមិនមាន ។ ដោយទំនងដូចគ្នានេះ ការប្រកបរបស់រូប និងនិព្វាន មួយអន្លើដោយអរូបក្ខន្ធទាំងឡាយ ក៏រមែងមិនមាន ។ ព្រោះថា ធម៌ទាំងនោះ មានចំណែកមិនស្មើគ្នាជាមួយនឹងធម៌ទាំងនោះ ។ ក៏ការប្រកបអរូបក្ខន្ធទាំងឡាយ មួយអន្លើដោយរូប ឬនិព្វាន រមែងមិនមានយ៉ាងណា, ការប្រកបអរូបក្ខន្ធទាំងឡាយ មួយអន្លើសូម្បីដោយអរូបធម៌ទាំងឡាយ ដែលមានសន្ដានផ្សេងគ្នា មានខណៈផ្សេងៗ គ្នា ក៏មិនមាន*

យ៉ាងនោះដែរ ។ ព្រោះថា សូម្បីធម៌ទាំងនោះ ជាវិសភាគដល់ធម៌ទាំងនោះ ដោយសេចក្ដីជាវិសភាគដោយសន្តាន និងខណៈនោះឯង ។ ក៏ប៉ុន្តែ សេចក្ដីជាវិសភាគនេះ មិនមានក្នុងសង្គហន័យ (គឺន័យដែលសង្គ្រោះចូលគ្នាបាន) ទេ ព្រោះខុសដោយអត្ថនៃការសង្គ្រោះ ។ ពិតមែនហើយ ហេតុត្រឹមតែការចូលដល់នូវការរាប់ ចាត់ជាអត្ថនៃការសង្គ្រោះបាន ។ តែមានក្នុងសម្បយោគន័យ ក៏ព្រោះលក្ខណៈ គឺភាវៈនៃធម៌ទាំងឡាយនោះ មានការកើតឡើងជាមួយគ្នាជាដើម ជាអត្ថនៃសម្បយោគ ព្រោះហេតុដូច្នោះ សេចក្ដីនៃវិសភាគនោះ ទើបមិនប្រកបលក្ខណៈនៃសម្បយោគក្នុងទីនេះ សូម្បីដោយធម៌មួយនៃបទឯណាយ៉ាងនេះ ដើម្បីបុច្ឆានូវបទនោះ សូម្បីធ្វើការសង្គ្រោះហើយ ព្រះមានព្រះភាគក៏ទ្រង់បដិសេធថា ***“មិនមាន”*** ដូច្នេះ, ធម៌របស់បទណា រមែងប្រកបលក្ខណៈនៃវិប្បយោគ ទើបព្រះមានព្រះភាគសម្ដែងវិប្បយោគរបស់ធម៌បទនោះ ។ ក៏បទឯណា រមែងសម្ដែងដល់មិស្សកធម៌ទាំងឡាយ ដែលមិនជាវិប្បយុត្តដោយធាតុ សូម្បីតែមួយ ក្នុងវិញ្ញាណធាតុ ៧ ដោយរូប ឬដោយនិព្វាន បទនោះ សូម្បីដោយប្រការទាំងពួង រមែងមិនប្រកបទុកក្នុងនិទ្ទេសនេះទេ ព្រោះហេតុដូច្នោះ បទទាំងនោះ ទើបព្រះមានព្រះភាគទ្រង់មិនកាន់យក ។ គប្បីជ្រាបខទាននៃបទទាំងនោះដូច្នេះ ៖

**“ធម្មាយតនំ ធម្មធាតុ ទុក្ខសច្ចញ្ច ជីវិតំ**
**សឡាយតនំ នាមរូបំ ចត្តារោ ច មហាភវា ។**
**ជាតិ ជរា ច មរណំ តិកេសេកូនវីសតិ**
**គោច្ឆកេសុ ច បញ្ញាស អដ្ឋ ចូឡន្តរេ បទា ។**
**មហន្តរេ បណ្ណរស អដ្ឋារស តតោ បរេ**
**តេវីសបទសតំ ឯតំ សម្បយោគេ ន លព្ភតិ។**

*ធម្មាយតនៈ ១ ធម្មធាតុ ១ ទុក្ខសច្ច ១ ជីវិត ១ សឡាយតនៈ ១ នាមរូប ១ ភពធំ ៤ (គឺឧបបត្តិភព កាមភព សញ្ញីភព និងបញ្ចវោការភព) ជាតិ ជរា និងមរណៈ ក្នុងតិកៈ ១៩ បទ ក្នុងគោច្ឆកៈ ៥០ បទ ក្នុងចូឡន្តរទុកៈ ៨ បទ ក្នុងមហន្តរទុកៈ ១៥ បទ តពីនោះទៀត ១៨ បទ រួមជា ១៣៧ បទ, បទទាំងនោះ មិនបានក្នុងសម្បយោគឡើយ”* ។

*ពិតមែនហើយ ធម្មាយតនៈដែលនរណាមួយ មិនអាចពោលថា* **“សម្បយុត្ត”** *ដូច្នេះ សូម្បីដោយវិញ្ញាណ មិនចាត់ចូលក្នុងនិទ្ទេសនោះ ព្រោះសេចក្តីនៃធម្មាយតនៈទាំងនោះ ជាសភាពលាយដោយរូប និងនិព្វាន ។ ក៏ព្រោះក្នុងនិទ្ទេសនេះ ធម៌ទាំងឡាយ មានវេទនាជាដើម សម្បយុត្តដោយវិញ្ញាណ ព្រោះហេតុដូច្នោះ ទើបមិនអាចដើម្បីពោលថា ជាវិប្បយុត្ត ។*

សូម្បីក្នុងបទទាំងឡាយដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។ បទទាំងនោះ សូម្បីក្នុងទីទាំងពួង រមែងមិនប្រកបជាមួយគ្នា ដោយប្រការដូច្នេះ, ព្រោះហេតុនោះ បទទាំងនោះ ទើបព្រះមានព្រះភាគទ្រង់មិនកាន់យកក្នុងទីនេះ ។ បទដ៏សេស មានខន្ធជាដើម រមែងប្រកបជាមួយគ្នាបាន ព្រោះហេតុដូច្នោះ ទើបព្រះអង្គទ្រង់កាន់យកបទទាំងនោះ ធ្វើបញ្ហា និងវិសជ្ជនា ដោយអំណាចនៃការបែកតែគ្រប់ៗ បទ និងដោយរួមបទនោះៗ ទុក ។

## បញ្ហា ៤ យ៉ាង

បណ្ដាបញ្ហាទាំងនោះ ***បញ្ហាទី ១*** បទថា **"ឯកេនាយតនេន"** បានដល់ មិនប្រកបដោយមនាយតនៈ, បទថា **"កេហិចិ"** បានដល់ មិនប្រកបដោយ វេទនា សញ្ញា និងសង្ខារ ដែលរាប់បញ្ចូលដោយធម្មាយតនៈ និងធម្មធាតុ ។

-***ក្នុងបញ្ហាទី ២*** បទថា **"តីហិ"** បានដល់ ដោយខន្ធដ៏សេសទាំងឡាយ វៀរលែងតែខន្ធដែលសួរហើយ សួរទៀត ។ ពីរបទថា **"កេហិចិ សម្បយុត្តា"** បានដល់ វេទនាខន្ធ សម្បយុត្តដោយសញ្ញាខន្ធ និងសង្ខារក្ខន្ធ ។ សូម្បីខន្ធក្រៅពីនេះ វៀរតែខ្លួនឯងចេញ ក៏សម្បយុត្តដោយខន្ធក្រៅនេះបាន ។ ពីរបទថា **"កេហិចិ វិប្បយុត្តា"** បានដល់ (មិនប្រកប) ដោយរូប និងនិព្វាន ។ អរូបក្នុងធម្មាយតនៈ និងធម្មធាតុ គប្បីជ្រាបក្នុងការមិនប្រកបដោយរូប និងអរូប ក៏គប្បីជ្រាបក្នុងការមិនប្រកបដោយ

អរូបក្នុងបទទាំងពួង មានប្រការដូច្នេះ ។

***-ក្នុងបញ្ហាទី ៣*** មានអត្ថងាយស្រួលទាំងអស់ ។

***-ក្នុងបញ្ហាទី ៤*** ព្រះមានព្រះភាគ មិនបានត្រាស់ពាក្យថា **“កតីហិ ខន្ធេហិ”** ជាដើមទេ, តែទ្រង់ត្រាស់ថា **“សម្បយុត្តំ”** និងពាក្យថា **“នត្ថិ”** ។ បទនោះ គប្បីជ្រាបដោយអំណាចនៃធម៌ទាំងឡាយ មានខន្ធជាដើម ។ ក្នុងបញ្ហាទាំងឡាយ ដែលមានសភាពយ៉ាងនោះ សូម្បីខាងមុខ ក៏មានន័យដូចគ្នានេះដែរ ។ ព្រះបាលីខាងមុខ ទ្រង់សង្ខេបទុក ព្រោះសម្ដែងដោយសរុបទុកក្នុងបញ្ហាខាងដើម ។ បណ្ឌិតគប្បីជ្រាបការប្រកបសេចក្ដីក្នុងបទទាំងពួងដោយន័យនេះចុះ ។ ប៉ុន្តែក្នុងទីណា បញ្ហានៅមិនប្រាកដ ខ្ញុំនឹងធ្វើបញ្ហានេះឲ្យប្រាកដហើយប្រព្រឹត្តទៅក្នុងទីនោះឯង ។

ពីរបទថា **“សោឡសហិ ធាតូហិ”** អធិប្បាយថា ចក្ខុវិញ្ញាណធាតុ វៀរលែងតែខ្លួនឯងចេញហើយ មិនប្រកបដោយវិញ្ញាណធាតុ ៦ និងរូបធាតុ ១០ ឡើយ ។ សូម្បីក្នុងធាតុដ៏សេសទាំងឡាយ ក៏មានន័យដូចគ្នានេះដែរ ។ ពីរបទថា **“តីហិ ខន្ធេហិ”** បានដល់ (សម្បយុត្ត) ដោយខន្ធដ៏សេសទាំងឡាយ វៀរលែងតែសង្ខារក្ខន្ធចេញ ។ ពីរបទថា **“ឯកាយ ធាតុយា”** បានដល់ ដោយមនោវិញ្ញាណធាតុ ។ ព្រោះថា សម្បយោគរបស់សមុទ័យ និងមគ្គដោយធាតុដទៃ រមែងមិនមាន ។ ពីរបទថា

**“ឯកេន ខន្ធេន”** បានដល់ ដោយសង្ខារក្ខន្ធ ។ បទថា **“ឯកេនាយតនេន”** បានដល់ ដោយធម្មាយតនៈ ១ ។ ពីរបទថា **“ឯកាយ ធាតុយា”** បានដល់ ដោយធម្មធាតុ ១ ។ ព្រោះនៅក្នុងសច្ចៈទាំងនោះ សច្ចៈ ២ មានខ្លះ សម្បយុត្តដោយធម្មធាតុ ។

ក្នុងបញ្ហាពោលដោយសុខិន្ទ្រិយជាដើម បទថា **“តីហិ”** បានដល់ សម្បយុត្តដោយខន្ធ គឺសញ្ញាខន្ធ សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ ។ ពីរបទថា **“ឯកាយ ធាតុយា”** បានដល់ (សម្បយុត្ត) ដោយកាយវិញ្ញាណធាតុ និងមនោវិញ្ញាណធាតុ[៤] ។ ពីរបទថា **“ឆហិ ធាតូហិ”** បានដល់ មិនប្រកប ដោយវិញ្ញាណធាតុទាំងឡាយ វៀរលែងតែកាយវិញ្ញាណធាតុចេញ ។

ក្នុងបញ្ហាពោលដោយ ***រូបភព*** ព្រះមានព្រះភាគត្រាស់ថា **“ន កេហិចិ”** ដូច្នេះ ព្រោះតែមានអរូបក្ខន្ធ និងអរូបាយតនៈ សូម្បីទាំងអស់ ។ តែត្រាស់ថា **“តីហិ ធាតូហិ វិប្បយុត្តា”**[៥] ដូច្នេះ ព្រោះភាវៈនៃឃានវិញ្ញាណ

---

[៤] ដោយវិញ្ញាណធាតុ មិនគួរនឹងមាន ព្រោះព្រះបាលីថា **“ឯកាយ ធាតុយា** = សម្បយុត្ត ដោយធាតុ ១ និងធាតុ ១” ក្នុងទីនេះ បានដល់ កាយវិញ្ញាណធាតុប៉ុណ្ណោះ ។

[៥] ក្នុងអដ្ឋកថានៃធាតុកថាបាលី ចែកសម្បយោគវិប្បយោគបទវណ្ណនានេះ បញ្ជាក់ថា **អរូបភវបណ្ហេ ឃានជិវ្ហាកាយវិញ្ញាណធាតូនំ បន នត្ថិ តាយ តីហិ ធាតូហិ វិប្បយុត្តោតិ វុត្តំ** ប្រែហើយ មិនចំសភាវៈ, តែក្នុងបាលីអដ្ឋកថារបស់ភូមា មិនមានពាក្យថា “**អរូបភវបណ្ហេ**” ទេ

ជិវ្ហាវិញ្ញាណ និងកាយវិញ្ញាណធាតុទាំងឡាយ មិនមាន ។

ក្នុងបញ្ហាពោលដោយ **អធិមោក្ខ** ពីរបទថា **"ទ្វីហិ ធាតូហិ"** បានដល់ សម្បយុត្តដោយមនោធាតុ និងមនោវិញ្ញាណធាតុ ។ បទថា **"បណ្ណរសហិ"** បានដល់ វិប្បយុត្តដោយរូបធាតុ ១០ ដ៏សេស និងវិញ្ញាណធាតុ ៥ មានចក្ខុវិញ្ញាណធាតុជាដើម ។

ក្នុងបញ្ហាពោលដោយ ***កុសល*** ព្រះមានព្រះភាគទ្រង់បដិសេធសម្បយោគ ព្រោះសេចក្ដីនៃខន្ធទាំង ៤ ជាភាវៈដែលកុសលទាំងឡាយកាន់យកហើយ ។

ក្នុងបញ្ហាពោលដោយ ***វេទនាត្តិក:*** ពីរបទថា **"ឯកេន ខន្ធេន"** បានដល់ ដោយវេទនាខន្ធប៉ុណ្ណោះ ។ បទថា **"បណ្ណរសហិ"** បានដល់ វិប្បយុត្តដោយចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាវិញ្ញាណធាតុ មនោធាតុ និងរូបធាតុទាំងឡាយ (គឺដោយទ្វិឡារិក-ធាតុ ១០) និងកាយវិញ្ញាណធាតុ ១ ។

ក្នុងបញ្ហាពោលដោយ ***នេវវិបាក នវិបាកធម្មធម្មា*** (គឺធម៌ដែលមិនមែនជាវិបាក និងមិនមែនជាហេតុនៃវិបាក) បទថា **"បញ្ចហិ"** បានដល់

---

បើប្រែតាមបាលីអដ្ឋកថាភូមាហើយ នឹងចំសភាវៈ ក្នុងទីនេះ ទើបប្រែតាមបាលីអដ្ឋកថា ភូមា ដោយកាត់ពាក្យថា " ***អរូបភវបណ្ណេ*** " ចេញ ។

*ដោយបញ្ចវិញ្ញាណធាតុ ៥ មានចក្ខុវិញ្ញាណធាតុជាដើម ។*

*ក្នុងបញ្ហាពោលដោយ* **អនុបាទិន្នុបាទានិយះ** *(គឺសភាវធម៌ទាំងឡាយដែលកម្មមិនបានប្រកាន់ទុកដោយជាផល និងមិនជាអារម្មណ៍របស់ឧបាទាន) ។*

*បទថា* **“ឆហិ”** *បានដល់ ដោយធាតុ ៦ វៀរលែងតែមនោ-វិញ្ញាណធាតុចេញ ។*

*ក្នុងបញ្ហាពោលដោយ* **សវិតក្កសវិចារះ** *បទថា* **“បណ្ណរសហិ”** *បានដល់ ដោយរូបធាតុទាំងឡាយ មួយអន្លើដោយបញ្ចវិញ្ញាណធាតុ ។*

*ក្នុងបញ្ហាពោលដោយ* **អវិតក្កវិចារមត្តា** *ពីរបទថា* **“ឯកេន ខេន្ធេន”** *ជាដើម បណ្ឌិតគប្បីជ្រាបដោយអំណាចនៃសង្ខារក្ខន្ធ ។ ពិតណាស់ វៀរវិចារៈក្នុងទុតិយជ្ឈានចេញ ធម៌ដ៏សេស ឈ្មោះថា មិនមានវិតក្កៈទេ មានត្រឹមតែវិចារៈប៉ុណ្ណោះ ។ វៀរលែងបីតិចេញហើយ ធម៌ដ៏សេស ឈ្មោះថាកើតព្រមជាមួយនឹងបីតិ ។ ក្នុងបញ្ហានេះ វិចារៈមិនសម្បយុត្តជាមួយវិចារៈទេ, បីតិក៏មិនសម្បយុត្តជាមួយបីតិដែរ ព្រោះហេតុដូច្នោះ ធម៌ទាំងនេះទើបឈ្មោះថា សម្បយុត្តទៅដោយធម៌ម្យ៉ាង ក្នុងសង្ខារក្ខន្ធ ធម្មាយតនៈ និងធម្មធាតុ ។ បទថា* **“សោឡសហិ”** *បានដល់ ដោយធាតុទាំងឡាយ ១៦ វៀរតែធម្មធាតុ និងមនោវិញ្ញាណធាតុចេញ ។*

*ក្នុងបញ្ហាពោលដោយ* **អវិតក្កៈ** *និង* **អវិចារៈ** *ពីរបទថា* **“ឯកាយ**

**ធាតុយា”** បានដល់ ដោយមនោធាតុ ១ ។ សុខសហគតធម៌ និងឧបេក្ខា-សហគតធម៌ ត្រាស់ទុកក្នុងវេទនាត្តិកៈនុ៎ះឯង, ទស្សនេនបហាតព្វធម៌ជាដើម ដូចគ្នានឹងកុសលដែរ ។ បរិត្តាធម៌ ដូចនឹងវិបាកធម៌ដែរ ។ ពីរបទថា **“ឯកាយធាតុយា”** បានដល់ ដោយធម្មធាតុ ១ ។ បទថា **“រេកហិចិ”** សេចក្តីថា ធម៌ឯណា ជាបរិត្តារម្មណ៍ មិនមានក្នុងបទនោះ មិនមែនវិប្បយុត្តដោយធម៌នោះទេ ។ ប៉ុន្តែ ធម្មធាតុរមែងចែកបដិសេធក្នុងបទដំបូងប៉ុណ្ណោះ ព្រោះភាវៈនៃបរិត្តារម្មណ៍ ជាសភាពដែលសង្គ្រោះដោយខន្ធទាំង ៤ បាន ដោយអំណាចនៃចិត្តុប្បាទ ៦ ដួង ។ មហគ្គតារម្មណ៍ជាដើម ដូចគ្នានឹងធម៌ដែលជាកុសលនុ៎ះដែរ ។ ក្នុងអនុប្បន្នធម៌ (គឺសភាវធម៌ដែលនៅមិនទាន់កើត) ទាំងឡាយ ពីរបទថា **“បញ្ចហិ ធាតូហិ** = វិប្បយុត្តដោយវិញ្ញាណធាតុ ៥ មានចក្ខុវិញ្ញាណធាតុជាដើម” ។ ក៏ឯវិញ្ញាណធាតុទាំង ៥ នោះ រមែងមិនញែកចំណែកដែលកើតឡើងនៃធម៌ទាំងឡាយ ដែលជាឧប្បាទិធម៌ (គឺសភាវធម៌ដែលសម្រេចហើយ ទើបកើតឡើង) ដោយចំណែកមួយ សូម្បីតែចំណែកនៃឧប្បន្នធម៌ (គឺធម៌ដែលកំពុងកើតឡើង ឬកំពុងដល់ខណៈទាំង ៣) ។ ធម៌ដែលជាបច្ចុប្បន្នារម្មណ៍ជាដើម ដូចគ្នានឹងធម៌ដែលជាបរិត្តារម្មណ៍ដែរ ។ ធម៌ដែលជាហេតុជាដើម ដូចនឹងធម៌ដែលជាសមុទ័យដែរ ។ ធម៌ដែលមានសម្បយុត្តហេតុ តែមិនមែនហេតុ ដូចនឹងបីតិសហគតធម៌ទេ ។ បរាមាស-

*សម្បយុត្ត ក៏ដូច្នោះដែរ ។* ***អនុបាទិន្នធម៌*** *(គឺធម៌ដែលកម្មមិនប្រកាន់ទុកដោយសេចក្ដីជាផល) ដូចនឹងអនុប្បន្នធម៌នោះដែរ ។ ធម៌ដ៏សេស ក្នុងបទទាំងពួង មានអត្ថងាយស្រួលមែនពិត ៕*

ចប់សម្បយោគវិប្បយោគបទនិទ្ទេស

---

## ៧. ពណ៌នាអំពីសម្បយុត្តេន វិប្បយុត្តបទនិទ្ទេស

*ឥឡូវនេះ ដើម្បីចែកបទ* **សម្បយុត្តេន វិប្បយុត្តៈ** *ទើបព្រះមានភាគទ្រង់ផ្ដើមពាក្យថា* **"វេទនាខន្ធេន"** *ជាដើម ។ ក្នុងបទនេះ មានលក្ខណៈដូច្នេះ ក៏ក្នុងវារៈនេះ ធម៌ឯណាសម្បយុត្តដោយបទដែលលើកឡើងសម្ដែងដើម្បីបុច្ឆា គឺធម៌ឯណាវិប្បយុត្តធម៌ទាំងនោះ ព្រះមានព្រះភាគទ្រង់ធ្វើបុច្ឆា និងវិសជ្ជនានូវការមិនប្រកបដល់ធម៌ទាំងនោះ ដោយខន្ធជាដើម ។ ក៏បទ (សម្បយុត្តេន វិប្បយុត្តៈ) រមែងមិនប្រកបក្នុងធម៌ទាំងឡាយ មានរូបក្ខន្ធជាដើម ។ ព្រោះធម៌ទាំងឡាយ ឈ្មោះថា សម្បយុត្តដោយរូបក្ខន្ធរមែងមិនមាន, ព្រោះហេតុដូច្នោះ រូបក្ខន្ធនោះផង បទដទៃមានរូបយ៉ាងនេះផង ព្រះមានព្រះភាគទ្រង់មិនកាន់យកក្នុងវារៈនេះទេ ។ ចំណែកបទឯណារមែងបំភ្លឺដល់សម្បយុត្តធម៌ទាំងឡាយ ក្នុងធម្មធាតុ និងវិញ្ញាណ ដែលមិនលាយឡំដោយធម៌ដទៃទេ ទើបព្រះមានព្រះភាគទ្រង់កាន់យកក្នុងវារៈនេះ ។*

*គប្បីជ្រាបខទានៃធម៌ទាំងនោះដូច្នេះ ៖*

**ចត្តារោ ខន្ធាយតនញ្ច ឯកំ ទ្វេ ឥន្ទ្រិយា ធាតុបទានិ សត្ត តយោ បដិច្ចាថ ផស្សសត្តកំ តិកេ តយោ សត្ត មហន្តរេ ច ឯកំ សវិតក្កំ សវិចារនេកំ យុត្តំ ឧបេក្ខាយ ចេ ឯកមេវ**

*នាមក្ខន្ធ ៤, អាយតនៈ ១ (គឺមនាយតនៈ), វិញ្ញាណធាតុ ៧, ឥន្ទ្រិយ ២ (គឺមនិន្ទ្រិយ និងឧបេក្ខិន្ទ្រិយ), បដិច្ចសមុប្បាទ ៣ (វិញ្ញាណ ផស្សៈ និងវេទនា), ពួកនៃធម៌ ៧ មានផស្សៈជាដើម, តិកមាតិកា ៣ (គឺអទុក្ខមសុខាយវេទនាយបទ សវិតក្កសវិចារបទ និងឧបេក្ខាសហគតបទ), មហន្តរទុកៈ ៧ (គឺចិត្តបទ ចេតសិកបទ ចិត្តសម្បយុត្តបទ ចិត្តសំសដ្ឋ-សមុដ្ឋានបទ ចិត្តសំសដ្ឋសមុដ្ឋានសហភូបទ និងចិត្តសំសដ្ឋានានុបរិវត្តិបទ) សវិតក្កបទ ១ សវិចារបទ ១ និងឧបេក្ខាសហគតបទ ដែលប្រកបដោយឧបេក្ខាវេទនា ១ បទ (រួមជា ៣៧ បទ) ។*

*សេចក្តីនេះឯង រាប់សង្គ្រោះក្នុងកាលជាទីបំផុត សូម្បីដោយពាក្យថា* **“ខន្ធា ចត្តារោ”** *ជាដើម ។ ក្នុងនិទ្ទេសនោះ បទណាមានពាក្យវិសជ្ជនាទំនង ដូចគ្នា, បទទាំងនោះ សូម្បីមិនប្រព្រឹត្តទៅតាមលំដាប់ ក៏លោករួមទុកធ្វើបញ្ហាដែលមានវេទនាខន្ធជាដើមក្នុងទីនោះដែរ ។ ក្នុងបញ្ហាទាំងនោះ គប្បីជ្រាបការចែកខន្ធជាដើម យ៉ាងនេះ ។*

## បញ្ហា ៣ យ៉ាង

ក្នុងបញ្ហាពោលដោយ **វេទនាខន្ធ** ជាដើមសិន, បទថា **"ឯកេន"** បានដល់ (មិនប្រកប) ដោយមនាយតនៈ ។ បទថា **"សត្តហិ"** បានដល់ វិញ្ញាណធាតុ ៧ ។ បទថា **"កេហិចិ"** បានដល់ ដោយវេទនាជាដើម ក្នុងធម្មាយតនៈ ។

ក្នុងបញ្ហាពោលដោយ ***វិញ្ញាណធាតុ*** ពាក្យថា **"គេ ធម្មា ន កេហិចិ"** សេចក្ដីថា វៀរលែងតែវិញ្ញាណធាតុដែលលើកឡើងដើម្បីបុច្ឆាហើយ ធម៌ដ៏សេសទាំងនោះ មានវិញ្ញាណធាតុ ៦ រូប និងនិព្វាន មិនវិប្បយុត្តដោយខន្ធទាំងឡាយពួកខ្លះ ឬដោយអាយតនៈទាំងឡាយ ព្រោះភាវៈនៃខន្ធ និងអាយតនៈទាំងនោះ នៅតែសង្គ្រោះចូលគ្នាបាន ។ ពីរបទថា **"ឯកាយ ធាតុយា"** បានដល់ ធម៌ណាៗ ដែលលើកឡើងដើម្បីបុច្ឆា វិប្បយុត្តហើយដោយធម៌នោះៗ ។

ក្នុងបញ្ហាពោលដោយ ***ឧបេក្ខិន្ទ្រិយ***, បទថា **"បញ្ចហិ"** បានដល់ (វិប្បយុត្ត) ដោយចក្ខុវិញ្ញាណធាតុជាដើម ដែលប្រកបដោយឧបេក្ខា (គឺចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាវិញ្ញាណធាតុ និងមនោធាតុ) ។ បណ្ឌិតគប្បីជ្រាបសេចក្ដីក្នុងបទទាំងពួង ដោយអំណាចនៃបទទាំងឡាយ ដែលវិប្បយុត្តដោយបទ ដែលលើកឡើងដើម្បីបុច្ឆាតាម

*ន័យនេះ មានប្រការដូច្នេះឯង ៕*

ចប់សម្បយុត្តេន វិប្បយុត្តបទនិទ្ទេស

## ៨.ពណ៌នាអំពីវិប្បយុត្តេន សម្បយុត្តបទនិទ្ទេស

*ឥឡូវនេះ ដើម្បីចែកបទ* **វិប្បយុត្តេន សម្បយុត្តៈ** *ទើបព្រះមាន-ព្រះភាគទ្រង់ផ្តើមពាក្យថា* **"រូបក្ខន្ធេន"** *ជាដើម ។ សូម្បីបុច្ឆាទាំងអស់ក្នុងបទទាំងនោះ ជាមោឃបុច្ឆាដូចគ្នា ។ ព្រោះថា នាមក្ខន្ធ ៤ ឈ្មោះថា វិប្បយុត្តដោយរូបក្ខន្ធ ។ សម្បយោគរបស់ធម៌ទាំងនោះ ដោយធម៌ដទៃទៀត ទើបមិនមាន ។ រូប និងនិព្វាន វិប្បយុត្តដោយវេទនាខន្ធ ។ សម្បយោគរបស់ធម៌ទាំងនោះ ក៏មិនមានដោយធម៌អ្វីៗ ឡើយ ។ បណ្ឌិតគប្បីជ្រាបសេចក្តីជាសម្បយោគ របស់វិប្បយុត្តធម៌ទាំងឡាយ ក្នុងបទទាំងពួងយ៉ាងនេះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់នូវពាក្យថា* **"នត្ថិ** *= មិនមាន"* *ដូច្នេះនោះឯង ក្នុងពាក្យវិសជ្ជនាបញ្ហាទាំងអស់ ព្រោះជាមោឃៈ នៃពាក្យបុច្ឆា ដូចពណ៌នាមកនេះ ៕*

ចប់វិប្បយុត្តេន សម្បយុត្តបទនិទ្ទេស

## ៩. ពណ៌នាអំពីសម្បយុត្តេន សម្បយុត្តបទនិទ្ទេស

*ឥឡូវនេះ ដើម្បីចែក **សម្បយុត្តេន សម្បយុត្តបទ** ទើបព្រះមានព្រះភាគទ្រង់ផ្ដើមពាក្យថា* **“វេទនាខន្ធេន”** *ជាដើម ។ ក្នុងនិទ្ទេសនោះ បទណា សម្បយុត្តដោយអំណាចនៃខន្ធជាដើម ព្រះភគវាទ្រង់ធ្វើបុច្ឆា និងវិសជ្ជនា សម្បយោគនោះឯង ដោយខន្ធជាដើមទៀត, បទថា (សម្បយុត្តេន សម្បយុត្ត) នោះ រមែងមិនប្រកបដោយរូប ឬដោយបទទាំងឡាយដែលលាយដោយរូប ឬដោយបទដែលសង្គ្រោះដោយរូបក្ខន្ធទាំងអស់ ។ ព្រោះថា សម្បយោគរបស់ធម៌ពួកដទៃដោយរូប ឬធម៌ ដែលលាយដោយរូបមិនមាន, បទដទៃ ក៏មិនមានដែរ, ព្រោះសេចក្ដីនៃខន្ធជាដើម ដែលគួរដល់សម្បយោគទាំងអស់ លោកកាន់យកដោយធម៌ដែលសង្គ្រោះ មួយអន្លើដោយរូបក្ខន្ធទាំងពួង ។ បទណា គប្បីដល់ការប្រកបជាមួយនឹងបទនោះ ព្រោះហេតុនោះ បទនោះ លោកមិនកាន់យកក្នុងទីនេះទេ ។ តែបទឯណា រមែងបំភ្លឺដល់ឯកទេសនៃអរូប ដែលមិនលាយដោយរូប បទទាំងនោះ ទ្រង់កាន់យកក្នុងនិទ្ទេសនេះ ។ គប្បីជ្រាបខទានរបស់បទទាំងនោះ ដូច្នេះ ៖*

**អរូបក្ខន្ធា ចត្តារោ មនាយតនមេវ ច**
**វិញ្ញាណធាតុយោ សត្ត ទ្វេ សច្ចា ចុទ្ទសិន្ទ្រិយា ។**
**បច្ចយេ ទ្វាទស បទា តតោ ឧបរិ សោឡស**

**តិកេសុ អដ្ឋ គោច្ឆកេ តេ ចត្តាឡីសមេវ ច ។**
**មហន្តរទុកេ សត្ត បទា បិដ្ឋិទុកេសុ ឆ**
**នវមស្ស បទស្សេតេ និទ្ទេសេ សង្គហំ គតា ។**

*នាមក្ខន្ធ ៤, មនាយតនៈ ១, វិញ្ញាណធាតុ ៧, សច្ចៈ ២ (គឺសមុទយ-សច្ច និងមគ្គសច្ច), ឥន្ទ្រិយ ១៤ (គឺមនិន្ទ្រិយជាដើម ដល់អញ្ញាតាវិន្ទ្រិយជាទីបំផុត), បដិច្ចសមុប្បាទ ១២ (គឺអវិជ្ជា, សង្ខារ, វិញ្ញាណ, ផស្សៈ, វេទនា, តណ្ហា, ឧបាទាន, កម្មភព, សោក, ទុក្ខ, ទោមនស្ស និងឧបាយាស); តពីនោះ បដិច្ចសមុប្បាទ ១៦ បទ (គឺសតិបដ្ឋានជាដើម រហូតដល់មនសិការជាទីបំផុត), ក្នុងតិកៈ ៨ បទ (គឺវេទនាតិកៈ ៣ បទ, វិតក្កត្តិកៈ ២ បទ បានដល់បឋមបទ និងទុតិយបទ, ព្រមទាំងបីតិត្តិកៈ ៣ បទ), ក្នុងគោច្ឆកៈ ៤៣ បទ (គឺហេតុគោច្ឆកៈ ៦ បទ, អាសវគោច្ឆកៈ ៤ បទ, សញ្ញោជនគោច្ឆកៈ ៤ បទ, គន្ថគោច្ឆកៈ ៤ បទ, ឱឃគោច្ឆកៈ ៤ បទ, យោគគោច្ឆកៈ ៤ បទ, នីវរណគោច្ឆកៈ ៤ បទ, បរាមាសគោច្ឆកៈ ៣ បទ, ឧបាទានគោច្ឆកៈ ៤ បទ និងកិលេសគោច្ឆកៈ ៦ បទ); ក្នុងមហន្តរទុកៈ ៧ បទ (គឺចិត្តបទ, ចេតសិកបទ, ចិត្តសម្បយុត្តបទ, ចិត្តសំសដ្ឋបទ, ចិត្តសំសដ្ឋសមុដ្ឋានបទ, ចិត្តសំសដ្ឋសមុដ្ឋានសហភូបទ, និងចិត្តសំសដ្ឋសមុដ្ឋានានុ-*

បរិវត្តិបទ) ; ក្នុងបិដ្ឋិទុកៈ ៦ បទ (គឺសវិតក្កបទ, សវិចារបទ, សប្បីតិកបទ, បីតិសហគតបទ, សុខសហគតបទ និងឧបេក្ខាសហគតបទ) ; ធម៌ទាំងឡាយ (១២០ បទ) ក៏ដល់ការសង្គ្រោះក្នុងបទទី ៩ ដែរ ។

## បញ្ហាមានច្រើន

ក៏ក្នុងបញ្ហាទាំងពួង ធម៌ពួកណាទ្រង់លើកឡើងដើម្បីបុច្ឆា ធម៌ទាំងនោះ តែងសម្បយុត្តដោយធម៌ណា, បណ្ឌិតគប្បីជ្រាបប្រភេទនៃធម៌ មានខន្ធជាដើម ដោយអំណាចនៃធម៌ទាំងនោះចុះ ។ ព្រោះថា នាមក្ខន្ធ ៣ ក្រៅពីនេះ សម្បយុត្តដោយវេទនាខន្ធ, វេទនាខន្ធក៏សម្បយុត្តដោយខន្ធទាំងនោះទៀត គឺវេទនាខន្ធនោះ សម្បយុត្តដោយខន្ធទាំង ៣ នោះ មានសញ្ញាខន្ធជាដើម ដោយមនាយតនៈ ១ ដោយវិញ្ញាណធាតុ ៧ និងដោយសញ្ញា សង្ខារទាំងឡាយខ្លះនោះឯង ក្នុងធម្មាយតនៈ និងធម្មធាតុ ។ ក្នុងបញ្ហាទាំងពួង ក៏មានន័យដូចគ្នានេះដែរ ។

ចប់សម្បយុត្តេន សម្បយុត្តបទនិទ្ទេស

---

## ១០.ពណ៌នាអំពីវិប្បយុត្តេន វិប្បយុត្តបទនិទ្ទេស

ឥឡូវនេះ ដើម្បីចែក **វិប្បយុត្តេន វិប្បយុត្តបទ** ទើបព្រះមានព្រះភាគទ្រង់ផ្ដើមពាក្យថា **"រូបក្ខន្ធេន"** ជាដើម ។ ក្នុងនិទ្ទេសនោះ ធម៌

ឯណាមានរូបក្ខន្ធជាដើម ដែលព្រះអង្គទ្រង់អារាធនាមកសម្ដែងទុកក្នុងនិទ្ទេសនៃសម្បយោគវិប្បយោគធម៌ទាំងនោះឯង គឺទ្រង់លើកឡើងសម្ដែងទុកក្នុងពាក្យបុច្ឆាទាំងពួង ។ ចំណែកបទទាំងឡាយដែលមកដោយលំដាប់នៃបទដទៃ ក៏ព្រោះលោករួមពាក្យវិសជ្ជនាដែលជាទំនងដូចគ្នាទុក ។ បណ្ដាបញ្ហាទាំងនោះ បទណាលើកឡើងសម្ដែងដើម្បីបុច្ឆា, បទនោះ វិប្បយុត្តដោយធម៌ឯណា, បណ្ឌិតគប្បីជ្រាបការចែកធម៌មានខន្ធជាដើម ដោយអំណាចនៃធម៌ទាំងនោះ ។ ព្រោះថា ធម៌ទាំងឡាយ មានវេទនាជាដើម វិប្បយុត្តដោយរូបក្ខន្ធ, ឯរូបក្ខន្ធ ក៏វិប្បយុត្តដោយធម៌ទាំងនោះ ។ ចំណែកខាងនិព្វានមានគតិដូចសុខុមរូបនោះដែរ ។ រូបក្ខន្ធនោះ វិប្បយុត្តដោយ នាមក្ខន្ធ ៤ ដោយមនាយតនៈ ១ ដោយវិញ្ញាណធាតុ ៧ និងដោយធម៌ទាំងឡាយមានវេទនាជាដើមពួកខ្លះ ក្នុងធម្មាយតនៈ និងធម្មធាតុ ។ ក្នុងបទទាំងពួងក៏មានន័យដូចគ្នានេះដែរ ។

ចប់វិប្បយុត្តេន វិប្បយុត្តបទនិទ្ទេស

## ១១.ពណ៌នាអំពីសង្គហិតេន សម្បយុត្តវិប្បយុត្តបទនិទ្ទេស

ឥឡូវនេះ ដើម្បីចែក **សង្គហិតេន សម្បយុត្តវិប្បយុត្តបទ** ទើបព្រះភគវាទ្រង់ផ្ដើមពាក្យថា **"សមុទយសច្ចេន"** ជាដើម ។ ក្នុងនិទ្ទេសនោះ

ធម៌ឯណា មានសមុទយសច្ចជាដើម ដែលព្រះអង្គទ្រង់អាពាធនាមកសម្ដែង ហើយ ក្នុងនិទ្ទេសនៃ **សង្គហិតេន សង្គហិតបទ** ធម៌ទាំងនោះឯង ទ្រង់លើកឡើងសម្ដែងក្នុងបុច្ឆាទាំងពួង (ក្នុងទីនេះ) ។ ចំណែកបទទាំងឡាយដែលមកដោយលំដាប់នៃបទដទៃនោះ ព្រោះរួមពាក្យវិសជ្ជនាជាទំនងដូចគ្នា ។ ក្នុងនិទ្ទេសនោះ ធម៌ឯណារាប់សង្គ្រោះបាន ដោយបទដែលលើកឡើងសម្ដែងដើម្បីបុច្ឆា ដោយការសង្គ្រោះដោយខន្ធជាដើម សម្បយោគ ឬវិប្បយោគរបស់ធម៌ទាំងនោះ រមែងមានដោយធម៌ឯណា បណ្ឌិតគប្បីជ្រាបការចែកខន្ធជាដើម ដោយអំណាចនៃធម៌ទាំងនោះ ។

ក្នុងបញ្ហានោះ មានន័យដូច្នេះ ធម៌ទាំងឡាយដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ រាប់សង្គ្រោះបានដោយសមុទយសច្ច ព្រោះការសង្គ្រោះជាខន្ធជាដើមមុន ។ ក៏ធម៌ទាំងនោះ វៀរលែងតែក្នុងសង្ខារក្ខន្ធទាំងឡាយ ត្រង់ធម្មាយតនៈ និងធម្មធាតុទាំងឡាយចេញ ឈ្មោះថា សម្បយុត្តដោយខន្ធ ៣ ដ៏សេស ដោយអាយតនៈ ១ ដោយវិញ្ញាណធាតុ ៧ និងវៀរតណ្ហាចេញហើយ ឈ្មោះថា សម្បយុត្តដោយធម៌ម្យ៉ាង ព្រោះសម្បយុត្តដោយធម៌ដ៏សេស និងវិប្បយុត្តដោយរូបក្ខន្ធ ១ ដោយរូបាយតនៈ ១០ ដោយរូបធាតុ ១០ ឈ្មោះថា វិប្បយុត្តដោយធម៌តែម្យ៉ាង ក្នុងធម្មាយតនៈ ១ និងក្នុងធម្មធាតុ ១ ព្រោះវិប្បយុត្តដោយរូប និងនិព្វាន ។ បណ្ឌិតគប្បីជ្រាបសេចក្ដីក្នុងបញ្ហាទាំងពួងដោយន័យនេះ មានប្រការដូច្នេះចុះ ៕

ចប់សង្គហិតេន សម្បយុត្តវិប្បយុត្តបទនិទ្ទេស

## ១២.ពណ៌នាអំពីសម្បយុត្តេន សង្គហិតាសង្គហិតបទនិទ្ទេស

ឥឡូវនេះ ដើម្បីចែកបទ **សម្បយុត្តេន សង្គហិតៈ** និង **អសង្គហិតៈ** ទើបព្រះមានព្រះភាគទ្រង់ផ្ដើមពាក្យថា **“វេទនាខន្ធេន”** ជាដើម ។ ក្នុងនិទ្ទេសនោះ ធម៌ឯណាមានវេទនាខន្ធជាដើម ដែលព្រះអង្គទ្រង់អារាធនាមកសម្ដែងក្នុងនិទ្ទេសនៃសម្បយុត្តេន សម្បយុត្តបទ ធម៌ពួកនោះឯង ទ្រង់អារាធនាឡើងក្នុងពាក្យបុច្ឆាទាំងពួង ។ ក្នុងបញ្ហានោះ ធម៌ឯណា សម្បយុត្តមួយអន្លើដោយបទដែលលើកឡើងសម្ដែងដើម្បីបុច្ឆាការរាប់ សង្គ្រោះចូលគ្នាបាន ឬការរាប់សង្គ្រោះចូលគ្នាមិនបានរបស់ធម៌ទាំងនោះ ដោយធម៌ឯណា បណ្ឌិតគប្បីជ្រាបការចែកធម៌ មានខន្ធជាដើម ដោយអំណាចនៃធម៌ទាំងនោះ ។ ក្នុងបញ្ហានោះ មានន័យដូច្នេះ ៖

ក៏វេទនាខន្ធ សម្បយុត្តដោយធម៌ទាំងឡាយ មានសញ្ញាជាដើម ។ ធម៌ទាំងនោះមានសញ្ញាជាដើម រាប់សង្គ្រោះបានដោយខន្ធ ៣ មានសញ្ញាខន្ធជាដើម ដោយអាយតនៈ ២ គឺធម្មាយតនៈ និងមនាយតនៈ, ដោយធាតុ ៨ គឺធម្មធាតុ ១ និងវិញ្ញាណធាតុ ៧, តែរាប់សង្គ្រោះ មិនបានដោយខន្ធ អាយតនៈ និងធាតុដ៏សេស ។ បណ្ឌិតគប្បីជ្រាបសេចក្ដីក្នុងបញ្ហាទាំងពួង ដោយឧបាយនេះចុះ ៕

ចប់សម្បយុត្តេន សង្គហិតាសង្គហិតបទនិទ្ទេស

## ១៧.ពណ៌នាអំពីអសង្គហិតេន សម្បយុត្តវិប្បយុត្តបទនិទ្ទេស

*ឥឡូវនេះ ដើម្បីចែក **អសង្គហិតេន សម្បយុត្តវិប្បយុត្តបទ** ទើបព្រះមានព្រះភាគទ្រង់ផ្ដើមពាក្យថា **"រូបក្ខន្ធេន"** ជាដើម ។ ក្នុងនិទ្ទេសនោះ ធម៌ឯណាមានបញ្ហាដូចនឹងរូបក្ខន្ធក្នុងនិទ្ទេសនៃអសង្គហិតេន អសង្គហិតបទទី ៥ និងធម៌ឯណា ដូចនឹងអរូបភព ធម៌ទាំងនោះឯង ព្រះអង្គទ្រង់អាភធនាមកសម្ដែងទុក; ចំណែកបទទាំងឡាយដ៏សេស ដែលមិនបានអាភធនាមក (ក្នុងទីនេះ) ព្រោះហេតុដូច្នោះ បទទាំងនោះ ទើបមិនបានអាភធនាមកសម្ដែងទេ ។ ព្រោះថា រូបធម៌ និងអរូបធម៌ទាំងឡាយ មិនបានរាប់សង្គ្រោះដោយវេទនាខន្ធ ដោយអំណាចនៃខន្ធជាដើម ទាំងឈ្មោះថាសម្បយោគនៃបទទាំងនោះ ព្រោះហេតុនោះ បទឯណាដែលមិនបានអាភធនាមកសម្ដែង បទទាំងនោះឯង ទ្រង់អាភធនាមកសម្ដែងរួមគ្នានឹងពាក្យវិសជ្ជនាដែលឆ្លើយដោយខ្លួនឯងដូចគ្នា ។ ក្នុងបញ្ហានោះ ធម៌ឯណាដែលសង្គ្រោះចូលក្នុងធម៌ដែលអាភធនាមកសម្ដែងដើម្បីបុច្ឆា ដោយអំណាចនៃធម៌មានខន្ធជាដើម ធម៌ទាំងនោះ សម្បយុត្ត និងវិប្បយុត្ត ដោយធម៌ឯណា, បណ្ឌិតគប្បីជ្រាបការចែកធម៌ មានខន្ធជាដើម ដោយអំណាចនៃធម៌ទាំងនោះ ។ ក្នុងបញ្ហានោះ មានន័យដូច្នេះ ៖*

*វិញ្ញាណពិតជារាប់សង្គ្រោះមិនបាន ដោយរូបក្ខន្ធ ដោយការ*

សង្គ្រោះ ៣ យ៉ាងមុន ។ វិញ្ញាណនោះ សម្បយុត្តដោយខន្ធ ៣ មានវេទនាខន្ធជាដើម និងដោយធម៌ទាំងឡាយមានវេទនាជាដើម ក្នុងធម្មាយតនៈ និងធម្មធាតុទាំងឡាយ ។ ថែមទាំងវិប្បយុត្តដោយរូបក្ខន្ធ ១ ដោយរូបាយតនៈ ១០ ដោយរូបធាតុ ១០ និងដោយធម៌ គឺរូប និងនិព្វាន ក្នុងធម្មាយតនៈ និងធម្មធាតុ, ព្រះមានព្រះភាគទ្រង់សំដៅយកវិញ្ញាណនោះ ទើបត្រាស់ថា **"តេ ធម្មា តីហិ ខន្ធេហិ"** ជាដើម បណ្ឌិតគប្បីជ្រាបសេចក្ដីទាំងពួង ដោយន័យនេះចុះ ៕

ចប់អសង្គហិតេន សម្បយុត្តវិប្បយុត្តបទនិទ្ទេស

## ១៤.ពណ៌នាអំពីវិប្បយុត្តេន សង្គហិតាសង្គហិតបទនិទ្ទេស

ឥឡូវនេះ ដើម្បីចែកបទ ***វិប្បយុត្តេន សង្គហិតាសង្គហិតបទ*** ទើបព្រះភគវាទ្រង់ផ្ដើមពាក្យថា **"រូបក្ខន្ធេន"** ជាដើម ។ ក្នុងនិទ្ទេសនោះ វិប្បយោគរបស់បទឯណា ដែលមិនបានអាភធនាឡើងមក (ក្នុងទីនេះ) ទេ, បទទាំងនោះ ព្រះមានព្រះភាគទ្រង់មិនបានកាន់យកក្នុងវារៈនេះឡើយ ។ ***សួរថា*** ក៏បទទាំងនោះ ជាបទអ្វី ? ឆ្លើយថា ជាបទធម្មាយតនៈជាដើម ។ ព្រោះថា វិប្បយោគ រមែងមិនមានក្នុងធម៌ទាំងឡាយ មានខន្ធជាដើម របស់ធម្មាយតនៈសូម្បីត្រឹមតែមួយបទ ។ សូម្បីក្នុងធម្មធាតុជាដើម ក៏

មានន័យដូចគ្នានេះដែរ ។ បណ្ឌិតគប្បីជ្រាបខទាននៃបទទាំងនោះ ដូច្នេះ ៖

**ធម្មាយតនំ ធម្មធាតុ ជីវិតិន្ទ្រិយមេវ ច**

**នាមរូបបទញ្ចេវ សឡាយតនមេវ ច**

**ជាតិអាទិត្តយំ ឯកំ បទំ ទីសតិមេ តិកេ**

**តិកាវសានិកំ ឯកំ សត្ត ចូឡន្តរេ បទា ។**

**ទសេវ គោច្ឆកេ ហោន្តិ មហន្តរម្ហិ ចុទ្ទស**

**ឆ បទានិ តតោ ឧទ្ធំ សព្វានិបិ សមាសតោ**

**បទានិ ច លព្ភន្តិ ចត្តាឡីសញ្ច សត្តធា ។**

*ធម្មាយតនៈ ធម្មធាតុ ជីវិតិន្ទ្រិយ នាមរូប សឡាយតនៈ ធម៌ទាំង ៣ មានជាតិជាដើម (គឺជាតិ ជរា និងមរណៈ) ក្នុងតិកៈទី ២០ បទមួយ (គឺអជ្ឈត្តពហិទ្ធបទ) បទចុងក្រោយរបស់តិកៈ ១ បទ (គឺអនិទស្សនអប្បដិឃបទ) ក្នុងចូឡន្តរទុកៈ ៧ បទ ក្នុងគោច្ឆកៈ ១០ បទ និងក្នុងមហន្តរទុកៈ ១៤ បទ តពីនោះទៀត ៦ បទ (គឺបិដ្ឋិទុកៈ ៦) សូម្បីបទទាំងអស់នេះ លោកសម្តែងទុកដោយសង្ខេប រួម ៤៧ បទទាំងនេះ រមែងប្រកបមិនបាន (សេចក្តីថាជាវិប្បយុត្ត) ដូច្នេះ ។*

*សូម្បីគាថាចុងក្រោយ មានពាក្យថា* **“ធម្មាយតនំ ធម្មធាតុ”** *ជាដើម ព្រះមានព្រះភាគត្រាស់ទុកដើម្បីសម្តែងអត្ថនោះឯង ។ ប៉ុន្តែ វៀរបទទាំងនេះហើយ បទដ៏សេសសូម្បីទាំងអស់ រមែងបាន (គឺថា អាចសង្គ្រោះ*

*ចូលគ្នាបាន) ។ ការចែកដោយសេចក្ដីជាខន្ធជាដើម ក្នុងបទទាំងនោះ បណ្ឌិតគប្បីជ្រាបដោយទំនងរបស់ន័យដែលពោលហើយនុ៎ះឯងចុះ ៕*

ចប់វិប្បយុត្តេន សង្គហិតាសង្គហិតបទនិទ្ទេស

---

## **ពាក្យនិគម (ធាតុកថា)**

*ក៏ដោយពាក្យមានប្រមាណប៉ុណ្ណេះ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គឈ្លាសក្នុងការចែកធាតុ ទ្រង់ត្រាស់គម្ពីរធាតុកថាឯណាទុក, ឥឡូវនេះ ការប្រកាសចែកនយមុខ គឺគោលជាប្រធានរបស់គម្ពីរនោះចប់សព្វគ្រប់ហើយ ។ សូម្បីន័យទាំងអស់នោះ ខ្ញុំ (ព្រះពុទ្ធឃោសាចារ្យ) ពោលទុកជាពាក្យសង្ខេបថា បុគ្គលអ្នកឈ្លាសអាចដើម្បីដឹងចំណែកនយមុខ គឺគោលដែលព្រះអង្គទ្រង់សម្ដែងនេះបាន ។ បើខ្ញុំនឹងគប្បីពោលសេចក្ដីពិស្ដារនៃគម្ពីរនេះ គ្រប់ ៗ បទទៅ ក៏នឹងនាំឱ្យពាក្យពេចន៍នោះច្រើនហួសពេក ទាំងសេចក្ដីនោះ ក៏មិនមានប្លែកគ្នាឡើយ ។*

*បុញ្ញកុសលឯណា ដែលខ្ញុំបានរចនាគម្ពីរនេះ ដើម្បីជាបែបផែនមានប្រមាណ ២ ភាណវារៈតូច សម្រេចចប់រួចរាល់អស់ ដោយប្រការដូច្នេះនេះ សូមកុសលផលបុណ្យនោះ ចូរមានដល់សត្វលោកទាំងឡាយដើម្បីសេចក្ដីសុខក្សេមក្សាន្ត រហូតអស់កាលជានិច្ចនិរន្តរ៍ចុះ ៕*

ចប់ធាតុកថាបករណ៍

# បរមត្ថទីបនី

# នៃបុគ្គលប្បញ្ញត្តិបករណ៍

## អារម្ភកថា

*ព្រះសាស្តា ព្រះអង្គទ្រង់ប្រកាសប្រភេទនៃធាតុ លុះទ្រង់សម្តែងធាតុកថាបករណ៍ដែលមានអត្ថដ៏ល្អិត ក្នុងសុរាល័យទេវលោកចប់ហើយ ព្រះជិនស្រីជាម្ចាស់ ជាអគ្គបុគ្គលក្នុងលោក ត្រាស់គម្ពីរបុគ្គលប្បញ្ញត្តិណាទុក ដែលសម្តែងដល់ប្រភេទនៃបញ្ញត្តិ ក្នុងលំដាប់នៃធាតុកថានោះ ។*

*ឥឡូវនេះ ដល់ឱកាសនៃការពណ៌នាគម្ពីរបុគ្គលប្បញ្ញត្តិនោះហើយ, ព្រោះហេតុដូច្នោះ ខ្ញុំ (ព្រះពុទ្ធឃោសាចារ្យ) នឹងពណ៌នាបករណ៍នោះ, អ្នកទាំងឡាយ ចូរមានចិត្តជាសមាធិស្តាប់ព្រះសទ្ធម្មនោះចុះ ៕*

ចប់អារម្ភកថា

## ១.ពណ៌នាអំពីមាតិកា ឧទ្ទេសវារៈ

*ឧទ្ទេសនៃបុគ្គលប្បញ្ញត្តិនេះថា* **“ឆ បញ្ញត្តិយោ ។ បេ ។ ខន្ធប្បញ្ញត្តិ បុគ្គលប្បញ្ញត្តិ”** *ដូច្នេះមុន ។ បណ្ដាបទទាំងនោះ បទថា* **“ឆ”** *គឺជាការកំណត់ចំនួន ។ ដោយពាក្យនោះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់បំណាននឹងបញ្ញត្តធម៌ឯណា ក្នុងបករណ៍នេះ ទើបទ្រង់សម្ដែងការកំណត់បញ្ញត្តិធម៌ទាំងនោះ ដោយការរាប់យ៉ាងសង្ខេប ។ បទថា* **“បញ្ញត្តិយោ”** *ជាពាក្យសម្ដែងពន្យល់ធម៌ដែលព្រះមានព្រះភាគទ្រង់កំណត់ទុក ។ ក្នុងបទមាតិកាទាំងនោះ ការបញ្ញត្ត ការសម្ដែង និងការប្រកាសក្នុងអាគតស្ថានថា “ទ្រង់ត្រាស់ប្រាប់ ទ្រង់សម្ដែង ទ្រង់បញ្ញត្ត ទ្រង់តែងតាំង” ឈ្មោះថា* ***បញ្ញត្តិ*** *។ ការតែងតាំង ការដាក់ទុក ក្នុងអាគតស្ថានថា “គ្រែ និងតាំងដែលគេតាក់តែងទុកល្អហើយ” ដូច្នេះ ក៏ឈ្មោះថា* ***បញ្ញត្តិ*** *។ បញ្ញត្តិទាំងពីរក្នុងទីនេះ រមែងសមគួរ ។*

*ពិតមែន ពាក្យថា* **“ឆ បញ្ញត្តិយោ”** *បានដល់ ការបញ្ញត្ត ៦, ការសម្ដែង ៦ និងការប្រកាស ៦ ដូច្នេះក្ដី; ការតាំងទុក ៦, ការដាក់ទុក ៦ ដូច្នេះក្ដី; ព្រះមានព្រះភាគទ្រង់បំណងយកក្នុងទីនេះ ។ ព្រះមានព្រះភាគទ្រង់សម្ដែងធម៌ (បញ្ញត្តិ ៦) ទាំងនោះ ប្រកបដោយនាមប្បញ្ញត្តិខ្វះ, រមែង*

*ទ្រទ្រង់តាំងធម៌ទាំងនោះទុក ដោយអំណាចនៃកោដ្ឋាសៈនោះៗ ខ្វះ ។*

*ពាក្យថា* **“ខន្ធប្បញ្ញត្តិ”** *ជាដើម ជាពាក្យសម្ដែងសរុបបញ្ញត្តិទាំងនោះទុកដោយសង្ខេប ។ បណ្ដាបញ្ញត្តិទាំង ៦ នោះ ការបញ្ញត្ត ការសម្ដែង ការប្រកាស ការតាំងទុក និងការដាក់ទុកនូវធម៌ទាំងឡាយ ដែលជាពួកក្រុមនឹងគ្នា ដែលជាខន្ធ ឈ្មោះថា* ***ខន្ធប្បញ្ញត្តិ*** *។ ការបញ្ញត្ត ការសម្ដែង ការប្រកាស ការតាំងទុក និងការដាក់ទុកនូវធម៌ទាំងឡាយ ដែលជាទីកើតនៃអាយតនៈទាំងឡាយ ឈ្មោះថា* ***អាយតនប្បញ្ញត្តិ*** *។ ការបញ្ញត្ត... នូវធម៌ទាំងឡាយ ដែលជាសភាពទ្រទ្រង់ទុកនូវធាតុទាំងឡាយ ឈ្មោះថា* **ធាតុប្បញ្ញត្តិ** *។ ការបញ្ញត្ត... នូវធម៌ទាំងឡាយដែលពិត ឈ្មោះថា* **សច្ចប្បញ្ញត្តិ** *។ ការបញ្ញត្ត... នូវធម៌ដែលជាធំទាំងឡាយ ឈ្មោះថា* **ឥន្ទ្រិយប្បញ្ញត្តិ** *។ ការបញ្ញត្ត... នូវបុគ្គលទាំងឡាយថា ជាបុគ្គល ឈ្មោះថា* **បុគ្គលប្បញ្ញត្តិ** *៕*

---

## បញ្ញត្តិ ៦ ក្រៅពីព្រះបាលី (បិដក)

*បើពោលដោយន័យរបស់អដ្ឋកថា បាលីមុត្តកៈ គឺក្រៅពីព្រះបាលី (បិដក) មានបញ្ញត្តិ ៦ ទៀត គឺ*

**១-វិជ្ជមានប្បញ្ញត្តិ** **២-អវិជ្ជមានប្បញ្ញត្តិ**

**៣-វិជ្ជមានេន អវិជ្ជមានបញ្ញត្តិ ៤-អវិជ្ជមានេន វិជ្ជមានបញ្ញត្តិ**
**៥-វិជ្ជមានេន វិជ្ជមានបញ្ញត្តិ ៦-អវិជ្ជមានេន អវិជ្ជមានបញ្ញត្តិ ។**

*បណ្ដាបញ្ញត្តិទាំង ៦ នោះ ការបញ្ញត្តធម៌ជាកុសល និងអកុសល ដែលជារបស់តែងតែមានជាធម្មតា កើតមានតាមសេចក្ដីពិត ដោយអំណាចនៃសច្ចិកត្ថៈ និងបរមត្ថៈ ឈ្មោះថា* **វិជ្ជមានបញ្ញត្តិ** *។*

*មួយទៀត ការបញ្ញត្តពាក្យទាំងឡាយ មានពាក្យថា ស្ត្រី និងបុរស ជាដើម ដែលសុទ្ធតែជាពាក្យជាភាសារបស់សត្វលោក ដែលមិនមាន (ដោយសភាពពិត) ឈ្មោះថា* **អវិជ្ជមានបញ្ញត្តិ** *។*

*សូម្បីបញ្ញត្តពាក្យថា សច្ចៈទី ៥ ជាដើម ឬពាក្យថា បុរសតាមប្រក្រតីរបស់ពួកតិរ្ថិយ ដែលគ្រាន់តែជាពាក្យពេចន៍ និងវត្ថុដែលស្វែងរកមិនបាន ដោយអាការទាំងពួង ក៏ឈ្មោះថា* **អវិជ្ជមានបញ្ញត្តិ** *ដែរ ។ បញ្ញត្តិដែលពោលមកនេះ មិនមានប្រើក្នុងព្រះពុទ្ធសាសនាទេ ព្រោះហេតុដូច្នេះ ទើបមិនកាន់យកក្នុងទីនេះ ។ គប្បីជ្រាបបញ្ញត្តិដ៏សេស ៤ ទៀត ដោយអំណាចនៃការកំណត់នូវវិជ្ជមាន និងអវិជ្ជមានទាំងនេះ ដូចតទៅ ៖*

*ពិតណាស់* ***វិជ្ជា ៣ និងអភិញ្ញា ៦*** *តែងមាន (ដោយពិតប្រាកដ) ចំណែកបុគ្គល មិនមានទេ (ដោយសភាពពិត) ក្នុងប្រយោគថា* ***បុគ្គលមានវិជ្ជា ៣ បុគ្គលមានអភិញ្ញា ៦*** *ជាដើម, ព្រោះហេតុដូច្នោះ បញ្ញត្តិបែបនេះ*

ទើបឈ្មោះថា **វិជ្ជមានេន អវិជ្ជមានបញ្ញត្តិ** ព្រោះបញ្ញត្តិអវិជ្ជមាន (វត្ថុដែលមិនមាន) រួមជាមួយនឹងវិជ្ជមាន (វត្ថុដែលមាន) យ៉ាងនេះថា បុគ្គលឈ្មោះថា មានវិជ្ជា ៣ ព្រោះអត្ថថា វិជ្ជា ៣ របស់គេមាន បុគ្គលឈ្មោះថា មានអភិញ្ញា ៦ ព្រោះអត្ថថា អភិញ្ញា ៦ របស់គេមានជាដើម ។

***ក៏ស្ត្រី និងបុរស*** រមែងមិនមាន (ដោយសភាពពិត), ប៉ុន្តែ រូបក៏រមែងមាន (ដោយសភាពពិត) ក្នុងពាក្យថា រូបស្ត្រី និងរូបបុរសជាដើម ព្រោះហេតុនោះ បញ្ញត្តិមានសភាពបែបនេះ ទើបឈ្មោះថា **អវិជ្ជមានេន វិជ្ជមានបញ្ញត្តិ** ព្រោះបញ្ញត្តិវិជ្ជមានរួមជាមួយនឹងអវិជ្ជមានយ៉ាងនេះ រូបរបស់ស្ត្រី ឈ្មោះថា ***រូបស្ត្រី*** ។ រូបរបស់បុរស ឈ្មោះថា ***រូបបុរស*** ជាដើម ។ ធម៌ទាំងឡាយមានចក្ខុជាដើមក្តី ផស្សចេតសិកក្តី រមែងមានដោយភាពពិត ក្នុងពាក្យទាំងឡាយ មានពាក្យថា **ចក្ខុសម្ផស្សៈ សោត-សម្ផស្សៈ** ជាដើម ព្រោះហេតុនោះ បញ្ញត្តិមានសភាពបែបនេះ ទើបឈ្មោះថា ***វិជ្ជមានេន វិជ្ជមានបញ្ញត្តិ*** ព្រោះបញ្ញត្តិដែលវិជ្ជមានរួមជាមួយនឹងវិជ្ជមានយ៉ាងនេះថា ***សម្ផស្សក្នុងចក្ខុ សម្ផស្សកើតពីចក្ខុ សម្ផស្សជាផលរបស់ចក្ខុ ឈ្មោះថា ចក្ខុសម្ផស្សជាដើម*** ។ ឥស្សរិយយសទាំងឡាយ មានក្សត្រជាដើមក្តី រមែងមិនមាន (ដោយសភាពពិត) បុត្ររបស់គេក្តី ក៏មិនមាន (ដោយពិតប្រាកដ) ក្នុងពាក្យទាំងឡាយ មានពាក្យថា បុត្ររបស់ក្សត្រ បុត្រ

*របស់ព្រាហ្មណ៍ជាដើម ព្រោះហេតុនោះ បញ្ញត្តិមានសភាពបែបនេះ ទើបឈ្មោះថា* **អវិជ្ជមានេន អវិជ្ជមានប្បញ្ញត្តិ** *ព្រោះបញ្ញត្តិដែលជាអវិជ្ជមានរួមជាមួយនឹងអវិជ្ជមានយ៉ាងនេះថា បុត្ររបស់ក្សត្រ ឈ្មោះថា* ***ខត្តិយបុត្រ*** *ជាដើម ។*

*ក្នុងបករណ៍បុគ្គលប្បញ្ញត្តិនេះ បញ្ញត្តិទាំង ៦ នោះ បានបញ្ញត្តិ ៣ ខ ដំបូងប៉ុណ្ណោះ ។*

*ពិតមែន បានជាមានឈ្មោះថា* **វិជ្ជមានប្បញ្ញត្តិ** *ព្រោះបញ្ញត្តសភាវៈដែលមានពិតមែនប៉ុណ្ណោះ ក្នុងឋាននេះថា* **ខន្ធប្បញ្ញត្តិ ។ ល ។ ឥន្ទ្រិយ-ប្បញ្ញត្តិ** *ជាដើម ។ ក្នុងបទថា បុគ្គលប្បញ្ញត្តិ ឈ្មោះថា* ***អវិជ្ជមានប្បញ្ញត្តិ*** *ដែលខ្ញុំនឹងពោលខាងមុខឯណោះ; តែក្នុងពាក្យទាំងឡាយ មានពាក្យថា បុគ្គលមានវិជ្ជា ៣ និងមានអភិញ្ញា ៦ ជាដើម បានឈ្មោះថា* ***វិជ្ជមានេន អវិជ្ជមានប្បញ្ញត្តិ*** *៕*

---

## បញ្ញត្តិ ៦ តាមន័យរបស់អាចារ្យ

*ក៏ពោលដោយន័យរបស់អាចារ្យដែលជា* ***អដ្ឋកថាមុត្តកៈ*** *(ក្រៅអំពីអដ្ឋកថា) មានបញ្ញត្តិ ៦ ដទៃទៀត គឺ*

**១-ឧបាទាបញ្ញត្តិ** *បញ្ញត្តិ ព្រោះអាស្រ័យ*

**២-ឧបនិធាបញ្ញត្តិ** *បញ្ញត្តិ គឺការប្រៀបធៀប*

**៣-សះមោធានប្បញ្ញត្តិ** *បញ្ញត្តិ គឺការប្រមូល*

**៤-ឧបនិក្ខិត្តប្បញ្ញត្តិ** *បញ្ញត្តិ គឺការលើកឡើង*

**៥-តជ្ជាបញ្ញត្តិ** *បញ្ញត្តិ ដែលលើកពីការលើកឡើងនោះ*

**៦-សន្តតិប្បញ្ញត្តិ** *បញ្ញត្តិ គឺការតគ្នា ។*

*បណ្ដាបញ្ញត្តិទាំង ៦ នោះ ការបញ្ញត្តយ៉ាងនេះថា ធម៌ឯណា សូម្បីជាសភាវៈ ដែលរកមិនបានដោយសច្ចិកត្ថ និងបរមត្ថ ដូចធម៌ទាំងឡាយមានរូប និងវេទនាជាដើម ដោយសេចក្ដីដូចគ្នា ឬជាមនុស្សម្នាក់ ដោយរូបនិងវេទនាជាដើម សន្មតគ្នាថា ជាសត្វ ព្រោះចូលទៅអាស្រ័យ គឺអាស្រ័យខន្ធទាំងឡាយផ្សេងៗ ទៀត ដោយរូប និងវេទនាជាដើម ធ្វើឲ្យជាហេតុឈ្មោះថា រថ ផ្ទះ ចង្ក្រាន ព្រោះអាស្រ័យចំណែកទាំងឡាយនោះៗ ដូច្នេះ និងឈ្មោះថា ផ្ទាំងសំពត់ជាដើម គឺព្រោះអាស្រ័យធម៌ទាំងឡាយ មានរូបនិងរសជាដើមទាំងឡាយនោះឯង ។ ឈ្មោះថា កាលវេលា និងឈ្មោះថាទិសទាំងឡាយ ព្រោះអាស្រ័យការវិលវល់នៃព្រះចន្ទ និងព្រះអាទិត្យជាដើម ឈ្មោះថា* ***ឧគ្គហនិមិត្ត****, ឈ្មោះថា* ***បដិភាគនិមិត្ត*** *គឺជារបស់សន្មតដែលប្រាកដដោយអាការនោះៗ ព្រោះចូលទៅអាស្រ័យ គឺអាស្រ័យនូវនិមិត្តនៃភូតរូបនោះៗ ក៏អានិសង្សនៃភាវនាធ្វើឲ្យជាហេតុ បញ្ញត្តិមានសភាពបែបនេះ ឈ្មោះថា* **ឧបាទាបញ្ញត្តិ** *។ រីឯបញ្ញត្តិនេះ ឈ្មោះថា* **បញ្ញត្តិ** *ព្រោះ*

*អត្ថថា ដែលបុគ្គលគួរដឹង មិនមែនព្រោះអត្ថថា ដែលបុគ្គលមិនគួរដឹងទេ ។ ឯឧបាទាបញ្ញត្តិនេះ ក៏គឺអវិជ្ជមានបញ្ញត្តិហ្នឹងឯង ។*

## ឧបនិធាបញ្ញត្តិ

*បញ្ញត្តិឯណា មានពាក្យជាដើមថា "ទីពីរ និងទីបី" ដូច្នេះ ព្រោះតាំងទុកនូវឈានទី ១ និងទី ២ ជាដើម និងមានពាក្យជាដើមថា "វែង ខ្លី ជិត ឆ្ងាយ" ដូច្នេះ ព្រោះការតាំងទុកអាស្រ័យនូវគ្នានឹងគ្នា បញ្ញត្តិនេះ ឈ្មោះថា* **ឧបនិធាបញ្ញត្តិ,** *ម្យ៉ាងទៀត* **ឧបនិធាបញ្ញត្តិ** *នេះ មានច្រើនប្រការ ដោយប្រភេទជាដើមថា ៖*

| | |
|---|---|
| **-តទញ្ញាបេក្ខូបនិធាបញ្ញត្តិ** | **-ហត្ថគតូបនិធាបញ្ញត្តិ** |
| **-សម្បយុត្តូបនិធាបញ្ញត្តិ** | **-សមារោបិតូបនិធាបញ្ញត្តិ** |
| **-អវិទូរគតូបនិធាបញ្ញត្តិ** | **-បដិភាគូបនិធាបញ្ញត្តិ** |
| **-តព្វហុលូបនិធាបញ្ញត្តិ** | **-តព្វិសិដ្ឋូបនិធាបញ្ញត្តិ ។** |

*បណ្ដាបញ្ញត្តិទាំងនោះ ពាក្យថា "ទីពីរ និងទីបី" ជាដើមនោះឯង ឈ្មោះថា* **តទញ្ញាបេក្ខូបនិធាបញ្ញត្តិ** *ព្រោះពោលដល់ការពិចារណាធម៌ដទៃក្រៅពីនោះ ។*

*បញ្ញត្តិមានពាក្យថា "បុគ្គលមានឆត្រក្នុងដៃ មានសស្ត្រាក្នុងដៃ" ជាដើម ឈ្មោះថា* **ហត្ថគតូបនិធាបញ្ញត្តិ** *ព្រោះពោលសំដៅយកការប្រើដៃ ។*

*បញ្ញត្តិមានពាក្យថា "បុគ្គលមានកុណ្ឌល មានផ្កាឈើប្រដាប់ក្បាល មានមុកុដ" ជាដើម ឈ្មោះថា* **សម្បយុត្តូបនិធាបញ្ញត្តិ** *ព្រោះពោលសំដៅយករបស់ដែលសម្បយុត្ត (ប្រកបនឹងបុគ្គល) ។*

*បញ្ញត្តិមានពាក្យថា "រទេះស្រូវ និងឆ្នាំងទឹកដោះថ្លា" ជាដើម ឈ្មោះថា* **សមារោបិតូបនិធាបញ្ញត្តិ** *ព្រោះពោលសំដៅយកវត្ថុដែលលើកឡើង ។*

*បញ្ញត្តិមានពាក្យថា "ល្អាងជិតដើមឥន្ទសាល ល្អាងជិតដើមប្រយង្គ និងវិមានជិតដើមចាមចុរី" * ជាដើម ឈ្មោះថា* **អវិទូរគតូបនិធាបញ្ញត្តិ** *ព្រោះសំដៅដល់កន្លែងដែលមិនឆ្ងាយពីគ្នា ។*

*បញ្ញត្តិមានពាក្យថា "ពណ៌សម្បុរដូចមាស និងមេគោដូចគោរបស់អ្នក" ជាដើម ឈ្មោះថា* **បដិភាគូបនិធាបញ្ញត្តិ** *ព្រោះពោលសំដៅយកចំណែកប្រៀបធៀបគ្នា ។*

*បញ្ញត្តិមានពាក្យថា "ស្រះបទុម ស្រុកព្រាហ្មណ៍" ជាដើម ឈ្មោះថា* **តព្វហុលូបនិធាបញ្ញត្តិ** *ព្រោះពោលសំដៅយកវត្ថុរបស់វត្ថុនោះមាន ច្រើន ។*

*បញ្ញត្តិមានពាក្យថា "កងដៃធ្វើដោយពេជ្រ" ជាដើម ឈ្មោះថា* **តព្វិសិដ្ឋូបនិធាបញ្ញត្តិ** *ព្រោះពោលសំដៅយកវត្ថុរបស់នោះប្រសើរ ។*

---

* បាលីថា សេរីសកៈ អ្នកខ្លះប្រែថា ដើមច្រេស ។

ក៏បញ្ញត្តិណា មានពាក្យថា "ឈើ ៣ ដើម, បទ ៨ បទ, គំនរស្រូវ និងគំនរផ្កាឈើ" ជាដើម ព្រោះបំណងយកការប្រជុំរបស់វត្ថុទាំងនោះៗ បញ្ញត្តិនេះ ឈ្មោះថា **សមោធានបញ្ញត្តិ** ។

បញ្ញត្តិឯណា មានពាក្យថា "២, ៣, ៤" ជាដើម ព្រោះសំដៅយកបទដើមៗ ឡើងមុនហើយ បញ្ញត្តិនេះ ឈ្មោះថា **ឧបនិក្ខិត្តបញ្ញត្តិ** ។

បញ្ញត្តិឯណា មានពាក្យថា "**បឋវី តេជោ** = រឹង ក្តៅ" ជាដើម ព្រោះសម្លឹងមើលសភាវធម៌នោះៗ បញ្ញត្តិនេះ ឈ្មោះថា **តជ្ជាបញ្ញត្តិ** ។

ក៏បញ្ញត្តិឯណា មានពាក្យជាដើមថា "អ្នកមានអាយុ ៨០ ឆ្នាំ, អ្នកមានអាយុ ៩០ ឆ្នាំ" ដូច្នេះ ព្រោះមើលទៅជារបស់ជាប់គ្នាមិនដាច់ខ្សែ បញ្ញត្តិនេះ ឈ្មោះថា **សន្តតិបញ្ញត្តិ** ។

មួយទៀត ក្នុងបញ្ញត្តិទាំង ៦ នោះ **តជ្ជាបញ្ញត្តិ** ក៏គឺ **វិជ្ជមានបញ្ញត្តិ** នោះឯង ។ បញ្ញត្តិដែលនៅសល់ រមែងរួមជាពួក **អវិជ្ជមានបញ្ញត្តិ** និង **អវិជ្ជមានេន អវិជ្ជមានបញ្ញត្តិ**៕

---

## ន័យម្យ៉ាងទៀត បញ្ញត្តិ ៦ របស់អាចារ្យ

ន័យម្យ៉ាងទៀត បញ្ញត្តិ ៦ តាមន័យរបស់អាចារ្យក្រៅអំពីអដ្ឋកថា គឺ

**១-កិច្ចបញ្ញត្តិ** **២-សណ្ឋានបញ្ញត្តិ**

**៣-លិង្គប្បញ្ញត្តិ** **៤-ភូមិបញ្ញត្តិ**

**៥-បច្ចត្តប្បញ្ញត្តិ** **៦-អសង្ខតប្បញ្ញត្តិ ។**

បណ្តាបញ្ញត្តិទាំង ៦ នោះ បញ្ញត្តិដោយអំណាចនៃកិច្ច មានពាក្យថា "អ្នកជាធម្មកថិក" ជាដើម ឈ្មោះថា **កិច្ចប្បញ្ញត្តិ** ។

បញ្ញត្តិដោយអំណាចនៃទ្រង់ទ្រាយ មានពាក្យថា "ស្គម ធាត់ មូល បួនជ្រុង" ជាដើម ឈ្មោះថា **សណ្ឋានប្បញ្ញត្តិ** ។

បញ្ញត្តិដោយអំណាចនៃភេទ មានពាក្យថា "ស្រី ប្រុស" ជាដើម ឈ្មោះថា **លិង្គប្បញ្ញត្តិ** ។

បញ្ញត្តិដោយអំណាចនៃភូមិ មានពាក្យថា "កាមាវចរ រូបាវចរ អរូបាវចរ អ្នកដែនកោសល អ្នកដែនមាគធៈ" ជាដើម ឈ្មោះថា **ភូមិ-បញ្ញត្តិ** ។

បញ្ញត្តិដោយអំណាចត្រឹមតែថា ការតាំងឈ្មោះចំពោះ មានពាក្យថា "លោកតិស្សៈ នាគៈ សុមនៈ" ជាដើម ឈ្មោះថា **បច្ចត្តប្បញ្ញត្តិ** ។

បញ្ញត្តិអសង្ខតធម៌ មានពាក្យថា "និរោធ គឺព្រះនិព្វាន" ជាដើម ឈ្មោះថា **អសង្ខតប្បញ្ញត្តិ** ។

***បណ្តាបញ្ញត្តិទាំងនោះ ភូមិបញ្ញត្តិពួកខ្លះ និងអសង្ខតប្បញ្ញត្តិ ក៏គឺ***

***វិជ្ជមានបញ្ញត្តិនុ៎ះឯង, កិច្ចបញ្ញត្តិ ចាត់ចូលជាពួកវិជ្ជមាននៃ អវិជ្ជមាន-បញ្ញត្តិ ។ បញ្ញត្តិដ៏សេស ឈ្មោះថា អវិជ្ជមានបញ្ញត្តិ ។***

*ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ ដើម្បីទ្រង់ចែកបញ្ញត្តិដែលព្រះអង្គទ្រង់ប្រមូលទុកដោយសង្ខេបក្នុងខទ្ទេសវារៈនុ៎ះឯង ដោយអំណាចនៃការសម្តែង ទើបត្រាស់ពាក្យថា* **“កិត្តាវតា”** *ជាដើម ក្នុងខទ្ទេសវារៈនោះ បណ្ឌិតគប្បីជ្រាបសេចក្តីនៃពាក្យសួរមុន យ៉ាងនេះថា ការបញ្ញត្ត ការសម្តែង និងការតែងតាំងនូវធម៌ ដែលជាគំនរទាំងឡាយថា “ជាខន្ធឯណានេះ ការបញ្ញត្ត ការសម្តែង និងការតែងតាំងនេះ មានប្រមាណប៉ុណ្ណេះ” ដូច្នេះ* ***ជាកថេតុកម្យតាបុច្ឆា*** *(សួរដើម្បីឆ្លើយខ្លួនឯង) ។ សូម្បីក្នុងពាក្យទាំងឡាយមានពាក្យថា* **“កិត្តាវតា អាយតនានំ”** *ជាដើម ខាងមុខ ក៏ន័យនេះដែរ ។*

*ចំណែកក្នុងពាក្យវិសជ្ជនា បណ្ឌិតគប្បីជ្រាបសេចក្តីយ៉ាងនេះថា ពាក្យថា* ***ខន្ធ ៥*** *ដោយសង្ខេប ឬដោយប្រភេទ គឺរូបក្ខន្ធ ។ ល ។ វិញ្ញាណ-ក្ខន្ធ ឬថា សូម្បីខន្ធ ៥ នោះ រូបក្ខន្ធជាកាមាវចរ, ខន្ធ ៤ ដ៏សេស ប្រព្រឹត្តទៅក្នុងភូមិ ៤ ជាដើម ការបញ្ញត្តដូច្នេះ រមែងមានដោយបញ្ញត្តិមានប្រមាណប៉ុន្មាន ការបញ្ញត្តធម៌ទាំងឡាយ ដែលជាកងថាជាខន្ធ មានដោយប្រមាណប៉ុណ្ណេះ ។*

បញ្ញត្តិថា “អាយតនៈមាន ១២ ដោយសង្ខេប ឬដោយប្រភេទថា ចក្ខាយតនៈ ។ ល ។ ធម្មាយតនៈ ឬថា សូម្បីក្នុងអាយតនៈទាំងនោះ អាយតនៈ ១០ ជាកាមាវចរ, អាយតនៈ ២ ប្រព្រឹត្តទៅក្នុងភូមិ ៤” ដូច្នេះ រមែងមានដោយបញ្ញត្តិ មានប្រមាណប៉ុន្មាន ការបញ្ញត្តធម៌ទាំងឡាយ ដែលជាប្រភពថា ជាអាយតនៈ រមែងមានដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

ក្នុងបញ្ញត្តិថា “ធាតុ ១៨ ដោយសង្ខេប ឬដោយប្រភេទថា ចក្ខុ-ធាតុ ។ ល ។ មនោវិញ្ញាណធាតុ ឬក៏បណ្ដាធាតុទាំងនោះ ធាតុ ១៦ ជាកាមាវចរ ធាតុ ២ ប្រព្រឹត្តទៅក្នុងភូមិ ៤” ដូច្នេះ រមែងជាបញ្ញត្តិមានប្រមាណប៉ុន្មាន, ការបញ្ញត្តធម៌ទាំងឡាយដែលជាសភាវៈ ទ្រទ្រង់ត្រាស់ទុកថា ជាធាតុ រមែងមានដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

បញ្ញត្តិថា “សច្ចៈ មាន ៤ ដោយសង្ខេប ឬក៏ដោយប្រភេទថា ទុក្ខសច្ច ។ ល ។ និរោធសច្ច ឬក៏សូម្បីបណ្ដាសច្ចៈទាំងនេះ សច្ចៈ ២ ជាលោកិយ, សច្ចៈ ២ ជាលោកុត្តរ” ដូច្នេះ រមែងមានដោយពាក្យបញ្ញត្តិមានប្រមាណប៉ុន្មាន, ការបញ្ញត្តធម៌ទាំងឡាយដែលពិតថា សច្ចៈរមែងមានដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

បញ្ញត្តិបែបនេះថា ឥន្ទ្រិយ ២២ ដោយសង្ខេប ឬដោយប្រភេទថា "ចក្ខុន្ទ្រិយ ។ ល ។ អញ្ញាតាវិន្ទ្រិយ ឬក៏សូម្បីបណ្ដាឥន្ទ្រិយទាំងនោះ ឥន្ទ្រិយ ១០ ជាកាមាវចរ, ឥន្ទ្រិយ ៩ ជាមិស្សកៈ, ឥន្ទ្រិយ ៣ ជាលោកុត្តរ" ដូច្នេះ រមែងមានដោយពាក្យបញ្ញត្តិ មានប្រមាណប៉ុនណា, ការបញ្ញត្តធម៌ទាំងឡាយដែលជាធំ ថាជាឥន្ទ្រិយ រមែងមានដោយពាក្យមានប្រមាណប៉ុណ្ណោះ ។ ព្រះមានព្រះភាគ លុះទ្រង់ចែករឿងបញ្ញត្តិដោយសង្ខេប ដោយពាក្យមានប្រមាណប៉ុណ្ណោះហើយ ទើបទ្រង់សម្ដែងបញ្ញត្តិ ៥ ដោយអំណាចនៃការសម្ដែងបញ្ញត្តិតទៅ ។

ឥឡូវនេះ ព្រះមានជោគលុះទ្រង់ចែករឿងបញ្ញត្តិដោយពិស្ដារហើយ ដើម្បីនឹងទ្រង់សម្ដែងបុគ្គលប្បញ្ញត្តិ (បញ្ញត្តិពោលអំពីបុគ្គល) ដោយអំណាចនៃការសម្ដែង **សមយវិមុត្តោ អសមយវិមុត្តោ** ជាដើម ។ ព្រះសម្មាសម្ពុទ្ធ ព្រះអង្គប្រៀបដូចជាបុគ្គលអ្នកត្រាច់ទៅក្នុងទីផ្សេងៗ និងបុគ្គលអ្នកកំពុងប្រព្រឹត្តទៅ ត្រាស់ខន្ធជាដើម ដែលជារឿងបញ្ញត្តិទាំង ៥ នេះ ទុកដោយពិស្ដារក្នុងវិភង្គប្បករណ៍ហើយ, ព្រោះហេតុដូច្នោះ ក្នុងបករណ៍បុគ្គលប្បញ្ញត្តិនេះ ទើបត្រាស់ធម៌ មានខន្ធជាដើមនោះ ដោយឯកទេសប៉ុណ្ណោះ ។ បុគ្គលប្បញ្ញត្តិទី ៦ ក៏មិនបានត្រាស់ទុកក្នុងខាងក្រោយឡើយ, សូម្បីក្នុងឧទ្ទេសវារៈនេះ ក៏ត្រាស់ទុកដោយឯកទេសប៉ុណ្ណោះ ព្រោះហេតុ

*ដូច្នោះ ព្រះមានព្រះភាគព្រះអង្គមានបំណងនឹងត្រាស់បុគ្គលប្បញ្ញត្តិ ដែលជាបញ្ញត្តិទី ៦ នោះដោយពិស្តារ ទើបទ្រង់តាំងមាតិកាទុកថា* **“សមយវិមុត្តោ អសមយវិមុត្តោ”** *ជាដើម ចាប់ផ្ដើមពីបុគ្គលមួយពួក រហូតដល់បុគ្គល ១០ ពួកយ៉ាងនេះឯង ។*

ចប់បទមាតិកាឧទ្ទេសវារៈ

## ២.អដ្ឋកថានិទ្ទេសវារៈ

## អដ្ឋកថាឯកកនិទ្ទេស អធិប្បាយបុគ្គល ១ ជំពូក

## ពណ៌នាអំពីសមយវិមុត្តបុគ្គល

*ឥឡូវនេះ ដើម្បីនឹងចែកមាតិកាតាមដែលបានតាំងទុកពីខាងដើម ទើបព្រះភគវាត្រាស់ពាក្យជាអាទិ៍ថា* **“កតមោ ច បុគ្គលោ សមយវិមុត្តោ** *= ក៏សមយវិមុត្តបុគ្គល តើដូចម្ដេច ?” ក្នុងពាក្យទាំងនោះ ពាក្យថា* **“ឥធ”** *បានដល់ ក្នុងសត្វលោក ។ ពាក្យថា* **“ឯកច្ចោ បុគ្គលោ”** *បានដល់ បុគ្គលពួកមួយ ។ ក្នុងពាក្យថា* **“កាលេន កាលំ”** *នេះ គប្បីជ្រាបសេចក្ដីដោយសត្តមីវិភត្តិ, អធិប្បាយថា ក្នុងកាលៗ ។ ពាក្យថា* **“សមយេន សមយំ”**

*នេះ ជាវេវចនៈរបស់ពាក្យមុននោះឯង (គឺជាវេវចនៈរបស់ពាក្យថា* **ការលនកាលំ***) ។ ពាក្យថា* **“ អដ្ឋ ខិមោក្ខេ ”** *បានដល់ សមាបត្តិ ៨ ដែលជារូបាវចរជ្ឈាន និងអរូបាវចរជ្ឈាន ។ ពិតមែន ពាក្យថា* ***វិមោក្ខ*** *នេះ ជាឈ្មោះរបស់សមាបត្តិទាំង ៨ នោះ ព្រោះរួចចាកធម៌ដែលជាសឹកសត្រូវទាំងឡាយ ។ ពាក្យថា* **“ ការយេន ”** *បានដល់ នាមកាយដែលកើតព្រមជាមួយនឹងវិមោក្ខ ។ ពាក្យថា* **“ ផុសិត្វា ខិហរតិ ”** *បានដល់ បានសមាបត្តិហើយ ទើបផ្លាស់ប្តូរឥរិយាបថ ។*

***សួរថា*** *ក៏សមយវិមុត្តបុគ្គលនេះ ពាល់ត្រូវវិមោក្ខហើយនៅក្នុងកាលណា ?*

*ឆ្លើយថា ក៏ធម្មតាថា កាលរបស់លោកអ្នកប្រាថ្នានឹងចូលសមាបត្តិមាន, តែមិនឈ្មោះថា* ***អកាល*** *ទេ ។*

*បណ្តាកាល និងអកាល គឺសម័យ និងមិនមែនសម័យទាំងពីរយ៉ាងនេះ ក៏កាលដែលកំពុងបដិបត្តិ (ជម្រះ) សរីរៈពីព្រឹកព្រហាម ១, កាលដែលកំពុងធ្វើវត្ត ១ ឈ្មោះថា សម័យមិនមែនជាកាលរបស់អ្នកចូលសមាបត្តិទេ ។ កាលជាទីបដិបត្តិសរីរៈ និងធ្វើវត្តស្រេចហើយ ទើបចូលទៅកាន់ទីសម្រាក, ចន្រ្កមរហូតដល់វេលានឹងទៅបិណ្ឌបាត ក្នុងចន្លោះនេះ ឈ្មោះថា* ***កាលរបស់លោកអ្នកចូលសមាបត្តិ*** *។*

*ក៏កាលជាទីវន្ទាព្រះចេតិយ របស់ភិក្ខុអ្នកកំណត់វេលាទៅបិណ្ឌបាតហើយចេញទៅ ១, កាលជាទីឈរនៅក្នុងរោង (បន្ទោបង់) វិតក្កៈ របស់ភិក្ខុអ្នកដែលចោមរោមដោយពួកនៃភិក្ខុ ១, កាលជាទីត្រាច់ទៅដើម្បីបិណ្ឌបាត ១, កាលជាទីត្រាច់ទៅក្នុងភូមិ ១, កាលជាទីឆាន់យាគូក្នុងរោងឆាន់ ១, កាលជាទីធ្វើវត្ត ១; កាលទាំងអស់នេះ ឈ្មោះថា* ***អកាល*** *គឺមិនមែនសម័យកាលរបស់លោកអ្នកចូលសមាបត្តិទេ ។ ក៏កាលបើមាន ឱកាសដែលស្ងាត់ឈឹង ក្នុងរោងឆាន់ និងនៅមិនទាន់ដល់វេលាឆាន់ភត្តាហារ សូម្បីក្នុងចន្លោះនៃកាលនេះ ក៏ឈ្មោះថា* ***កាលរបស់លោកអ្នកចូលសមាបត្តិ*** *ដែរ ។*

*មួយទៀត វេលាឆាន់ភត្តាហារ ១, វេលាទៅកាន់វិហារ ១, វេលាទុកដាក់រក្សាបាត្រ និងចីវរ ១, វេលាធ្វើវត្តក្នុងពេលថ្ងៃ ១, វេលាក្នុងការសាកសួរ ១, កាលទាំងអស់នេះ ក៏ឈ្មោះថា អកាល គឺមិនមែនសម័យកាលរបស់លោកអ្នកចូលសមាបត្តិឡើយ ។ កាលណា មិនមែនកាលទេ, កាលនោះឯង មិនមែនសម័យឡើយ ។*

*សូម្បីកិច្ចទាំងអស់នោះ វៀរលែងកាលដ៏សេស សម័យដ៏សេស លោកហៅថា បុគ្គលពួកខ្លះក្នុងលោកនេះ បានវិមោក្ខ ៨ មានប្រការដូចពោលមកហើយ ដោយសហជាតនាមកាយ ។ ល ។ ប្រការមួយទៀត បុគ្គលនេះ ឈ្មោះថា ពាល់ត្រូវសហជាតធម៌ទាំងឡាយព្រមទាំងផស្សៈ ។*

ឈ្មោះថា ពាល់ត្រូវអប្បនាដោយឧបចារៈ ឈ្មោះថា រមែងពាល់ត្រូវអប្បនាដទៃទៀត ដោយអប្បនាដំបូង ។ ក៏ធម៌ឯណា កើតព្រមជាមួយនឹងធម៌ណា, ធម៌ទាំងនោះ ឈ្មោះថា ជាធម៌ដែលលោកបានហើយជាមួយនឹងធម៌ទាំងនោះ ព្រោះហេតុដូច្នោះ ទើបឈ្មោះថា ពាល់ត្រូវហើយ សូម្បីដោយផស្សៈ ។ សូម្បីឧបចារៈ ក៏ជាហេតុនៃការបានអប្បនាដែរ ។ អប្បនាដំបូង ក៏ជាហេតុឲ្យបានអប្បនាដទៃ ៗ ទៀតដូចគ្នាដែរ ។ ក្នុងឧបចារៈ និងអប្បនាទាំងនោះ គប្បីជ្រាបការពាល់ត្រូវសហជាតធម៌ទាំងឡាយ ដោយសហជាតធម៌ទាំងឡាយរបស់ព្រះយោគីនោះ មានប្រការដូច្នេះ ។

ក៏ **បឋមជ្ឈាន** មានអង្គ ៥ មានវិតក្កៈជាដើម វៀរអង្គឈានទាំង ៥ ចេញហើយ ធម៌ដ៏សេស ៥០ ហៅថា **នាមក្ខន្ធ ៤** ។ ព្រះយោគីបុគ្គលពាល់ត្រូវ គឺបានចំពោះ ***បឋមជ្ឈានសមាបត្តិវិមោក្ខ*** ដោយនាមកាយនោះហើយទើបនៅ ។

**ទុតិយជ្ឈាន** មានអង្គ ៣ គឺ ***បីតិ សុខ*** និង ***ឯកគ្គតា*** ។ **តតិយ-ជ្ឈាន** មានអង្គ ២ គឺ ***សុខ*** និង ***ឯកគ្គតា*** ។ **ចតុត្ថជ្ឈាន** មានអង្គ ២ គឺ ***ឧបេក្ខា*** និង ***ឯកគ្គតា*** ។ មួយទៀត ***អាកាសានញ្ចាយតនជ្ឈាន ។ ល ។ នេវសញ្ញានាសញ្ញាយតនជ្ឈាន*** មានអង្គ ២ ដូចនឹងចតុត្ថជ្ឈានដែរ ។ ក្នុងឈានទាំងនោះ គឺតាំងពីបឋមជ្ឈានដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន វៀរ

*វែលែងអង្គឈានទាំងនោះចេញហើយ ធម៌ទាំងឡាយដ៏សេស ៥០ ហៅថា* **នាមក្ខន្ធ ៤** *។ ព្រះយោគីបុគ្គលពាល់ត្រូវ គឺបានចំពោះនូវនេវសញ្ញានា-សញ្ញាយតនជ្ឈានសមាបត្តិវិមោក្ខ ដោយនាមកាយនោះហើយទើបនៅ ។*

*ពាក្យថា* **“បញ្ញាយ ចស្ស ទិស្វា”** *អធិប្បាយថា ព្រោះឃើញនូវការប្រព្រឹត្តទៅនៃសង្ខារដោយវិបស្សនាបញ្ញា ឃើញសច្ចធម៌ទាំង ៤ ដោយមគ្គប្បញ្ញា ។*

*ពាក្យថា* **“ឯកច្ចេ អាសវា បរិក្ខីណា ហោន្តិ”** *អធិប្បាយថា អាសវៈទាំងឡាយ ដែលបឋមមគ្គជាដើម គប្បីសម្លាប់ចំណែកមួយៗ អស់ទៅហើយ បុគ្គលនេះ លោកហៅថា* **“សមយវិមុត្តោ** *= អ្នករួចហើយ ដោយសម័យ” ។ ក្នុងបទថា* **“បុគ្គលោ សមយវិមុត្តោ”** *នេះ នឹងពោលថា បុគ្គលអ្នកបានសមាបត្តិ ៨ ពាល់ត្រូវវិមោក្ខដោយនាមកាយនោះហើយទើបនៅក៏គួរ; តែក្នុងព្រះបាលីលោកពោលទុកថា* **“ឯកច្ចេ អាសវា បរិក្ខីណា** *= អាសវៈពួកខ្លះអស់ទៅហើយ” ។ ពិតយ៉ាងនោះមែន ក៏ឈ្មោះថា អាសវៈទាំងឡាយរបស់បុថុជ្ជនអស់ទៅហើយ រមែងមិនមាន, ព្រោះហេតុដូច្នោះទើបព្រះមានព្រះភាគទ្រង់មិនបំណងយកបុថុជ្ជន ដែលពិតគួរនឹងពោលថា សូម្បីព្រះខីណាស្រពអ្នកបានសមាបត្តិ ៨ ពាល់ត្រូវវិមោក្ខដោយនាមកាយនោះហើយ, តែថា ធម្មតាអាសវៈទាំងឡាយរបស់ព្រះខីណាស្រពនោះ នៅ*

*មិនអស់ទៅ រមែងមិនមានឡើយ ព្រោះហេតុនោះ ព្រះខីណាស្រពនោះ ព្រះមានព្រះភាគ ក៏មិនបានទ្រង់បំណាច់យកឡើយ ។ ក៏ពាក្យថា* **“សមយវិមុត្តោ”** *នេះ គប្បីជ្រាបថា ជាឈ្មោះរបស់ព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមី រួមមានតែ ៣ ជំពូកប៉ុណ្ណោះ ។*

## ចប់សមយវិមុត្តបុគ្គល

---

## ពណ៌នាអំពីអសមយវិមុត្តបុគ្គល

*ក៏ក្នុងនិទ្ទេសនៃបទថា* **“អសមយវិមុត្តោ”** *ដូច្នេះ គប្បីជ្រាបដូចពាក្យមុន ដោយន័យដែលពោលមកហើយនុ៎ះឯង ។ ម្យ៉ាងទៀត ពាក្យថា* **“អសមយវិមុត្តោ”** *នេះ ក្នុងទីនេះ ជាឈ្មោះរបស់ព្រះអរហន្តសុក្ខវិបស្សកៈ, តែថា ព្រះអរហន្តសុក្ខវិបស្សកៈ ព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី ព្រះអរហន្តលោកបានសមាបត្តិ ៨ និងបុថុជ្ជន រមែងមិនបានក្នុងទុកៈនេះទេ (ទុកៈនេះ គឺសមយវិមុត្តោ អសមយវិមុត្តោ) ព្រោះហេតុដូច្នោះ ទើបឈ្មោះថា* **ទុកមុត្តកបុគ្គល** *។ ព្រោះហេតុដូច្នោះ ទើបព្រះសាស្តាទ្រង់រួបរួមបុគ្គលទាំងឡាយ ដែលព្រះអង្គទ្រង់កាន់យក និងមិនទ្រង់កាន់យកក្នុងខាងក្រោយ ហើយលើកឡើងកាន់បែបផែនព្រមទាំងបិដ្ឋិវដ្តកបុគ្គលទាំងឡាយ គឺអ្នកបែរទៅខាងក្រោយ ព្រោះភាវៈនៃព្រះអង្គជាអ្នក*

មានបញ្ញាជាគ្រឿងត្រាស់ដឹងហើយដោយល្អ ទើបត្រាស់នូវពាក្យជាដើមថា **"សព្វេបិ អរិយបុគ្គលា** = សូម្បីទាំងអស់ ជាព្រះអរិយបុគ្គល" ។

បណ្តាបទទាំងនោះ បទថា **"អរិយវិមោក្ខ"** បានដល់ វិមោក្ខដែលជាលោកុត្តរ ដែលដល់នូវការរាប់ថាជា **អរិយៈ** ព្រោះឆ្ងាយចាកកិលេសទាំងឡាយ ។

## *សេចក្តីនេះ មានពាក្យអធិប្បាយទុកថា*

សម័យក្តី អសម័យក្តី របស់លោកអ្នកចូលសមាបត្តិ ៨ ខាងក្រៅពុទ្ធសាសនាមាន ។ សម័យ ឬអសម័យរបស់លោកអ្នកផុតដោយមគ្គ-វិមោក្ខ រមែងមិនមាន ។ សទ្ធារបស់បុគ្គលណា មានកម្លាំង និងវិបស្សនាដែលបុគ្គលឯណា ប្រារព្ធហើយ, តែការចាក់ធ្លុះមគ្គ និងផលរបស់អ្នកនោះដែលកំពុងដើរ, ឈរ, អង្គុយ, ដេក, ទំពា និងបរិភោគមិនមាន ព្រោះហេតុដូច្នោះ សម័យ ឬអសម័យរបស់អ្នកផុតដោយមគ្គវិមោក្ខ ទើបមិនមាន ។ ព្រោះហេតុដូច្នោះ បទថា **"មគ្គវិមោក្ខេន វិមុច្ចនស្ស សមយោ វា អសមយោ វា នត្ថិ"** នេះ ព្រះមានព្រះភាគ ព្រះអង្គជាធម្មរាជា ទ្រង់រួបរួមបុគ្គលទាំងឡាយ ដែលព្រះអង្គទ្រង់កាន់យក និងទ្រង់មិនកាន់យកក្នុងពេលក្រោយ ហើយលើកឡើងកាន់បែបដែនដែលជាបិដ្ឋិវដ្តកៈនេះ ។ សូម្បីបុថុជ្ជនអ្នកបានសមាបត្តិ ៨ ក៏ព្រះអង្គមិនបានទ្រង់ព្រះបំណងយក ដោយ

*បែបដែននេះឡើយ, តែថា ព្រះមានជោគកាលនឹងទ្រង់ចែកបុគ្គលអ្នកបាន សមាបត្តិ ៨ នោះ ក៏គប្បីចែកនូវភាពជាសមយវិមុត្តបុគ្គល ដោយអំណាច នៃកិលេសដែលលោកសង្កត់សង្កិនទុកហើយដោយសមាបត្តិ ៕*

ចប់អសមយវិមុត្តបុគ្គល

........................................

## ពណ៌នាអំពីកុប្បធម្មបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ* ***កុប្បធម្មបុគ្គល*** *ជាដើម ៖*

*សមាបត្តិធម៌ ដែលបុគ្គលណាសម្រេចហើយ រមែងកម្រើក រមែង វិនាស ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា* **កុប្បធម្មោ** *= អ្នក មានធម៌ដែលកម្រើក ។ បទថា* **“រូបសហគតានំ”** *អធិប្បាយថា សមាបត្តិ ដែលប្រកបដោយរូបនោះ ពោលគឺដែលមានរូបជានិមិត្ត គឺប្រព្រឹត្តទៅព្រម ជាមួយនឹងរូបនោះ សម្គាល់សេចក្ដីថា មិនលើកវៀររូបាវចរជ្ឈានទាំង ៨ ដែលមានរូបជាអារម្មណ៍ឡើយ ។ បទថា* **“អរូបសហគតានំ”** *អធិប្បាយថា វត្ថុដទៃវៀរចាករូប មិនឈ្មោះថា* **រូប** *ព្រោះហេតុដូច្នោះ ទើបឈ្មោះថា* **អរូប** *សមាបត្តិដែលសហគតៈដោយអរូប គឺដែលប្រព្រឹត្តទៅព្រមជាមួយ នឹងអរូបនោះ មិនលើកវៀរអរូបាវចរជ្ឈានទាំង ៤ ដែលមានអរូបជា អារម្មណ៍ចេញ ។ ពាក្យថា* **“ន និកាមលាភី”** *សេចក្ដីថា ឈ្មោះថា មិន*

*មែនជាអ្នកបានតាមសេចក្ដីប្រាថ្នា ព្រោះមិនបានដោយអាការដែលប្រាថ្នា ដោយភាពជាអ្នកមិនជំនាញក្នុងការប្រព្រឹត្តមកហើយ ដោយអាការ ៥ យ៉ាង ។ អធិប្បាយថា អ្នកមិនជំនាញចូលសមាបត្តិ ។ ពាក្យថា* **“ន អកិច្ឆលាភី”** *បានដល់ បានដោយលំបាក គឺបានដោយកម្រ អធិប្បាយថា អ្នកណាសង្កត់សង្កិនកិលេសទាំងឡាយ ទុកដោយអាគម** សម្រេចឧបចារៈ សម្រេចអប្បនា និងបាននូវចិត្តមញ្ជូសា (ហិប គឺចិត្ត គង់សំដៅដល់ការសន្សំសុខវិហារធម៌) លំបាក ដោយសម្បយោគ គឺសេចក្ដីព្យាយាមជាសសន្ធារដែលលំបាក រមែងមិនអាចដើម្បីសម្រេចនូវសម្បទានោះ បុគ្គលនោះ ឈ្មោះថា មិនមែនជាអ្នកបានដោយលំបាកទេ ។ ពាក្យថា* **“ន អកសិរលាភី”** *បានដល់ ជាអ្នកបានមិនបរិបូណ៌ អធិប្បាយថា ចូលសមាបត្តិហើយ មិនអាចដើម្បីនឹងផ្សាយទៅរហូតអស់កាលយូរបាន គឺឲ្យប្រព្រឹត្តទៅបានត្រឹមតែមួយវារចិត្ត ឬពីរវារចិត្ត ហើយក៏ចេញដោយរហ័សនោះតែម្ដង ។ បទថា* **“យត្ថិច្ឆកំ”** *បានដល់ ការប្រាថ្នាដើម្បីនឹងចូលសមាបត្តិក្នុងឱកាសឯណា ។ បទថា* **“យទិច្ឆកំ”** *សេចក្ដីប្រាថ្នាដើម្បីនឹងអន្ទុយចូលសមាបត្តិណាៗ គឺឈានមានកសិណជាអារម្មណ៍ ឬឈានមានអានាបាណៈ*

---

* អាគម ក្នុងទីនេះ មិនមែនជាមន្តអាគមទេ ។

ជាអារម្មណ៍ ឬថាឈានមានអសុភជាអារម្មណ៍ ។ បទថា **“យាវតិច្ឆកំ”** សេចក្តីថា រមែងប្រាថ្នាអស់កាលមានប្រមាណប៉ុនណា ដោយការកំណត់វេលាជាយូរអង្វែង ។

## សេចក្តីនេះ មានពាក្យអធិប្បាយទុកដូច្នេះ

ព្រះយោគីរមែងប្រាថ្នានឹងចូលខ្លះ ចេញខ្លះ នូវសមាបត្តិណាៗ ក្នុងទីណាៗ រហូតដល់អស់កាលយូរមានប្រមាណប៉ុនណា រមែងមិនអាចដើម្បីនឹងចូលខ្លះ ចេញខ្លះ នូវសមាបត្តិនោះៗ ក្នុងទីនោះៗ រហូតដល់អស់ កាលយូរមានប្រមាណប៉ុណ្ណោះ គឺងើយមើលព្រះចន្ទ ឬព្រះអាទិត្យ ហើយកំណត់ថា “កាលព្រះចន្ទ ឬព្រះអាទិត្យនេះ ទៅកាន់ទីមានប្រមាណប៉ុណ្ណោះហើយ អាត្មាអញនឹងចេញចាកសមាបត្តិ” ហើយក៏ចូលឈាន រមែងមិនអាចដើម្បីនឹងចេញតាមការកំណត់ទុក រមែងចេញក្នុងចន្លោះវិញ ព្រោះខ្លួនជាអ្នកមិនជំនាញក្នុងសមាបត្តិ ។

បទថា **“បមាទមាគម្ម”** បានដល់ អាស្រ័យនូវសេចក្តីប្រមាទ ។ ពាក្យថា **“អយំ ឧច្ចតិ”** បានដល់ បុគ្គល ៣ ជំពូក គឺបុថុជ្ជនអ្នកបានសមាបត្តិ ៨ ព្រះសោតាបន្ន និងព្រះសកទាគាមី បុគ្គលទាំងនេះ លោកហៅថា **“កុប្បធម្មោ** = អ្នកមានធម៌ដែលកម្រើក” ។ ក៏ពាក្យថា **“កុប្ប-ធម្មោ”** នេះ ជាឈ្មោះរបស់បុគ្គល ៣ ជំពូកនោះ ក៏ធម៌ទាំងឡាយដែល

ជាសត្រូវចំពោះសមាធិ និងវិបស្សនារបស់លោកទាំងនោះ លោកសង្កត់ទុកមិនល្អ ជម្រះលាងទុកមិនល្អ ព្រោះហេតុដូច្នោះ សមាបត្តិរបស់លោកទាំងនោះ ទើបវិនាសសូន្យទៅ ។ មួយទៀត វិនាសទៅ សូន្យទៅ ព្រោះមានសីលដាច់ ឬព្រោះការមិនឈានកន្លងអាបត្តិប៉ុណ្ណោះ ក៏មិនមែន ។ ក៏នាគរិកបោក្ខធម៌នេះ រមែងវិនាស ព្រោះករណីយកិច្ច ឬព្រោះហេតុត្រឹមតែការបែកធ្លាយនៃវត្ថុមានប្រមាណតិចតួច ។

## *ក្នុងសេចក្តីនេះ មានរឿងដូចតទៅនេះ ជាឧទាហរណ៍*

បានឮថា ព្រះថេរៈមួយរូបចម្រើនសមាបត្តិ គឺយកស្ថានទីមួយជាទីធ្វើសមាបត្តិ កាលបើលោកទៅកាន់ស្រុកដើម្បីបិណ្ឌបាត ពួកក្មេងលេងនៅត្រង់បរិវេណ ក៏នាំគ្នាជៀសចេញទៅ ព្រះថេរៈមកហើយគិតថា “ពួកក្មេងគង់នឹងមកបោសបរិវេណ” ទើបលោកមិនបោស ចូលទៅកាន់វិហារដោយគិតថា “យើងនឹងចូលសមាបត្តិ” លោកមិនអាចដើម្បីនឹងចូលបាន ទើបរំពឹងដល់សីលថា “ព្រោះហេតុអ្វីទៅហ្ន៎” ដូច្នេះ មិនឃើញការឈានកន្លងសូម្បីមានប្រមាណតិចតួច ទើបពិចារណាមើលថា “វត្ថុភេទ ការបែកធ្លាយនៃវត្ថុរបស់យើងមានឬ ?” បានដឹងថា ខ្លួនមិនបានបោសប្រាសនូវបរិវេណ ទើបបោសហើយ ក៏ទៅអង្គុយចូលសមាបត្តិ ៕

## ចប់កុប្បធម្មបុគ្គល

## ពណ៌នាអំពីអកុប្បធម្មបុគ្គល

និទ្ទេសនៃ ***អកុប្បធម្មបុគ្គល*** បណ្ឌិតគប្បីជ្រាបដោយអំណាចនៃបដិបក្ខន័យរបស់កុប្បធម្មបុគ្គល ដែលពោលទុកហើយនោះឯង ។ ក៏ពាក្យថា **“អកុប្បធម្មោ”** នេះ ជាឈ្មោះរបស់ព្រះអរិយបុគ្គល ២ ជំពូក គឺព្រះអនាគាមីអ្នកបានសមាបត្តិ ៨ និងព្រះខីណាស្រព ។ ពិតមែនហើយ ធម៌ទាំងឡាយដែលជាសត្រូវចំពោះសមាបត្តិ និងវិបស្សនារបស់លោកទាំងនោះ លោកសង្កត់ទុកល្អហើយ ជម្រះលាងទុកល្អហើយ ព្រោះហេតុដូច្នោះ កាលបើលោកទាំងនោះ សូម្បីញុំាងកាលឲ្យកន្លងទៅដោយកិច្ច មានការសន្ទនា និងភាពជាអ្នកត្រេកអរដោយពួកគណៈជាដើម ឬដោយសេចក្ដីប្រមាទដែលមិនសមគួរដល់ខ្លួនយ៉ាងណាមួយដទៃៗ ។ សមាបត្តិ ក៏មិនកម្រើក មិនវិនាស, តែថា ព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី និងព្រះខីណាស្រពជាសុក្ខវិបស្សកៈ រមែងមិនបានក្នុងទុកៈនេះទេ លោកទាំងនោះ ទើបឈ្មោះថា **ឋកមុត្តកបុគ្គល** ។

ព្រោះហេតុដូច្នោះ ទើបព្រះសាស្ដាទ្រង់រួបរួមបុគ្គលទាំងឡាយ ដែលព្រះអង្គទ្រង់កាន់យក និងទ្រង់មិនកាន់យកក្នុងពេលក្រោយ ហើយលើកឡើងកាន់បែបផែន ជាមួយនឹងបដិវិដ្ឋកបុគ្គលទាំងឡាយទុកសូម្បីក្នុងទុកៈនេះ ព្រោះព្រះអង្គមានបញ្ញាជាគ្រឿងត្រាស់ដឹងល្អ ទើបត្រាស់ពាក្យជាដើមថា

**"សព្វេបិ អរិយបុគ្គលា** = *សូម្បីព្រះអរិយបុគ្គលទាំងអស់"* ។

*ម្យ៉ាងទៀត ប្រសិនបើការកម្រើក សេចក្ដីវិនាស នៃសមាបត្តិ ៨ របស់លោក នឹងគប្បីមានឡើង, តែលោកុត្តរធម៌ដែលលោកចាក់ធ្លុះហើយមួយគ្រា មិនអាចកម្រើក និងវិនាសទៅឡើយ ពាក្យនេះលោកពោលសំដៅយកអ្នកសម្រេចលោកុត្តរធម៌នោះ ៕*

ចប់អកុប្បធម្មបុគ្គល

---

## ពណ៌នាអំពី

## បរិហានធម្មបុគ្គល និងអបរិហានធម្មបុគ្គល

*សូម្បីនិទ្ទេសនៃបរិហានធម្មបុគ្គល និងអបរិហានធម្មបុគ្គលទាំងឡាយ បណ្ឌិតគប្បីជ្រាបដោយអំណាចនៃ* **កុប្បធម្មបុគ្គល** *និង* **អកុប្ប-ធម្មបុគ្គល** *ទុំះឯង ។ ក៏ក្នុងទីនេះ ពាក្យថា "សេចក្ដីសាបសូន្យក្ដី សេចក្ដីមិនសាបសូន្យក្ដី នៃធម៌ទាំងឡាយ ព្រោះអាស្រ័យសេចក្ដីប្រមាទរបស់បុគ្គល" នេះ លោកប្រាថ្នាយកតែម្យ៉ាង ទើបជាការដែលពោលប្លែកផ្សេងគ្នាត្រឹមតែបរិយាយទេសនាប៉ុណ្ណោះ, ធម៌ដ៏សេសទាំងអស់ដូចគ្នាដែរ" ៕*

ចប់បរិហានធម្មបុគ្គល និងអបរិហានធម្មបុគ្គល

---

## ពណ៌នាអំពីចេតនាភព្វបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ* ***ចេតនាភព្វបុគ្គល*** *៖*

*ពាក្យថា* **“ចេតនាភព្វោ”** *បានដល់ គួរដើម្បីនឹងដល់ភាពមិនសាបសូន្យជុំវិញនៃចេតនា ។ ពាក្យថា* **“សចេ អនុសញ្ចេតិ”** *បានដល់ បើចូលសមាបត្តិ អធិប្បាយថា ក៏ព្រះយោគីកាលចូលសមាបត្តិ ឈ្មោះថា រមែងយកចិត្តទុកដាក់ ទើបលោកមិនសាបសូន្យ ព្រះយោគីក្រៅអំពីនេះ រមែងសាបសូន្យ ៕*

ចប់ចេតនាភព្វបុគ្គល

---

## ពណ៌នាអំពីអនុរក្ខនាភព្វបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ* ***អនុរក្ខនាភព្វបុគ្គល*** *៖*

*ពាក្យថា* **“អនុរក្ខនាភព្វោ”** *បានដល់ គួរដើម្បីដល់ភាពមិនសាបសូន្យជុំវិញនៃការតាមរក្សា ។ ពាក្យថា* **“សចេ អនុរក្ខតិ”** *សេចក្ដីថា បើព្រះយោគីលះបង់ធម៌ដែលមិនមានឧបការៈ សេពធម៌ ដែលមានឧបការៈចូលសមាបត្តិ ។ ក៏កាលលោកបដិបត្តិហើយយ៉ាងនេះ ឈ្មោះថា តាមរក្សា ទើបលោកមិនសាបសូន្យ, ព្រះយោគីក្រៅអំពីនេះ រមែងសាបសូន្យ,*

សូម្បីព្រះយោគីទាំងពីរពួកនេះ ជាអ្នកអាចដើម្បីតាំងសមាបត្តិធ្វើឲ្យមាំមួន, តែព្រះយោគីដែលឈ្មោះថា ***អនុរក្ខនាភព្វបុគ្គល*** ប៉ុណ្ណោះ មានសេចក្តីអង់អាចច្រើនជាងព្រះយោគី ដែលឈ្មោះថា ***ចេតនាភព្វបុគ្គល,*** ព្រោះថា ***ចេតនាភព្វបុគ្គល*** មិនដឹងធម៌ដែលមានឧបការៈ និងមិនមានឧបការៈ, កាលមិនដឹងទើបបន្ថយ គឺរមែងនាំធម៌ដែលជាឧបការៈចេញទៅហើយ សេពធម៌ដែលមិនមានឧបការៈ, កាលសេពធម៌ដែលមិនមានឧបការៈទាំងនោះ លោករមែងសាបសូន្យចាកសមាបត្តិ ។ ***តែអនុរក្ខនាភព្វបុគ្គល*** រមែងដឹងធម៌ដែលមានឧបការៈ និងមិនមានឧបការៈ កាលដឹងក៏រមែងបន្ថយ គឺនាំធម៌ដែលមិនមានឧបការៈចេញទៅ សេពធម៌ដែលមានឧបការៈទាំងឡាយ ទើបមិនសាបសូន្យចាកសមាបត្តិ ។ ប្រៀបដូចអ្នកស្រែដែលរក្សាស្រែ ២ នាក់ ជាឧទាហរណ៍ដូចតទៅនេះ ៖

មនុស្សម្នាក់ មានរោគស្កមលឿង អត់ធន់ចំពោះត្រជាក់ជាដើមមិនបាន, មនុស្សម្នាក់មិនមានរោគ អត់ធន់ចំពោះរងាជាដើមបាន; មនុស្សដែលមានរោគ មិនចុះអំពីខ្ទមទៅខាងក្រោម, គេលះបោលការរក្សាស្រែទាំងយប់ទាំងថ្ងៃ ពួកសេក ព្រាប និងក្អែកជាដើម នាំគ្នាមកកាន់ស្រែរបស់គេក្នុងវេលាថ្ងៃ ចឹកស៊ីកួរស្រូវសាលី, ក្នុងវេលាយប់ ពួកម្រឹគ និងជ្រូកជាដើម ចូលទៅកាន់លានស្រែទាត់កកាយ ដូចជាកន្លែងដែលខ្លួនធ្វើទុក

ដោយខ្លួនឯង, គ្រាទាត់កកាយហើយក៏ទៅ; គេរមែងមិនបាន សូម្បីត្រឹមតែស្លូងស្រូវទៀត ព្រោះហេតុនៃសេចក្ដីប្រមាទរបស់ខ្លួន; ចំណែកបុគ្គលដែលមិនមានរោគ មិនលះបោលការរក្សាស្រែរហូតទាំងយប់ទាំងថ្ងៃ គេរមែងបានស្រូវប្រមាណ ៤ រទេះខ្វះ, ៨ រទេះខ្វះ, អំពីទីប្រមាណមួយករីសៈ ព្រោះសេចក្ដីមិនប្រមាទរបស់ខ្លួន ។ ក្នុងព្រះយោគី ២ រូបនោះ បណ្ឌិតគប្បីជ្រាបព្រះយោគីជាចេតនាភព្វបុគ្គល ដូចមនុស្សមានរោគរក្សាស្រែ, គប្បីជ្រាបព្រះយោគីជាអនុរក្ខនាភព្វបុគ្គល ដូចមនុស្សមិនមានរោគ ។

បណ្ឌិតគប្បីជ្រាបសេចក្ដីសាបសូន្យ អំពីសមាបត្តិរបស់ចេតនាភព្វបុគ្គលដែលមិនដឹងធម៌មានឧបការៈ និងមិនមានឧបការៈ ហើយលះធម៌ដែលមានឧបការៈ សេពធម៌ដែលមិនមានឧបការៈ ដូចការមិនបានគ្រាប់ពូជដែលនឹងដាំបន្តទៅទៀត របស់មនុស្សមានរោគ ព្រោះសេចក្ដីប្រមាទរបស់ខ្លួន, គប្បីជ្រាបសេចក្ដីមិនសាបសូន្យ ចាកសមាបត្តិរបស់អនុរក្ខនាភព្វបុគ្គលអ្នកដឹងធម៌ មានឧបការៈ និងមិនមានឧបការៈ ហើយលះធម៌ដែលមិនមានឧបការៈ សេពនូវធម៌មានឧបការៈ ប្រៀបដូចនឹងការបានស្រូវ ៤ រទេះ ៨ រទេះ អំពីទីប្រមាណមួយករីសៈរបស់បុគ្គលអ្នកមិនមានរោគ ព្រោះសេចក្ដីមិនប្រមាទរបស់ខ្លួន ។ អនុរក្ខនាភព្វបុគ្គលប៉ុណ្ណោះ បណ្ឌិតគប្បីជ្រាបថាមានសេចក្ដីអង់អាចជាងចេតនាភព្វបុគ្គល ក្នុងការធ្វើសមាបត្តិឲ្យមាំមួនរឹងប៉ឹង

*ដោយប្រការដូច្នេះ ។*

ចប់អនុរក្ខនាភព្វបុគ្គល

---

## ពណ៌នាអំពីបុគ្គលបុថុជ្ជន

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ **បុគ្គលជាបុថុជ្ជន** ៖*

*ពាក្យថា* **“តីណិ សញ្ញោជនានិ”** *បានដល់ ទិដ្ឋិសញ្ញោជនៈ ១, សីលព្វតបរាមាសសញ្ញោជនៈ ១ និងវិចិកិច្ឆាសញ្ញោជនៈ ១; ក៏សញ្ញោជនៈទាំងនោះ ឈ្មោះថា លោកលះបានហើយ ក្នុងខណៈនៃផលចិត្ត ។ ព្រះអង្គរមែងសម្តែងថា ក៏បុថុជ្ជននេះ រមែងមិនមាន សូម្បីក្នុងខណៈនៃផលចិត្ត ។*

*ពាក្យថា* **“តេសញ្ច ធម្មានំ”** *បានដល់ សញ្ញោជនធម៌ទាំងនោះ ។ ក៏បុថុជ្ជន ឈ្មោះថា អ្នកបដិបត្តិហើយដើម្បីលះសញ្ញោជនៈទាំងនោះ ក្នុងខណៈនៃមគ្គចិត្ត ។ តែបុថុជ្ជននេះ រមែងមិនមាន សូម្បីក្នុងខណៈនៃមគ្គចិត្ត ពាលបុថុជ្ជន អ្នកល្ងង់ខ្លៅប៉ុណ្ណោះ ដែលលះកម្មដ្ឋានហើយ បណ្ឌិតជ្រាបថា ព្រះមានព្រះភាគ ត្រាស់ទុកក្នុងបុថុជ្ជននិទ្ទេសនេះ ដោយហេតុមានប្រមាណត្រឹមតែប៉ុណ្ណោះឯង ។*

ចប់បុថុជ្ជនបុគ្គល

══ ∶ ∶ ══

## ពណ៌នាអំពីគោត្រភូបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ **គោត្រភូបុគ្គល** ៖*

*ពីរបទថា* **“យេសំ ធម្មានំ”** *បានដល់ កុសលធម៌លើស ៥០ ដែលកើតឡើងព្រមនឹងគោត្រភូញាណណា ។ បទថា* **“អរិយធម្មស្ស”** *បានដល់លោកុត្តរមគ្គ ។ ពីរបទថា* **“អវក្កន្តិ ហោតិ”** *បានដល់ រមែងឈានចុះគឺកើតប្រាកដ ។ ពីរបទថា* **“អយំ វុច្ចតិ”** *សេចក្តីថា បុគ្គលនេះ ព្រះមានព្រះភាគត្រាស់ហៅថា* **គោត្រភូបុគ្គល** *ព្រោះឈានកន្លងញាណរបស់បុថុជ្ជន គោត្ររបស់បុថុជ្ជន, មណ្ឌលរបស់បុថុជ្ជន និងបញ្ញត្តិរបស់បុថុជ្ជនទាំងពួង ហើយទើបឈានចុះកាន់ញាណរបស់ព្រះអរិយៈ, គោត្ររបស់ព្រះអរិយៈ មណ្ឌលរបស់ព្រះអរិយៈ និងបញ្ញត្តិរបស់ព្រះអរិយៈ បានដោយញាណដែលមានព្រះនិព្វានជាអារម្មណ៍ ៕*

ចប់គោត្រភូបុគ្គល

---

## ពណ៌នាអំពីភយូបរតបុគ្គល និងអភយូបរតបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ **ភយូបរតបុគ្គល** ៖*

*បុគ្គលឯណាលះបង់ចោល សេចក្តីអាក្រក់ ព្រោះការភ័យខ្លាច ព្រោះ*

ហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា **ភយូបរតោ** = អ្នកលះបង់ចោល សេចក្ដីអាក្រក់ ព្រោះការភ័យខ្លាច ។ អធិប្បាយថា ក៏ព្រះសេក្ខបុគ្គល ៧ ពួក និងបុថុជ្ជនទាំងឡាយ អ្នកមានសីល ខ្លាចហើយរមែងវៀរចាកបាប គឺ មិនធ្វើបាបឡើយ ។

ព្រះអរិយបុគ្គល និងបុថុជ្ជនទាំងឡាយ រមែងភ័យខ្លាច ៤ យ៉ាង គឺ

**១-ទុគ្គតិភ័យ ២-វដ្ដភ័យ**

**៣-កិលេសភ័យ ៤-ឧបវាទភ័យ ។**

ក្នុងភ័យទាំងនេះ ភ័យ គឺការទៅកាន់គតិអាក្រក់ ឈ្មោះថា ***ទុគ្គតិ-ភ័យ*** ព្រោះអត្ថថា ដែលបុគ្គលគប្បីភ័យ ។ សូម្បីក្នុងភ័យទាំង ៣ ដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។ បណ្ដាអ្នកទាំងនោះ បុថុជ្ជនរមែងខ្លាចទុគ្គតិភ័យ ដោយគិតថា បើលោកនឹងធ្វើបាបមែន អបាយទាំង ៤ នឹងដូចជាពស់ ថ្លាន់កំពុងស្រេកឃ្លាន ហាមាត់រង់ចាំ លោកកាលសោយទុក្ខនៅក្នុងអបាយ ទាំងនោះ នឹងធ្វើយ៉ាងណា ? ទើបមិនធ្វើបាប ។ ក៏សង្សារវដ្ដមានខាងដើម និងខាងចុង ដែលដឹងមិនបានទុំះឯង ឈ្មោះថា ***វដ្ដភ័យ*** ។ សូម្បីអកុសល ទាំងពួង ឈ្មោះថា ***កិលេសភ័យ*** ។ ការតិះដៀល ឈ្មោះថា ***ឧបវាទភ័យ*** ។

បុថុជ្ជនខ្លាចភ័យទាំងនោះ រមែងមិនធ្វើបាប, តែព្រះសេក្ខៈ ៣ ជំពូក គឺព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមីទាំង ៣ នេះ កន្លងផុត

*អំពីទុគ្គតិភ័យបានហើយ ទើបញុំាងភ័យទាំង ៣ ដ៏សេស ហើយមិនធ្វើបាប ។ ព្រះសេក្ខៈអ្នកតាំងនៅក្នុងមគ្គ ឈ្មោះថា អ្នកវៀរចាកភ័យដោយអំណាចនៃការសម្រេច ឬព្រោះភាពជាអ្នកកាត់ភ័យមិនទាន់ដាច់ស្រេចនៅឡើយ ។*

*ព្រះខីណាស្រព ឈ្មោះថា* **អភយូបរតបុគ្គល** *លោកមិនភ័យខ្លាចសូម្បីភ័យត្រឹមតែម្យ៉ាង ក្នុងបណ្ដាភ័យទាំង ៤ នោះ ។ ពិតមែនហើយ ព្រះខីណាស្រពលោកកាត់ភ័យបានដាច់ហើយ ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា* **“អភយូបរតោ** *= អ្នកលះបង់ចោលសេចក្ដីអាក្រក់មិនមែនព្រោះសេចក្ដីភ័យខ្លាច***”** *។*

***សួរថា*** *លោកក៏មិនខ្លាច សូម្បីតែឧបវាទភ័យ គឺការតិះដៀលឬ ?*

*ឆ្លើយថា មិនខ្លាចទេ, តែមិនគួរពោលថា* ***លោករក្សាឧបវាទភ័យឡើយ*** *សេចក្ដីនេះ បណ្ឌិតគប្បីជ្រាបដូចព្រះថេរៈជាខីណាស្រពក្នុងស្រុក* **ទោណុប្បលវាបី** *ជាតួយ៉ាង ៕*

ចប់ភយូបរតបុគ្គល និងអភយូបរតបុគ្គល

## ពណ៌នាអំពីអភព្វាគមនបុគ្គល និងភព្វាគមនបុគ្គល

វិនិច្ឆ័យក្នុងនិទ្ទេសនៃ ***អភព្វាគមនបុគ្គល*** ៖

អ្នកឯណា មិនគួរដើម្បីនឹងសម្រេចនូវសម្មត្តនិយាម ព្រោះហេតុនោះ អ្នកនោះ ទើបឈ្មោះថា **"អភព្វាគមនបុគ្គល"** ។ បទថា **"កម្មាវរណេន** = ដោយកម្មដែលជាគ្រឿងរារាំង" បានដល់ អនន្តរិយកម្ម ៥ យ៉ាង ។ បទថា **"កិលេសាវរណេន** = ដោយកិលេសជាគ្រឿងរារាំង" បានដល់ និយតមិច្ឆាទិដ្ឋិ ។ បទថា **"វិបាកាវរណេន** = ដោយវិបាកជាគ្រឿងរារាំង" បានដល់ បដិសន្ធិដោយអហេតុកៈ និងទ្វិហេតុកចិត្ត ។ បទថា **"អសទ្ធា** = អ្នកមិនមានសទ្ធា" បានដល់ ជាអ្នកវៀរចាកការជឿក្នុងព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។ បទថា **"អច្ឆន្ទិកា** = អ្នកមិនមានឆន្ទៈ" បានដល់ អ្នកវៀរចាកសេចក្ដីពេញចិត្តក្នុងកត្តុកម្យតាកុសល ។ វៀរអ្នកជម្ពូទ្វីបចេញហើយ បុគ្គលទាំងនោះ គប្បីជ្រាបថា អ្នកនៅក្នុងទ្វីបទាំង ៣ ក្រៅអំពីនេះ ក្នុងបណ្ដាបុគ្គលទាំងនោះ បុគ្គលទាំងឡាយ ឈ្មោះថា ចូលដល់នូវភាពជាអ្នកមិនមានឆន្ទៈ ។ បទថា **"ទុប្បញ្ញា** = មានបញ្ញាទន់ខ្សោយ" បានដល់ វៀរចាកភវង្គបញ្ញា ។ បទថា **"អភព្វា** = អ្នកមិនគួរ" បានដល់ មិនមានឧបនិស្ស័យនៃមគ្គ និងផល ។ បទថា **"និយាមំ"** បានដល់

*មគ្គនិយាម ។ បទថា* **“ឱក្កមិតុំ”** *សេចក្ដីថា មិនគួរដើម្បីនឹងឈានកន្លង គឺចុះទៅកាន់និយាម ពោលគឺសម្មត្តៈ ក្នុងធម៌ទាំងឡាយដែលជាកុសល ដើម្បីនឹងតាំងមាំក្នុងមគ្គផលនោះបាន ។*

*និទ្ទេសនៃ* ***ភព្វាគមនបុគ្គល*** *បណ្ឌិតគប្បីជ្រាបដោយបដិបក្ខន័យ អំពីពាក្យដែលពោលមកហើយ ។ ព្រះមានព្រះភាគត្រាស់ទុកក្នុងទុកៈនេះ យ៉ាងនេះថា ៖*

*“បុគ្គលឯណា ធ្វើបញ្ចានន្តរិយកម្ម ១, ជាអ្នកនិយតមិច្ឆាទិដ្ឋិ ១, អ្នកចាប់បដិសន្ធិមកដោយអហេតុកៈ និងទ្វិហេតុកចិត្ត ១, អ្នកមិនជឿព្រះរតនត្រ័យ មានព្រះពុទ្ធរតនៈជាដើម ១, សេចក្ដីពេញចិត្ត ដើម្បីនឹងធ្វើកុសលរបស់អ្នកឯណា មិនមាន ១, អ្នកមានភវង្គបញ្ញាមិនបរិបូណ៌ ១, ឧបនិស្ស័យនៃមគ្គ និងផលរបស់អ្នកឯណា មិនមាន ១, សូម្បីបុគ្គលទាំងអស់នោះ ជាអ្នកមានភព្វវិបរិត មិនគប្បីឈានចុះកាន់សម្មត្តនិយាមធម៌ គឺមគ្គផល និងនិព្វានបានឡើយ”៕*

## ចប់អភព្វាគមនបុគ្គល និងភព្វាគមនបុគ្គល

## ពណ៌នាអំពីនិយតបុគ្គល និងអនិយតបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ **និយតានិយតបុគ្គល** ៖*

*បទថា **“អនន្តរិកា”** បានដល់ អ្នកពោរពេញដោយអនន្តរិយកម្ម ។ បទថា **“មិច្ឆាទិដ្ឋិកា”** បានដល់ អ្នកពោរពេញដោយនិយតមិច្ឆាទិដ្ឋិ ។ ក៏សូម្បីបុគ្គលទាំងអស់នោះ ឈ្មោះថា និយតៈ (ទៀង) ព្រោះជាអ្នកទៀងដើម្បីប្រយោជន៍ដល់នរក ។ ចំណែកព្រះអរិយបុគ្គល ៨ ជំពូក ឈ្មោះថា ទៀង ព្រោះជាអ្នកទៀងដើម្បីប្រយោជន៍ដល់មគ្គ និងផលខាងលើ ដោយភាពជាអ្នកចម្រើនដោយបញ្ញាដ៏ប្រពៃ និងដើម្បីប្រយោជន៍ដល់ **អនុបាទា-បរិនិព្វាន** ។ ចំណែកបុគ្គលដ៏សេស មានគតិមិនទៀង ប្រៀបដូចកំណាត់ឈើដែលបុគ្គលចោលទៅក្នុងអាកាស កាលនឹងធ្លាក់ចុះលើផែនដី នរណាមួយ ក៏មិនដឹងថា ខាងចុង ឬកណ្តាល ឬថាគល់ នឹងធ្លាក់ចុះមុន យ៉ាងណា, បុគ្គលទាំងនោះ ក៏ដូចគ្នាដែរ បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា អ្នកមិនទៀង ព្រោះការកំណត់ពិតប្រាកដមិនបានថា អ្នកនេះនឹងកើតក្នុងគតិឈ្មោះឯណោះដូច្នេះ ។*

*ក៏តាមន័យដែលអ្នកឧត្តរកុរុទ្វីប មានគតិទៀងតាមដែលព្រះអង្គត្រាស់ទុកនោះ មិនមែនត្រាស់ដោយអំណាចនៃនិយតធម៌ទេ; តាមពិត មិច្ឆត្តធម៌ និងសម្មត្តធម៌ប៉ុណ្ណោះ ឈ្មោះថា **និយតៈ** ។ ក៏បុគ្គលនេះ ព្រះមានព្រះភាគត្រាស់ហៅថា **“បុគ្គលនិយតោ”** ដោយអំណាចនៃមិច្ឆត្តធម៌ និងសម្មត្តធម៌*

*ទាំងនោះ មានប្រការដូច្នេះ ៕*

ចប់និយតបុគ្គល និងអនិយតបុគ្គល

---

## ពណ៌នាអំពីបដិបន្នកបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ **បដិបន្នកបុគ្គល** ៖*

*បទថា* **“មគ្គសមង្គិនោ** *= អ្នកព្រមព្រៀងដោយមគ្គ”* *បានដល់បុគ្គលអ្នកតាំងនៅក្នុងមគ្គ, ក៏បុគ្គលអ្នកតាំងនៅក្នុងមគ្គទាំងនោះ ឈ្មោះថា* **បដិបន្នកបុគ្គល** *ព្រោះជាអ្នកបដិបត្តិដើម្បីត្រូវការផល ។ បទថា* **“ផលសមង្គិនោ”** *បានដល់ អ្នកព្រមព្រៀងដោយផល ព្រោះជាអ្នកព្រមព្រៀងក្នុងការបានផល ។ ការពិតរាប់តាំងអំពីការបានផលឡើងទៅ លោកទាំងនោះ សូម្បីនៅមិនចូលផលសមាបត្តិ ក៏ឈ្មោះថា តាំងនៅក្នុងផលនោះមែនពិត ៕*

ចប់បដិបន្នកបុគ្គល

---

## ពណ៌នាអំពីសមសីសីបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ **សមសីសីបុគ្គល** ៖*

*ពីរបទថា* **“អបុព្វំ អចរិមំ”** *បានដល់ មិនមុន មិនក្រោយ អធិប្បាយថា ព្រមគ្នាតែម្ដង ។ បទថា* **“បរិយាទានំ”** *បានដល់ សេចក្ដីអស់ទៅជុំវិញ ។ បទថា* **“អយំ”** *សេចក្ដីថា បុគ្គលនេះ ព្រះមានព្រះភាគត្រាស់ហៅឈ្មោះថា* **សមសីសី** *។*

*ក៏សមសីសីបុគ្គលនោះ មាន ៣ ពួក គឺ*

**១-ឥរិយាបថសមសីសី**

**២-រោគសមសីសី**

**៣-ជីវិតសមសីសី ។**

*បណ្ដាបុគ្គលទាំងនោះ បុគ្គលឯណាកំពុងចង្ក្រម ផ្ដើមតាំងវិបស្សនា ក៏សម្រេចព្រះអរហត្តទាំងនៅចង្ក្រមនោះឯង ហើយបរិនិព្វាន **ដូចព្រះបទុមត្ថេរ** ។ បុគ្គលឯណា កំពុងនៅឈរ ផ្ដើមតាំងវិបស្សនា ក៏សម្រេចព្រះអរហត្តកំពុងឈរនោះឯង ហើយបរិនិព្វាន **ដូចព្រះតិស្សត្ថេរ** អ្នកនៅក្នុង **វិហារកោដបព៌ត** ។ បុគ្គលឯណា កំពុងអង្គុយផ្ដើមតាំងវិបស្សនា ក៏សម្រេចព្រះអរហត្តកំពុងអង្គុយនោះឯង ហើយបរិនិព្វាន ។ បុគ្គលឯណា កំពុងដេក ផ្ដើមតាំងវិបស្សនា ក៏សម្រេចព្រះអរហត្ត កំពុងដេកនោះឯង ហើយ*

*បរិនិព្វាន ។ បុគ្គលទាំងអស់ដូចពោលមកនេះ ឈ្មោះថា* **ឥរិយាបថ-សមសីសីបុគ្គល** *។*

*មួយទៀត បុគ្គលឯណាកើតរោគអ្វីមួយ ហើយផ្ដើមតាំងវិបស្សនាខាងក្នុងរោគនោះឯង សម្រេចព្រះអរហត្តហើយបរិនិព្វាន ដោយរោគនោះឯង បុគ្គលនេះ ឈ្មោះថា* **រោគសមសីសីបុគ្គល** *។*

***សួរថា*** *បុគ្គលឈ្មោះថា* **ជីវិតសមសីសី** *តើយ៉ាងណា ?*

*ឆ្លើយថា ពាក្យថា* **“សីសៈ”** *មាន ១៣ យ៉ាង គឺ*

**១-តណ្ហា** *ឈ្មោះថា បលិពោធសីសៈ*

**២-មានះ** *ឈ្មោះថា ពន្ធនសីសៈ*

**៣-ទិដ្ឋិ** *ឈ្មោះថា បរាមាសសីសៈ*

**៤-ឧទ្ធច្ចៈ** *ឈ្មោះថា វិក្ខេបសីសៈ*

**៥-អវិជ្ជា** *ឈ្មោះថា កិលេសសីសៈ*

**៦-សទ្ធា** *ឈ្មោះថា អធិមោក្ខសីសៈ*

**៧-វីរិយៈ** *ឈ្មោះថា បគ្គហសីសៈ*

**៨-សតិ** *ឈ្មោះថា ឧបដ្ឋានសីសៈ*

**៩-សមាធិ** *ឈ្មោះថា អវិក្ខេបសីសៈ*

**១០-បញ្ញា** *ឈ្មោះថា ទស្សនសីសៈ*

**១១-ជីវិតិន្ទ្រិយ** *ឈ្មោះថា បវត្តសីសៈ*

**១២-វិមោក្ខ** *ឈ្មោះថា គោចរសីសៈ*

**១៣-និរោធ** *ឈ្មោះថា សង្ខារសីសៈ ។*

*បណ្តាសីសៈទាំងនោះ* ***អរហត្តមគ្គ*** *រមែងគ្របសង្កត់អវិជ្ជា គឺកិលេសសីសៈ, ចុតិចិត្ត រមែងគ្របសង្កត់ជីវិតិន្ទ្រិយ គឺបវត្តសីសៈ, ចិត្តដែលគ្របសង្កត់អវិជ្ជា រមែងមិនអាចដើម្បីនឹងគ្របសង្កត់ជីវិតិន្ទ្រិយបានទេ, ចុតិចិត្តដែលគ្របសង្កត់ជីវិតិន្ទ្រិយ ក៏មិនអាចដើម្បីនឹងគ្របសង្កត់ចិត្តដែលមានអវិជ្ជាបានដែរ, ចិត្តដែលគ្របសង្កត់អវិជ្ជា ក៏ម្យ៉ាង, ចិត្តដែលគ្របសង្កត់ជីវិតិន្ទ្រិយ ក៏ម្យ៉ាង ។ សីសៈទាំងពីរយ៉ាងនេះ របស់បុគ្គលឯណាដល់ការអស់ទៅព្រមគ្នា បុគ្គលនោះ ទើបឈ្មោះថា* **ជីវិតសមសីសី** *។*

***សួរថា*** *សីសៈទាំងពីរយ៉ាងនេះ មានព្រមគ្នា យ៉ាងណា ?*

*ឆ្លើយថា ព្រោះមានព្រមគ្នា ដោយវារៈ ។ អធិប្បាយថា ការចេញចាកមគ្គ រមែងមានក្នុងវារៈណា វារៈនោះ ឈ្មោះថា មានព្រមគ្នា គឺថា បុគ្គលណា តាំងនៅក្នុង* ***បច្ចវេក្ខណញ្ញាណ ១៩ យ៉ាង*** *គឺបច្ចវេក្ខណៈក្នុង* ***សោតាបត្តិមគ្គ ៥ យ៉ាង, សកទាគាមិមគ្គ ៥ យ៉ាង, អនាគាមិមគ្គ ៥ យ៉ាង និងក្នុងអរហត្តមគ្គ ៤ យ៉ាង*** *ហើយធ្លាក់ចុះកាន់ភវង្គ ទើបបរិនិព្វានសេចក្តីអស់ទៅនៃសីសៈទាំងពីរយ៉ាងនេះ ទើបឈ្មោះថា ព្រមគ្នា ព្រោះ*

*សេចក្តីព្រមគ្នា ដោយវារៈទាំងនោះ ព្រោះហេតុដូច្នោះ បុគ្គលនោះ ទើបព្រះមានព្រះភាគត្រាស់ថា* **ជីវិតសមសីសី** *។ កំបុគ្គលនេះប៉ុណ្ណោះ ព្រះមានព្រះភាគទ្រង់ប្រាថ្នាយកក្នុង* ***សមសីសីនិទ្ទេស*** *នេះ ៕*

ចប់សមសីសីបុគ្គល

---

## ពណ៌នាអំពីឋិតកប្បីបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ* ***ឋិតកប្បីបុគ្គល*** *៖*

*កប្ប*[៦] *តាំងនៅ ព្រោះហេតុដូច្នោះ ទើបឈ្មោះថា* **ឋិតកប្បោ** *។*

---

[៦] មួយមហាកប្ប មានអាយុស្មើនឹង ២៥៦ អន្តរកប្ប, មួយអសង្ខេយ្យកប្ប ស្មើនឹង ១ ក្នុង ៤ របស់មហាកប្ប ។ លោកចែកមហាកប្បចេញជា ៤ ភាគ គឺ

**ក.សំវដ្តអសង្ខេយ្យ** បានដល់ លោកដែលកំពុងវិនាស

**ខ.សំវដ្តដ្ឋាយីអសង្ខេយ្យកប្ប** បានដល់ លោកដែលវិនាសស្រេចហើយ

**គ.វិវដ្តអសង្ខេយ្យកប្ប** បានដល់ លោកដែលកំពុងចម្រើន

**ឃ.វិវដ្តដ្ឋាយី អសង្ខេយ្យកប្ប** បានដល់ លោកដែលចម្រើនស្រេចហើយ ។

**អន្តរកប្ប** បានដល់ រយៈវេលាដែលលោកប្រមាណទុកដូច្នេះ គឺកាលមនុស្សមានអាយុ ដល់ ១ អសង្ខេយ្យឆ្នាំហើយ ក៏ថយចុះមកដល់មួយរយឆ្នាំ រហូតដល់ ១០ ឆ្នាំ និងត្រឡប់ផ្តើមឡើងទៅគ្រប់ជួររយៈជីវិតរហូតដល់ ១ អសង្ខេយ្យឆ្នាំទៀត ទើបរាប់ជាមួយអន្តរកប្ប, **៦៤ អន្តរកប្ប ទើបជាមួយអសង្ខេយ្យកប្ប** ។ម្យ៉ាងទៀត អាយុក្ខ័យរបស់មនុស្សដែលថយចុះ និងចម្រើនឡើងរយៈពេលនោះ ហៅថា **អាយុកប្ប** ។

*កប្បតាំងនៅរបស់បុគ្គលនោះមាន ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា* **ឋិតកប្បី** *= អ្នកមានកប្បដែលតាំងនៅ ។ អធិប្បាយថា ជាអ្នកអាចដើម្បីនឹងឲ្យកប្បតាំងនៅបាន ។*

*ពាក្យថា* **"ឧឌ្ឍនវេលា អស្សាតិ ឈាយនការលោ ភវេយ្យ** *= វេលាជាទីឆេះរបស់កប្បនោះមាន ព្រោះហេតុនោះ កប្បនោះ ទើបឈ្មោះថា* **ឈាយនការលោ** *= មានកាលជាទីឆេះ ។ ពាក្យថា* **" នេវ តាវ "** *សេចក្ដីថា បុគ្គលអ្នកដល់ព្រមដោយមគ្គនេះ (មគ្គសមង្គីបុគ្គល) មិនបានធ្វើឲ្យជាក់ច្បាស់នូវព្រះសោតាបត្តិផលត្រឹមណា, កប្បក៏មិនត្រូវបានភ្លើងឆេះត្រឹមនោះទេ, សូម្បីកប្បកំពុងឆេះ លោកអ្នកដល់ព្រមដោយមគ្គនោះ មិនឆេះឡើយ, គប្បីតាំងនៅបាន ។ ពិតមែនហើយ ក៏ឈ្មោះថា* ***កប្បវិនាស គឺជាវិកាលធំ ជាមហាបយោគ ជាមហាលោកវិនាស*** *ដោយអំណាចនៃការឆេះរហូតសែនកោដិចក្រវាល ។ ព្រះមានព្រះភាគត្រាស់ថា* ***មហាវិនាស*** *នេះ គប្បីប្រាកដហើយយ៉ាងនេះតែម្ដង, តែកាលព្រះសាសនាតាំងនៅ ឈ្មោះថា* ***កប្បវិនាស*** *ក៏មិនមានឡើយ, ទាំងសាសនា ក៏មិនមាន ក្នុងវេលាដែលកប្បវិនាស ។ តែឈ្មោះថា កប្បវិនាសរមែងមានក្នុងវេលាដែលដល់ទីបំផុតហើយ ។ សូម្បីកាលបើយ៉ាងនោះ ព្រះសាស្ដាទ្រង់នាំហេតុនេះមក ដើម្បីនឹងសម្ដែងសេចក្ដីមិនមានអន្តរាយ ។ សូម្បីហេតុនេះ នឹង*

គប្បីមាន, តែអន្តរាយទាំងឡាយនៃផលចិត្តរបស់មគ្គបុគ្គល ដែលអ្វីៗ ក៏មិនអាចនឹងធ្វើបានឡើយ ។

***សួរថា*** ក៏បុគ្គលនេះ សូម្បីឲ្យកប្បតាំងនៅបាន គប្បីតាំងនៅ រហូតអស់កាលមានប្រមាណប៉ុនណា ។

ឆ្លើយថា ការចេញចាកមគ្គរមែងមានក្នុងវេលាវារៈណា, លោកក៏គប្បីតាំងនៅរហូតអស់កាលមានប្រមាណប៉ុណ្ណោះ ។

ពាក្យថា **“អថ ភវង្គំ អាវដ្ដេន្តំ មនោទ្វារាវជ្ជនំ ឧប្បជ្ជតិ តតោ តីណិ អនុលោមានិ ឯកំ គោត្រភូចិត្តំ ឯកំ មគ្គចិត្តំ ទ្វេ ផលចិត្តានិ បញ្ច បច្ចវេក្ខណញ្ញាណានិ”** អធិប្បាយថា កាលភវង្គចិត្តរលត់ហើយ មនោទ្វារាវជ្ជនចិត្ត ក៏កើតឡើង, តអំពីនោះ ***អនុលោមញ្ញាណ ក៏កើតឡើង ៣ ខណៈ គោត្រភូចិត្តកើតឡើង ១ ខណៈ មគ្គចិត្តកើតឡើង ១ ខណៈ ផលចិត្តកើតឡើង ២ ខណៈ បច្ចវេក្ខណញ្ញាណកើតឡើង ៥ ដង*** បុគ្គលនេះ គប្បីតាំងនៅរហូតអស់កាលមានប្រមាណប៉ុណ្ណោះ ។

ម្យ៉ាងទៀត ដើម្បីនឹងសម្ដែងរឿងនេះ ដោយសេចក្ដីឧបមាដែលមានខាងក្រៅ លោកអាចារ្យទាំងឡាយ សម្ដែងរឿងនេះទុកយ៉ាងនេះថា ៖

ក៏បើបុគ្គលគប្បីយកខ្សែ ៣ ចង្វាយ ចងដុំសិលាក្រាស់ឃ្មឹកជាមួយគ្នា មានប្រមាណមួយយោជន៍ ព្យួរទុកលើក្បាលរបស់បុគ្គលអ្នកដល់ព្រមដោយ

សោតាបត្តិមគ្គ, កាលខ្សែមួយចន្សាយដាច់ហើយ ដុំសិលាក៏ព្យួរដោយខ្សែពីរចន្សាយ, កាលខ្សែទីពីរដាច់ហើយ ក៏នៅព្យួរដោយខ្សែត្រឹមតែមួយ, កាលខ្សែមួយនោះ ដាច់ហើយ ដុំសិលានោះ ក៏អណ្តែតទៅលើអាកាស ដូចការបោកបញ្ឆោតរបស់ដុំពពកដែលអណ្តែត, ដុំសិលានោះ មិនបានធ្វើអន្តរាយដល់បុគ្គលអ្នកបាន ***មគ្គានន្តរៈ*** គឺអ្នកមិនមានអ្វីឃាត់ឃាំងចន្លោះមគ្គនិងផលនោះទេ ។ ការសម្តែងនេះ ជាការចង្អុលបង្ហាញត្រឹមតែបន្តិចបន្តួច, ការសម្តែងគ្រាមុននោះឯង ជាការចង្អុលបង្ហាញមានច្រើនហើយ ។

ក៏បុគ្គលអ្នកតាំងនៅក្នុងសោតាបត្តិមគ្គប៉ុណ្ណោះ នឹងឈ្មោះថា តាំងនៅរហូតមួយកប្បក៏ទេ, សូម្បីអ្នកដល់ព្រមដោយមគ្គក្រៅអំពីនេះ ក៏តាំងនៅរហូតកប្បដូចគ្នា ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ទាញយកបុគ្គលដែលព្រះអង្គទ្រង់កាន់យក និងទ្រង់មិនកាន់យកពេលក្រោយហើយ លើកឡើងកាន់បែបដែននេះ ព្រមនឹងបិដ្ឋិវដ្តកបុគ្គលទាំងឡាយ ។ សូម្បីបុគ្គលអ្នកដល់ព្រមដោយមគ្គទាំងអស់ ឈ្មោះថា ***ឋិតកប្បី*** អ្នកតាំងនៅរហូតកប្បដូច្នេះ ៕

ចប់ឋិតកប្បីបុគ្គល

## ពណ៌នាអំពីអរិយបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ **ព្រះអរិយបុគ្គល** ៖*

*ឈ្មោះថា* **អរិយៈ** *ព្រោះជាអ្នកឆ្ងាយចាកកិលេសទាំងឡាយ ។ ឈ្មោះថា* **អរិយៈ** *ព្រោះប្រសើរជាងលោក ព្រមទាំងទេវលោក, បុគ្គលអ្នកមានសេចក្ដីបរិសុទ្ធជាអត្ថ ឈ្មោះថា **អត្ថនៃអរិយៈ**, ព្រោះហេតុនោះសូម្បីព្រោះអត្ថថា ជាអ្នកបរិសុទ្ធ ទើបឈ្មោះថា* **អរិយៈ** *។ ពួកជនទាំងឡាយដ៏សេស មិនឈ្មោះថា* **អរិយៈ** *ទេ ព្រោះភាពជាអ្នកមិនបរិសុទ្ធ៕*

ចប់អរិយបុគ្គល

---

## ពណ៌នាអំពីសេក្ខបុគ្គល និងអសេក្ខបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ **ព្រះសេក្ខបុគ្គល** ៖*

*បុគ្គលឯណាដល់ព្រមដោយអរិយមគ្គក្នុងខណៈនៃមគ្គចិត្តផង ដល់ព្រមដោយអរិយផល ក្នុងខណៈនៃផលចិត្តផង ជនទាំងនេះ នៅសិក្សានូវសិក្ខាទាំង ៣ មានអធិសីលសិក្ខាជាដើម, ព្រោះហេតុនោះ ជនទាំងនោះទើបឈ្មោះ* **សេក្ខា** *= អ្នកនៅសិក្សា ។ ចំណែកព្រះអរហន្ត លោកសិក្សានូវសិក្ខាទាំង ៣ ក្នុងខណៈនៃអរហត្តផល កិច្ច គឺការសិក្សារមែងមិនមានដល់លោកទៀតទេ, ព្រោះហេតុដូច្នោះ ព្រះអរហន្ត ទើបឈ្មោះថា*

**អសេក្ខា** = *អ្នកមិនសិក្សា ។ ព្រះអរិយបុគ្គល ៧ ជំពូក លោកកំពុងសិក្សាដោយអាការយ៉ាងនេះ ព្រោះហេតុនោះ លោកទើបឈ្មោះថា* **សេក្ខា** *។ ព្រះខីណាស្រពទាំងឡាយ ឈ្មោះថា* **សិក្ខិតាសេក្ខា** = *អសេក្ខបុគ្គលដែលសិក្សាស្រេចហើយ អំពីបុគ្គលដទៃ ព្រោះភាវៈនៃសីលជាដើម លោកសិក្សាហើយក្នុងសំណាក់នៃបុគ្គលដទៃ ព្រះពុទ្ធជាម្ចាស់ និងព្រះបច្ចេកពុទ្ធជាម្ចាស់ទាំងឡាយ ឈ្មោះថា* **អសិក្ខិតាសេក្ខា** = *អសេក្ខបុគ្គលដែលមិនសិក្សាអំពីសំណាក់បុគ្គលដទៃ ព្រោះភាវៈនៃព្រះអង្គជាសយម្ភូ គឺជាអ្នកត្រាស់ដឹងដោយខ្លួនឯង ។ បុគ្គលទាំងឡាយដ៏សេស កំពុងសិក្សាក៏មិនមែន, សិក្សាហើយក៏មិនមែន ព្រោះហេតុនោះ ទើបឈ្មោះថា* **នេវ-សេក្ខានាសេក្ខា ៕**

ចប់សេក្ខបុគ្គល និងអសេក្ខបុគ្គល

---

## ពណ៌នាអំពីតេវិជ្ជបុគ្គល និងឆឡភិញ្ញបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ* ***តេវិជ្ជបុគ្គល ៖***

*បុគ្គលអ្នកញ៉ាំង* ***បុព្វេនិវាស*** *និង* ***ទិព្វចក្ខុញ្ញាណ*** *ឲ្យកើតឡើង ហើយសម្រេចព្រះអរហត្តខាងក្រោយក្តី អ្នកសម្រេចព្រះអរហត្តមុន ហើយញ៉ាំងបុព្វេនិវាស និងទិព្វចក្ខុញ្ញាណឲ្យកើតឡើងក្តី ឈ្មោះថា អ្នកមានវិជ្ជា ៣*

ទាំងអស់ (តេវិជ្ជោ), ក៏ខកំណត់ក្នុងការសម្រេច ជាធុរៈក្នុងទីនេះថា “ក៏ពាក្យដែលពោលទុកក្នុងព្រះសូត្រ ជាការសម្តែងដោយអម, ពាក្យដែលពោលទុកក្នុងព្រះអភិធម្ម ជាការសម្តែងដោយត្រង់” ព្រោះហេតុនោះ បុគ្គលអ្នកញ៉ាំងវិជ្ជា ២ ឲ្យកើតឡើងមុន ហើយសម្រេចព្រះអរហត្តខាងក្រោយនោះឯង ព្រះអង្គទ្រង់បំណងយកក្នុង ***តេវិជ្ជនិទ្ទេស*** នេះ ។ សូម្បីក្នុងបុគ្គលអ្នកមានអភិញ្ញា ៦ ក៏មានន័យដូចគ្នានេះ ៕

ចប់តេវិជ្ជបុគ្គល និងឆឡភិញ្ញបុគ្គល

---

## ពណ៌នាអំពីសម្មាសម្ពុទ្ធបុគ្គល

វិនិច្ឆ័យក្នុងនិទ្ទេសនៃ ***សម្មាសម្ពុទ្ធបុគ្គល*** ៖

ពាក្យថា **“បុព្វេ អននុស្សុតេសុ”** បានដល់ ក្នុងធម៌ដែលមិនធ្លាប់ស្តាប់មកអំពីមុន ក្នុងសំណាក់នៃបុគ្គលដទៃ ក្នុងកាលមុនអំពីការត្រាស់ដឹងសច្ចធម៌ក្នុងបច្ឆិមភព ។ ក៏ក្នុងភពមុនៗ អំពីភពនេះ ព្រះសព្វញ្ញូពោធិសត្វទ្រង់ផ្នួសក្នុងព្រះពុទ្ធសាសនារៀន ព្រះត្រៃបិដកទាំង ៣ ហើយលើកឡើងកាន់គតបច្ចាគតវត្ត គឺវត្តដែលនាំកម្មដ្ឋានទៅ និងនាំត្រឡប់មកផ្តើមតាំងកម្មដ្ឋានរហូតដល់អនុលោម និងគោត្រភូញាណ ។ ព្រោះហេតុនោះ ពាក្យ

ថា **"សម្មាសម្ពុទ្ធោ"** នេះ លោកពោលសំដៅយកភាពជាអ្នកមិនមាននរណាមួយ ជាអាចារ្យក្នុងបច្ចិមភព គឺជាតិចុងក្រោយបំផុតប៉ុណ្ណោះ ។

ពិតយ៉ាងនោះមែន ព្រះតថាគតជាម្ចាស់ ទ្រង់ត្រាស់ដឹងសច្ចធម៌ទាំង ៤ ដោយព្រះអង្គឯង ដោយញាណដែលប្រចក្សដល់ព្រះអង្គថា **"ឥទំ ទុក្ខំ ។ ល ។ ឥទំ ទុក្ខនិរោធគាមិនីបដិបទា"** ដូច្នេះ ក្នុងសង្ខតធម៌ទាំង-ឡាយ ដែលមិនបានស្តាប់ក្នុងសំណាក់នៃបុគ្គលដទៃ ព្រោះភាពនៃព្រះអង្គជាអ្នកមានបារមីពេញបរិបូណ៌ហើយ ។ ពាក្យថា **"គត្ត"** បានដល់ ***អរហត្តមគ្គ*** ពោលគឺបញ្ញាជាគ្រឿងត្រាស់ដឹងសច្ចធម៌ទាំង ៤ នោះ ។ ពាក្យថា **"ពលេសុ ចសីភាវំ"** បានដល់ រមែងដល់ភាពជាអ្នកជំនាញក្នុងការប្រព្រឹត្តសព្វញ្ញុតញ្ញាណ និងទសពលញ្ញាណទាំងឡាយ ។ ក៏កិច្ចដទៃឈ្មោះថា គួរធ្វើ រមែងមិនមានដល់ព្រះពុទ្ធទាំងឡាយ ចាប់ផ្តើមអំពីការសម្រេចព្រះសព្វញ្ញុតញ្ញាណ និងទសពលញ្ញាណ ។ ដូចយ៉ាងឥស្សរិយយសទាំងអស់ នរណាមួយ មិនគួរពោលថា ឈ្មោះថា ឥស្សរិយយសនេះមិនមកដល់ខត្តិយកុមារជាឧភតោសុជាត ចាប់ផ្តើមអំពីការបានអភិសេក, ឥស្សរិយយសនេះ រមែងជាធម្មជាតិមកហើយទាំងអស់ យ៉ាងណា; ឈ្មោះថា គុណនេះ ដែលនរណាមួយ ក៏មិនគួរពោលថា មិនមកដល់ហើយដល់ព្រះពុទ្ធទាំងឡាយ, ព្រះពុទ្ធទាំងឡាយមិនចាក់ធ្លុះហើយ, នឹងមិនប្រចក្ស

ដល់ព្រះពុទ្ធទាំងឡាយ ចាប់ផ្ដើមអំពីការសម្រេចអរហត្តមគ្គ សូម្បីគុណ គឺព្រះសព្វញ្ញុតញ្ញាណទាំងពួង ឈ្មោះថា មកហើយ ព្រះពុទ្ធបានចាក់ធ្លុះហើយ ធ្វើឲ្យប្រចក្សហើយដូច្នោះដែរ ។

ពាក្យថា **“អយំ វុច្ចតិ”** សេចក្ដីថា បុគ្គលនេះ បានដល់ បុគ្គលអ្នកមានសព្វញ្ញុគុណដែលចាក់ធ្លុះហើយ ដោយអរិយមគ្គ ដោយអានុភាពនៃសេចក្ដីសម្រេចហើយ ដោយបារមីដែលបរិបូណ៌ មានប្រការដូច្នេះ ទើបលោកហៅថា **“សម្មាសម្ពុទ្ធោ”**៕

ចប់សម្មាសម្ពុទ្ធបុគ្គល

---

## ពណ៌នាអំពីបច្ចេកសម្ពុទ្ធបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ **បច្ចេកសម្ពុទ្ធបុគ្គល*** ៖

បណ្ឌិតគប្បីជ្រាប សេចក្ដីនៃបទថា **“បុព្វេ អននុស្សុតេសុ”** ដោយន័យដែលពោលទុកក្នុងពេលមុននុ៎ះឯង ។ មែនពិត ព្រះបច្ចេកពុទ្ធជាម្ចាស់ក្នុងបច្ឆិមភព ក៏មិនមាននរណាមួយ ជាអាចារ្យ លោកចាក់ធ្លុះសច្ចធម៌ទាំង ៤ ដោយអត្តុក្កំសិកញ្ញាណ គឺញាណដែលដឹងចំពោះខ្លួនឯងនោះ, តែមិនបានសម្រេចព្រះសព្វញ្ញុតញ្ញាណ និងទសពលញ្ញាណឡើយ ៕

ចប់បច្ចេកសម្ពុទ្ធបុគ្គល

## ពណ៌នាអំពីឧភតោភាគវិមុត្តបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ* ***ឧភតោភាគវិមុត្តបុគ្គល*** *៖*

*ពាក្យថា* **“ អដ្ឋវិមោក្ខេ កាយេន វិហរតិ ”** *សេចក្ដីថា បានសមាបត្តិ ៨ ដោយសហជាតនាមកាយហើយ ។ ពាក្យថា* **“ បញ្ញាយ ចស្ស ទិស្វា ”** *សេចក្ដីថា អាសវៈទាំង ៤ អស់ហើយ ព្រោះឃើញការប្រព្រឹត្តទៅនៃសង្ខារដោយវិបស្សនាបញ្ញា, ឃើញសច្ចធម៌ទាំង ៤ ដោយមគ្គប្បញ្ញា ។ ពាក្យថា* **“ អយំ វុច្ចតិ ”** *សេចក្ដីថា បុគ្គលនេះ គឺអ្នកឃើញបែបនេះ លោកហៅថា* ***ឧភតោភាគវិមុត្តបុគ្គល*** *។ ក៏បុគ្គលនេះ ផុតវិសេសហើយអំពីចំណែកទាំង ២ អស់ពីរដង ព្រោះហេតុនោះ ទើបហៅថា* ***ឧភតោភាគវិមុត្ត*** *= អ្នកផុតវិសេសហើយ អំពីចំណែកទាំង ២ អស់ពីរដង ។*

*សេចក្ដីនេះ ថេរវាទពោលទុកជាឧទាហរណ៍ ដូចតទៅនេះ៖*

*ព្រះចុល្លនាគត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក ពោលទុកមុនថា បុគ្គលណាផុតហើយដោយ* ***វិក្ខម្ភនវិមោក្ខសមាបត្តិ*** *និងផុតហើយដោយ* ***សមុច្ឆេទវិមោក្ខមគ្គ*** *ព្រោះហេតុនោះ ទើបលោកហៅថា* ***ឧភតោភាគវិមុត្តបុគ្គល*** *។*

*ព្រះមហាធម្មរក្ខិតត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក ពោលទុកថា បុគ្គល*

*នេះអាស្រ័យនាមហើយ ពោលថា “ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា ‘ម្នាលឧបសីវៈ អណ្តាតភ្លើង ត្រូវកម្លាំងខ្យល់ផាត់ហើយ រមែងរលត់ទៅ មិនចូលដល់ការរាប់បាន’ យ៉ាងណា, មុនីអ្នករួចផុតវិសេសហើយអំពីនាមកាយ រមែងរលត់ទៅ គឺរមែងឧបាទាបរិនិព្វាន រមែងមិនចូលដល់នូវការរាប់ថា ជាមនុស្ស ជាសត្វបានយ៉ាងនោះ” ; លុះនាំព្រះសូត្ររឿងឧបសីវមាណវបញ្ហាទី ៦ ក្នុងសោឡសបញ្ហាមកហើយ ទើបពោលថា ឈ្មោះថា* ***ឧភតោភាគវិមុត្តបុគ្គល*** *ព្រោះរួចផុតវិសេសហើយអំពីនាមកាយនិងរូបកាយ ។*

*ចំណែកព្រះចូឡាភយត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក ពោលទុកថា “បុគ្គលអ្នករួចផុតវិសេសហើយ ដោយវិក្ខម្ភនវិមោក្ខសមាបត្តិអស់មួយវារៈ ផុតវិសេសហើយ ដោយសមុច្ឆេទវិមោក្ខមគ្គ អស់មួយវារៈ ទើបហៅថា ឧភតោភាគវិមុត្តបុគ្គល” ដូច្នេះ ។ ក៏ព្រះថេរៈទាំង ៣ រូបនេះ ជាបណ្ឌិតលោកតាំងវាទៈទុកឲ្យជាបែបផែនដោយការពិចារណាថា “ហេតុក្នុងវាទៈទាំង ៣ រមែងឃើញបាន” ក៏កាលពោលដោយសង្ខេប បុគ្គលឯណាផុតវិសេសហើយ អំពីរូបកាយដោយអរូបសមាបត្តិ ផុតវិសេសហើយអំពីនាមកាយដោយមគ្គ ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា* ***ឧភតោភាគវិមុត្ត-***

***បុគ្គល*** ព្រោះរួចផុតវិសេសហើយអំពីចំណែកទាំងពីរ ។ បុគ្គលដែលឈ្មោះថា ***ឧភតោភាគវិមុត្ត*** នោះ មាន ៥ ជំពូក គឺបុគ្គលអ្នកបាននូវអរូបសមាបត្តិ ៤ ចេញចាកអរូបសមាបត្តិមួយៗ ហើយពិចារណាសង្ខារទាំងឡាយ ទើបសម្រេចព្រះអរហត្តជា ៤ ជំពូក និងព្រះអនាគាមីអ្នកចេញចាកនិរោធសមាបត្តិ ហើយសម្រេចព្រះអរហត្ត ១ ។ បណ្តាព្រះអរិយៈទាំង ៥ នោះ ៤ ពួកដំបូង លោកមិនចូលនិរោធ ដែលមានសមាបត្តិជាប្រធានទេ ព្រោះហេតុនោះ ទើបឈ្មោះថា ***ឧភតោភាគវិមុត្ត*** ដោយបរិយាយ, ព្រះអនាគាមីអ្នកបាន សមាបត្តិនោះហើយ កាលចេញចាកសមាបត្តិ ក៏ចម្រើនវិបស្សនាសម្រេចព្រះអរហត្ត ព្រោះហេតុដូច្នោះ ទើបឈ្មោះថា ***ឧភតោភាគវិមុត្តសេដ្ឋបុគ្គល*** ដោយនិប្បរិយាយ ។

***សួរថា*** អរូបាវចរជ្ឈានក្តី រូបាវចរចតុត្ថជ្ឈានក្តី មានអង្គ ២ គឺ **ឧបេក្ខា** និង **ឯកគ្គតា** ព្រោះហេតុដូច្នោះ បុគ្គលធ្វើរូបាវចរចតុត្ថជ្ឈាន ដែលមានអង្គ ២ នោះ ឲ្យជាបទដ្ឋានហើយសម្រេចព្រះអរហត្ត ក៏គប្បីជាអ្នកឈ្មោះថា ***ឧភតោភាគវិមុត្ត*** មិនមែនឬ ?

ឆ្លើយថា មិនគប្បីជាដូច្នោះទេ ។

***សួរថា*** ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះភាវៈនៃអ្នកនោះ នៅមិនទាន់ផុតអំពីរូបកាយ ។

ព្រោះថា ***រូបាវចរចតុត្ថជ្ឈាន*** នោះ ផុតអំពីកិលេសកាយប៉ុណ្ណោះ, មិនបានផុតអំពីរូបកាយទេ ព្រោះហេតុដូច្នោះ អ្នកចេញចាកសមាបត្តិនោះ ហើយសម្រេចព្រះអរហត្ត ទើបមិនឈ្មោះថា ***ឧភតោភាគវិមុត្ត***, ចំណែកអរូបាវចរជ្ឈាន ផុតហើយអំពីនាមកាយផង អំពីរូបកាយផង ព្រោះហេតុដូច្នោះ អ្នកធ្វើអរូបាវចរជ្ឈាននោះឲ្យជាបាទ ហើយសម្រេចព្រះអរហត្ត គប្បីជ្រាបថា ឈ្មោះថា ***ឧភតោភាគវិមុត្តបុគ្គល*** ៕

ចប់ឧភតោភាគវិមុត្តបុគ្គល

---

## ពណ៌នាអំពីបញ្ញាវិមុត្តបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ **បញ្ញាវិមុត្តបុគ្គល*** ៖

*អ្នកឯណារួចផុតវិសេស ហើយដោយបញ្ញា ព្រោះហេតុដូច្នោះ ទើបឈ្មោះថា* **បញ្ញាវិមុត្តបុគ្គល** *។ បញ្ញាវិមុត្តបុគ្គលនោះ មាន ៥ ជំពូក គឺព្រះអរហត្តសុក្ខវិបស្សកៈ ១ និងបុគ្គលអ្នកចេញចាកឈានទាំង ៤ ហើយពន្ធះព្រះអរហត្ត ៤ ជំពូកទៀត ។ ក៏បណ្តាព្រះអរហន្តទាំងនោះ សូម្បីព្រះអរហន្តមួយព្រះអង្គដែលបានវិមោក្ខ ៨ ក៏មិនមានឡើយ ។ ដោយហេតុនោះឯង ទើបលោកពោលពាក្យជាដើមថា* **“ន ហេវ ខោ អដ្ឋវិមោក្ខេ”**, *តែបណ្តាអរូបាវចរជ្ឈានទាំងឡាយ សូម្បីកាលមានត្រឹមតែឈានមួយ*

*ក៏ឈ្មោះថា **ឧភតោភាគវិមុត្តបុគ្គល** បានដូចគ្នាដែរ ៕*

ចប់បញ្ញាវិមុត្តបុគ្គល

---

## ពណ៌នាអំពីកាយសក្ខីបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ **កាយសក្ខីបុគ្គល** ៖*

*ពាក្យថា* **"ឯកច្ចេ អាសវា"** *បានដល់ អាសវៈខ្លះ ដែលប្រហារដោយមគ្គខាងក្រោម ៣ ។ ពាក្យថា* **"អយំ វុច្ចតិ"** *បានដល់ បុគ្គលនេះគឺអ្នកមានសភាពបែបនេះ លោកហៅថា* **កាយសក្ខី** *។ ក៏បុគ្គលនោះឈ្មោះថា* **កាយសក្ខី** *ព្រោះធ្វើឲ្យច្បាស់ នូវវិមោក្ខដែលខ្លួនពាល់ត្រូវហើយ ។ បុគ្គលឯណាពាល់ត្រូវផលដែលកើតអំពីឈានមុន ហើយធ្វើនិរោធ គឺនិព្វានឲ្យច្បាស់ខាងក្រោយ, សូម្បីបុគ្គលនេះ ក៏ឈ្មោះថា* **កាយ-សក្ខី** *ដែរ ។ កាយសក្ខីបុគ្គលនេះ មាន ៦ ជំពូក រាប់តាំងអំពីសោតា-បត្តិផល រហូតដល់អរហត្តមគ្គ ៕*

ចប់កាយសក្ខីបុគ្គល

---

## ពណ៌នាអំពីទិដ្ឋិប្បត្តបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ **ទិដ្ឋិប្បត្តបុគ្គល** ៖*

ពាក្យថា **"ឥធំ ទុក្ខំ"** បានដល់ ទុក្ខមានប្រមាណប៉ុណ្ណេះ មិនលើស អំពីនេះទេ ។ សូម្បីក្នុងហេតុឲ្យកើតទុក្ខជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ពាក្យថា **"យថាភូតំ បជានាតិ"** សេចក្ដីថា វៀរតណ្ហាចេញហើយ រមែង ដឹងទុក្ខ គឺឧបាទានក្ខន្ធ ៥ ដោយកិច្ច តាមសេចក្ដីពិតថា ជាទុក្ខសច្ច ។ ក៏ តណ្ហារមែងញ៉ាំងទុក្ខឲ្យកើត ឲ្យកើតឡើង ឲ្យបង្កើត គឺឲ្យប្រព្រឹត្តទៅ ទុក្ខ នេះ រមែងកើតអំពីតណ្ហានោះ ព្រោះហេតុនោះ រមែងដឹងច្បាស់នូវតណ្ហា នោះ តាមសេចក្ដីពិតថា **"អយំ ទុក្ខសមុទយោ** = នេះជាដែនកើតឡើង នៃទុក្ខ" ។ ក៏ព្រោះហេតុដែលទុក្ខនេះផង សមុទ័យនេះផង ដល់ព្រះនិព្វាន ហើយរមែងរលត់ទៅ រមែងស្ងប់រម្ងាប់ គឺរមែងដល់សេចក្ដីមិនត្រូវប្រព្រឹត្ត ទៅ ព្រោះហេតុដូច្នោះ រមែងដឹងច្បាស់នូវព្រះនិព្វាននោះ តាមសេចក្ដីពិត ថា **"អយំ ទុក្ខនិរោធោ** = នេះជាទីរលត់ទៅនៃទុក្ខ" ។ មួយទៀត មគ្គ ឯណាជាផ្លូវប្រកបដោយអង្គ ៨, ទុក្ខនេះរមែងដល់នូវសេចក្ដីរលត់ទៅ ដោយមគ្គនោះ ព្រោះហេតុដូច្នោះ រមែងដឹងទូទៅនូវមគ្គនោះ តាមសេចក្ដី ពិតថា **"អយំ ទុក្ខនិរោធគាមិនីបដិបទា** = នេះជាការបដិបត្តិឲ្យដល់នូវ សេចក្ដីរលត់ទុក្ខ" ។

ឥឡូវនេះ ដើម្បីនឹងសម្ដែងអរិយសច្ចទាំង ៤ ក្នុងខណៈជាមួយគ្នា ទើបព្រះអង្គត្រាស់ពាក្យជាដើមថា **"តថាគតប្បវេទិតា** = ធម៌ដែលតថាគត

*បានចាក់ធ្លុះហើយ ។ បណ្ដាបទទាំងនោះ បទថា* **“ តថាគតប្បវេទិតា ”** *សេចក្ដីថា សច្ចធម៌ទាំង ៤ ដែលព្រះតថាគតទ្រង់គង់ប្រថាប់ក្រោមមហា-ពោធិមណ្ឌល ទ្រង់ចាក់ធ្លុះហើយ គឺទ្រង់ប្រចក្សហើយ បានដល់ ធ្វើឲ្យប្រាកដហើយ ។ បទថា* **“ ធម្មា ”** *បានដល់ ធម៌ គឺអរិយសច្ចទាំង ៤ ។ ពាក្យថា* **“ ទេវា ទិដ្ឋា ហោន្តិ ”** *បានដល់ ធម៌ដែលខ្លួនឃើញល្អហើយ ។ ពាក្យថា* **“ ទេវា ចរិតា ”** *បានដល់ ប្រព្រឹត្តល្អហើយ ។ ក្នុងធម៌ទាំងនោះ អធិប្បាយថា បានដល់ បញ្ញាដែលខ្លួនប្រព្រឹត្តល្អហើយ ។ ពាក្យថា* **“ អយំ វុច្ចតិ ”** *បានដល់ បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា* **ទិដ្ឋិប្បត្តោ** *។ ក៏បុគ្គលនេះ សម្រេចធម៌ដែលខ្លួនឃើញហើយ ព្រោះហេតុដូច្នោះ ទើបឈ្មោះថា* **ទិដ្ឋិប្បត្តោ** *។ ញាណ គឺបញ្ញាថា* **“ ទុក្ខា សង្ខារា, សុខោ និរោធោ** *= សង្ខារទាំងឡាយជាទុក្ខ, និរោធជាសុខ” ដែលបុគ្គលនោះ ឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយបញ្ញា ព្រោះហេតុនោះ អ្នកនោះ ទើបឈ្មោះថា* **ទិដ្ឋិប្បត្តោ** *។ ទិដ្ឋិប្បត្តបុគ្គលនេះ ក៏មាន ៦ ជំពូក ដូចព្រះអរិយបុគ្គលឈ្មោះថា* **កាយសក្ខី** *ដែរ ៕*

ចប់ទិដ្ឋិប្បត្តបុគ្គល

---

## ពណ៌នាអំពីសទ្ធាវិមុត្តបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ **សទ្ធាវិមុត្តបុគ្គល** ៖*

*បទថា* **"នោ ច ខោ យថា ទិដ្ឋិប្បត្តស្ស"** *អធិប្បាយថា អាសវៈទាំងឡាយរបស់សទ្ធាវិមុត្តបុគ្គល ជាធម្មជាតិអស់ទៅ មិនដូចគ្នានឹងទិដ្ឋិប្បត្តបុគ្គលទេ ។*

***សួរថា*** *សេចក្ដីផ្សេងគ្នាក្នុងការលះកិលេសនៃព្រះអរិយបុគ្គលទាំងពីរនោះ នៅមានឬ ?*

*ឆ្លើយថា មិនមានទេ ។*

***សួរថា*** *បើដូច្នោះ ព្រោះហេតុអ្វីបានជាសទ្ធាវិមុត្តបុគ្គល មិនដូចគ្នានឹងទិដ្ឋិប្បត្តបុគ្គល ?*

*ឆ្លើយថា ព្រោះសេចក្ដីប្លែកផ្សេងគ្នាដោយធម៌ដែលលោកគប្បីសម្រេច ។ ក៏ទិដ្ឋិប្បត្តបុគ្គល លោកគ្របសង្កត់កិលេសបានដោយការសម្រេចមិនលំបាកឡើយ អាចដើម្បីគ្របសង្កត់កិលេសទាំងឡាយ ដោយមិនលំបាក គឺមិនកម្រ ។ តែសទ្ធាវិមុត្តបុគ្គលជាអ្នកលំបាក ដោយសេចក្ដីទុក្ខលំបាក ទើបអាចសង្កត់កិលេសទាំងឡាយបាន ព្រោះហេតុដូច្នោះ ទើបលោកមិនដល់ទិដ្ឋិប្បត្តបុគ្គលឡើយ ។*

*មួយទៀត សេចក្ដីប្លែកផ្សេងគ្នា សូម្បីដោយបញ្ញារបស់លោកទាំង*

ពីរនោះ ក៏នៅមានដែរ ។ ក៏វិបស្សនាញាណនៃមគ្គ ៣ ខាងលើរបស់ទិដ្ឋិប្បត្ត ជាគុណជាតខ្លាំងក្លា, ក្លៀវក្លា, ស្រស់ថ្លា ប្រព្រឹត្តទៅ ។

វិបស្សនាញាណរបស់សទ្ធាវិមុត្ត មិនខ្លាំងក្លា, មិនក្លៀវក្លា, មិនស្រស់ថ្លា ប្រព្រឹត្តទៅ ។ សូម្បីព្រោះហេតុនោះ ទើបលោកមិនដល់ទិដ្ឋិប្បត្តបុគ្គល ។

ដូចយ៉ាងថា បុរសកំលោះ ២ នាក់ កាលនឹងសម្ដែងសិល្បៈ ម្នាក់មានដាវដែលមុតក្លានៅក្នុងដៃ, ម្នាក់មានដាវចាស់គំរិល; ដើមចេកកាលបើត្រូវកាត់ដោយដាវដែលមុតក្លា រមែងមិនបានឮសំឡេង, តែកាលត្រូវកាត់ដោយដាវដែលចាស់គំរិល រមែងបញ្ចេញសំឡេងឮថា "កដៈ កដៈ" ដូច្នេះយ៉ាងណា, ក្នុងសេចក្ដីនោះ បណ្ឌិតគប្បីជ្រាបពាក្យឧបមេយ្យដូច្នេះថា ៖

ការដែលវិបស្សនាញាណនៃមគ្គ ៣ របស់ទិដ្ឋិប្បត្តបុគ្គលជាគុណជាតមុតក្លា ក្លៀវក្លា និងស្រស់ថ្លាវិសេសហើយ គប្បីជ្រាបថា ដូចនឹងការកាត់ដើមចេក ដែលមិនបានឮសំឡេងដោយដាវដ៏មុតដូច្នោះ និងសេចក្ដីដែលវិបស្សនាញាណនៃមគ្គទាំង ៣ របស់សទ្ធាវិមុត្តបុគ្គល ជាគុណជាតមិនមុតក្លា មិនក្លៀវក្លា និងមិនស្រស់ថ្លាវិសេសឡើយ គប្បីជ្រាបថា ដូចនឹងការយកដាវដែលចាស់គំរិលកាត់ដើមចេក មានសំឡេងកើតឡើងដូច្នោះ ។ ក៏លោកអាចារ្យហាមន័យនេះថា "**នោ**" ដូច្នេះ ហើយលោកធ្វើការសន្និដ្ឋានថា សទ្ធាវិមុត្តបុគ្គលមិនដល់ទិដ្ឋិប្បត្តបុគ្គលទេ ព្រោះញាណដែលលោកគប្បី

សម្រេចប្លែកផ្សេងគ្នានោះឯង, ក៏លោកបានពោលទុកក្នុងគម្ពីរអដ្ឋកថាដែលមានមកហើយ ។

ពិតមែន ក្នុងលោកទាំងពីរពួកនោះ ការអស់កិលេសរបស់សទ្ធាវិមុត្តបុគ្គល រមែងមានក្នុងខណៈនៃមគ្គដែលជាបុព្វភាគចំណែកខាងដើម ដូចបុគ្គលអ្នកកំពុងជឿហើយស្ទង់មើល នឹងបង្អោនចិត្តជឿ ។ ញាណជាគ្រឿងកាត់កិលេសរបស់ទិដ្ឋិប្បត្តបុគ្គល រមែងមានក្នុងខណៈនៃមគ្គដែលជាចំណែកខាងដើម មិនយឺត ជារបស់មុតប្រព្រឹត្តទៅ ។ ព្រោះហេតុដូច្នោះ ទើបលោកឧបមាថា ប្រៀបដូចយកដាវដែលមិនមុត កាត់ដើមចេក កន្លែងដែលត្រូវកាត់នោះ រមែងមិនរាបស្មើ ដាវរមែងមិនឆ្លងកាត់ទៅដោយលឿនរហ័ស ទើបធ្វើឲ្យបានឮសំឡេង គឺត្រូវប្រើសេចក្ដីព្យាយាមខ្លាំងយ៉ាងណា, មគ្គភាវនាដែលជាចំណែកខាងដើមរបស់សទ្ធាវិមុត្តបុគ្គលបែបនេះ ក៏ដូច្នោះដែរ ។ ញាណ គឺបញ្ញារបស់ទិដ្ឋិប្បត្តបុគ្គលនោះ ប្រៀបដូចបុគ្គលកាលយកដាវដែលមុតកាត់ដើមចេក កន្លែងដែលត្រូវកាត់រមែងរាបស្មើ ដាវឆ្លងកាត់ទៅបានលឿនរហ័ស ធ្វើឲ្យមិនបានឮសំឡេង, គេមិនត្រូវប្រើសេចក្ដីព្យាយាមខ្លាំង យ៉ាងណា, គប្បីជ្រាបថា មគ្គភាវនាដែលជាចំណែកខាងដើមរបស់ទិដ្ឋិប្បត្តបុគ្គលអ្នកមានសភាពបែបនេះ ក៏ដូច្នោះដែរ ។

ពាក្យថា **“អយំ វុច្ចតិ”** សេចក្ដីថា បុគ្គលនេះ គឺអ្នកបែបនេះ លោក

*ហៅថា* **“សទ្ធាវិមុត្តោ”** *។ ពិតមែន សទ្ធាវិមុត្តបុគ្គលនេះ កំពុងជឿ ឈ្មោះថា បានរួចផុតហើយ ព្រោះហេតុនោះ ទើបឈ្មោះថា* **សទ្ធា-វិមុត្តោ** *។ ក៏សទ្ធាវិមុត្តបុគ្គលនេះ មាន ៦ ជំពូក ដូចនឹងកាយសក្ខី-បុគ្គលដែរ ៕*

ចប់សទ្ធាវិមុត្តបុគ្គល

---

## ពណ៌នាអំពីធម្មានុសារីបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ* ***ធម្មានុសារីបុគ្គល*** *៖*

*ព្រះមានព្រះភាគ ទ្រង់សម្ដែងព្រះអរិយបុគ្គលអ្នកតាំងនៅក្នុង* **សោតាបត្តិមគ្គ** *ដោយបទថា* **“បដិបន្នស្ស”** *នេះ ។ បទថា* **“អធិមត្តំ”** *បានដល់ មានកម្លាំង ។ អ្នកឯណា រមែងនាំមកនូវបញ្ញា ព្រោះហេតុនោះ អ្នកនោះ ទើបឈ្មោះថា* **បញ្ញាវាហី** *= អ្នកមានប្រក្រតីនាំមកនូវបញ្ញា, អធិប្បាយថា បញ្ញារមែងនាំបុគ្គលនេះទៅ ។ លោកហៅថា* **“បញ្ញាវាហី”** *ដូច្នេះ ក៏មានខ្លះ ។ ពាក្យថា* **“បញ្ញាបុព្វង្គមំ”** *បានដល់ ឃើញបញ្ញាជាបុរេចារិក គឺធ្វើបញ្ញាឲ្យជាប្រធាន ។*

*ពាក្យថា* **“អយំ វុច្ចតិ”** *សេចក្ដីថា បុគ្គលនេះ គឺអ្នកបែបនេះ លោក*

ហៅថា ***ធម្មានុសារី*** ។ ក៏បុគ្គលឯណារមែងឮ គឺរមែងតាមឮដោយធម៌ ពោលគឺបញ្ញា ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា ***ធម្មានុសារី*** ។ ពាក្យថា **“ធម្មានុសារី”** នេះ ជាឈ្មោះនៃបុគ្គលអ្នកតាំងនៅក្នុងសោតាបត្តិមគ្គ, តែកាលលោកសម្រេចផល ឈ្មោះថា ***ទិដ្ឋិប្បត្តបុគ្គល*** ៕

ចប់ធម្មានុសារីបុគ្គល

---

## ពណ៌នាអំពីសទ្ធានុសារីបុគ្គល

វិនិច្ឆ័យក្នុងនិទ្ទេសនៃ ***សទ្ធានុសារីបុគ្គល*** ៖

អ្នកណារមែងនាំមកនូវសទ្ធា ព្រោះហេតុនោះ អ្នកនោះ ទើបឈ្មោះថា **“សទ្ធាវាហី** = អ្នកនាំមកនូវសទ្ធា”, អធិប្បាយថា សទ្ធានាំបុគ្គលនេះមក ។ លោកពោលថា **“សទ្ធាវាហី”** ដូច្នេះខ្លះ ក៏មានដែរ ។ បទថា **“សទ្ធាបុព្វង្គមំ”** បានដល់ ធ្វើសទ្ធាឲ្យជាបុរេចារិក គឺឲ្យជាប្រធាន ។

ពីរបទថា **“អយំ វុច្ចតិ”** សេចក្ដីថា បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា ***សទ្ធានុសារី*** ។ បុគ្គលឯណារមែងឮ គឺរមែងតាមឮដោយសទ្ធា ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា ***សទ្ធានុសារី*** ។ ពាក្យថា **“សទ្ធានុសារី”** នេះ ជាឈ្មោះរបស់សោតាបត្តិមគ្គ ។ តែកាលលោក

សម្រេចផលចិត្តហើយ ឈ្មោះថា ***សទ្ធាវិមុត្ត*** ។ ក៏ឈ្មោះថា ***ធុរៈ*** មាន ២ យ៉ាង, ឈ្មោះថា ***អភិនិវេស*** មាន ២ យ៉ាង និងឈ្មោះថា ***សីសៈ*** មាន ២ យ៉ាង របស់លោកអ្នកដែលញ៉ាំងលោកុត្តរធម៌ឲ្យកើតឡើង ។

បណ្ដាធុរៈជាដើមនេះ ឈ្មោះថា ធុរៈមាន ២ យ៉ាង គឺ ***សទ្ធាធុរៈ*** និង ***បញ្ញាធុរៈ*** ។

ឈ្មោះថា ***អភិនិវេស*** គឺការអាស្រ័យមាន ២ យ៉ាង គឺភិក្ខុមួយរូប រមែងនៅដោយអំណាចនៃការអាស្រ័យ ***សមថៈ*** (សមថាភិនិវេស) មួយរូបទៀត រមែងនៅដោយអំណាចនៃការអាស្រ័យ ***វិបស្សនា*** (វិបស្សនា-ភិនិវេស) និងឈ្មោះថា ***សីសៈ*** គឺទីបំផុតនេះ ក៏មាន ២ យ៉ាង គឺភិក្ខុមួយរូបសម្រេចធម៌ដល់ទីបំផុតហើយ ឈ្មោះថា ***ឧភតោភាគវិមុត្ត***, ភិក្ខុមួយរូបទៀត សម្រេចធម៌ដល់ទីបំផុតហើយ មានឈ្មោះថា ***បញ្ញាវិមុត្ត*** ។ អធិប្បាយថា ភិក្ខុពួកណាមួយ រមែងញ៉ាំងលោកុត្តរធម៌ឲ្យកើតឡើង, លោកទាំងនោះរមែងធ្វើធម៌ ២ យ៉ាងនេះ គឺ **សទ្ធា** និង **បញ្ញា** ឲ្យជាធុរៈ អាស្រ័យឋានទាំងពីរនេះ គឺ ***សមថាភិនិវេស*** និង ***វិបស្សនាភិនិវេស*** និងរមែងរួចផុតដោយ ***សីសៈ*** ទាំងពីរពួកនេះ គឺ ***ឧភតោភាគវិមុត្តសីសៈ*** និង ***បញ្ញាវិមុត្តសីសៈ*** ។

បណ្ដាលោកទាំងនោះ ភិក្ខុរូបណាបានសមាបត្តិ ៨ ធ្វើបញ្ញាឲ្យជាធុរៈ អាស្រ័យអំណាចសមថៈ ធ្វើអរូបសមាបត្តិយ៉ាងណាមួយឲ្យជាបទដ្ឋាន ហើយ

ផ្តើមតាំងវិបស្សនា សម្រេចព្រះអរហត្ត ភិក្ខុរូបនោះក្នុងខណៈនៃសោតាបត្តិមគ្គ ឈ្មោះថា ***ធម្មានុសារី,*** តែក្នុងឋាន ៦ ខាងមុខ គឺតាំងអំពីសោតាបត្តិផល ដល់អរហត្តមគ្គ ឈ្មោះថា ***កាយសក្ខី*** ។ កាលសម្រេចព្រះអរហត្តផលហើយ ឈ្មោះថា ***ឧភតោភាគវិមុត្ត*** ។

មួយរូបទៀត ធ្វើបញ្ញាតែម្យ៉ាងប៉ុណ្ណោះ ឲ្យជាធុរៈ អាស្រ័យអំណាចនៃវិបស្សនា ពិចារណាសុទ្ធសង្ខារ ឬរូបាវចរជ្ឈានយ៉ាងណាមួយ សម្រេចព្រះអរហត្ត ។ សូម្បីភិក្ខុនេះ ក្នុងខណៈនៃសោតាបត្តិមគ្គ ឈ្មោះថា ***ធម្មានុសារី,*** តែក្នុងឋាន ៦ ខាងមុខ គឺតាំងអំពីសោតាបត្តិផល ដល់អរហត្តមគ្គ ឈ្មោះថា ***ទិដ្ឋិប្បត្តៈ*** ។ កាលសម្រេចព្រះអរហត្តផល ឈ្មោះថា ***បញ្ញាវិមុត្ត*** ។ ***ឈ្មោះ ២ យ៉ាង*** គឺ ***បញ្ញាវិមុត្ត*** និង ***ទិដ្ឋិប្បត្តៈ*** មិនធ្លាប់មានក្នុងទីនេះ នឹងរួមជាមួយឈ្មោះមុន ៗ ៣ ទៀត គឺ ***ធម្មានុសារី កាយសក្ខី*** និង ***ឧភតោភាគវិមុត្ត*** ទើបត្រូវជា ៥ ឈ្មោះដូចគ្នា ។

មួយរូបទៀត លោកមានសមាបត្តិ ៨ ធ្វើសទ្ធាឲ្យជាធុរៈ អាស្រ័យអំណាចសមថៈ ធ្វើអរូបសមាបត្តិយ៉ាងណាមួយឲ្យជាបទដ្ឋាន ផ្តើមតាំងវិបស្សនា សម្រេចព្រះអរហត្ត ។ ភិក្ខុនេះ ក្នុងខណៈនៃសោតាបត្តិមគ្គ ឈ្មោះថា ***សទ្ធានុសារី,*** តែក្នុងឋាន ៦ ខាងមុខ ឈ្មោះថា ***កាយសក្ខី*** មែនពិត ។ កាលសម្រេចព្រះអរហត្តផលហើយ ឈ្មោះថា ***ឧភតោភាគវិមុត្ត***

*តែម្យ៉ាង ។ ឈ្មោះម្យ៉ាងប៉ុណ្ណោះ គឺ* ***សទ្ធានុសារី*** *មិនធ្លាប់មានមកក្នុងទីនេះ រួមនឹងឈ្មោះ ៥ ខាងដើម ក៏ជា ៦ ឈ្មោះដូចគ្នា ។*

*ភិក្ខុមួយរូបទៀត ធ្វើសទ្ធានុសារីនេះឯង ឲ្យជាធុរៈ អាស្រ័យអំណាចនៃវិបស្សនា ពិចារណាសង្ខារសុទ្ធ ឬរូបាវចរជ្ឈានយ៉ាងណាមួយ ហើយសម្រេចអរហត្ត, សូម្បីភិក្ខុនេះ ក្នុងខណៈនៃសោតាបត្តិផល រហូតដល់អរហត្តមគ្គ ឈ្មោះថា* ***សទ្ធានុសារី;*** *ក្នុងឋាន ៦ ខាងមុខ គឺតាំងអំពីសោតាបត្តិផល ដល់អរហត្តមគ្គ ឈ្មោះថា* ***សទ្ធាវិមុត្ត,*** *កាលលោកសម្រេចអរហត្តផលហើយ ទើបឈ្មោះថា* ***បញ្ញាវិមុត្ត*** *។ ឈ្មោះម្យ៉ាងប៉ុណ្ណោះ គឺ* ***សទ្ធាវិមុត្ត*** *មិនធ្លាប់មានមកក្នុងទីនេះ ហើយរួមនឹងឈ្មោះ ៦ ខាងដើម ក៏ត្រូវជា ៧ ឈ្មោះដូចគ្នា ។*

*ព្រះអរិយបុគ្គលទាំង ៧ ជំពូកនេះ ឈ្មោះថា* ***ជាទក្ខិណេយ្យបុគ្គល*** *ដ៏ប្រសើរក្នុងលោក ៕*

ចប់សទ្ធានុសារីបុគ្គល

## ពណ៌នាអំពីសត្តក្ខត្តុំបរមបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ* ***សត្តក្ខត្តុំបរមបុគ្គល*** *៖*

*ពាក្យថា* **“សត្តក្ខត្តុំ”** *បានដល់ អស់ ៧ ដង ។ ការកើតឡើងក្នុងភព ពោលគឺការកាន់យកនូវអត្តភាពមាន ៧ ជាតិ ជាយ៉ាងក្រៃលែងរបស់បុគ្គលនោះ ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា* **សត្តក្ខត្តុំបរមោ** *= អ្នកមាន ៧ ជាតិជាយ៉ាងក្រៃលែង ព្រោះលោកមិនកាន់យកភពទី ៨ អំពីភពទី ៧ នោះទេ, អរិយមគ្គ ឈ្មោះថា* **“សោតោ** *= ក្រសែ”* *ក្នុងពាក្យថា* **“សោតាបន្នោ ហោតិ”** *នេះ បុគ្គលអ្នកប្រកបដោយមគ្គដែលឈ្មោះថា* **សោតោ** *នោះ ឈ្មោះថា* ***សោតាបន្ន*** *។ ដូចយ៉ាងពាក្យដែលព្រះអង្គត្រាស់ទុកថា “ក៏សារីបុត្ត តថាគតពោលពាក្យថា* **‘សោតោ សោតោ’** *ដូច្នេះនេះ សារីបុត្ត* **សោតោ** *ជាយ៉ាងណា ?” ព្រះសារីបុត្តក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន មគ្គមានអង្គ ៨ ដែលជាអរិយៈនេះ គឺសម្មាទិដ្ឋិ ។ ល ។ សម្មាសមាធិប៉ុណ្ណោះ ឈ្មោះថា* **សោតោ”** *។ ព្រះអង្គត្រាស់សួរថា “សារីបុត្ត តថាគតហៅថា សោតាបន្ន, សារីបុត្ត សោតាបន្ននោះ ជាយ៉ាងណា ?” ។*

*ព្រះសារីបុត្តក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលឯណា*

*ប្រកបដោយមគ្គមានអង្គ ៨ ដែលជាអរិយៈនេះ បុគ្គលនោះឯង ឈ្មោះថា **ព្រះសោតាបន្ន**, សូម្បីក្នុងខណៈនៃមគ្គយ៉ាងនេះថា លោកអ្នកមានអាយុ មានឈ្មោះយ៉ាងនេះ ឬមានគោត្រយ៉ាងនេះ ក៏ឈ្មោះរបស់ផលដែលមគ្គឲ្យហើយ ព្រោះហេតុនោះ ព្រះសោតាបន្ន ទើបព្រះអង្គទ្រង់បំណាងយកក្នុងខណៈនៃផល ” ។*

*បទថា* **“ អវិនិបាតធម្មោ ”** *បានដល់ ភាវៈ គឺការមិនទៅកាន់អបាយ ពោលគឺវិនិបាតដោយអំណាចនៃការកើតឡើង ។ បទថា* **“ និយតោ ”** *បានដល់ ឈ្មោះថា **និយតៈ** គឺទៀងដោយនិយាមនៃមគ្គ ។ បទថា* **“ សម្ពោធិ-បរាយនោ ”** *បានដល់ ភាពជាអ្នកមានការត្រាស់ដឹង ដែលនឹងប្រព្រឹត្តទៅក្នុងខាងមុខ ។ មែនពិត ព្រះសោតាបន្ននោះ រមែងត្រាស់ដឹងដោយមគ្គដែលខ្លួនបានចំពោះហើយ ព្រោះហេតុដូច្នោះ លោកទើបឈ្មោះថា* **សម្ពោធិ-បរាយនោ** *។ ម្យ៉ាងទៀត ព្រះសោតាបន្ននោះ នឹងត្រាស់ដឹងដោយមគ្គខាងលើទាំង ៣ ដោយពិត ព្រោះហេតុនោះ លោកទើបឈ្មោះថា* **សម្ពោធិ-បរាយនោ** *។*

*ពីរបទថា* **“ ទេវេ ច មនុស្សេ ច ”** *បានដល់ ទេវលោក និងមនុស្ស-លោក ។ ពីរបទថា* **“ សន្ធាវិត្វា សំសរិត្វា ”** *បានដល់ ការទៅវិញទៅមក*

*ដោយអំណាចនៃបដិសន្ធិ ។ ពីរបទថា* **“ទុក្ខស្សន្តំ ករោតិ”** *បានដល់ ការធ្វើផ្លូវដែលជាទីបំផុតនៃវដ្តទុក្ខ ។*

*ពីរបទថា* **“អយំ វុច្ចតិ”** *សេចក្តីថា បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅឈ្មោះថា* **សត្តក្ខត្តុបរមោ** *= អ្នកមាន ៧ ជាតិជាយ៉ាងក្រៃលែង ។ ក៏* ***សត្តក្ខត្តុបរមបុគ្គល*** *នេះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ហើយ ដោយភពដែលលាយឡំគ្នា ដោយអំណាចនៃទេវលោក និងមនុស្សលោក តាមកាលដែលសមគួរ ៕*

ចប់សត្តក្ខត្តុំបរមបុគ្គល

---

## ពណ៌នាអំពីកោលំកោលបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ* ***កោលំកោលបុគ្គល*** *៖*

*បុគ្គលឯណា រមែងចេញអំពីត្រកូលទៅកាន់ត្រកូល ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា* ***កោលំកោលៈ*** *។ អធិប្បាយថា ក៏ឈ្មោះថា ការកើតក្នុងត្រកូលទាប ចាប់ផ្តើមអំពីការធ្វើឲ្យច្បាស់នូវសោតាបត្តិផលទៅ រមែងមិនមាន, លោករមែងកើតក្នុងត្រកូលដែលមានភោគៈច្រើនតែម្យ៉ាង ។*

*ពាក្យថា* **“ទ្វេ វា តីណិ វា កុលានិ”** *បានដល់ ទៅកាន់ភព ២ ឬភព ៣ ដោយអំណាចនៃការកើតជាទេវតា និងមនុស្ស ។*

*សូម្បី* ***កោលំកោលបុគ្គល*** *នេះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ហើយ ដោយអំណាចនៃមិស្សកភព គឺភពដែលលាយឡំគ្នានុ៎ះឯង ។ ក៏ក្នុងពាក្យថា* **“ទ្វេ វា តីណិ វា”** *ត្រឹមតែជាទេសនាប៉ុណ្ណោះ ។* ***កោលំកោល-បុគ្គល*** *នោះឯង រមែងត្រាច់ទៅរហូតដល់ភពទី ៦ ទើបធ្វើផ្លូវ គឺមគ្គដែលជាទីអស់ទៅនៃវដ្តទុក្ខបាន ៕*

ចប់កោលំកោលបុគ្គល

---

## ពណ៌នាអំពីឯកពីជីបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ* ***ឯកពីជីបុគ្គល*** *៖*

*ឈ្មោះថា ពូជ គឺ* ***ខន្ធ*** *ដែលព្រះភគវាត្រាស់ហើយ ក៏ព្រះសោតាបន្នអង្គឯណាមានពូជ គឺខន្ធមួយដងប៉ុណ្ណោះ គឺមានការកាន់យកអត្តភាពមួយដង ព្រះសោតាបន្ននោះ ឈ្មោះថា* ***ឯកពីជី*** *។ ក៏ពាក្យថា* **“មានុស្សកំភវំ”** *នេះ ត្រឹមតែជាទេសនាក្នុងទីនេះប៉ុណ្ណោះ ។ តែនឹងពោលថា “ញុំាំងទេវភពឲ្យកើត” ដូច្នេះខ្លះ ក៏សមគួរដូចគ្នា ។ ក៏ឈ្មោះទាំងនេះ ជាឈ្មោះនៃព្រះអរិយៈទាំងនោះ ដោយអំណាចនៃឈ្មោះដែលព្រះមានព្រះភាគទ្រង់កាន់យកហើយនុ៎ះឯង ។ ពិតមែន ព្រះសោតាបន្នអ្នកទៅដល់ទីមាន*

ប្រមាណប៉ុណ្ណោះ ឈ្មោះថា ***សត្តក្ខត្តុបរមបុគ្គល,*** អ្នកទៅដល់ទីមានប្រមាណប៉ុណ្ណោះ ឈ្មោះថា ***កោលំកោលបុគ្គល,*** អ្នកទៅដល់ទីមានប្រមាណប៉ុណ្ណោះ ឈ្មោះថា ***ឯកពីជីបុគ្គល*** ព្រោះហេតុដូច្នោះ ឈ្មោះព្រះសោតាបន្នទាំងនោះ ទើបព្រះមានព្រះភាគទ្រង់កាន់យកហើយ ។ តែថាដោយកំណត់ជាក់លាក់ (ដោយនិយម) ពាក្យថា ព្រះសោតាបន្នរូបនេះ ជា ***សត្តក្ខត្តុបរម:*** ជា ***កោលំកោល:*** រូបនេះ ជា ***ឯកពីជី*** រមែងមិនមានទេ ។

***សួរថា*** ក៏នរណា កំណត់ប្រភេទ ព្រះអរិយបុគ្គលទាំងនោះបាន ?

ឆ្លើយថា ព្រះថេរៈពួកខ្លះ ពោលទុកមុនថា **“បុព្វហេតុ និយមេតិ** = បុព្វហេតុរមែងកំណត់យ៉ាងពិតប្រាកដ” ។ ពួកខ្លះពោលថា **“បឋមមគ្គោ និយមេតិ** = មគ្គទីមួយកំណត់យ៉ាងពិតប្រាកដ” ។ ពួកខ្លះ ពោលថា **“ឧបរិ តយោ មគ្គា និយមេន្តិ** = មគ្គខាងលើ ៣ កំណត់យ៉ាងពិតប្រាកដ” ។ ពួកខ្លះពោលថា **“តិណ្ណំ មគ្គានំ វិបស្សនា និយមេតិ** = វិបស្សនានៃមគ្គទាំង ៣ កំណត់យ៉ាងពិតប្រាកដ” ។

បណ្តាវាទៈនៃព្រះថេរៈទាំងនោះ វាទៈថា **“បុព្វហេតុ និយមេតិ”** រមែងសំដៅសេចក្តីថា ឧបនិស្ស័យនៃបឋមមគ្គ រមែងជាគុណជាតិដែលបុព្វហេតុធ្វើហើយ មគ្គខាងលើ ៣ ប្រាសចាកឧបនិស្ស័យកើតឡើង ក្នុង

*វាទៈថា* **"បឋមមគ្គោ និយមេតិ"** *សំដៅសេចក្ដីថា មគ្គ ៣ ជាធម្មជាតិគ្មានប្រយោជន៍ ។ ក្នុងវាទៈថា* **"ឧបរិ តយោ មគ្គា និយមេន្តិ"** *សំដៅសេចក្ដីថា កាលបឋមមគ្គនៅមិនកើតឡើងនោះឯង មគ្គខាងលើ ៣ កើតឡើងហើយ ។ ក៏វាទៈថា* **"តិណ្ណំ មគ្គានំ វិបស្សនា និយមេតិ"** *ដែលប្រែថា វិបស្សនានៃមគ្គទាំង ៣ កំណត់យ៉ាងពិតប្រាកដ រមែងត្រឹមត្រូវ ។ បើវិបស្សនានៃមគ្គទាំង ៣ មានកម្លាំង ព្រះសោតាបន្នក៏ឈ្មោះថា* ***ឯកពីជី*** *។ បើអន់ជាងវិបស្សនារបស់ឯកពីជី ក៏ឈ្មោះថា* ***កោលំកោលៈ,*** *បើអន់ជាងវិបស្សនារបស់កោលំកោលៈនោះ ក៏ឈ្មោះថា* ***សត្តក្ខត្តុបរមៈ*** *ដោយប្រការដូច្នេះ ។*

*មួយទៀត ព្រះសោតាបន្នអង្គខ្លះ មានអធ្យាស្រ័យក្នុងវដ្ដៈ ជាអ្នកត្រេកអរក្នុងវដ្ដៈ រមែងត្រាច់ទៅក្នុងវដ្ដៈជារឿយៗ នោះឯង ប្រាកដហើយ; ក៏ជនទាំងនោះ មានប្រមាណប៉ុណ្ណេះ គឺ*

**១-អនាថបណ្ឌិកសេដ្ឋី**

**២-ឧបាសិកា វិសាខា**

**៣-ចូឡរថទេវបុត្រ**

**៤-មហារថទេវបុត្រ**

**៥-អនេកវណ្ណទេវបុត្រ**

**៦-ស្តេចសក្កទេវរាជ**

**៧-នាគទត្តទេវបុត្រ ។**

ទាំងអស់នេះ មានអធ្យាស្រ័យក្នុងវដ្តៈ កើតក្នុងទេវលោក ៦ ជាន់ តាំងអំពីដើម ជម្រះចិត្តឲ្យស្អាតក្នុងទេវលោកនោះឯង ហើយតាំងនៅក្នុងអកនិដ្ឋភព ទើបបរិនិព្វាន, ជនទាំងនោះ ព្រះអង្គទ្រង់មិនបានកាន់យកក្នុងទីនេះឡើយ, ក៏ជនទាំងនោះ ព្រះអង្គទ្រង់មិនបានកាន់យកប៉ុណ្ណេះ ក៏ទេ, ព្រះសោតាបន្នអង្គណាកើតក្នុងមនុស្សលោក ត្រាច់ទៅក្នុងមនុស្សលោកនោះឯង អស់ ៧ ជង ហើយទើបសម្រេចព្រះអរហត្តក្តី ព្រះសោតាបន្នអង្គណា កើតក្នុងទេវលោកទាំងឡាយ ត្រាច់ទៅមកៗ ក្នុងទេវលោកនោះឯង អស់ ៧ ជង ហើយសម្រេចព្រះអរហត្តក្តី សូម្បីព្រះសោតាបន្នទាំងនេះ ព្រះមានព្រះភាគ ក៏មិនបានទ្រង់កាន់យកដែរ ។

តែគប្បីជ្រាបថា ក្នុងទីនេះ ព្រះអង្គទ្រង់កាន់យកព្រះសោតាបន្ន ដែលឈ្មោះថា ***សត្តក្ខត្តុបរមៈ*** និង ***កោលំកោលៈ*** ដោយអំណាចនៃភពដែលលាយគ្នា និងព្រះសោតាបន្នអ្នកកើតក្នុងភពរបស់មនុស្សប៉ុណ្ណោះ ឈ្មោះថា ***ឯកពីជី*** ។

បណ្តាព្រះសោតាបន្នទាំងនោះ អង្គមួយៗ រមែងដល់ភាវៈ ៤ យ៉ាង ដោយអំណាចនៃទុក្ខាបដិបទាជាដើម ។ ពោលដោយសទ្ធាធុរៈ ព្រះសោតា-

*បន្ន មាន ១២ ជំពូក គឺឈ្មោះថា* ***សត្តក្ខត្តុបរមៈ*** *មាន ៤ ជំពូក, ឈ្មោះថា* ***កោលំកោលៈ*** *មាន ៤ ជំពូក, ឈ្មោះថា* ***ឯកពីជី*** *មាន ៤ ជំពូក ។ ពោលដោយបញ្ញាធុរៈ បើព្រះសោតាបន្ន អាចញ៉ាំងលោកុត្តរធម៌ឲ្យកើតដោយបញ្ញា ធ្វើបញ្ញាឲ្យជាធុរៈយ៉ាងនេះថា "យើងនឹងឲ្យលោកុត្តរធម៌កើតឡើង" សូម្បីបានសម្រេចជាព្រះសោតាបន្ន អ្នកនេះ ឈ្មោះថា* ***សត្តក្ខត្តុ-បរមៈ*** *ជាដើម ដោយអំណាចនៃបដិបទា ៤ យ៉ាង ក៏ព្រោះសោតាបន្ន ១២ ជំពូក ដូចគ្នានោះឯង ព្រោះហេតុដូច្នោះ ព្រះសោតាបន្នទាំង ២៤ ជំពូកនេះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ទុកហើយក្នុងឋាននេះ ដោយអំណាចនៃព្រះអរិយៈ អ្នកចូលទៅសម្ងឹងធម៌ដែលតាំងនៅដោយសទ្ធា ឬបញ្ញាក្នុងទីនេះដែរ ៕*

ចប់ឯកពីជីបុគ្គល

---

## ពណ៌នាអំពីសកទាគាមីបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ* ***សកទាគាមីបុគ្គល*** *៖*

*បុគ្គលឯណា រមែងមកម្ដងទៀត ដោយអំណាចនៃបដិសន្ធិ ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា* **សកទាគាមី** *= អ្នកមកបដិសន្ធិម្ដងទៀត ។*

បទថា **“សកិទេវ”** បានដល់ ម្ដងប៉ុណ្ណោះ ។ បណ្ដាព្រះសកទាគាមី ៥ ជំពូក និង ៨ ជំពូក ព្រះអង្គទ្រង់មិនបំណងយកទេ, តែទ្រង់បំណងយកត្រឹមតែមួយពួកប៉ុណ្ណោះក្នុងទីនេះ ដោយបទថា **“ឥមំ លោកំ អាគន្ត្វា”** ព្រោះថា ព្រះសកទាគាមីពួកខ្លះ សម្រេចសកទាគាមិផលក្នុងលោកនេះ រមែងបរិនិព្វានក្នុងលោកនេះតែម្ដង, ពួកខ្លះ សម្រេចសកទាគាមិផលក្នុងលោកនេះ បរិនិព្វានក្នុងទេវលោក, ពួកខ្លះ សម្រេចក្នុងទេវលោក បរិនិព្វានក្នុងទេវលោកនុ៎ះឯង, ពួកខ្លះ សម្រេចក្នុងទេវលោក ហើយកើតឡើងក្នុងលោកនេះ ទើបបរិនិព្វាន, រួមព្រះសកទាគាមីទាំង ៤ ជំពូក ដូចពោលមកនេះ ព្រះអង្គទ្រង់មិនបានប្រាថ្នាយកក្នុងសទាគាមីនិទ្ទេសនេះឡើយ ។

តែព្រះសកទាគាមីពួកណា សម្រេចក្នុងលោកនេះ ហើយតាំងជីវិតនៅក្នុងទេវលោក រហូតអស់អាយុ កើតឡើងក្នុងលោកនេះទៀត ទើបបរិនិព្វាន ព្រះសកទាគាមីមួយពួកនេះប៉ុណ្ណោះ គប្បីជ្រាបថា ព្រះអង្គទ្រង់កាន់យកក្នុងសកទាគាមីនិទ្ទេសនេះ ។

ពាក្យឯណាដែលនៅសល់ក្នុងទីនេះ ដែលខ្ញុំមិនបានពោលទេ, ពាក្យទាំងអស់នោះ ខ្ញុំបានពោលហើយក្នុងលោកុត្តរកុសលនិទ្ទេស ក្នុងអដ្ឋកថានៃធម្មសង្គហៈខាងក្រោយ ។

***សួរថា*** ក៏ព្រះសកទាគាមីនេះ មានការធ្វើដែលប្លែកផ្សេងគ្នាពីព្រះ

*សោតាបន្ន ដែលឈ្មោះថា **ឯកពីជី** យ៉ាងណាខ្លះ ?*

*ឆ្លើយថា ព្រះសោតាបន្នដែលឈ្មោះថា ឯកពីជី លោកមានបដិសន្ធិតែម្តងប៉ុណ្ណោះ, ចំណែកព្រះសកទាគាមី លោកមានបដិសន្ធិ ២ ដង សេចក្តីនេះ ជាការធ្វើប្លែកផ្សេងពីគ្នា រវាងព្រះអរិយៈទាំងពីរពួកនោះ ។*

ចប់សកទាគាមីបុគ្គល

---

## ពណ៌នាអំពីអនាគាមីបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃ **អនាគាមីបុគ្គល** ៖*

*កាមធាតុ ព្រះមានព្រះភាគត្រាស់ហៅថា* **ឱរំ** *= ទាប ក្នុងពាក្យថា* **“ឱរម្ភាគិយានំ សញ្ញោជនានំ”** *គ្រឿងចងទាំង ៥ នេះ ដែលបុគ្គលណានៅលះមិនទាន់បានហើយ ព្រោះហេតុនោះ បុគ្គលនោះ សូម្បីកើតក្នុងភវគ្គភូមិ ក៏ត្រូវតែគ្រឿងចងទាំងនោះ ទាញឲ្យធ្លាក់ទៅក្នុងកាមធាតុនោះតែម្តង ដូចត្រីដែលលេបផ្លែសន្ទូច និងដូចក្អែកដែលគេយកខ្សែវ័ងចងជើងទុក ព្រោះហេតុដូច្នោះ គ្រឿងចងទាំង ៥ លោកទើបហៅថា* ***ឱរម្ភាគិយៈ*** *អធិប្បាយថា ឱរម្ភាគិយៈនេះ ជារបស់ខាងក្រោម គឺជាចំណែកខាងក្រោម ។*

*បទថា* **“បរិក្ខយា”** *បានដល់ ព្រោះការអស់ទៅដោយជុំវិញនៃគ្រឿង*

*បង់ទាំងនោះ ។*

*បទថា* **"ឱបបាតិកោ"** *បានដល់ អ្នកមានកំណើតជា* ***ឱបបាតិកៈ*** *។ សំដៅសេចក្តីថា ការដេកក្នុងគភ៌របស់ព្រះអនាគាមីនោះ លោកផុតចេញហើយ ដោយបទថា* **"ឱបបាតិកោ"** *នេះ ។*

*ពាក្យថា* **"តត្ថ បរិនិព្វាយី"** *បានដល់ ព្រះអនាគាមីដែលបរិនិព្វាន ក្នុងសុទ្ធាវាសទេវលោកនោះ ។*

*ពាក្យថា* **"អនាវត្តិធម្មោ តស្មា លោកា"** *សេចក្តីថា បានដល់ ការមិនមកអំពីព្រហ្មលោក ហើយត្រឡប់មកកាន់កាមលោកនេះ ដោយអំណាចនៃបដិសន្ធិជាសភាវៈ ។ ក៏ការមករបស់ព្រះអនាគាមីនោះ ដើម្បីប្រយោជន៍ដល់ការឃើញព្រះពុទ្ធជាម្ចាស់ ព្រះថេរៈ និងស្តាប់ព្រះសទ្ធម្ម ដែលតាមធម្មតាមិនបានហាមទុកឡើយ ។*

*ពាក្យថា* **"អយំ វុច្ចតិ"** *សេចក្តីថា បុគ្គលនេះ គឺត្រឡប់មកទៀត ដោយអំណាចនៃបដិសន្ធិ ។*

ចប់អនាគាមីបុគ្គល

---

## ពណ៌នាអំពីអន្តរាបរិនិព្វាយីបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃព្រះអនាគាមីឈ្មោះថា* ***អន្តរាបរិនិព្វាយីបុគ្គល*** *៖*

*ពាក្យថា* **“ឧប្បន្នំ វា សមនន្តរា”** *សេចក្តីថា ជាកាលជាប់គ្នា និង កាលកើតឡើងខ្លះ ។ ពាក្យថា* **“អប្បត្តំ វា វេមជ្ឈំ អាយុប្បមាណំ”** *សេចក្តីថា នៅមិនដល់ប្រមាណពាក់កណ្តាលអាយុខ្លះ អធិប្បាយថា នៅមិនដល់ពាក់កណ្តាលអាយុ លោករមែងញ៉ាំងអរិយមគ្គឲ្យកើតឡើង ហើយបរិនិព្វាន ។ ក៏សេចក្តីថា* **“វេមជ្ឈំ បត្តំ** *= ដល់ផ្លូវកណ្តាលខ្លះ”* *បណ្ឌិតគប្បីជ្រាបដោយការកំណត់នូវសព្ទថា* ***វា*** *។ ព្រះអនាគាមីអន្តរាបរិនិព្វាយី ៣ ជំពូកដែលសម្រេចហើយ ដោយប្រការដូច្នេះ ។ ពាក្យថា* **“ឧបរិដ្ឋិមានំ សញ្ញោជនានំ”** *បានដល់ ឧទ្ធម្ភាគិយសំយោជនៈ ៥ ខាងលើ ឬបានដល់ កិលេស ៨ ។ បទថា* **“បហានាយ”** *បានដល់ ញ៉ាំងមគ្គឲ្យកើតឡើង ដើម្បីប្រយោជន៍ដល់ការលះសំយោជនៈទាំងនោះ ។*

*ពីរបទថា* **“អយំ វុច្ចតិ”** *សេចក្តីថា បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា* ***អន្តរាបរិនិព្វាយី*** *ព្រោះបរិនិព្វានក្នុងចន្លោះពាក់កណ្តាលនៃអាយុទុំះឯង៕*

ចប់អន្តរាបរិនិព្វាយីបុគ្គល

## ពណ៌នាអំពីឧបហច្ចបរិនិព្វាយីបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃព្រះអនាគាមីឈ្មោះថា **ឧបហច្ចបរិនិព្វាយីបុគ្គល** ៖*

*ពាក្យថា* **“អតិក្កមិត្វា វេមជ្ឈំ អាយុប្បមាណំ”** *បានដល់ ឈានកន្លងហួសពាក់កណ្ដាលប្រមាណនៃអាយុ ។ ពាក្យថា* **“ឧបហច្ច ខាកាលកិរិយំ”** *បានដល់ ជិតនឹងធ្វើកាលកិរិយា អធិប្បាយថា ជិតកាលនឹងអស់អាយុហើយ ។ ពាក្យថា* **“អយំ វុច្ចតិ”** *សេចក្ដីថា បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា **ឧបហច្ចបរិនិព្វាយី** ព្រោះឈានកន្លងហួសពាក់កណ្ដាល ៥០០ មហាកប្ប នៃអាយុដែលមាន ១០០០ មហាកប្ប ជាប្រមាណក្នុងអវិហាភូមិទាំងឡាយមុន ហើយទើបតាំងនៅក្នុងកប្បទី ៦០០ មហាកប្ប ឬទី ៧០០ មហាកប្ប ឬថាទី ៨០០ មហាកប្ប ឬក៏ទី ៩០០ មហាកប្ប ឬក៏ថាទី ១០០០ មហាកប្ប យ៉ាងណាមួយមែនពិត ហើយទើបសម្រេចព្រះអរហត្ត និងបរិនិព្វាន ដោយកិលេសបរិនិព្វាន ។*

ចប់ឧបហច្ចបរិនិព្វាយីបុគ្គល

---

## ពណ៌នាអំពីអសង្ខារបរិនិព្វាយី និងសសង្ខារបរិនិព្វាយីបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃព្រះអនាគាមីដែលឈ្មោះថា **អសង្ខារបរិនិព្វាយី***

និង ***សសង្ខារបរិនិព្វាយី*** ៖

*ព្រះអនាគាមីឯណា មិនធ្វើសេចក្តីព្យាយាមយ៉ាងខ្លាំងក្លា ដោយមិនប្រញាប់ប្រញាល់ពេក មានទុក្ខតិច សម្រេចព្រះអរហត្ត ហើយបរិនិព្វាន ដោយកិលេសបរិនិព្វានតាមធម្មតា ព្រោះហេតុដូច្នោះ ទើបលោកឈ្មោះថា* ***អសង្ខារបរិនិព្វាយី*** *= អ្នកបរិនិព្វានតាមធម្មតា ដោយមិនបានធ្វើសេចក្តីព្យាយាមយ៉ាងខ្លាំងក្លាទេ, ចំណែកព្រះអនាគាមីណា ធ្វើសេចក្តីព្យាយាមយ៉ាងខ្លាំងក្លា ដោយប្រញាប់ប្រញាល់បន្ទាន់ មិនយឺតយូរ មានសេចក្តីទុក្ខលំបាក សម្រេចព្រះអរហត្តហើយបរិនិព្វាន ដោយកិលេសបរិនិព្វានតាមធម្មតា ព្រោះហេតុដូច្នោះ ទើបលោកហៅថា* ***សសង្ខារបរិនិព្វាយី*** *= អ្នកបរិនិព្វានតាមធម្មតា ដោយការធ្វើសេចក្តីព្យាយាមយ៉ាងខ្លាំងក្លា ។*

ចប់អសង្ខារបរិនិព្វាយី និងសសង្ខារបរិនិព្វាយីបុគ្គល

---

## ពណ៌នាអំពីឧទ្ធំសោតោអកនិដ្ឋគាមីបុគ្គល

*វិនិច្ឆ័យក្នុងនិទ្ទេសនៃព្រះអនាគាមីឈ្មោះថា* ***ឧទ្ធំសោតោបុគ្គល*** ៖

**តណ្ហាសោតំ** *= ក្រសែ គឺតណ្ហា ឬ* **វដ្តសោតំ** *= ក្រសែ គឺវដ្តៈ របស់ព្រះអនាគាមីនោះ មាននៅខាងលើ ព្រោះជាធម្មជាតនាំទៅខាងលើ, ព្រោះហេតុដូច្នោះ ទើបលោកឈ្មោះថា* **ឧទ្ធំសោតោ** *= អ្នកមានក្រសែ*

គឺតណ្ហា ឬវដ្តៈខាងលើ ។ មយ៉ាងទៀត **មគ្គសោតំ** = ក្រសែ គឺមគ្គរបស់ព្រះអនាគាមីនោះ មាននៅខាងលើ ព្រោះលោកទៅកាន់ភពខាងលើហើយទើបបាន ព្រោះហេតុដូច្នោះ ទើបលោកឈ្មោះថា **ឧទ្ធំសោតោ** = អ្នកមានក្រសែ គឺមគ្គខាងលើ ។ ពីរបទថា **"អកនិដ្ឋំ គច្ឆតិ"** បានដល់ អ្នកមានប្រក្រតីទៅកាន់អកនិដ្ឋភព ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **"អវិហាតោ ចុតោ អតប្បំ គច្ឆតិ"** ជាដើមថា ព្រះអនាគាមីកាលនៅក្នុងអវិហាភូមិ រហូត ១០០០ មហាកប្ប មិនអាចសម្រេចអរហត្តបាន ទើបទៅកាន់សុទស្សីភូមិ ។ សូម្បីកាលលោកនៅក្នុងសុទស្សីភូមិរហូត ៨០០០ មហាកប្ប ក៏មិនអាចសម្រេចព្រះអរហត្តបាន ទើបទៅកាន់អកនិដ្ឋភូមិ ។ អធិប្បាយថា កាលលោកនៅក្នុងអកនិដ្ឋភូមិនោះ ទើបញ៉ាំងអរិយមគ្គឲ្យកើតឡើងបាន ។

មួយទៀត ដើម្បីប្រយោជន៍ដល់ការជ្រាបនូវប្រភេទរបស់ព្រះអនាគាមីទាំងនេះ អ្នកសិក្សាគប្បីជ្រាបនូវពួក ៤ នៃព្រះអនាគាមីដែលឈ្មោះថា ***ឧទ្ធំសោតោអកនិដ្ឋគាមី*** ។

បណ្ដាព្រះអនាគាមីទាំងនោះ អង្គណាជម្រះទេវលោកទាំង ៤ ឲ្យស្អាត ចាប់ផ្ដើមអំពីអវិហាភូមិ នឹងទៅកាន់អកនិដ្ឋភូមិ ទើបបរិនិព្វានអង្គនោះ ឈ្មោះថា ***ឧទ្ធំសោតោអកនិដ្ឋគាមី*** ។

*ក៏អង្គណា ជម្រះទេវលោកទាំង ៣ ខាងក្រោមឲ្យស្អាត ហើយតាំងនៅក្នុងសុទស្សីទេវលោក ទើបបរិនិព្វាន អង្គនោះ ឈ្មោះថា* **ឧទ្ធំសោតោ-នអកនិដ្ឋគាមី** *= អ្នកមានក្រសែខាងលើ, តែមិនទៅកាន់អកនិដ្ឋភូមិ ។*

*អង្គណាទៅកាន់អកនិដ្ឋភូមិនោះឯង អំពីសុទស្សីទេវលោកនេះ ហើយទើបបរិនិព្វាន អង្គនោះ ឈ្មោះថា* **ន ឧទ្ធំសោតោអកនិដ្ឋគាមី** *= អ្នកមិនមានក្រសែខាងលើទេ, តែទៅកាន់អកនិដ្ឋភូមិ ។*

*ក៏អង្គណាតាំងនៅក្នុងទេវលោក ៤ ខាងក្រោម រមែងបរិនិព្វានក្នុងទីនោះឯង អង្គនោះ ឈ្មោះថា* **ន ឧទ្ធំសោតោ ន អកនិដ្ឋគាមី** *= អ្នកមិនមានក្រសែខាងលើ និងមិនទៅកាន់អកនិដ្ឋភូមិ ។*

*ព្រោះហេតុដូច្នោះ កាលរួមព្រះអនាគាមីទាំងអស់នោះ ទើបមាន ៤៨ ជំពូក ដោយប្រការដូច្នេះ ។*

***សួរថា*** *ព្រះអនាគាមីមាន ៤៨ ជំពូក តើអ្វីខ្លះ ?*

*ឆ្លើយថា ក្នុងអវិហាភូមិមុន, ព្រះអនាគាមីជាអន្តរាបរិនិព្វាយី ៣ ជំពូក, ជាឧបហច្ចបរិនិព្វាយី ១ ជំពូក, ជាឧទ្ធំសោតោ ១ ជំពូក, ព្រះអនាគាមីទាំងនោះ រួមជា ១០ ជំពូក គឺជាអសង្ខារបរិនិព្វាយី ៥ ជំពូក និងជាសសង្ខារបរិនិព្វាយី ៥ ជំពូក; ក្នុងអតប្បា សុទស្សា និងសុទស្សី-ភូមិ ក៏ដូចគ្នា គឺមាន ៤ ភូមិ មួយភូមិៗ ១០ ជំពូក រួមជា ៤០ ជំពូក,*

តែព្រះអនាគាមីដែលឈ្មោះថា **ឧទ្ធំសោតោ** មិនមានក្នុងជាន់អកនិដ្ឋភូមិទេ, មានតែព្រះអនាគាមីដែលឈ្មោះថា **អន្តរាបរិនិព្វាយី ៣ ជំពូកប៉ុណ្ណោះ**, ឧបហច្ចបរិនិព្វាយី ១ ជំពូក, ព្រះអនាគាមីទាំងនោះជា ៨ ជំពូក គឺជាអសង្ខារបរិនិព្វាយី ៤ ជំពូក និងជាសសង្ខារបរិនិព្វាយី ៤ ជំពូក ទើបរួមជាព្រះអនាគាមី ៤៨ ជំពូក ដោយប្រការដូច្នេះ ។ ព្រះអនាគាមីទាំងអស់នោះ បណ្ឌិតលោកសម្តែងប្រៀបធៀបហើយ ដោយផ្កាភ្លើងដែលកើតអំពីដែក ដូចឧទាហរណ៍តទៅនេះ ៖

ដូចយ៉ាងថា កាលបើជាងដែកវាយនូវចុងដែកស្រួចរបស់កាំបិតបត់ និងកាំបិតកាត់ក្រចកដែលក្តៅរហូតដល់ថ្ងៃ ត្រង់ដុំដែក ផ្កាភ្លើងកើតឡើងហើយ ក៏រលត់ទៅ យ៉ាងណា, ព្រះអនាគាមីដែលមានសភាពបែបនេះ បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា **អន្តរាបរិនិព្វាយី** ពួកទី ១ ក៏ដូច្នោះដែរ ។

**សួរថា** ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះកិលេសរលត់ទៅមិនមានសល់ ក្នុងលំដាប់ដែលកើតឡើងនោះឯង ។

កាលជាងដែកវាយនូវចុងដែកស្រួចជាដើម ដែលក្តៅរហូតថ្ងៃ ដែលធំជាងនោះ ត្រង់ដុំដែក ផ្កាភ្លើងក៏បាញ់ចេញឡើងទៅកាន់អាកាស ហើយក៏រលត់ទៅ យ៉ាងណា, ព្រះអនាគាមីដែលមានសភាពបែបនេះ គប្បីជ្រាបថា

ឈ្មោះថា ***អន្តរាបរិនិព្វាយី*** ពួកទី ២ ក៏ដូច្នោះដែរ ។

***សួរថា*** ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះលោកមានព្រះជន្មាយុ មិនទាន់បានដល់ពាក់កណ្ដាល ក៏បរិនិព្វាន ។

កាលជាងដែកវាយនូវចុងដែកស្រួចជាដើម ដែលក្ដៅរហូតថ្ងៃ ដែលធំជាងនោះ (សំដៅដល់ធំឡើងៗ ទៅជាលំដាប់) ត្រង់ដុំដែក ផ្កាភ្លើងបាញ់ចេញឡើងទៅកាន់អាកាស ហើយបែរត្រឡប់ចុះមកកាន់ផែនដី នៅមិនទាន់ខ្ទប់ ក៏រលត់ទៅ យ៉ាងណា, ព្រះអនាគាមី ដែលមានសភាពបែបនេះ គប្បីជ្រាបថា ឈ្មោះថា ***អន្តរាបរិនិព្វាយី*** ពួកទី ៣ ក៏ដូច្នោះដែរ ។

***សួរថា*** ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះដល់ពាក់កណ្ដាលនៃអាយុ នៅឆ្ងាយពីការធ្វើកាលកិរិយា ហើយក៏បរិនិព្វានទៅ ។

កាលជាងដែកវាយនូវចុងដែកស្រួចជាដើម ដែលក្ដៅរហូតថ្ងៃ ដែលធំជាងនោះ ត្រង់ដុំដែក ផ្កាភ្លើងបាញ់ចេញឡើងកាន់អាកាសហើយធ្លាក់ចុះទៅលើផែនដី គ្រាន់តែខ្ទប់នឹងផ្ទៃដីភ្លាម ក៏រលត់ទៅ យ៉ាងណា, ព្រះអនាគាមីមានសភាពបែបនេះ គប្បីជ្រាបថា ឈ្មោះថា ***ឧបហច្ចបរិនិព្វាយី*** ក៏ដូច្នោះដែរ ។

***សួរថា*** *ព្រោះហេតុអ្វី ?*

*ឆ្លើយថា ព្រោះចូលជិតការធ្វើកាលកិរិយាហើយ បានញ៉ាំងសេចក្តីប្រព្រឹត្តទៅនៃអាយុឲ្យអស់ទៅ ហើយទើបបរិនិព្វាន ។*

*កាលជាងដែកវាយនូវចុងដែកស្រួចជាដើម ដែលក្តៅរហូតថ្ងៃ ដែលធំជាងនោះ ត្រង់ដុំដែក ក្រមរផ្កាភ្លើងសាចធ្លាក់ទៅត្រង់ស្មៅ ឬត្រង់ឈើបន្តិចបន្តួច ហើយក៏ឆេះស្មៅ ឬឈើបន្តិចបន្តួច ហើយក៏រលត់ទៅ យ៉ាងណា, ព្រះអនាគាមី ដែលមានសភាពបែបនេះ គប្បីជ្រាបថា ឈ្មោះថា* ***អសង្ខារបរិនិព្វាយី*** *ក៏ដូច្នោះដែរ ។*

***សួរថា*** *ព្រោះហេតុអ្វី ?*

*ឆ្លើយថា ព្រោះបរិនិព្វានដោយការប្រកបសេចក្តីព្យាយាម មានប្រមាណបន្តិចបន្តួច គឺដោយដំណើរការទៅយ៉ាងសប្បាយ ។*

*កាលជាងដែកវាយនូវដែកស្រួចជាដើម ដែលក្តៅរហូតថ្ងៃ ដែលធំជាងនោះ ត្រង់ដុំដែក ក្រមរផ្កាភ្លើងក៏សាចធ្លាក់ទៅត្រង់ចំគំនរឈើ ឬគំនរស្មៅធំ ហើយឆេះគំនរឈើ ឬគំនរស្មៅធំនោះអស់ ទើបរលត់ទៅ យ៉ាងណា, ព្រះអនាគាមីបែបនេះ គប្បីជ្រាបថា ឈ្មោះថា* ***សសង្ខារបរិនិព្វាយី*** *ក៏ដូច្នោះដែរ ។*

***សួរថា*** *ព្រោះហេតុអ្វី ?*

ឆ្លើយថា ព្រោះបរិនិព្វានដោយ ការធ្វើសេចក្តីព្យាយាមយ៉ាងខ្លាំងក្លា គឺដំណើរការទៅយ៉ាងម៉ឺងម៉ាត់ ។

ក្រមរផ្កាភ្លើងដទៃទៀត រមែងធ្លាក់ទៅត្រង់ចំគំនរឈើ និងគំនរស្មៅដែលធំនោះ លុះកាលគំនរឈើ ឬគំនរស្មៅដែលធំជាងនោះ ត្រូវភ្លើងឆេះហើយ ធ្យូងដែលប្រាសចាកអណ្តាតភ្លើង ក៏កើតឡើង ហើយដុតឆេះរោងរបស់នាយជាងដែក រួចក៏រាលទៅឆេះភូមិ ស្រុក ក្រុង និងដែន ដល់ប្រាំងសមុទ្រទើបរលត់ទៅ យ៉ាងណា, ព្រះអនាគាមីបែបនេះ គប្បីជ្រាបថា ឈ្មោះថា ***ឧទ្ធំសោតោអកនិដ្ឋគាមី*** ក៏ដូច្នោះដែរ ។

***សួរថា*** ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះលោកធ្វើការពង្រីកពូជ ក្នុងភពជាអនេក ហើយធ្វើឲ្យអស់រលីងដោយការពន្ទះធម៌ដែលត្រឹមត្រូវទើបបរិនិព្វាន ។ ក៏ដុំដែកនោះឯង មានតូចខ្លះ ធំខ្លះ ដែលផ្សេងដោយចុងដែកស្រួចជាដើម ព្រោះហេតុដូច្នោះ ទើបលោកពោលទុកក្នុងព្រះសូត្រ ត្រង់វារៈទាំងអស់ថា **“អយោកបល្លំ** = ដុំដែក**”** ។

ដូចយ៉ាងពាក្យដែលព្រះអង្គត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ ក៏ភិក្ខុក្នុងព្រះធម្មវិន័យនេះ ជាអ្នកបដិបត្តិយ៉ាងនេះហើយ រមែងបានចំពោះនូវឧបេក្ខា គឺភាពព្រងើយៗថា ឧបេក្ខាមិនគប្បីមាន និងមិនគប្បីមានដល់

យើង មិនបានមានហើយ នឹងមិនមានដល់យើង, វត្ថុឯណាមាន យើង រមែងលះវត្ថុនោះ, លោកអង្គនោះរមែងមិនត្រេកអរក្នុងភព រមែងមិនត្រេកអរក្នុងការកើត; លំដាប់នោះ លោករមែងឃើញបទដ៏ក្រៃលែង ដែលស្ងប់ហើយ ដោយសម្មប្បញ្ញា (ដឹងដោយប្រពៃ) ក៏បទនោះឯង ដែលលោកធ្វើឲ្យច្បាស់ហើយនូវវត្ថុទាំងពួង ដោយប្រការទាំងពួង, តែលោកនៅលះមានានុស័យទាំងពួងមិនបាន ដោយប្រការទាំងពួង, នៅលះភវរាគា-នុស័យទាំងពួង ដោយប្រការទាំងពួងមិនបាន, នៅលះអវិជ្ជានុស័យទាំងពួង ដោយប្រការទាំងពួងមិនបាន, អ្នកនោះ ឈ្មោះថា ***អន្តរាបរិនិព្វាយី*** ព្រោះការអស់ទៅដោយជុំវិញនៃឱរម្ភាគិយសំយោជនៈទាំង ៥ ហើយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុគ្គលកាលវាយនូវដុំដែកដែលក្តៅរហូតថ្ងៃ ផ្កាភ្លើងកើតឡើងហើយ ក៏គប្បីរលត់ទៅ យ៉ាងណាមិញ, ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុជាអ្នកបដិបត្តិហើយយ៉ាងនេះ ។ល។ រមែងជាអ្នកឈ្មោះថា ***អន្តរាបរិនិព្វាយី*** យ៉ាងនោះដែរ" ។

ម្នាលភិក្ខុទាំងឡាយ ក៏ភិក្ខុក្នុងព្រះធម្មវិន័យនេះ ជាអ្នកបដិបត្តិហើយយ៉ាងនោះ ។ល។ ឈ្មោះថា ***អន្តរាបរិនិព្វាយី*** ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុគ្គលកាលវាយនូវដុំដែកដែលក្តៅរហូតទាំងថ្ងៃ ផ្កាភ្លើងកើតហើយ កើតឡើងហើយ ក៏គប្បីរលត់ទៅ យ៉ាងណាមិញ, ម្នាលភិក្ខុទាំងឡាយ ភិក្ខុ

ជាអ្នកបដិបត្តិហើយយ៉ាងនេះ ។ ល ។ រមែងជាអ្នកមានឈ្មោះថា ***អន្តរាបរិនិព្វាយី*** ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ក៏ភិក្ខុក្នុងព្រះធម្មវិន័យនេះ ជាអ្នកបដិបត្តិហើយ យ៉ាងនេះ ។ ល ។ រមែងជាអ្នកមានឈ្មោះថា ***អន្តរាបរិនិព្វាយី*** ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុគ្គលកាលវាយនូវដុំដែកទាំងឡាយ ដែលក្តៅរហូតទាំងថ្ងៃ ក្រមរផ្កាភ្លើងកើតឡើងហើយ នៅមិនទាន់ខ្ទប់ផ្ទៃដី ក៏គប្បីរលត់ទៅ យ៉ាងណាមិញ, ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបដិបត្តិហើយយ៉ាងនេះ រមែងឈ្មោះថា ***អន្តរាបរិ-និព្វាយី*** ក៏ដូច្នោះដែរ; ម្នាលភិក្ខុទាំងឡាយ ក៏ភិក្ខុក្នុងព្រះធម្មវិន័យនេះ ជាអ្នកបដិបត្តិហើយយ៉ាង នេះ រមែងឈ្មោះថា ***ឧបហច្ចបរិនិព្វាយី*** ម្នាលភិក្ខុទាំងឡាយ ប្រៀបដូច បុគ្គលកាលវាយនូវដុំដែកដែលក្តៅរហូតទាំងថ្ងៃ ក្រមរផ្កាភ្លើងកើតហើយ កើតឡើងហើយ ខ្ទប់នឹងផ្ទៃដីហើយ គប្បីរលត់ទៅយ៉ាងណា, ភិក្ខុទាំងឡាយ ភិក្ខុដែលជាអ្នកបដិបត្តិហើយយ៉ាងនេះ ។ល ។ រមែងឈ្មោះថា ***ឧបហច្ចបរិនិព្វាយី*** ។

ម្នាលភិក្ខុទាំងឡាយ ក៏ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកបដិបត្តិហើយយ៉ាងនេះ ។ ល ។ រមែងឈ្មោះថា ***អសង្ខារបរិនិព្វាយី*** ព្រោះការអស់ទៅជុំវិញ នៃឱរម្ភាគិយសំយោជនៈទាំង ៥ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុគ្គលវាយនូវដុំដែកដែលក្តៅរហូតថ្ងៃ ក្រមរផ្កាភ្លើងកើតហើយ កើតឡើង

ហើយ គប្បីបាញ់ចេញទៅធ្លាក់នៅត្រង់គំនរស្មៅ ឬគំនរឈើបន្តិចបន្តួច ក្រមរ (កម្ទេច) ផ្កាភ្លើងនោះ គប្បីឲ្យភ្លើងកើតខ្លះ ឲ្យផ្សែងកើតខ្លះ, ក្នុងទីនោះ លុះឲ្យភ្លើងកើតហើយក្តី ឲ្យផ្សែងកើតហើយក្តី ក៏ឆេះគំនរឈើ គំនរស្មៅបន្តិចបន្តួចនោះៗ ឯង រហូតអស់ហើយ គប្បីរលត់ទៅឯង ព្រោះអស់ពូជ យ៉ាងណាមិញ, ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបដិបត្តិហើយ យ៉ាងនេះ ។ល។ រមែងឈ្មោះថា ***អសង្ខារបរិនិព្វាយី*** ព្រោះការអស់ទៅដោយជុំវិញនៃឱរម្ភាគិយសំយោជនៈទាំង ៥ ដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ក៏ភិក្ខុក្នុងព្រះធម្មវិន័យនេះ ជាអ្នកបដិបត្តិហើយយ៉ាងនេះ រមែងឈ្មោះថា ***សសង្ខារបរិនិព្វាយី*** ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុគ្គលកាលវាយដុំដែក ដែលក្តៅរហូតថ្ងៃ ក្រមរផ្កាភ្លើងកើតហើយ កើតឡើងហើយ គប្បីធ្លាក់ទៅត្រង់ចំគំនរស្មៅ និងគំនរឈើដែលចម្រើនហើយ គប្បីឲ្យភ្លើងកើតឡើងខ្លះ ឲ្យផ្សែងកើតឡើងខ្លះ ។ល។ ហើយក៏ឆេះគំនរស្មៅ និងគំនរឈើដែលចម្រើននោះៗ ឯង រហូតអស់ហើយ ក៏គប្បីរលត់ទៅ ព្រោះអស់ពូជ យ៉ាងណា, ម្នាលភិក្ខុទាំងឡាយ ភិក្ខុបដិបត្តិហើយយ៉ាងនេះ ។ ល ។ ឈ្មោះថា ***សសង្ខារបរិនិព្វាយី*** ។ ភិក្ខុទាំងឡាយ ក៏ភិក្ខុក្នុងព្រះធម្មវិន័យនេះ ជាអ្នកបដិបត្តិហើយយ៉ាងនេះ ។ល។ រមែងជាអ្នកឈ្មោះថា ***ឧទ្ធំសោតោអកនិដ្ឋគាមី*** ព្រោះការអស់ទៅជុំវិញនៃ

ទិវម្ភាគិយសំយោជនៈទាំង ៥ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុគ្គលកាល វាយនូវដុំដែកដែលក្តៅរហូតថ្ងៃ ក្រមរផ្កាភ្លើងកើតហើយ កើតឡើងហើយ គប្បីធ្លាក់ទៅត្រង់គំនរស្មៅ ឬគំនរឈើដែលធំ គប្បីឲ្យភ្លើងកើតខ្លះ ឲ្យផ្សែង កើតខ្លះ ។ល។ ហើយក៏ឆេះគំនរស្មៅ គំនរឈើដែលធំនោះៗ ឯង នឹងគប្បីរាលដាលទៅ ឆេះគុម្ពឈើខ្លះ ព្រៃឈើខ្លះ លុះឆេះហើយ ក៏មកកាន់ ភាគផ្ទៃដែលជាពូជស្រស់ ឬដល់ផ្លូវ ឬក៏ដល់សិលា ឬថា ដល់ទឹក ឬក៏ថា ដល់ស្ថានដែលជាទីរីករាយ ក៏រលត់ទៅ ព្រោះដាច់ពូជ យ៉ាងណា, ម្នាល ភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបដិបត្តិហើយយ៉ាងនេះ ។ល។ រមែងជាអ្នក ឈ្មោះថា ***ឧទ្ធំសោតោអកនិដ្ឋគាមី*** ដូច្នោះដែរ ។

និទ្ទេសនៃព្រះអរិយបុគ្គល អ្នកបដិបត្តិក្នុងការធ្វើឲ្យជាក់ច្បាស់នូវ សោតាបត្តិផលជាដើម មានសេចក្តីងាយស្រួលមែនពិត ។

ពាក្យថា **"អយំ វុច្ចតិ"** សេចក្តីថា បុគ្គលនេះ គឺអ្នកបែបនេះ លោក ហៅថា ព្រះអរហន្ត ។ ក៏ពាក្យថា ***"ព្រះអរហន្ត"*** ក្នុងទីនេះ គប្បីជ្រាបថា មាន ១២ ជំពូក ។

***សួរថា*** មាន ១២ ជំពូកតើអ្វីខ្លះ ?

ឆ្លើយថា ក៏វិមោក្ខ មាន ៣ យ៉ាង គឺ ***សុញ្ញតវិមោក្ខ ១, អនិមិត្ត-វិមោក្ខ ១*** និង ***អប្បណិហិតវិមោក្ខ ១;*** បណ្តាវិមោក្ខទាំងនោះ ព្រះខីណា-

*ស្រព អ្នករួចផុតដោយសុញ្ញតវិមោក្ខមាន ៤ ជំពូក ដោយអំណាចនៃបដិបទា ៤ យ៉ាង និងព្រះខីណាស្រពដែលរួចផុត ដោយអនិមិត្តវិមោក្ខ ឬអប្បណិហិតវិមោក្ខក៏ដូចគ្នា, ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបថា ព្រះអរហន្តមាន ១២ ជំពូក ដោយប្រការដូច្នេះ ។*

*ក៏បុគ្គលទាំងនេះ មានប្រមាណប៉ុណ្ណេះ គឺព្រះសកទាគាមី ១២ ជំពូក ដែលដូចព្រះអរហន្ត ១២ ជំពូក, ព្រះសោតាបន្ន ២៤ ជំពូក គឺព្រះសោតាបន្ន ១២ ជំពូក គុណដោយធុរៈ ២ គឺសទ្ធាធុរៈ ១ និងបញ្ញាធុរៈ ១ និងព្រះអនាគាមី ៤៨ ជំពូក ទាំងអស់នេះ កាលលោកផុតចាកលោកនេះហើយ រមែងមិនកើតក្នុងលទ្ធិខាងក្រៅព្រះពុទ្ធសាសនាឡើយ, រមែងកើតឡើងតែក្នុងព្រះសាសនានៃព្រះសព្វញ្ញូពុទ្ធជាម្ចាស់នេះប៉ុណ្ណោះ ៕*

ចប់អដ្ឋកថាឯកកនិទ្ទេស

តែត្រឹមប៉ុណ្ណេះ

## ២.អដ្ឋកថាទុកនិទ្ទេស អធិប្បាយបុគ្គល ២ ជំពូក

## ពណ៌នាអំពីបុគ្គលចូលចិត្តក្រោធជាដើម

*បុគ្គលអ្នកមានសេចក្ដីក្រោធជាប្រក្រតី គឺអ្នកក្រោធច្រើន ឈ្មោះថា*

អ្នកចូលចិត្តក្រោធ ។ សូម្បីព្រះភគវាត្រាស់សួរបុគ្គលយ៉ាងនេះ ដើម្បីនឹងទ្រង់សម្ដែងបុគ្គលដោយធម៌ ទើបត្រាស់ពាក្យថា **“ តត្ថ កតមោ កោធោ** = សេចក្ដីក្រោធក្នុងខនោះ ជាយ៉ាងណា ? ” ជាដើម ។ សូម្បីក្នុងនិទ្ទេសនៃ ***ឧបនាហីបុគ្គល*** អ្នកចងសេចក្ដីក្រោធទុកជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ពាក្យជាដើមថា **“ កោធោ កុជ្ឈនា ”** មានសេចក្ដីដូចដែលខ្ញុំពោលហើយ ខាងក្រោយនុ៎ះឯង ។ ពាក្យជាដើមថា **“ កោធោ ”** មានសេចក្ដីដូចដែលខ្ញុំពោលហើយក្នុងកាលមុន; ក្នុង ***ឧបនាហីនិទ្ទេស*** ជាដើមដូចគ្នា ។

ពីរបទថា **“ អយំ កោធោ អប្បហីនោ ”** សេចក្ដីថា លះមិនបានដោយវិក្ខម្ភនប្បហាន ឬដោយតទង្គប្បហាន ឬថាដោយសមុច្ឆេទប្បហាន ។

សូម្បីក្នុងបុគ្គលដែលចងសេចក្ដីក្រោធទុកជាដើមខាងមុខ ក៏មានន័យដូចគ្នានេះដែរ ៕

---

## ពណ៌នាអំពីអហិរិកបុគ្គល គឺអ្នកមិនមានហិរិជាដើម

គប្បីជ្រាបវិនិច្ឆ័យក្នុង ***អហិរិកបុគ្គល*** តទៅ ៖

ពីរបទថា **"ឥមិនា អហិរិកេន"** សេចក្ដីថា អ្នកប្រកបដោយធម៌ គឺសេចក្ដីមិនខ្មាសនេះ ដែលមានប្រការយ៉ាងនេះ ។ សូម្បីក្នុងពាក្យជាដើមថា **"អនោត្តប្បេន"** ក៏មានន័យដូចគ្នានេះដែរ ។

បទថា **"អជ្ឈត្តសញ្ញោជនោ"** បានដល់ អ្នកមានគ្រឿងចងខាងក្នុង ។

ពីរបទថា **"ពហិទ្ធា សញ្ញោជនោ"** បានដល់ អ្នកមានគ្រឿងចងខាងក្រៅ ។ សូម្បីគ្រឿងចងទាំងពីរនេះ បណ្ឌិតគប្បីសម្ដែងការឧបមាដោយរោងកូនគោ ។ ពិតមែន ព្រះសោតាបន្ន និងព្រះសកទាគាមី ដែលតាំងជីវិតនៅក្នុងកាមលោកនេះ ប្រៀបដូចកូនគោដែលគេចងឲ្យដេកនៅខាងក្នុងរោងរបស់វានោះឯង ។

គ្រឿងចង គឺសំយោជនៈនៃព្រះសោតាបន្ន និងព្រះសកទាគាមីទាំងនេះ តាំងនៅក្នុងកាមលោកនេះ, សូម្បីខ្លួនលោក ក៏តាំងនៅក្នុងភពនេះដូចគ្នា ។ បើព្រះសោតាបន្ន និងព្រះសកទាគាមីតាំងនៅក្នុងរូបភព ឬអរូបភព ក៏ប្រៀបដូចនឹងកូនគោដែលគេចងទុក ខាងក្នុងរោងរបស់វា, តែខ្លួនវា ដេកនៅខាងក្រៅរោង; ព្រោះថា គ្រឿងចងនៃព្រះសោតាបន្ន និងព្រះសកទាគាមីទាំងនោះ តាំងនៅក្នុងកាមលោកនេះ, តែលោកនៅក្នុងព្រហ្មលោក ។ ព្រះអនាគាមីអ្នកនៅក្នុងរូបភព ប្រៀបដូចនឹងកូនគោ ដែល

គេចងទុកខាងក្រៅរោង, ខ្លួនវាក៏ដេកនៅខាងក្រៅរោងដែរ ព្រោះថា គ្រឿងចង គឺសំយោជនៈនៃព្រះអនាគាមីនោះ នៅខាងក្រៅអំពីកាមលោក, សូម្បីខ្លួនលោក ក៏តាំងនៅខាងក្រៅអំពីកាមលោកដូចគ្នាដែរ ។ ចំណែកព្រះអនាគាមី អ្នកស្ថិតនៅក្នុងកាមលោកនេះ ប្រៀបដូចនឹងកូនគោដែលគេចងទុកខាងក្រៅរោង, តែខ្លួនដេកនៅខាងក្នុងរោង ។ ព្រោះថា គ្រឿងចងរបស់អនាគាមីនោះ នៅក្នុងរូបភព និងអរូបភព, តែលោកនៅក្នុងកាមភពនេះ ៕

ចប់អហិរិកបុគ្គល

## ពណ៌នាអំពីអក្កោធនបុគ្គល គឺបុគ្គលអ្នកមិនក្រោធ

បទថា **“ចហីនោ”** បានដល់ សេចក្តីក្រោធដែលបុគ្គលលះបានហើយដោយវិក្ខម្ភនប្បហាន ឬដោយតទង្គប្បហាន ឬក៏ដោយសមុច្ឆេទប្បហាន ៕

## ពណ៌នាអំពីបុគ្គលរកបានដោយលំបាក ២ ជំពូក

បទថា **“ទុល្លភា”** បានដល់ មិនមែនបុគ្គលដែលរកបានដោយងាយ ។

បទថា **“បុព្វការី”** បានដល់ អ្នកធ្វើឧបការៈមុនទុំះឯង ។

បទថា **“កតវេទី”** បានដល់ ការប្រកាសឧបការគុណដែលបុគ្គលដទៃ

ធ្វើហើយ គឺធ្វើឧបការគុណឲ្យប្រាកដ ។

បណ្ឌិតគប្បីសម្តែងបុគ្គលទាំងពីរពួកនោះ ដោយអាគារិយបុគ្គល និង អនាគារិយបុគ្គល គឺគ្រហស្ថ និងបព្វជិត; ក៏បណ្តាគ្រហស្ថទាំងឡាយ មាតា និងបិតា ឈ្មោះថា **បុព្វការី** = អ្នកធ្វើឧបការៈមុន, ចំណែកបុត្រ និងធីតា អ្នកបដិបត្តិ និងធ្វើការអភិវាទជាដើមដល់មាតា និងបិតា ឈ្មោះថា **កតញ្ញូ** (អ្នកដឹងឧបការគុណដែលបុព្វការីជនធ្វើហើយ) ។ ចំពោះបព្វជិតទាំងឡាយ អាចារ្យ និងឧបជ្ឈាយ៍ ឈ្មោះថា **បុព្វការី** ។ អន្តេវាសិក និងសទ្ធិ-វិហារិកទាំងឡាយ (កូនសិស្ស និងអ្នកនៅរួម) ដែលបដិបត្តិអាចារ្យ និង ឧបជ្ឈាយ៍ ឈ្មោះថា **កតញ្ញូ** ។ ដើម្បីប្រកាសបុគ្គលទាំងពីរជំពូកនោះ ឲ្យជាក់ច្បាស់ បណ្ឌិតគប្បីពោលដល់រឿងព្រះសោណត្ថេរដែលចិញ្ចឹមមើល ថែទាំព្រះឧបជ្ឈាយ៍ជាដើម ។

ន័យមួយទៀត បុគ្គលណា កាលអ្នកដទៃមិនបានធ្វើឧបការៈទេ មិនសម្លឹងដល់ឧបការៈដែលអ្នកដទៃធ្វើក្នុងខ្លួន ហើយធ្វើឧបការៈ អ្នកនោះ ក៏ឈ្មោះថា **បុព្វការី,** ប្រៀបដូចមាតា និងបិតាមួយពួក អាចារ្យ និង ឧបជ្ឈាយ៍មួយពួក បុព្វការីបុគ្គលនោះ ឈ្មោះថា រកបានដោយលំបាក

ព្រោះភាវៈនៃសត្វទាំងឡាយ ត្រូវតណ្ហាគ្របសង្កត់ទុក ។

បុគ្គលឯណា ដឹងឧបការៈដែលអ្នកដទៃធ្វើចំពោះខ្លួន ប្រកាសនូវឧបការៈដែលប្រព្រឹត្តទៅ តាមសមគួរដល់ឧបការៈដែលអ្នកដទៃធ្វើហើយ អ្នកនោះ ឈ្មោះថា **កតញ្ញូកតវេទី,** ប្រៀបដូចបុគ្គលដែលប្រតិបត្តិដោយប្រពៃក្នុងមាតា និងបិតា ឬក្នុងអាចារ្យ និងឧបជ្ឈាយ៍ទាំងឡាយ ។ កតញ្ញូ-កតវេទីបុគ្គលនោះ ឈ្មោះថា រកបានដោយលំបាក ព្រោះភាវៈនៃសត្វទាំងឡាយ ត្រូវអវិជ្ជាគ្របសង្កត់ទុក ។

ម្យ៉ាងទៀត បុគ្គលដែលមានមេត្តាស្រឡាញ់រាប់អានដោយមិនមានហេតុ ឈ្មោះថា **បុព្វការី** ។ បុគ្គលមេត្តាស្រឡាញ់រាប់អានដោយមានហេតុ ឈ្មោះថា **កតញ្ញូកតវេទី** ។

បុគ្គលដែលធ្វើប្រយោជន៍ ដោយមិនសម្លឹងដល់ហេតុជាដើម យ៉ាងនេះថា ***"អ្នកនេះនឹងធ្វើឧបការៈដល់យើង"*** ឈ្មោះថា **កតញ្ញូកតវេទី** ។

អ្នកមកផងនឹង ទៅខាងមុខក្ដី ឈ្មោះថា **បុព្វការី** ។ អ្នកមកក្ដី ទៅខាងមុខក្ដី ឈ្មោះថា **កតញ្ញូកតវេទី** ។

*អ្នកសម្តែងធម៌ ឈ្មោះថា* **បុព្វការី** *។ អ្នកប្រតិបត្តិធម៌ ឈ្មោះថា* **កតញ្ញូកតវេទី** *។*

*ព្រះអរហន្តសម្មាសម្ពុទ្ធ ឈ្មោះថា* **បុព្វការី** *ក្នុងលោកនេះ ព្រមទាំងទេវលោក ។ ព្រះអរិយសាវក ឈ្មោះថា* **កតញ្ញូកតវេទី** *។*

*ចំណែកក្នុងគម្ពីរអដ្ឋកថានៃ* ***ទុកនិបាត*** *លោកពោលពាក្យទុកមានប្រមាណប៉ុណ្ណេះថា អ្នកធ្វើឧបការៈមុន ឈ្មោះថា* **បុព្វការី** *។ អ្នកដឹងឧបការៈដែលអ្នកដទៃធ្វើហើយ ធ្វើតបខាងក្រោយវិញ ឈ្មោះថា* **កតវេទី** *។ បណ្តាបុគ្គលទាំង ២ នោះ បុព្វការីជនរមែងធ្វើសេចក្តីសម្គាល់ថា* ***"យើងជាអ្នកឱ្យបំណុល"*** *បុគ្គលដែលធ្វើតបជំនួសខាងក្រោយវិញ រមែងធ្វើសេចក្តីសម្គាល់ថា* ***"យើងជាអ្នកសងបំណុល"*** *។*

---

## ពណ៌នាអំពីបុគ្គលឱ្យឆ្អែតបានដោយលំបាក ២ ជំពូក

*បទថា* **"ទុត្តប្បយា"** *បានដល់ អ្នកឲ្យខ្លួនឆ្អែត គឺអ្នកដែលនរណាមួយមិនអាចឲ្យឆ្អែតបាន ។ ក៏ភិក្ខុឯណា អាស្រ័យត្រកូលឧបដ្ឋាក ឬត្រកូលរបស់ញាតិ កាលបើចីវរដែល(គេ)ឲ្យចាស់ហើយ ក៏ប្រមូលចីវរដែលត្រកូល*

*ទាំងនោះប្រគេន ហើយមិនប្រើប្រាស់ កាន់យកចីវរដែលត្រកូលទាំងនោះប្រគេនហើយ ជាញឹកញាប់ៗ ក៏សន្សំទុកនោះឯង ។ មួយទៀត ភិក្ខុឯណាលះចីវរដែលខ្លួនបានហើយៗ ដោយន័យនុ៎ះៗ ឯង ប្រគេនដល់ភិក្ខុដទៃ សូម្បីបានចីវរជារឿយៗ ក៏ធ្វើយ៉ាងនោះឯង ។*

*បុគ្គល ២ ពួកនេះ នរណាមួយ បង្អោននាំបច្ច័យចូលទៅប្រគេនទាំងវទេះ ក៏មិនអាចដើម្បីឲ្យឆ្អែតបាន, ព្រោះហេតុដូច្នោះ ទើបឈ្មោះថា* **ទុត្តប្បយា** *= ដែលនរណាមួយ ឲ្យឆ្អែតបានដោយលំបាក ៕*

---

## ពណ៌នាអំពីបុគ្គលឱ្យឆ្អែតបានដោយងាយ ២ ជំពូក

*ពាក្យថា* **“ន និស្សជ្ជតិ”** *បានដល់ ធ្វើឲ្យជារបស់ៗ ខ្លួន មិនឲ្យដល់អ្នកដទៃ, តែកាលបើមានអតិរេកលាភ (របស់សល់) ក៏មិនប្រមូលទុក រមែងប្រគេនដល់ភិក្ខុដទៃ សេចក្ដីនេះ មានពាក្យអធិប្បាយទុកដូច្នេះ ក៏ភិក្ខុណាមានចីវរចាស់ហើយ បានសំពត់សាដកអំពីត្រកូលឧបដ្ឋាក ឬត្រកូលញាតិ ក៏កែច្នៃឲ្យបានជាចីវរប្រើកើត មិនព្រមបោះបោល សូម្បីប៉ះហើយ ក៏នៅប្រើដណ្ដប់បាន, កាលត្រកូលទាំងនោះ ប្រគេនថ្មី ក៏មិនប្រញាប់ទទួលដោយរហ័ស (សំដៅដល់មានការពិចារណា) នេះ មួយពួក, មួយពួកទៀតនោះ គឺភិក្ខុណា ប្រើចីវរដែលបានហើយៗ ដោយខ្លួនឯង រមែងមិនប្រគេន*

ដល់ភិក្ខុពួកដទៃ, សូម្បីភិក្ខុទាំងពីរពួកនេះ នរណាមួយ ក៏អាចឲ្យផ្អែតបាន ដោយងាយ, ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **សុភរ** = ដែលអ្នកដទៃឲ្យផ្អែតបាន ដោយងាយ ។

ពាក្យថា **“អាសវា”** បានដល់ កិលេសទាំងឡាយ ។

ពាក្យថា **“ន កុក្កុច្ចាយិតព្វំ កុក្កុច្ចាយតិ”** សេចក្ដីថា រមែងប្រព្រឹត្តមិនចូលចិត្តវត្ថុដែលមិនគួរស្អប់ ដូចភិក្ខុបានសាច់ជ្រូកហើយប្រព្រឹត្តមិនចូលចិត្តថា ជាសាច់ខ្លាឃ្មុំ, បានសាច់ម្រឹគហើយប្រព្រឹត្តមិនចូលចិត្តថា ជាសាច់ខ្លាដំបង, កាលបើពេល (នៃភត្ត) នៅមាន រមែងប្រព្រឹត្តមិនចូលចិត្តថា ពេលមិនមាន, មិនត្រូវហាម; តែប្រព្រឹត្តមិនចូលចិត្តថា យើងត្រូវហាមចេញ កាលល្អងធូលីមិនធ្លាក់ចូលទៅក្នុងបាត្រឡើយ រមែងប្រព្រឹត្តមិនចូលចិត្តថា ល្អងធូលីធ្លាក់ចូលទៅហើយ, កាលគេមិនធ្វើសាច់ត្រីឧទ្ទិសចំពោះខ្លួន ក៏ប្រព្រឹត្តមិនចូលចិត្តថា គេធ្វើសាច់ត្រីឧទ្ទិសចំពោះយើង ។

ពាក្យថា **“កុក្កុច្ចាយិតព្វំ ន កុក្កុច្ចាយតិ”** សេចក្ដីថា រមែងមិនប្រព្រឹត្ត មិនចូលចិត្ត វត្ថុដែលគួរប្រព្រឹត្តមិនចូលចិត្ត ដូចភិក្ខុបានសាច់ខ្លាឃ្មុំហើយ រមែងមិនប្រព្រឹត្ត មិនចូលចិត្តថា ជាសាច់ខ្លាឃ្មុំ ។ ល ។ លុះកាលគេធ្វើសាច់ត្រីឧទ្ទិស គឺចោះចំពោះខ្លួន រមែងមិនប្រព្រឹត្ត មិនចូលចិត្តថា គេធ្វើសាច់ត្រីឧទ្ទិសចំពោះយើង ។

ចំណែកក្នុង ***អដ្ឋកថា អង្គុត្តរនិកាយ*** លោកពោលពាក្យទុកមានប្រមាណប៉ុណ្ណេះថា ពាក្យថា **“ កុក្កុច្ចាយិតព្វំ ”** បានដល់ ការមិនតាំងទុក ការមិនពិចារណានូវចំណែកដែលជារបស់សង្ឃ ឈ្មោះថា ដែលនរណាមួយមិនគប្បីវង្វៀស រមែងវង្វៀសវត្ថុនោះ ។ ពាក្យថា **“ កុក្កុច្ចាយិតព្វំ ”** សេចក្ដីថា ការតាំងទុក ការពិចារណានូវវត្ថុដែលជារបស់សង្ឃនោះនុ៎ះឯង រមែងមិនវង្វៀសរបស់នោះទេ ។

ពាក្យថា **“ ឥរមេសំ ”** សេចក្ដីថា អាសវៈទាំងឡាយ រមែងចម្រើនយ៉ាងពិតប្រាកដដល់បុគ្គលទាំង ២ នេះ ទាំងក្នុងពេលថ្ងៃ ទាំងក្នុងពេលយប់ ដូចស្មៅ និងវល្លិជាដើម រីកលូតលាស់ល្អចម្រើននៅក្នុងភូមិភាគដែលល្អ ។ ក្នុងធម៌ស បណ្ឌិតគប្បីជ្រាបដោយន័យនេះថា ភិក្ខុឯណាបានកប្បិយមំសៈគឺសាច់ដែលសមគួរហើយ ក៏ទទួលយកសាច់ដែលសមគួរនោះឯង ឈ្មោះថា រមែងប្រព្រឹត្តមិនចូលចិត្តវត្ថុដែលមិនគួរប្រព្រឹត្ត មិនគួរចូលចិត្ត ។

ពាក្យថា **“ ហីនាធិមុត្តោ ”** បានដល់ អ្នកមានអធ្យាស្រ័យដ៏អាក្រក់ ។

ពាក្យថា **“ ទុស្សីលោ ”** បានដល់ អ្នកមិនមានសីល ។

ពាក្យថា **“ បាបធម្មោ ”** បានដល់ អ្នកមានធម៌ដ៏លាមក ។

ពាក្យថា **“ បណីតាធិមុត្តោ ”** បានដល់ អ្នកមានអធ្យាស្រ័យដ៏ប្រណីត ។

*ពាក្យថា* **“ កល្យាណធម្មោ ”** *បានដល់ អ្នកមានធម៌ដែលចម្រើន គឺមានធម៌ដ៏ស្អាត មានធម៌ដ៏ល្អ ។*

*ពាក្យថា* **“ តិណ្ណោ** *= ឆ្លែតហើយ ”* *បានដល់ អ្នកតាំងខ្លួនទុកល្អហើយ គឺដល់ទីបំផុតហើយ ។*

*ពាក្យថា* **“ តារេតា** *= អ្នកញុំាងបុគ្គលដទៃឲ្យឆ្លែត ”* *បានដល់ អ្នកធ្វើបុគ្គលទាំងឡាយដទៃឲ្យឆ្លែត ។*

*ក្នុងពាក្យថា* **“បច្ចេកសម្ពុទ្ធា ឃេ ច តថាគតសាវកា ”** *នេះ គប្បីជ្រាបពាក្យអធិប្បាយថា ព្រះបច្ចេកពុទ្ធជាម្ចាស់ទាំងឡាយ លោកឆ្លែតហើយ គឺបរិបូណ៌ហើយដោយលោកុត្តរធម៌ទាំង ៩ ប្រការ, តែមិនអាចដើម្បីឲ្យបុគ្គលទាំងឡាយដទៃ ឆ្លែតបានទេ, ព្រោះថា ការត្រាស់ដឹងរបស់សត្វទាំង-ឡាយ ដោយធម្មកថារបស់ព្រះបច្ចេកពុទ្ធទាំងឡាយនោះ រមែងមិនមាន ។ តែថា ទេវតា និងមនុស្សទាំងឡាយ មិនមានប្រមាណ មានការត្រាស់ដឹងធម៌ ដោយធម្មកថានៃព្រះសាវកទាំងឡាយ ។ ព្រះសាវកទាំងឡាយនោះ កាលសម្ដែងធម៌ មិនបានសម្ដែងឲ្យជាពាក្យសម្ដីរបស់ខ្លួនឯងទេ, តែសម្ដែងធម្មកថាធ្វើឲ្យជាពាក្យសម្ដីរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ, សូម្បីបរិស័ទដែលអង្គុយប្រជុំគ្នាដើម្បីនឹងស្ដាប់ ក៏ធ្វើសេចក្ដីគោរពថា “ ភិក្ខុរូបនេះ មិនបានសម្ដែងធម៌ដែលខ្លួនឯងបានចាក់ធ្លុះហើយទេ, គឺរមែងសម្ដែងធម៌ដែលព្រះពុទ្ធ*

ជាម្ចាស់ទាំងឡាយទ្រង់ត្រាស់ដឹងហើយ, ព្រោះហេតុដូច្នោះ ការធ្វើសេចក្ដីគោរពកោតក្រែង ទើបមានដល់ព្រះពុទ្ធជាម្ចាស់ទាំងឡាយនោះពិតៗ” ។

បណ្ដាបុគ្គលទាំងនោះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ប៉ុណ្ណោះ ឈ្មោះថាញុំាងបុគ្គលដទៃឲ្យឆ្អែត ដោយប្រការដូច្នេះ ដូចយ៉ាងថា កាលព្រះរាជាបញ្ជាថា ***“អ្នកទាំងឡាយ ចូរឱ្យវត្ថុនេះ និងវត្ថុនេះ ដល់បុគ្គលឈ្មោះឯណោះ”*** ដូច្នេះ, រាជបុរសនាំរបស់មកឲ្យដល់បុគ្គលឈ្មោះឯណោះ ក៏ពិតមែនហើយ, ប៉ុន្តែ ព្រះរាជាប៉ុណ្ណោះ ឈ្មោះថា ជាអ្នកឲ្យរបស់នោះ សូម្បីរបស់ដែលជនទាំងឡាយណា បានហើយ ជនទាំងនោះរមែងទទួលយកដោយគិតថា “ឋានន្តរៈ ដែលព្រះរាជាទ្រង់ព្រះរាជទានហើយ ដល់យើង សម្បត្តិ គឺឥស្សរិយយសដែលព្រះរាជាទ្រង់រាជទានហើយ ដល់យើងប៉ុណ្ណោះ”, តែកាន់យក ដោយសេចក្ដីគិតថា “ឋានន្តរជាដើម ដែលរាជបុរសទាំងឡាយឲ្យដល់ពួកយើង មិនមាន យ៉ាងណា”, សេចក្ដីឧបមាជាគ្រឿងញុំាងពាក្យឧបមេយ្យ ឲ្យដល់ព្រមនេះ បណ្ឌិតគប្បីជ្រាបដូច្នោះចុះ ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានសេចក្ដីងាយស្រួលទាំងអស់ ដោយប្រការដូច្នេះឯង ៕

ចប់អដ្ឋកថាទុកនិទ្ទេស

ត្រឹមតែប៉ុណ្ណោះ

## ៣.អដ្ឋកថាតិកនិទ្ទេស អធិប្បាយបុគ្គល ៣ ពំពូក
## ពណ៌នាអំពីបុគ្គលមិនមានសេចក្ដីសង្រួមជាដើម

បទថា **“ទុស្សីលោ”** បានដល់ អ្នកមិនមានសីល ។

បទថា **“បាបធម្មោ”** បានដល់ អ្នកមានធម៌ដ៏លាមក ។ មួយវិញទៀត ឈ្មោះថា ***អ្នកទ្រុស្តសីល*** ព្រោះសេចក្ដីវិបត្តិនៃសីល, ឈ្មោះថា ***អ្នកមានធម៌ដ៏លាមក*** ព្រោះសេចក្ដីវិបត្តិនៃទិដ្ឋិ ។ មួយវិញទៀត ឈ្មោះថា ***អ្នកទ្រុស្តសីល*** ព្រោះដាច់សេចក្ដីសង្រួមតាមកាយទ្វារ និងវចីទ្វារ, ឈ្មោះថា ***អ្នកមានធម៌ដ៏លាមក*** ព្រោះដាច់សេចក្ដីសង្រួមតាមមនោទ្វារ ។ ឈ្មោះថា ***អ្នកទ្រុស្តសីល*** ព្រោះភាពជាអ្នកប្រកបការងារដែលមិនស្អាត ។ ឈ្មោះថា ***អ្នកមានធម៌ដ៏លាមក*** ព្រោះភាពជាអ្នកមានអធ្យាស្រ័យដែលមិនស្អាត ។ ឈ្មោះថា ***អ្នកទ្រុស្តសីល*** ព្រោះវៀរចាកកុសលសីល, ឈ្មោះថា អ្នកមានធម៌ដ៏លាមក ព្រោះប្រកបដោយអកុសលសីល ។

បទថា **“អសុចិ = មិនស្អាត”** បានដល់ អ្នកប្រកបដោយកម្ម ដែលមិនស្អាតទាំងឡាយ មានកាយកម្មជាដើម ។

បទថា **“សង្កស្សរសមាចារោ”** បានដល់ អ្នកមានសមាចារដែលអ្នកដទៃ គប្បីរឭកបានដោយសេចក្ដីរង្កៀស, អធិប្បាយថា “អ្នកមានសមាចារ

ដែលអ្នកដទៃ ឃើញទោសយ៉ាងណាមួយ ដែលមិនសមគួរ ហើយរង្កៀស យ៉ាងនេះថា ‘កម្មនេះ នឹងជាអំពើដែលភិក្ខុនេះធ្វើហើយ” ឬមានសមាចារ ដែលខ្លួនគប្បីរពុកបាន ដោយសេចក្តីរង្កៀសរបស់ខ្លួននោះឯង ឈ្មោះថា អ្នកមានសមាចារដែលគួរឲ្យរង្កៀស ។ ក៏ព្រោះគេឃើញពួកភិក្ខុប្រជុំប្រឹក្សាគ្នា ដល់កិច្ចយ៉ាងណាមួយនោះឯង ក្នុងកន្លែងជាទីសម្រាកពេលថ្ងៃជាដើម ទើបគេមានសមាចារដែលគួររង្កៀសយ៉ាងនេះថា “ពួកភិក្ខុទាំងនេះ ដឹងកម្មដែលយើងធ្វើឬ ទើបប្រឹក្សាគ្នា” ។ បទថា **“បដិច្ឆន្នកម្មន្តោ”** បានដល់ប្រកបដោយធម៌ដ៏លាមក ដែលសមគួរដល់ការបិទបាំង ។

ពីរបទថា **“អស្សមណោ សមណបដិញ្ញោ”** សេចក្តីថា អ្នកមិនមែនជាសមណៈឡើយ, តែប្តេជ្ញាខ្លួនយ៉ាងនេះថា ***“យើងជាសមណៈ”*** ព្រោះជាអ្នកមានគុណធម៌ដែលគួរដល់ភាពជាសមណៈ ។

ពីរបទថា **“អព្រហ្មចារី ព្រហ្មចារីបដិញ្ញោ”** សេចក្តីថា ក៏ភិក្ខុអ្នកទ្រុស្តសីលនោះ ឃើញសម្លាញ់សហធម្មិក ជាព្រហ្មចារី អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ស្លៀកដណ្តប់រៀបរយទ្រទ្រង់បាត្រល្អឥតខ្ចោះ ត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងស្រុក (គាម) និគមជនបទ និងរាជធានីទាំងឡាយ ហើយសម្រេចការចិញ្ចឹមជីវិត, សូម្បីខ្លួនឯង ក៏បដិបត្តិដូច្នោះ ដោយអាការដូច្នោះ រមែងដូចជាអ្នកឲ្យប្តេជ្ញាថា ***“ខ្ញុំព្រះករុណា ជាព្រហ្មចារី”*** ពោលថា ខ្ញុំព្រះករុណា

ជាភិក្ខុ ហើយចូលទៅកាន់រោងឧបោសថជាដើម រមែងប្តេជ្ញាថា ខ្លួនជាព្រហ្មចារីបុគ្គលពិតៗ ។ បុគ្គលដែលកាន់យកលាភដែលជារបស់សង្ឃ ក៏មានន័យដូចគ្នានេះដែរ ។

បទថា **“អន្តោបូតិ”** បានដល់ អ្នកមានកម្មដ៏ស្អុយតាមចូលទៅខាងក្នុង ។ ម្យ៉ាងទៀត ឈ្មោះថា អ្នកស្អុយក្នុង ព្រោះវៀរចាកសារនៃគុណ ដោយភាពជាអ្នកមិនមានគុណ ។

បទថា **“ អវស្សុតោ”** បានដល់ អ្នកមានរាគៈជាដើមទទឹកហើយ; បទថា **“កសម្ពុជាតោ * ”** បានដល់ អ្នកមានរាគៈជាដើមកើតឡើងហើយ ។ ម្យ៉ាងទៀត ទឹកបដិកូលចូលទៅកាន់សាកសពដែលទទឹក ព្រះអដ្ឋក៏ត្រាស់ហៅថា ***កសម្ពុ*** ។ ក៏បុគ្គលឈ្មោះថា ***អ្នកទ្រុស្តសីល*** ក្នុងព្រះសាសនានេះ ដូចទឹកលឿងដែលសើមក្នុងសាកសព ព្រោះភាពនៃខ្លួនជាអ្នកដែលបណ្ឌិតគប្បីស្អប់ ព្រោះហេតុដូច្នោះ បុគ្គលឯណា ដូចជាទឹកលឿងនៃសាកសព បុគ្គលនោះ ទើបឈ្មោះថា ***កសម្ពុជាត*** ។

បទថា **“តស្ស ន ឯវំ ហោតិ”** សេចក្តីថា ព្រោះហេតុអ្វី ទើបលោកមិនមានសេចក្តីគិតយ៉ាងនោះទេ ? ព្រោះសីលដែលលោកតាំងនៅ

* បាលីថា កសម្ពុកជាតោ ។

*ហើយ គប្បីអាចដើម្បីនឹងបានព្រះអរហត្ត លោកក៏ទម្លាយចេញហើយ, ដូចយ៉ាងថា កូនមនុស្សចណ្ឌាល សូម្បីបានឮថា ខត្តិយកុមារឈ្មោះឯណោះ ចូរអភិសេកក្នុងរាជសម្បត្តិ ក៏ព្រោះជនទាំងឡាយ អ្នកកើតខាងក្រោយក្នុងត្រកូលឯណា រមែងដល់ការអភិសេកខ្លួន, មិនបានកើតក្នុងត្រកូលនោះ ទើបមិនបានសេចក្តីគិតយ៉ាងនេះថា សូម្បីឈ្មោះថា យើងនោះ ក៏នឹងគប្បីដល់ការអភិសេកដូចខត្តិយកុមារដោយពិតៗ យ៉ាងណា ភិក្ខុអ្នកទ្រុស្តសីល សូម្បីស្តាប់ថា* ***"ភិក្ខុឈ្មោះឯណោះ សម្រេចព្រះអរហត្ត"*** *ដូច្នេះ ព្រោះភាវៈនៃសីលដែលខ្លួនតាំងនៅហើយនោះមិនមាន ទើបមិនមានសេចក្តីគិតយ៉ាងនេះថា "សូម្បីឈ្មោះថាយើងនោះ នឹងគប្បីសម្រេចព្រះអរហត្ត ដូចភិក្ខុអ្នកមានសីលដោយពិតៗ" ដូចគ្នា ។*

*ពីរបទថា* **"អយំ ទុច្ចតិ"** *សេចក្តីថា បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា* **និរាសោ** *អ្នកមិនមានបំណង ព្រោះមិនមានសង្ឃឹមដែលនឹងបានជាព្រះអរហត្ត ។*

*បទថា* **"តស្ស ឯវំ ហោតិ"** *សេចក្តីថា ព្រោះហេតុនៃសីលដែលលោកតាំងនៅហើយ អាចដើម្បីសម្រេចព្រះអរហត្តជាសភាពមាំមួន ។ ដូចយ៉ាងថា កុមារអ្នកសុជាតិ គឺកើតល្អហើយ ខណៈស្តាប់ពាក្យថា* ***"ខត្តិយកុមារឈ្មោះឯណោះ គេអភិសេកហើយ"*** *ព្រោះហេតុដែលខ្លួនកើត*

*ក្នុងត្រកូលនោះ ទើបមានសេចក្តីត្រិះរិះយ៉ាងនេះថា* ***“សូម្បីយើងក៏គប្បីដល់ការអភិសេក ដូចកុមារនោះដោយពិត។”*** *យ៉ាងណា ភិក្ខុអ្នកមានសីល ខណៈបានឮថា* ***“ភិក្ខុឈ្មោះឯណោះ សម្រេចព្រះអរហត្តហើយ”*** *ព្រោះហេតុនៃសីលដែលលោកតាំងនៅហើយ គួរនឹងសម្រេចព្រះអរហត្ត ជាធម្មជាតិមាំមួន ទើបមានសេចក្តីគិតយ៉ាងនេះថា* ***“សូម្បីយើងក៏គប្បីសម្រេចព្រះអរហត្ត ដូចនឹងភិក្ខុអ្នកមានសីលដោយពិត។”*** *ដូចគ្នា ។ បទថា* **“អយំ ខុច្ចតិ”** *សេចក្តីថា បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា* **អាសំសោ** *បុគ្គលដែលមានបំណង ព្រោះថា លោកនោះមានសង្ឃឹមហើយ គឺប្រាថ្នានូវព្រះអរហត្ត ព្រោះហេតុនោះ ទើបលោកហៅថា* **អាសំសោ** *= បុគ្គលដែលមានបំណង ។*

*បទថា* **“យាហិស្ស បុព្វេ អវិមុត្តស្ស”** *សេចក្តីថា បំណងក្នុងការរួចផុតកម្រិតណា របស់ព្រះខីណាស្រពដែលមិនបានរួចផុត ដោយការរួចផុតដោយអរហត្តមគ្គ ក្នុងកាលមុន បំណងនោះរបស់លោកស្ងប់រម្ងាប់ហើយ ព្រោះហេតុដូច្នោះ ទើបព្រះខីណាស្រពលោកមិនមានការគិតយ៉ាងនោះឡើយ; ដូចយ៉ាងក្សត្រដែលអភិសេកហើយ ខណៈទ្រង់ស្តាប់ពាក្យថា “ខត្តិយកុមារឈ្មោះឯណោះ គេអភិសេកក្នុងរាជសម្បត្តិហើយ” ព្រោះ*

ព្រះរាជាមួយអង្គមិនមានការអភិសេកពីរដង មិនមានស្វេតច្ឆត្រពីរដង ទើបមិនមានសេចក្តីត្រិះរិះយ៉ាងនេះថា សូម្បីយើងក៏គប្បីដល់ការអភិសេក ដូចខត្តិយកុមារនោះដោយពិតៗ យ៉ាងណា, ព្រះខីណាស្រពខណៈបានព្ទថា "ភិក្ខុឈ្មោះឯណោះ សម្រេចព្រះអរហត្តហើយ" ដូច្នេះ ព្រោះភាពជាព្រះអរហត្តពីរដងមិនមាន ទើបលោកមិនមានការគិតយ៉ាងនេះថា "សូម្បីយើងក៏នឹងគប្បីសម្រេចព្រះអរហត្ត ដូចភិក្ខុនោះ ដោយពិតៗ" ដូច្នេះ ។ បទថា "**អយំ ទុច្ចតិ**" សេចក្តីថា បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា **ទិគតាសោ** គឺបុគ្គលប្រាសចាកបំណង ព្រោះលោកប្រាសចាកបំណងក្នុងភាពជាព្រះអរហន្ត ។

---

## ពណ៌នាអំពីគិលានូបមបុគ្គលជាដើម

ជនទាំងនោះ លោកហៅថា **គិលានូបមា** គឺអ្នកប្រៀបដូចបុគ្គលឈឺដោយឧបមាណា ដើម្បីនឹងសម្តែងឧបមានោះមុន ទើបលោកពោលពាក្យជាដើមថា "**តយោ គិលានា**" ។ បណ្តាបទទាំងនោះ បទថា "**សប្បាយានិ**" បានដល់ ការដែលជាប្រយោជន៍ គឺធ្វើឲ្យចម្រើន ។ បទថា "**បដិរូបំ**" បានដល់ គួរ ។ ដោយពាក្យថា "**នេវ វុដ្ឋាតិ តម្ហា អាពាធា**" ព្រះមានព្រះភាគត្រាស់ដល់បុគ្គលជាអ្នកឈឺដែលដល់ទីបំផុតហើយ ប្រកបដោយ

រោគទាំងឡាយ មានរោគខ្យល់ និងរោគឆ្អួតជ្រូកជាដើម ដែលដោះស្រាយមិនបាន ។ ដោយពាក្យថា **"ទុដ្ឋាតិ តម្ហា អាពាធា"** នេះ ព្រះអង្គត្រាស់ដល់អាពាធបន្តិចបន្តួចដែលផ្សេងដោយរោគទាំងឡាយ មានរោគកណ្តាស់ រោគកមរមាស់ រោគស្នាមចុចៗ រោគបូស និងរោគចាស់ជរាជាដើម ។ ក៏សេចក្តីសុខរបស់ជនពួកណា រមែងមានដោយការបដិបត្តិ ព្រះមានព្រះភាគត្រាស់ សំដៅដល់បុគ្គលដែលអាពាធទាំងអស់នោះ ដោយពាក្យថា **"លភន្តោ សប្បាយានិ នោ អលភន្តោ"** ដូច្នេះនេះ ។

ក៏ក្នុងទីនេះ បុគ្គលដែលឧបដ្ឋាកមនុស្សឈឺ ត្រូវប្រកបទៅដោយអង្គគុណទាំងឡាយ គឺជាបណ្ឌិត ១, ជាអ្នកឧស្សាហ៍ ១, មិនខ្ជិលច្រអូស ១, គប្បីជ្រាបថា ឈ្មោះថា ***ឧបដ្ឋាកសមគួរ*** ។

បទថា **"គិលានុបដ្ឋាកោ អនុញ្ញាតោ"** សេចក្តីថា បុគ្គលណាដែលភិក្ខុសង្ឃគប្បីឲ្យ ព្រោះហេតុដូច្នោះ បុគ្គលនោះ ទើបឈ្មោះថា **អនុញ្ញាតោ** = អ្នកដែលភិក្ខុសង្ឃអនុញ្ញាតហើយ ។ ក៏បុគ្គលជាអ្នកឈឺនោះ កាលមិនអាចដើម្បីញុំាងអត្តភាពឲ្យប្រព្រឹត្តទៅតាមធម្មតារបស់ខ្លួន ភិក្ខុសង្ឃគប្បីអបលោកឲ្យដោយពាក្យថា ***"សូមឱ្យភិក្ខុ ឬសាមណេរមួយរូប បដិបត្តិទំនុកបម្រុងភិក្ខុដែលអាពាធនេះ"***, ក៏បើភិក្ខុ ឬសាមណេរនោះ នៅបដិបត្តិ ភិក្ខុអ្នកអាពាធ

*នោះ ដរាបណា, អ្នកឈឺក្ដី ភិក្ខុ ឬសាមណេរក្ដី មានសេចក្ដីត្រូវការដោយវត្ថុណា វត្ថុទាំងអស់នោះ ជាភារៈដល់សង្ឃប៉ុណ្ណោះ ។*

*បទថា* **“អញ្ញម្បិ គិលានា ឧបដ្ឋាតព្វា”** *សេចក្ដីថា បុគ្គលជាអ្នកឈឺ ២ ជំពូក សូម្បីក្រៅអំពីនេះ ភិក្ខុសង្ឃក៏គួរឧបដ្ឋាកដែរ ។*

***សួរថា*** *ព្រោះហេតុអ្វី ?*

*ឆ្លើយថា “ព្រោះបុគ្គលឯណា ជាអ្នកឈឺដល់ទីបំផុតហើយ អ្នកនោះកាលមិនមាននរណាឧបដ្ឋាក ក៏គប្បីអន់ចិត្តថា ប្រសិនបើ ភិក្ខុ ឬសាមណេរគប្បីបដិបត្តិយើង, សេចក្ដីសុខនឹងគប្បីមានដល់យើង; តែពួកគេមិនបដិបត្តិយើងទេ” ដូច្នេះ ហើយគប្បីទៅកើតក្នុងអបាយ ។ ក៏អ្នកឈឺនោះកាលបើ ភិក្ខុសាមណេរ ទំនុកបម្រុងបដិបត្តិហើយ គេរមែងមានសេចក្ដីគិតយ៉ាងនេះថា* ***“កិច្ចឯណា ដែលភិក្ខុសង្ឃគប្បីធ្វើ កិច្ចទាំងអស់នោះ ភិក្ខុសង្ឃក៏ធ្វើហើយ តែយើងមានកម្មវិបាក”*** *ភិក្ខុដែលអាពាធនោះ ញុំាងមេត្តាចិត្តឲ្យតាំងឡើងក្នុងភិក្ខុសង្ឃ ហើយកើតក្នុងឋានសួគ៌ ។*

*មួយទៀត ភិក្ខុឯណា មានអាពាធបន្តិចបន្តួច បានឧបដ្ឋាកក៏ដោយមិនបានក៏ដោយ រមែងសះស្បើយអំពីរោគបាន ភិក្ខុដែលអាពាធបន្តិចបន្តួចនោះ សូម្បីវៀរចាកភេសជ្ជៈ ព្យាធិក៏អាចស្ងប់រម្ងាប់បាន,* ***តែបើគេធ្វើ***

***ភេសជ្ជៈឱ្យឆាន់*** អាពាធបន្តិចបន្តួចនោះ ក៏រមែងស្ងប់រម្ងាប់បានដោយឆាប់រហ័ស ។

*លំដាប់នោះ អ្នកជំងឺដែលសះស្បើយអំពីរោគហើយនោះ គេអាចដើម្បីរៀនព្រះពុទ្ធវចនៈ ឬធ្វើសមណធម៌ ដោយហេតុនេះ ទើបលោកពោលទុកថា* ***"ភិក្ខុសង្ឃគប្បីឧបដ្ឋាកអ្នកជំងឺសូម្បីពួកដទៃ"*** ។

*បទថា* **"នេវ ឱក្កមតិ"** *បានដល់ មិនបានចូលទៅ ។*

*បទថា* **"និយាមំ កុសលេសុ ធម្មេសុ សម្មត្តំ"** *បានដល់ សម្មតធម៌ ពោលគឺមគ្គនិយាមក្នុងកុសលធម៌ទាំងឡាយ ព្រះមានព្រះភាគទ្រង់ត្រាស់ដល់បុគ្គលដែលមានបទយ៉ាងក្រៃលែង (បទបរម) ដោយធម៌ខនេះ ។ ទ្រង់កាន់យកឧគ្ឃដិតញ្ញូបុគ្គល ដូចជាព្រះនាលកត្ថេរក្នុងព្រះសាសនាដោយវារៈទី ២ និងទ្រង់កាន់យកឧគ្ឃដិតញ្ញូបុគ្គលដែលមានបច្ចេកពោធិញ្ញាណ ដែលលោកបានទិវាទក្នុងសំណាក់នៃព្រះបច្ចេកពុទ្ធទាំងឡាយ មួយដងក្នុងពុទ្ធន្តរ ហើយទើបចាក់ធ្លុះសច្ចធម៌ គឺសម្រេចជាព្រះបច្ចេកពុទ្ធ ។ ព្រះអង្គទ្រង់ពោលដល់វិបចិតញ្ញូបុគ្គលដោយវារៈទី ៣ ។ ក៏នេយ្យបុគ្គលរមែងជាអ្នកអាស្រ័យវិបចិតញ្ញូបុគ្គលនោះឯង ។*

*បទថា* **"ធម្មទេសនា អនុញ្ញាតា"** *សេចក្តីថា ព្រះអង្គទ្រង់អនុញ្ញាតព្រះធម្មទេសនាមួយខែៗ ៨ ដង ។*

បទថា **"អរញ្ញសម្បិ ធម្មោ ទេសេតព្វោ"** សេចក្តីថា ព្រះធម្មកថិកគួរពោលធម៌ដល់ជនទាំងឡាយ សូម្បីក្រៅអំពីនេះ ។

***សួរថា*** ព្រោះហេតុអ្វី ?

ឆ្លើយថា "ព្រោះបទបរមបុគ្គល សូម្បីមិនអាចចាក់ធ្លុះធម៌ក្នុងអត្តភាពនេះ, តែក៏នឹងជាបច្ច័យទៅក្នុងកាលខាងមុខ" ។

មួយទៀត អ្នកជំងឺឯណា បានឃើញរូបព្រះតថាគតក្តី មិនបានឃើញក្តី, និងបានព្រះធម្មវិន័យក្តី មិនបានក្តី, គេរមែងត្រាស់ដឹងធម៌បាន អ្នកជំងឺនោះ កាលមិនបានត្រាស់ដឹងនៅឡើយ, តែកាលបានបច្ច័យដ៏សមគួរក៏នឹងត្រាស់ដឹងបានដោយឆាប់រហ័សនោះតែម្តង, ព្រោះហេតុដូច្នោះ ព្រះធម្មកថិកទាំងឡាយ គប្បីសម្តែងធម៌ដល់ជនទាំងឡាយនោះ ដោយហេតុដែលពោលមកនេះ ។ តែថា ត្រូវសម្តែងធម៌ដល់បុគ្គលទី ៣ ជារឿយៗ ។

---

## ពណ៌នាអំពីកាយសក្ខីបុគ្គលជាដើម

បុគ្គលទាំងឡាយ ដែលឈ្មោះថា ***កាយសក្ខី ទិដ្ឋិប្បត្តៈ*** និង ***សទ្ធាវិមុត្ត*** ខ្ញុំបានពោលទុកហើយ ខាងក្រោយឯណោះ ។

## ពណ៌នាអំពីគូថភាណីបុគ្គលជាដើម

បទថា **"សភគ្គោ"** បានដល់ នៅក្នុងសភា គឺទីប្រជុំ ។

បទថា **"បរិសគ្គតោ"** បានដល់ នៅក្នុងបរិស័ទអ្នកស្រុក ។

បទថា **"គាមមជ្ឈគ្គតោ"** បានដល់ នៅកណ្ដាលអ្នកជនបទទាំងឡាយ ។

បទថា **"ញាតិមជ្ឈគ្គតោ"** បានដល់ នៅក្នុងកណ្ដាលនៃទាយាទទាំង-ឡាយ (អ្នកទទួលមរតក ហៅថា ទាយាទ) ។

បទថា **"បូគមជ្ឈគ្គតោ"** បានដល់ នៅកណ្ដាលអាមាត្យទាំងឡាយ ។

បទថា **"រាជកុលមជ្ឈគ្គតោ"** បានដល់ នៅក្នុងរោងមហាវិនិច្ឆ័យត្រង់កណ្ដាលរាជត្រកូល ។

បទថា **"អភិនីតោ"** បានដល់ ត្រូវគេនាំទៅដើម្បីប្រយោជន៍ដល់ការសួរ ។

បទថា **"សក្ខិបុដ្ឋោ"** បានដល់ ត្រូវគេធ្វើឲ្យជាសាក្សីហើយសួរ ។

ពាក្យថា **"ឯហម្ភោ បុរិស"** នេះ ជាអាលបនៈគឺពាក្យសម្រាប់ហៅ ។

ពាក្យថា **"អត្តហេតុ វា បរហេតុ វា"** បានដល់ ព្រោះហេតុនៃអវយវៈ មានដៃ និងជើងជាដើម ឬព្រោះហេតុនៃទ្រព្យរបស់ខ្លួន ឬរបស់អ្នកដទៃ ។

*ក្នុងពាក្យថា* **“អាមិសកិញ្ចិក្ខហេតុ ខា”** *នេះ លាភ លោកប្រាថ្នា យកថា* ***អាមិស*** *គឺរបស់ផ្សេងៗ ។*

*ពាក្យថា* **“កិញ្ចិក្ខំ”** *បានដល់ ប្រាក់ជំនួញណាៗ ក៏ដោយ ដែលមានប្រមាណបន្តិចបន្តួច អធិប្បាយថា ព្រោះហេតុនៃប្រាក់ជំនួញ មានប្រមាណតិចតួច ដោយហោចទៅ មានសត្វទា សត្វចាបពូក ដុំទឹកដោះថ្លា និងដុំទឹកដោះខាប់ជាដើម ។*

*ពីរបទថា* **“សម្បជានមុសា ភាសិតា ហោតិ”** *សេចក្ដីថា ធ្វើការពោលមុសាវាទ ទាំងដែលដឹងខ្លះហើយនោះឯង ។*

*ពីរបទថា* **“អយំ ទុច្ចតិ”** *សេចក្ដីថា បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា* ***គូថភាណី*** *គឺអ្នកមានវាទៈដូចលាមក ព្រោះមានវាចាដូចនឹងលាមក (ខុច្ចារៈ) លោកអធិប្បាយទុកដូចយ៉ាងថា ក៏ឈ្មោះថា លាមក មិនជាទីពេញចិត្តដល់មហាជន យ៉ាងណា, ពាក្យនិយាយរបស់បុគ្គលពោលកុហកនេះ ក៏មិនជាទីពេញចិត្តដល់ទេវតា និងមនុស្សទាំងឡាយដូច្នោះដែរ ។*

*ពីរបទថា* **“អយំ ទុច្ចតិ”** *សេចក្ដីថា បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា* ***បុប្ផភាណី*** *គឺអ្នកមានវាចាដូចផ្កាឈើ ។ ដូចយ៉ាងថា ផ្កាម្លិះទាំងឡាយ ទាំងដែលកំពុងក្រពុំ ឬកំពុងរីក រមែងជាទីស្រឡាញ់ ជាទីប្រាថ្នារបស់មហាជន យ៉ាងណា, វាចារបស់បុគ្គលនេះ ក៏រមែងជាទីស្រឡាញ់*

ពេញចិត្តរបស់ទេវតា និងមនុស្សទាំងឡាយ យ៉ាងនោះដែរ ។

**ទោសោ** គឺទោសៈ លោកហៅថា **ឯលំ** = សេចក្ដីអាក្រក់, ក្នុងពាក្យថា **"នេលា"** វិគ្រោះថា ទោសរបស់វាចានោះមិនមាន ព្រោះហេតុនោះ វាចានោះ ទើបហៅថា **នេលា** = វាចាមិនមានទោស ។ អធិប្បាយថា អត់ទោស ដូចទោសដែលពោលទុកក្នុងពាក្យថា **"នេលង្គោ សេតបច្ឆាទោ"** ។

បទថា **"កណ្ណសុខា"** បានដល់ ឈ្មោះថា នាំមកនូវសេចក្ដីសុខដល់ត្រចៀកទាំងពីរ ព្រោះជាវាចាពីរោះដោយព្យញ្ជនៈ, អធិប្បាយថា មិនធ្វើការចាក់ដោតត្រចៀកឲ្យកើតឡើង, ដូចការចាក់ដោតដោយម្ជុលទាំងឡាយ ។ គប្បីជ្រាបវិគ្រោះផ្សេង ៗ ដូច្នេះ ៖

វាចាណា មិនញ៉ាំងសេចក្ដីក្រោធឲ្យកើតឡើងក្នុងសរីរៈទាំងអស់ រមែងញ៉ាំងសេចក្ដីស្រឡាញ់ឲ្យកើត ព្រោះជាវាចាពីរោះដោយអត្ថ ព្រោះហេតុនោះ វាចានោះ ទើបឈ្មោះថា **បេមនីយា** = គួរជាទីស្រឡាញ់ ។

វាចាណា រមែងទៅកាន់ហឫទ័យ មិនមានអ្វីៗ មកប៉ះខ្ទប់ ចូលទៅកាន់ចិត្ត ដោយសប្បាយ ព្រោះហេតុនោះ វាចានោះ ទើបឈ្មោះថា **ហទយង្គមា** = ពេញហឫទ័យ ។

វាចាណា ជារបស់អ្នកនៅក្នុងក្រុង ព្រោះជាវាចាដែលសម្បូណ៌ដោយ

គុណ ព្រោះហេតុនោះ វាចានោះ ទើបឈ្មោះថា បោរីវាចាអ្នកក្រុង ។ វាចាឯណា ដែលពោលហៅថា **"ម្នាលកុមារដ៏ល្អ ដូចនារីដែលមានវណ្ណធម៌ដ៏ល្អ"** សូម្បីវាចានេះ ក៏ហៅថា បោរីវាចាដែរ ។ វាចាណា ជារបស់មានហើយដល់អ្នកក្រុង សូម្បីវាចានោះ ក៏ឈ្មោះថាបោរីវាចាដែរ ។ អធិប្បាយថា ជាពាក្យសម្តីរបស់អ្នកក្រុង ។ ពិតមែនហើយ អ្នកក្រុងទាំងឡាយមានពាក្យសម្តីដែលគួរសម រមែងពោលហៅបុគ្គលដែលសមគួរជាឪពុកថា "ឪពុក" ហៅអ្នកសមគួរជាម៉ែថា "ម៉ែ" និងពោលហៅអ្នកសមគួរ ជាបងប្អូនប្រុសថា "បងប្រុស ប្អូនប្រុស" ។

ពាក្យសម្តីឯណា (ដែលពោលមកហើយ) បែបនេះ រមែងជាទីស្រឡាញ់ពេញចិត្តដល់ជនជាចំនួនច្រើន ព្រោះហេតុដូច្នោះ វាចានោះ ទើបឈ្មោះថា **ពហុជនកន្តា** = វាចាជាទីពេញចិត្តរបស់មនុស្សចំនួនច្រើន ។

វាចាឯណា ជាទីញ៉ាំងចិត្តឲ្យសប្បាយរីករាយ គឺធ្វើសេចក្តីចម្រើនដល់ចិត្តរបស់ជនជាចំនួនច្រើន ដោយសេចក្តីជាវាចាដែលពេញចិត្តនោះឯង ។ ព្រោះហេតុដូច្នោះ វាចានោះ ទើបឈ្មោះថា **ពហុជនមនាបា** = វាចាជាទីពេញចិត្តដល់ជនជាចំនួនច្រើន ។

ពីរបទថា **"អយំ ខុច្ចតិ"** សេចក្តីថា បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា **មធុភាណី** = អ្នកមានវាចាដូចទឹកឃ្មុំ ។ បាលីថា **"មធុភាណី** =

មានរាវចាទន់ភ្លន់ដូច្នេះខ្លះ ។ អធិប្បាយថា ជារាវចាពីរោះសូម្បីទាំង ២ ដូចយ៉ាងថា ធម្មតា ចតុមធុរស គឺរសផ្សំដោយវត្ថុ ៤ យ៉ាង មានប្រេងធ្មើពីទឹកដោះសត្វ ១, ប្រេងល្ង ១, ទឹកឃ្មុំ ១ និងទឹកត្នោត ១ កាលលាយច្របល់គ្នាហើយបានក្លាយជារសដ៏ប្រណីត យ៉ាងណា, ពាក្យសម្ដីរបស់បុគ្គលនេះ ក៏ជារបស់ពីរោះដល់ទេវតា និងមនុស្សទាំងឡាយដូច្នោះដែរ ៕

---

## ពណ៌នាអំពីអរុក្ខបមចិត្តបុគ្គលជាដើម

បទថា **“អភិសជ្ជតិ”** បានដល់ រមែងភ្ជក់ចិត្ត ។

បទថា **“កុប្បតិ”** បានដល់ រមែងកម្រើកដោយសារសេចក្ដីក្រោធ ។

បទថា **“ព្យាបជ្ជតិ”** បានដល់ រមែងលះបង់នូវភាវៈប្រក្រតី ទើបឈ្មោះថា ជាអ្នកស្អុយ ។

បទថា **“បតិដ្ឋីយតិ”** បានដល់ រមែងដល់ភាពជាអ្នករឹងប៉ឹង និងថោកទាប ។

បទថា **“កោបំ”** បានដល់ សេចក្ដីក្រោធដែលមានកម្លាំងខ្សោយ ។

បទថា **“ទោសំ”** បានដល់ ទោសដែលមានកម្លាំងច្រើនជាងសេចក្ដីក្រោធនោះ ដោយអំណាចនៃការប្រទូស្តរ៉ាយ ។

បទថា **"អប្បច្ចយំ"** បានដល់ ទោមនស្ស គឺសេចក្តីខូចចិត្ត ដែលមានអាការមិនត្រេកអរ ។

បទថា **"ធុដ្ឋារុគោ"** បានដល់ ដំបៅពុំរ៉ៃ ។

បទថា **"ករដ្ឋន"** បានដល់ ដោយចុងកំណាត់ឈើ ។

បទថា **"កថលាយ"** បានដល់ ដោយអំបែងក្បឿង ។

បទថា **"អាសខំ ឧធតិ"** បានដល់ រមែងហូរចេញច្រើន ។

ក៏តាមធម្មតាដំបៅពុំរ៉ៃនោះ រមែងហូរចេញនូវវត្ថុបដិកូល ៣ យ៉ាង គឺ **បុព្វំ** = ទឹកខ្ទុះ, **លោហិតំ** = ទឹកឈាម, **យូសំ** = ទឹកហូរពីមុខរបួស (ទឹករងៃ) ។ ក៏ដំបៅនោះ អ៊ីៗ ខ្ទប់ហើយ វត្ថុបដិកូលទាំងនោះ រមែងហូរចេញមកច្រើន ។

ពាក្យថា **"ឯវមេវ ខោ"** នេះ មានការប្រៀបធៀបដោយសេចក្តីឧបមា ដូចតទៅនេះ ៖

ក៏បុគ្គលដែលតែងតែក្រោធ លោកប្រៀបដូចដំបៅពុំរ៉ៃ (ដំបៅស្អុយរលួយ) ការប្រព្រឹត្តសូម្បីរបស់អ្នកចូលចិត្តក្រោធ ប្រៀបដូចការហូរចេញរបស់វត្ថុបដិកូល ៣ យ៉ាង មានទឹកខ្ទុះជាដើម តាមធម្មតារបស់ខ្លួន សេចក្តីប្រទូសរ៉ាយប្រៀបដូចសាកសពដែលហើមប៉ោងឡើង តាមធម្មតារបស់ខ្លួន ពាក្យសម្តីរបស់អ្នកតែងតែក្រោធនោះ សូម្បីមានប្រមាណបន្តិចបន្តួច លោក

កំប្រៀបដូចការប៉ះទង្គិចដោយកំណាត់ឈើ ឬអំបែងក្បឿង បណ្ឌិតគប្បី ឃើញភាវៈ គឺការប៉ោងឡើងដោយប្រមាណច្រើនសន្ទឹកសន្ធាប់ របស់អ្នកចូលចិត្តក្រោធនោះ ដោយការគិតយ៉ាងនេះថា "បុគ្គលនេះ និយាយយ៉ាងនេះឈ្មោះអ្នកដូចនឹងយើង" លោកប្រៀបដូចការហូរចេញច្រើនសន្ទឹកសន្ធាប់នៃវត្ថុបដិកូលទាំងឡាយ ។

ពីរបទថា "**អយំ វុច្ចតិ**" សេចក្ដីថា បុគ្គលនេះ គឺអ្នកបែបនេះ ហៅថា **អរុក្ខូបមចិត្តោ** = អ្នកមានចិត្តប្រៀបដោយដំបៅរ៉ាំរ៉ៃ អធិប្បាយថា អ្នកមានចិត្តប្រៀបដូចដំបៅទុំស្អុយ ។

បទថា "**រត្តន្ធការតិមិសាយ**" សេចក្ដីថា ក្នុងភាពងងឹតអ័ព្ទ ដែលធ្វើភាពងងឹត ដោយហាមការកើតឡើងនៃចក្ខុវិញ្ញាណក្នុងវេលាយប់ ។

បទថា "**វិជ្ជន្តរិកាយ**" បានដល់ ក្នុងខណៈនៃផ្លេកបន្ទោរប្រព្រឹត្តទៅ ។ សូម្បីក្នុងពាក្យថា "**វិជ្ជន្តរិកាយ**" នេះ គប្បីជ្រាបការប្រៀបធៀបដោយឧបមា ដូចតទៅនេះ ៖

ព្រះយោគាវចរ គឺអ្នកធ្លាក់ចុះកាន់សេចក្ដីព្យាយាម បណ្ឌិតគប្បីជ្រាបដូចបុរសអ្នកមានចក្ខុល្អ កិលេសទាំងឡាយដែលព្រះសោតាបត្តិមគ្គ គប្បីប្រហារ ប្រៀបដូចសេចក្ដីងងឹត, ការកើតឡើងនៃសោតាបត្តិមគ្គញ្ញាណប្រៀបដូចផ្លេកបន្ទោរ, ការឃើញព្រះនិព្វានក្នុងខណៈនៃសោតាបត្តិមគ្គ

ប្រៀបដូចការឃើញរូបដោយជុំវិញ របស់បុរសដែលមានចក្ខុក្នុងចន្លោះនៃផ្លេកបន្ទោរ ។ កិលេសទាំងឡាយ ដែលព្រះសកទាគាមិមគ្គគប្បីប្រហារ ប្រៀបដូចការរំខាន គឺការគ្របដណ្តប់ដោយភាពងងឹតទៀត, ការកើតឡើងនៃសកទាគាមិមគ្គ ប្រៀបដូចផ្លេកបន្ទោរប្រព្រឹត្តទៅទៀត, ការឃើញព្រះនិព្វានក្នុងខណៈនៃសកទាគាមិមគ្គ ប្រៀបដូចការឃើញរូបដោយជុំវិញរបស់បុរសដែលមានចក្ខុក្នុងចន្លោះនៃផ្លេកបន្ទោរ ។ កិលេសទាំងឡាយ ដែលព្រះអនាគាមិមគ្គគប្បីប្រហារ ប្រៀបដូចជាការរំខាន គឺការគ្របដណ្តប់ដោយសេចក្តីងងឹតទៀត, ការកើតឡើងនៃអនាគាមិមគ្គញ្ញាណ ប្រៀបដូចផ្លេក-បន្ទោរប្រព្រឹត្តទៅទៀត, ការឃើញព្រះនិព្វាន ក្នុងខណៈនៃអនាគាមិមគ្គ ប្រៀបដូចការឃើញរូបដោយជុំវិញ របស់បុរសដែលមានចក្ខុ ក្នុងចន្លោះនៃផ្លេកបន្ទោរ ។

ពីរបទថា **“អយំ វុច្ចតិ”** សេចក្តីថា បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា **“វិជ្ជូបមចិត្តោ** = បុគ្គលមានចិត្តប្រៀបដូចផ្លេកបន្ទោរ ។ អធិប្បាយថា អ្នកមានចិត្ត ដូចជាផ្លេកបន្ទោរ ព្រោះភាពភ្លឺក្នុងវេលាដែលប្រហារមានបន្តិចបន្តួច ។

ក្នុងសេចក្តីដែលបុគ្គលមានចិត្ត ប្រៀបដោយគ្រាប់ពេជ្រ មានការប្រៀបធៀបដោយឧបមាដូចតទៅនេះ ៖

ក៏បណ្ឌិតគប្បីជ្រាបញាណក្នុងអរហត្តមគ្គ ប្រៀបដូចគ្រាប់ពេជ្រ ។ កិលេសទាំងឡាយ ដែលអរហត្តមគ្គគប្បីប្រហារ ប្រៀបដូចដុំកែវមណី ឬដុំថ្ម បណ្ឌិតគប្បីជ្រាបកិលេសទាំងឡាយ ត្រូវកាត់ដាច់ដោយអរហត្តមគ្គ-ញាណ ប្រៀបដូចការមិនមាននៃភាវៈដែលដុំកែវមណី ឬដុំថ្ម ដែលត្រូវគ្រាប់ពេជ្រកាត់ដាច់ហើយ មិនចម្រើនឡើង, បណ្ឌិតគប្បីជ្រាបកិលេសទាំងឡាយ ត្រូវអរហត្តមគ្គកាត់ដាច់ហើយ មិនកើតឡើងទៀត ប្រៀបដូចដុំកែវមណី ឬដុំថ្ម ដែលគ្រាប់ពេជ្រ កាត់ដាច់ទៅហើយ មិនបរិបូណ៌ទៀត ។

ពីបទថា **“អយំ វុច្ចតិ”** សេចក្ដីថា បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា **វជិរូបមចិត្តោ** = បុគ្គលមានចិត្តប្រៀបដូចគ្រាប់ពេជ្រ ។ អធិប្បាយថា អ្នកមានចិត្តដូចជាគ្រាប់ពេជ្រ ព្រោះជាអ្នកអាចដើម្បីធ្វើការដកហូតឡើងនូវកិលេសទាំងឡាយ ៕

## ពណ៌នាអំពីអន្ធបុគ្គល គឺបុគ្គលដែលខ្វាក់ជាដើម

បទថា **"តថារូបំ ចក្ខុ ន ហោតិ"** សេចក្ដីថា ចក្ខុ គឺបញ្ញាដែលមានជាតិយ៉ាងនោះ មានភាវៈយ៉ាងនោះ រមែងមិនមានដល់គេ ។

ពីរបទថា **"ផាតឹ ករេយ្យ"** បានដល់ គប្បីធ្វើការបង្កើបឲ្យដឹង គឺឲ្យចម្រើន ។

បទថា **"សាវជ្ជានវជ្ជេ"** បានដល់ ធម៌ដែលមានទោស និងគ្មានទោស ។

បទថា **"ហីនបណីតេ"** បានដល់ មិនក្រៃលែង និងមិនខ្ពង់ខ្ពស់ ។

បទថា **"កណ្ហសុក្កសប្បដិភាគេ"** សេចក្ដីថា ធម៌ទាំងពួកខ្មៅ ទាំងពួកសនោះឯង លោកហៅថា **សប្បដិភាគៈ** = មានចំណែកប្រៀបដោយអំណាចនៃបដិបក្ខ ព្រោះមានការហាមនូវគ្នានឹងគ្នា ។ ក៏ក្នុងទីនេះ មានសេចក្ដីសង្ខេបដូច្នេះថា បុគ្គលគួរដឹងកុសលធម៌ទាំងឡាយថា ជាកុសលធម៌ទាំងឡាយជាដើម ដោយបញ្ញាចក្ខុណា, គួរដឹងអកុសលធម៌ទាំងឡាយថា ជាអកុសលធម៌ទាំងឡាយជាដើម ដោយបញ្ញាចក្ខុនោះ, សូម្បីក្នុងធម៌ដែលមានទោសជាដើម ក៏មានន័យដូចគ្នានេះដែរ ។

ក៏បណ្ឌិតគប្បីជ្រាបសេចក្ដី សូម្បីក្នុងភាវៈដ៏សេស ដោយន័យនេះថា បុគ្គលគប្បីជ្រាបដោយបញ្ញាចក្ខុឯណាថា "បណ្ដាធម៌ដែលមានចំណែកប្រៀបដោយធម៌ខ្មៅ និងធម៌ស, សម្រាប់ពួកធម៌ខ្មៅមានចំណែកប្រៀប

ដោយពួកធម៌ស, សម្រាប់ពួកធម៌ស ក៏មានចំណែកប្រៀបដោយពួកធម៌ខ្មៅ" ដូច្នេះ ។ ចក្ខុ គឺបញ្ញា សូម្បីមានសភាពបែបនេះ រមែងមិនមានដល់គេឡើយ ។

ពីរបទថា **"អយំ វុច្ចតិ"** សេចក្ដីថា បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា **អន្ធោ** = អ្នកខ្វាក់, ព្រោះមិនមានបញ្ញាចក្ខុជាគ្រឿងរួបរួមភោគទ្រព្យដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម្មិកភព គឺភពនេះ និងមិនមានបញ្ញាចក្ខុជាគ្រឿងញ៉ាំងប្រយោជន៍ឲ្យសម្រេចក្នុងសម្បរាយិកភព គឺភពមុខ ។ បុគ្គលជំពូកទី ២ លោកហៅថា **ឯកចក្ខុ** = អ្នកមានភ្នែកម្ខាង, ព្រោះមានបញ្ញាចក្ខុដែលជាគ្រឿងរួបរួម រកភោគទ្រព្យបានក្នុងភពនេះ, តែមិនមានបញ្ញាចក្ខុដែលជាគ្រឿងញ៉ាំងប្រយោជន៍ឲ្យសម្រេចក្នុងភពខាងមុខឡើយ ។ បុគ្គលជំពូកទី ៣ លោកហៅថា **ទ្វិចក្ខុ** = អ្នកមានភ្នែកទាំងសងខាង, ព្រោះមានបញ្ញាចក្ខុ ដែលជាគ្រឿងញ៉ាំងប្រយោជន៍ឲ្យសម្រេចក្នុងភពខាងមុខ ៕

## ពណ៌នាអំពីបុគ្គលដែលមានបញ្ញាប្រៀបដូចភាជនៈផ្កាប់ជាដើម

ពីរបទថា **"ធម្មំ ទេសេន្តិ"** សេចក្ដីថា ភិក្ខុទាំងឡាយ លះការងាររបស់ខ្លួន ហើយសម្ដែងធម៌ដោយការគិតថា "ឧបាសកមកដើម្បីត្រូវការស្ដាប់ធម៌" ។

បទថា **"អាទិកល្យាណំ"** សេចក្ដីថា រមែងសម្ដែងធម៌ឲ្យល្អ ឲ្យចម្រើន គឺមិនឲ្យមានទោស គឺប្រាសចាកទោសក្នុងចំណែកខាងដើម សូម្បីក្នុងបទដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។ ក៏ក្នុងពាក្យថា **"អាទិ"** នេះ បានដល់ជាពាក្យផ្ដើមគ្រាដំបូង ។

បទថា **"មជ្ឈេ"** បានដល់ ជាការពោលត្រង់កណ្ដាល ។

បទថា **"បរិយោសានំ"** បានដល់ ជាពាក្យចុងបំផុត ។

ភិក្ខុទាំងឡាយកាលសម្ដែងធម៌ដល់យើង រមែងសម្ដែងធម៌ឲ្យល្អ ឲ្យចម្រើន មិនឲ្យមានទោសនោះឯង ទាំងក្នុងពាក្យផ្ដើមគ្រាដំបូង ទាំងក្នុងពាក្យដែលមានត្រង់កណ្ដាល និងទាំងក្នុងពាក្យដែលពោលទុកក្នុងទីបំផុត ។ ម្យ៉ាងទៀត ក្នុងទីនេះ សេចក្ដីល្អនៃព្រះធម៌ទេសនាដែលជាខាងដើម កណ្ដាល និងទីបំផុត ព្រមទាំងសេចក្ដីល្អទាំង ៣ យ៉ាងនោះ ជាលម្អនៃព្រះសាសនាក៏មាន ។ ក្នុងបណ្ដាសេចក្ដីល្អនៃទេសនា និងសេចក្ដីល្អនៃព្រះសាសនានោះ គប្បីជ្រាបសេចក្ដីល្អនៃទេសនាមុន គឺ ៖

ព្រះគាថា ៤ បទ នៃទេសនាបទដំបូង ហៅថា ជាសេចក្ដីល្អខាងដើម, ពីរបទតមក ហៅថា ជាសេចក្ដីល្អត្រង់កណ្ដាល, បទចុងក្រោយ ហៅថា ជាសេចក្ដីល្អក្នុងទីបំផុត ។ សម្រាប់ព្រះសូត្រដែលមានរឿងតែមួយ និទាន ជាសេចក្ដីល្អខាងដើម, អនុសន្ធិ គឺការតភ្ជាប់ ជាសេចក្ដីល្អ

ត្រង់កណ្ដាល, វាចាដែលពោលចុងក្រោយថា **"ឥទមវោច"** ជាសេចក្ដីល្អក្នុងទីបំផុត ។ ចំពោះព្រះសូត្រដែលមានអនុសន្ធិច្រើន គឺមានរឿងច្រើន (អនេកានុសន្ធិ) អនុសន្ធិដំបូងជាសេចក្ដីល្អខាងដើម, តអំពីនោះ អនុសន្ធិមួយក្ដី ច្រើនៗ អនុសន្ធិក្ដី ជាសេចក្ដីល្អត្រង់កណ្ដាល, អនុសន្ធិចុងក្រោយជាសេចក្ដីល្អក្នុងទីបំផុត ។ គប្បីជ្រាបន័យរបស់ព្រះធម្មទេសនា ត្រឹមតែប៉ុណ្ណេះសិនចុះ ។

ក៏ចំពោះន័យរបស់ព្រះសាសនា ***សីល*** ចាត់ជាសេចក្ដីល្អខាងដើម, ***សមាធិ*** ចាត់ជាសេចក្ដីល្អត្រង់កណ្ដាល, ***វិបស្សនា*** ចាត់ជាសេចក្ដីល្អក្នុងទីបំផុត ។ ម្យ៉ាង ***សមាធិ*** ជាសេចក្ដីល្អខាងដើម, ***វិបស្សនា*** ជាសេចក្ដីល្អត្រង់កណ្ដាល, ***មគ្គ*** ជាសេចក្ដីល្អក្នុងទីបំផុត ។ ម្យ៉ាងទៀត ***វិបស្សនា*** ជាសេចក្ដីល្អខាងដើម, ***មគ្គ*** ជាសេចក្ដីល្អត្រង់កណ្ដាល, ***ផល*** ជាសេចក្ដីល្អក្នុងទីបំផុត ។ ម្យ៉ាងវិញទៀត ***មគ្គ*** ជាសេចក្ដីល្អខាងដើម, ***ផល*** ជាសេចក្ដីល្អត្រង់កណ្ដាល, ***និព្វាន*** ជាសេចក្ដីល្អក្នុងទីបំផុត ។ មួយវិញសោត លោកចាត់ជាគូ ១ គឺ ***សីល*** និង ***សមាធិ*** ចាត់ជាសេចក្ដីល្អខាងដើម, ***វិបស្សនា*** និង ***មគ្គ*** ចាត់ជាសេចក្ដីល្អត្រង់កណ្ដាល, ***ផល*** និង ***ព្រះនិព្វាន*** ចាត់ជាសេចក្ដីល្អក្នុងទីបំផុត ។

បទថា **"សត្ថំ"** បានដល់ សម្ដែងធម៌ឲ្យប្រព្រឹត្តទៅជាមួយប្រយោជន៍ ។

បទថា **"សព្យញ្ជនំ"** បានដល់ សម្តែងធម៌ធ្វើឲ្យមានអក្សរបរិបូណ៌ ។

បទថា **"កេវលបរិបុណ្ណំ"** បានដល់ សម្តែងធ្វើឲ្យបរិបូណ៌ ដោយសព្វគ្រប់ គឺមិនឲ្យខ្វះខាតឡើយ ។

បទថា **"បរិសុទ្ធំ"** បានដល់ សម្តែងឲ្យបរិសុទ្ធ ឲ្យប្រាកដ គឺឲ្យបាត់សេចក្តីស្រពេចស្រពិល ។

ពីរបទថា **"ព្រហ្មចរិយំ បកាសេន្តិ"** សេចក្តីថា ក៏កាលសម្តែងធម៌យ៉ាងនោះ ឈ្មោះថា រមែងប្រកាសអដ្ឋង្គិកមគ្គដ៏ប្រសើរ ដែលសង្គ្រោះដោយត្រៃសិក្ខា គឺសីល សមាធិ និងបញ្ញា ដែលលោកអ្នកប្រសើរប្រព្រឹត្តហើយ ។ បទថា **"នេវ អាធិំ មនសិករោតិ"** បានដល់ មិនធ្វើមនសិការនូវពាក្យដែលតាំងទុកខាងដើម ។

បទថា **"កុម្ភោ"** បានដល់ ភាជនៈ ។

បទថា **"និកុជ្ជោ"** បានដល់ ភាជនៈដែលគេតាំងផ្កាប់មាត់ទុក ។

ក្នុងពាក្យថា **"ឯវមេវ"** នេះ មានសេចក្តីថា ***បណ្ឌិតគប្បីជ្រាបបុគ្គលមានបញ្ញាដែលប្រៀបដោយភាជនៈផ្កាប់*** ក៏ដូចជាឆ្នាំងដែលគេផ្កាប់មាត់ទុកដែរ ។ បណ្ឌិតគប្បីជ្រាបវេលាដែលគេបានស្តាប់ព្រះធម៌ទេសនា ប្រៀបដូចវេលាដែលស្រោចដោយទឹក ។ គប្បីឃើញវេលាដែលគេអង្គុយលើអាសនៈនោះហើយមិនអាចដើម្បីរៀនធម៌បាន, ប្រៀបដូចវេលាដែលទឹកហូរចេញទៅ

*អំពីភាជនៈ ។ គប្បីជ្រាបថា វេលាដែលគេក្រោកឡើងអំពីអាសនៈហើយ កំណត់ធម៌មិនបាន ប្រៀបដូចវេលាដែលទឹកមិនដក់នៅក្នុងភាជនៈ ។*

*ពីរបទថា* **“អយំ វុច្ចតិ”** *សេចក្ដីថា បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា* **អវកុជ្ជបញ្ញោ** *= អ្នកមានបញ្ញាដូចភាជនៈផ្កាប់ ។ អធិប្បាយថា មានបញ្ញាដូចភាជនៈទឹកដែលគេគាំងផ្កាប់មាត់ទុក ។*

*បទថា* **“អាកិណ្ណានិ”** *បានដល់ ដាក់ចូលហើយ ។*

*ពីរបទថា* **“សតិសម្មោសា បកិរេយ្យ”** *សេចក្ដីថា ព្រោះភ្លេចសតិ វត្ថុរបស់ទាំងឡាយទើបខ្ចាត់ខ្ចាយចេញទៅ ។ បណ្ឌិតគប្បីជ្រាបបុគ្គលដែលមានបញ្ញាដូចថ្នក់ ក៏ដូចជាថ្នក់ដែលលោកត្រាស់ទុកក្នុងពាក្យថា* **“ឯវមេវ”** *នេះដែរ ។ បណ្ឌិតគប្បីជ្រាបពុទ្ធវចនៈ មានប្រការផ្សេងៗ ដូចអាហារដែលទំពាស៊ីមានប្រភេទផ្សេងៗ; គប្បីជ្រាបថា វេលាដែលគេអង្គុយលើអាសនៈនោះ ហើយរៀនពុទ្ធវចនៈ ដូចវេលាដែលគេអង្គុយទំពាស៊ីរបស់ដែលគួរទំពាស៊ីផ្សេងៗ ក្នុងថ្នក់ ។ គប្បីជ្រាបថា វេលាដែលគេក្រោកអំពីអាសនៈនោះ ហើយដើរទៅមិនអាចកំណត់ធម៌បាន ប្រៀបដូចវេលាដែលគេភ្លេចសតិក្រោកឡើងធ្វើឲ្យរបស់ទំពាស៊ីខ្ចាតខ្ចាត់ខ្ចាយចេញទៅ ។*

*ពីរបទថា* **“អយំ វុច្ចតិ”** *សេចក្ដីថា បុគ្គលនេះ គឺ អ្នកបែបនេះ លោកហៅថា* **ឧច្ឆង្គបញ្ញោ** *= អ្នកមានបញ្ញាដូចថ្នក់លេច, អធិប្បាយថា*

មានបញ្ញាប្រាកដដូចជាថ្នក់លេច ។

បទថា **“ឧក្កុជ្ជោ”** បានដល់ ក្អមដែលគេដាក់ផ្ងារមាត់ឡើងលើ ។

បទថា **“សណ្ឋាតិ”** បានដល់ ទឹកដែលដក់នៅ ។ ក្នុងពាក្យថា **“ឯវមេវ ខោ”** នេះ បណ្ឌិតគប្បីជ្រាបបុគ្គលដែលមានបញ្ញាច្រើន ដូចក្អមដែលគេដាក់ផ្ងារមាត់ឡើងខាងលើ គប្បីជ្រាបថា វេលាដែលគេបានស្ដាប់ធម៌ទេសនាហើយ ដូចវេលាដែលគេស្រោចទឹក (គឺចាក់ទឹកដាក់ក្អម) ។ គប្បីជ្រាបថា វេលាដែលគេអង្គុយរៀនពុទ្ធវចនៈក្នុងទីនោះ ប្រៀបដូចវេលាដែលទឹកដក់នៅ, គប្បីជ្រាបថា វេលាដែលក្រោកឡើងអំពីអាសនៈដើរទៅអាចកំណត់ពុទ្ធវចនៈបាន ប្រៀបដូចវេលាដែលទឹកហូរចេញទៅ ។

ពីរបទថា **“អយំ វុច្ចតិ”** សេចក្ដីថា បុគ្គលនេះ គឺអ្នកបែបនេះហៅថា **បុថុប្បញ្ញោ** = បុគ្គលមានបញ្ញាច្រើន, អធិប្បាយថា មានបញ្ញាទូលំទូលាយ ៕

---

## ពណ៌នាអំពីបុគ្គលមានរាគៈមិនទាន់នៅប្រាសហើយជាដើម

ព្រះសោតាបន្ន និងព្រះសកទាគាមី នៅមិនទាន់ប្រាសចាករាគៈ ក្នុងកាមគុណទាំង ៥ និងភពទាំង ៣ យ៉ាងណា, សូម្បីបុថុជ្ជនក៏ដូច្នោះដែរ ។ តែចំពោះបុថុជ្ជននោះ ព្រះមានព្រះភាគទ្រង់មិនបានកាន់យក ព្រោះមិន

ជាទព្វបុគ្គលទេ ។ ដូចនាយជាងឈើអ្នកឈ្លាសជំនាញ ចូលទៅកាន់ព្រៃដើម្បីត្រូវការទព្វសម្ភារៈ គេរមែងកាត់ដើមឈើដែលប្រទះហើយ និងដួបហើយ ចាប់ផ្ដើមអំពីដើម, តែថា ឈើឯណាដែលគួរដល់ទព្វសម្ភារៈបាន, គេរមែងកាត់ដើមឈើទាំងនោះឯង យ៉ាងណា, ព្រះអរិយសាវកទាំងឡាយដែលមានទព្វជាតិនោះ (អ្នកមានជាតិនៃសេចក្ដីអង់អាច) ព្រះភគវាក៏ទ្រង់កាន់យកហើយ; សូម្បីក្នុងទីនេះ ក៏ដូច្នោះដែរ; ចំណែកបុថុជ្ជនបណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់មិនកាន់យកឡើយ ព្រោះភាវៈជាអ្នកមិនមានទព្វជាតិ គឺអ្នកមិនមានភាពអង់អាចដើម្បីនឹងត្រាស់ដឹងធម៌ ។ (ពាក្យថា ***ទព្វ*** សព្ទនេះ ប្រែបានច្រើនយ៉ាង ដូចគួរ, សមគួរ, អាច, បញ្ញា, ទ្រព្យសម្បត្តិ, វត្ថុដែលមានតម្លៃ) ។

ពីរបទថា **"ភវេសុ វីតរាគោ"** បានដល់ អ្នកប្រាសចាករាគៈ ក្នុងបញ្ចកាមគុណ គឺ រូប សំឡេង ក្លិន រស និងផោដ្ឋព្វៈ ដែលគួរស្រឡាញ់ គួរប្រាថ្នា ។

ពីរបទថា **"ភវេសុ អវីតរាគោ"** បានដល់ អ្នកនៅមិនទាន់ប្រាស-ចាករាគៈ គឺអ្នកត្រេកអរក្នុងរូបភព និងអរូបភព ។

បទថា **"អនុសេតិ"** បានដល់ សេចក្ដីក្រោធរមែងនៅដេកត្រាំ ព្រោះមិនទាន់លះអនុស័យបាន ។

*បទថា* **“ន ខិប្បំ លុជ្ជតិ”** *បានដល់ សេចក្តីក្រោធនោះ រមែងមិនសាបសូន្យទៅក្នុងចន្លោះ គឺថាដោយវេលាកើតឡើងមករហូតកប្ប ក៏មិនសាបសូន្យ ។*

*បទថា* **“ឯវរេខ”** *សេចក្តីថា សូម្បីសេចក្តីក្រោធរបស់បុគ្គលនោះ រមែងមិនរលត់ទៅក្នុងចន្លោះ គឺក្នុងថ្ងៃព្រឹកឡើង ឬក្នុងថ្ងៃតៗ ទៅ ក៏មិនរលត់ (គង់សំដៅដល់ការរលត់មិនកើតទៀត) ដូច្នោះ, អធិប្បាយថា ក៏សេចក្តីក្រោធនោះ រមែងមាននៅអស់វេលាយូរអង្វែង, តែរមែងរលត់ទៅ ព្រោះមរណៈ* នោះៗ ឯង៕*

---

## ពណ៌នាអំពីបុគ្គលប្រៀបដូចគំនូសលើថ្មជាដើម

*ពីរបទថា* **“អយំ វុច្ចតិ”** *សេចក្តីថា បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា* **បាសាណលេខូបមោ** *= បុគ្គលប្រៀបដូចគំនូសថ្ម ដែលមាន*

---

* ក្នុងគម្ពីរសម្មោហវិនោទនី ត្រង់សច្ចវិភង្គនិទ្ទេស អធិប្បាយពាក្យថា **មរណៈ** នេះ ទុក ៣ យ៉ាង គឺ

**១.ខណិកមរណៈ** = ស្លាប់គ្រប់ខណៈ ក៏គឺភង្គខណៈរបស់រូប និងនាម

**២.សម្មុតិមរណៈ** = ស្លាប់ដោយសម្មតិ បានដល់ មនុស្សស្លាប់ សត្វស្លាប់

**៣.សមុច្ឆេទមរណៈ** = ស្លាប់មិនកើត បានដល់ ព្រះអរហន្តបរិនិព្វាន ។

ស្នាមជាប់នៅរហូតអស់កាលដ៏យូរ ដោយសេចក្តីដូចជាការក្រោធ ប្រៀបដូចស្នាមគំនូសសរសេរទុកលើថ្ម ។

បទថា **"សោ ច ខ្វស្ស កោធោ"** សេចក្តីថា ការក្រោធរបស់អ្នកតែងតែក្រោធនោះ មានសេចក្តីក្រោធរហ័ស សូម្បីមានហេតុត្រឹមតែបន្តិចបន្តួច ។

បទថា **"ន ចិរំ"** សេចក្តីថា សេចក្តីក្រោធ រមែងដេកសម្ងំមិនយូរ ព្រោះគេលះសេចក្តីក្រោធមិនបាន ។ អធិប្បាយថា ដូចស្នាមគំនូសដែលបុគ្គលគូសលើផែនដី រមែងរលុបបាត់ទៅដោយខ្យល់ជាដើម យ៉ាងរហ័សយ៉ាងណា, ការក្រោធរបស់គេ សូម្បីកើតឡើងហើយរហ័ស ក៏រមែងរលត់ទៅយ៉ាងឆាប់រហ័សដូច្នោះដែរ ។

ពីរបទថា **"អយំ វុច្ចតិ"** សេចក្តីថា បុគ្គលនេះ គឺអ្នកបែបនេះលោកហៅថា **បឋវីលេខូបមោ** = បុគ្គលប្រៀបដូចគំនូសដី ដែលតាំងនៅមិនយូរដោយភាវៈ គឺសេចក្តីក្រោធ ដូចស្នាមគំនូសសរសេរលើផែនដី ។

បទថា **"អាគាឡ្ហេន"** បានដល់ ពាក្យសម្តីដែលថោកទាប គឺបានដល់ ពាក្យសម្តីចេសរឹងរូស ដែលកាត់ប្រៀកហឫទ័យ ។

បទថា **"ផរុសេន"** បានដល់ ពាក្យសម្តីដែលមិនសប្បាយត្រចៀក ។

បទថា **"អមនាបេន"** បានដល់ ពាក្យសម្តីដែលមិនសប្បាយចិត្ត ។

បទថា **"សំសន្ទតិ"** បានដល់ ជាមួយគ្នា ។

បទថា **"សន្និយតិ"** បានដល់ ការតភ្ជាប់ ។

បទថា **"សមោធានតិ"** បានដល់ មិនមានខណ្ឌចន្លោះ ។

ម្យ៉ាងទៀត បទថា **"សំសន្ទតិ"** អធិប្បាយថា រមែងដល់ការប្រជុំចុះក្នុងការធ្វើរបស់ចិត្តដោយចិត្ត គឺថារមែងចូលដល់ឯកីភាវៈ គឺភាពជាមួយគ្នា ដូច ***ខីរោទកៈ*** គឺទឹក និងទឹកដោះស្រស់ ។

បទថា **"សន្និយតិ"** អធិប្បាយថា រមែងដល់ការប្រជុំចុះក្នុងការធ្វើផ្លូវកាយដោយកាយជាដើម ដែលមានការឈរ និងដើរជាដើម គឺថារមែងជារបស់ប្រឡូកប្រឡំគ្នា ដូចលូជាមួយនឹងបាយ (ដែលដាក់រួមគ្នាដែរ) ។

បទថា **"សមោធានតិ"** អធិប្បាយថា រមែងដល់ការប្រជុំចុះក្នុងការធ្វើតាមផ្លូវវាចា ដោយពាក្យសម្ដីមានការសាកសួរទុក្ខទោសជាដើម ឈ្មោះថារមែងចូលដល់ភាពជាទីស្រឡាញ់ក្រៃលែង ដូចសម្លាញ់ជាទីស្រឡាញ់ (របស់) អ្នកមកពីស្ថានទីផ្សេងៗ ដែរ ។

ម្យ៉ាងទៀត អធិប្បាយថា កាលបើគេចូលដល់ភាពជាអ្នកធ្វើដោយសេចក្ដីជាមួយគ្នាតាំងពីដើមមកជាមួយនឹងសម្លាញ់ទាំងនោះ ក្នុងកិច្ចដែលគួរធ្វើទាំងឡាយ ទើបឈ្មោះថា ស្និទ្ធស្នាលនឹងគ្នា ។ បណ្ឌិតគប្បីជ្រាបការស្និទ្ធស្នាលនឹងគ្នានោះថា នៅតែប្រព្រឹត្តទៅតាំងពីដើមរហូតដល់កណ្ដាល និង

មិនមានការផ្លាស់ប្តូររហូតដល់ទីបំផុតដូច្នេះខ្លះ ។

ពីរបទថា **"អយំ វុច្ចតិ"** សេចក្តីថា បុគ្គលនេះ គឺអ្នកមានសភាព បែបនេះ លោកហៅថា **ឧទកេលខូបមោ** = បុគ្គលប្រៀបដូចគំនូសទឹក ព្រោះស្និទ្ធនឹងគ្នារហ័សហើយ ដូចស្នាមគូសក្នុងទឹក ៕

---

## ពណ៌នាអំពីបុគ្គលប្រៀបដូចសំពត់សម្បកឈើ ៣ ប្រភេទ

បុគ្គល ៣ ជំពូកទាំងនោះ ហៅថា **វោត្ថកូបមា** = អ្នកប្រៀបដូចសំពត់សម្បកឈើដោយឧបមាឯណា, ដើម្បីនឹងសម្តែងពាក្យឧបមានោះមុន ទើបលោកពោលពាក្យថា **"តយោ វោត្ថកា"** ជាដើម ។ បណ្តាបទទាំងឡាយនោះ បទថា **"នវោ"** បានដល់ សំពត់ដែលត្បាញថ្មី ។ បទថា **"វោត្ថកោ"** បានដល់ សំពត់ដែលត្បាញដោយសម្បកដើមព្រាល ។ បទថា **"ទុព្វណ្ណោ"** បានដល់ សំពត់ដែលមានពណ៌អាក្រក់ ។ បទថា **"ទុក្ខសម្ផស្សោ"** បានដល់ សំពត់ដែលមានសម្ផស្សរឹង ។ បទថា **"អប្បគ្ឃោ"** បានដល់ សំពត់ដែលមានតម្លៃមិនខ្ពស់ គឺមានតម្លៃប្រមាណមួយកហាបណៈ (មួយកហាបណៈ = ៤ បាទ) ។ បទថា **"មជ្ឈិមោ"** បានដល់ សំពត់កណ្តាលចាស់ កណ្តាល ថ្មី សំពត់នោះកន្លងហួសភាពជារបស់ថ្មី, តែនៅមិនដល់ភាពជារបស់ចាស់គ្រាំគ្រា

*ឡើយ; សូម្បីក្នុងវេលាប្រើប្រាស់ ក៏មានពណ៌មិនស្អាត មានសម្ផស្ស មិនសប្បាយ មានតម្លៃតិច កាលវាយតម្លៃលក់ខ្ពស់ ក៏បានតម្លៃត្រឹមតែពាក់កណ្ដាល ។ មួយទៀត ក្នុងវេលាដែលសំពត់នោះចាស់ហើយ ក៏មានតម្លៃត្រឹមតែមួយមាសកៈ (១ បាទ) ឬត្រឹមតែមួយ ១ កាកណិកៈ (កាកណិកៈ = តម្លៃសាច់ដែលក្អែកស៊ីមួយដង ជាតម្លៃដែលទាបបំផុតក្នុងសម័យនោះ) ។ បទថា* **"ឧក្ខលិបរិមជ្ជនំ"** *បានដល់ សំពត់ជូតឆ្នាំងបាយ ។ បទថា* **"នវោ"** *សេចក្ដីថា ពោលដោយឧបសម្បទ រាប់អំពី ៥ វស្សាចុះមក ភិក្ខុនោះ សូម្បីមានអាយុ ៦០ ឆ្នាំ ក៏ឈ្មោះថា* ***នវ:*** *គឺអ្នកថ្មី (ក្មេង) មែនពិត ។ បទថា* **"ទុព្វណ្ណកាយ"** *សេចក្ដីថា ព្រោះមានវណ្ណៈមិនស្អាត ដោយវណ្ណៈនៃសរីរៈខ្លះ ដោយវណ្ណៈនៃគុណសេចក្ដីល្អខ្លះ ។ ក៏វណ្ណៈនៃសរីរៈរបស់អ្នកទ្រុស្ដសីល អង្គុយក្នុងកណ្ដាលបរិស័ទ រមែងមិនរុងរឿង ព្រោះភាពនៃខ្លួនមិនមានអំណាច, សម្រាប់ក្នុងវណ្ណៈ គឺគុណសេចក្ដីល្អរបស់អ្នកទ្រុស្ដសីលនោះ ក៏មិនចាំបាច់ត្រូវពោលដល់ឡើយ ។ បទថា* **"យេ ខោ បនស្ស"** *សេចក្ដីថា ក៏ជនឯណា ជាអ្នកឧបដ្ឋាក ឬជាញាតិ និងជាមិត្តជាដើម របស់អ្នកទ្រុស្ដសីលនោះ គេរមែងសេពគប់បុគ្គលម្នាក់ ។ បទថា* **"តេសន្តំ"**

*សេចក្ដីថា ការសេពគប់នោះ រមែងមិនប្រព្រឹត្តទៅដើម្បីប្រយោជន៍ រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីទុក្ខរហូតអស់កាលយូរ ដូចពួកមិច្ឆាទិដ្ឋិដែលសេពគប់គ្រូទាំង ៦ ឬដូចកោកាលិកភិក្ខុជាដើម ដែលសេពគប់ភិក្ខុទេវទត្តដូច្នោះ ។ បទថា* **"មជ្ឈិមោ"** *សេចក្ដីថា ពោលដោយការឧបសម្បទ រាប់តាំងអំពី ៥ វស្សារហូតដល់ ៩ វស្សា* * *ឈ្មោះថា* ***មជ្ឈិមភិក្ខុ*** *។*

*បទថា* **"ថេរោ"** *សេចក្ដីថា តាំងពី ១០ វស្សាឡើងទៅ ឈ្មោះថា* ***ព្រះថេរៈ*** *។*

*បទថា* **"ឯវមាហំសុ"** *បានដល់ រមែងពោលយ៉ាងនេះ; បទថា* **"កិន្នុ ខោ តុយ្ហំ"** *សេចក្ដីថា មានពាក្យដែលលោកអធិប្បាយទុកថា នឹងមានប្រយោជន៍អ្វីដល់លោក ដោយពាក្យពោលរបស់មនុស្សពាល ។ បទថា* **"តថារូបំ"** *បានដល់ ដែលជាហេតុខក្មេបនីយកម្ម ដែលមានជាតិយ៉ាងនោះ មានសភាវៈយ៉ាងនោះ ៕*

---

* ក្នុងទីដទៃ រាប់តាំងពី ៥ - ១០ វស្សា ។

## ពណ៌នាអំពីបុគ្គលប្រៀបដូចសំពត់ដែនកាសី ៣ ប្រភេទ

*សំពត់សាច់ល្អិត ដែលគេត្បាញដោយអំបោះ ដែលគេកាន់យកកប្បាស ៣ ប្រភេទ ហើយក្រងចូលគ្នា ហៅថា សំពត់ដែនកាសី ។ សំពត់ដែលត្បាញថ្មីនោះ រាប់តម្លៃមិនបានទេ, ដែលប្រើប្រាស់ពាក់កណ្តាលចាស់ពាក់កណ្តាលថ្មី មានតម្លៃ ១ ពាន់ខ្វះ ៣០ ពាន់ខ្វះ, តែក្នុងវេលាដែលចាស់ហើយ ក៏នៅតែមានតម្លៃដល់ ៨ ពាន់ក៏មាន ១០ ពាន់ក៏មាន ។*

*ពីរបទថា* **“តេសន្តំ ហោតិ”** *សេចក្តីថា ការសេពនោះរបស់បុគ្គលទាំងនោះ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ រហូតអស់កាលយូរ ដូចបុគ្គលទាំងឡាយអ្នកសេពគប់ព្រះសម្មាសម្ពុទ្ធជាដើម ។ ព្រោះថា សត្វទាំងឡាយ ដែលអាស្រ័យព្រះសម្មាសម្ពុទ្ធមួយព្រះអង្គហើយ រួចផុតចាក* ***អាសវក្កិលេស*** *រហូតដល់សម័យសព្វថ្ងៃនេះ រាប់ប្រមាណមិនបាន សត្វទាំងឡាយដែលអាស្រ½យ* ***ព្រះសារីបុត្ត ព្រះមហាមោគ្គលានត្ថេរ និងព្រះអសីតិមហាសាវក*** *ហើយទៅកាន់ឋានសួគ៌ ក៏ប្រមាណមិនបានដូចគ្នា, សូម្បីសត្វដែលដើរទៅតាមទិដ្ឋានុគតិ គឺតាមគំរូរបស់ព្រះអរិយៈទាំងនោះ រហូតដល់សម½យសព្វថ្ងៃនេះ ក៏ប្រមាណមិនបានដែរ ។*

*ពីរបទថា* **“អាវេធយ្យំ គច្ឆតិ”** *សេចក្តីថា ពាក្យរបស់ព្រះថេរៈនោះអាស្រ័យអត្ថ រមែងដល់នូវភាពជារបស់ដែលបុគ្គលគប្បីប្រមូលរក្សាទុក គឺ*

*ដាក់ទុកលើក្បាលដែលជាអវយវៈខ្ពស់បំផុត និងក្នុងបេះដូង ដូចគ្នានឹងសំពត់ដែនកាសីដែលមានតម្លៃរាប់មិនបាន រមែងដល់ភាពជារបស់ដែលបុគ្គលគប្បីរក្សាទុក គឺដាក់ទុកក្នុងហិបសម្រាប់ដាក់របស់ក្រអូបដូច្នោះដែរ ។*

*ពាក្យដ៏សេសក្នុងទីនេះ បណ្ឌិតគប្បីជ្រាបតាមលំអានរបស់ន័យដែលពោលទុកហើយ ខាងក្រោយនុ៎ះចុះ ៕*

---

## ពណ៌នាអំពីបុគ្គលដែលប្រមាណបានដោយងាយជាដើម

*អ្នកឯណា ដែលគេគប្បីប្រមាណបានដោយងាយ ព្រោះហេតុនោះ អ្នកនោះ ទើបឈ្មោះថា* **សុប្បមេយ្យោ** *= បុគ្គលដែលគេប្រមាណបានដោយងាយ ។*

*បទថា* **“ឥធ”** *បានដល់ ក្នុងសត្វលោកនេះ ។*

*បទថា* **“ឧទ្ធតោ”** *បានដល់ អ្នកប្រកបដោយសេចក្តីរវើរវាយ ។*

*បទថា* **“ឧន្នឡោ”** *បានដល់ អ្នកមានមានះ ដូចបបុសដែលបុគ្គលលើកឡើងហើយ អធិប្បាយថា អ្នកលើកមានះដែលទទេហើយតាំងនៅ ។*

*បទថា* **“ចបលោ”** *បានដល់ អ្នកប្រកបដោយសេចក្តីញាប់ញ័រ មានការប្រដាប់បាត្រជាដើម ។*

*បទថា* **“មុខរោ”** *បានដល់ អ្នកមានមាត់រឹង ។*

បទថា **“ទិកិច្ឆាខារេចា”** បានដល់ អ្នកមានវាចាដែលបុគ្គលដទៃសង្កេតមិនបាន ។

បទថា **“អសមាហិតោ”** បានដល់ អ្នកវៀរចាកភាពជាអ្នកមានចិត្តតាំងមាំ ។

បទថា **“ទិព្ភន្តចិត្តោ”** បានដល់ អ្នកមានចិត្តវិលទៅ គឺថាអ្នកមានចំណែកប្រៀបដោយមេគោដែលបែរទៅ និងមេម្រឹគដែលផាកទៅ ។

បទថា **“បាកដិន្ទ្រិយោ”** បានដល់ អ្នកមានឥន្ទ្រិយដែលបង្ហាញឲ្យដឹង ។

ពីរបទថា **“អយំ ទុច្ចតិ”** សេចក្ដីថា បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា **សុប្បមេយ្យោ**; ដូចយ៉ាងថា នរណាមួយ ក៏រមែងកាន់យកប្រមាណនៃទឹក មានចំនួនបន្តិចបន្តួចបាន យ៉ាងណា, នរណាមួយ ក៏រមែងកាន់យកប្រមាណបុគ្គលដែលប្រកបដោយអង្គ ដែលមិនមែនគុណបានដោយងាយដូច្នោះដែរ ។ ព្រោះហេតុនោះ អ្នកនោះ លោកហៅថា **សុប្បមេយ្យោ** = ***អ្នកប្រមាណបានដោយងាយ*** ។

បុគ្គលឯណាដែលគេប្រមាណបានដោយលំបាក បានដល់ បុគ្គលដែលគេប្រមាណមិនបាន ដោយហេតុនោះ បុគ្គលនោះ ទើបហៅថា **ទុប្ប-មេយ្យោ** = បុគ្គលដែលគេប្រមាណបានដោយលំបាក ។ ការផ្សារដែលមានចិត្តរវើរវាយជាដើម បណ្ឌិតគប្បីជ្រាបដោយអំណាចនៃសេចក្ដីដែល

ជុះយគ្នាអំពីពាក្យដែលពោលមកហើយ ។

ពីរបទថា **"អយំ ឧទុច្ចតិ"** សេចក្ដីថា បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា **ឧប្បមេយ្យោ** ដូចយ៉ាងថា នរណាមួយ រមែងប្រមាណទឹកក្នុងមហាសមុទ្របានដោយលំបាក យ៉ាងណា, នរណាមួយ ក៏រមែងកាន់យកប្រមាណនៃបុគ្គលដែលប្រកបដោយអង្គនៃគុណទាំងនេះ បានដោយលំបាកដូច្នោះដែរ គឺរមែងដល់នូវភាវៈដែលនរណាមួយ គប្បីពោលថា "អ្នកនេះ ជាព្រះអនាគាមី ឬថាជាព្រះខីណាស្រពហ្ន៎" ព្រោះហេតុដូច្នោះ បុគ្គលនេះ ទើបលោកហៅថា **ឧប្បមេយ្យោ** = បុគ្គលដែលគេប្រមាណបានដោយលំបាក ។

បទថា **"ន សក្កា បមេតុំ"** សេចក្ដីថា បុគ្គលឯណា ដែលនរណាមួយមិនអាចដើម្បីប្រមាណបាន, ដូចយ៉ាងថា នរណាមួយ មិនអាចដើម្បីប្រមាណអាកាសបាន យ៉ាងណា, នរណាមួយ ក៏មិនអាចដើម្បីកាន់យកប្រមាណនៃព្រះខីណាស្រពបានដូច្នោះដែរ ។ ព្រោះហេតុនោះ បុគ្គលនោះ លោកហៅថា **អប្បមេយ្យោ** អ្នកដែលមិនមាននរណាមួយ ប្រមាណបានឡើយ ៕

## ពណ៌នាអំពីបុគ្គលមិនគួរសេពគប់ជាដើម

បទថា **"ន សេវិតព្វោ"** បានដល់ អ្នកដែលនរណាមួយ មិនគួរចូលទៅរក ។

បទថា **"ន ភជិតព្វោ"** បានដល់ អ្នកដែលនរណាមួយ មិនគប្បីទាក់ទង ។

បទថា **"ន បយិរុបាសិតព្វោ"** បានដល់ អ្នកដែលនរណាមួយ មិនគួរចូលទៅអង្គុយជិតញយៗ ដោយអំណាចនៃការចូលទៅអង្គុយក្នុងសំណាក់ ។ បណ្ឌិតគប្បីជ្រាបភាពជាមនុស្សអាក្រក់ ដោយកាន់យកការប្រៀបធៀបក្នុងពាក្យជាដើមថា **"ហីនោ ហោតិ សីលេន"** ។ ក៏បុគ្គលណារក្សាសីល ៥, អ្នកនោះ គឺបុគ្គលដែលរក្សាសីល ១០ មិនគប្បីសេពគប់ ។ ចំណែកបុគ្គលណា រក្សាសីល ១០, អ្នកនោះ គឺបុគ្គលដែលរក្សាចតុប្បារិសុទ្ធិសីលមិនគប្បីសេពគប់ឡើយ ។

បទថា **"អញ្ញត្រ អនុទយា អញ្ញត្រ អនុកម្បា"** សេចក្តីថា វៀរចាកសេចក្តីអាណិត និងសេចក្តីអនុគ្រោះ អធិប្បាយថា ក៏បុគ្គលបែបនេះដែលនរណាមួយ មិនគួរសេពគប់ដើម្បីប្រយោជន៍របស់ខ្លួនឯង, តែថាការចូលទៅរកគេដោយអំណាចនៃសេចក្តីអាណិត និងសេចក្តីអនុគ្រោះ ក៏សមគួរ ។

បទថា **"សទិសោ ហោតិ"** បានដល់ ជាអ្នកស្មើគ្នា ។

បទថា **"សីលសាមញ្ញគតានំ សតំ"** សេចក្តីថា សប្បុរសទាំងឡាយ

*ដល់ភាពជាអ្នកស្មើគ្នាដោយសីល ។*

*បទថា* **“សីលកថា ច នោ ភវិស្សតិ”** *សេចក្ដីថា ពាក្យសម្ដីដែលប្រារព្ធសីលនោះ នឹងមានដល់ពួកយើង ជាអ្នកមានសីលស្មើគ្នាយ៉ាងនេះ ។*

*បទថា* **“សា ច នោ ផាសុ ភវិស្សតិ”** *សេចក្ដីថា ក៏សីលកថា (ការនិយាយដល់សីល) នោះ នឹងការនៅជាផាសុកភាព, នឹងជាការនៅយ៉ាងសប្បាយដល់ពួកយើង ។*

*បទថា* **“សា ច នោ បវត្តិនី ភវិស្សតិ”** *សេចក្ដីថា ពាក្យសម្ដីរបស់ពួកយើងអ្នកពោលនឹងប្រព្រឹត្តទៅសូម្បីរហូតថ្ងៃ រហូតយប់ ក៏នឹងមិនធ្វើឲ្យរញ្ជួយចិត្ត; ពិតមែនហើយ កាលបុគ្គលទាំងពីរមានសីលស្មើគ្នា ពេលម្នាក់ពោលពណ៌នាដល់សីល ម្នាក់ទៀត ក៏រមែងត្រេកអរ, ព្រោះហេតុនោះ ពាក្យសម្ដីរបស់គេទាំងនោះ រមែងនឹងមានសេចក្ដីសុខ, នឹងប្រព្រឹត្តទៅរហូតមិនជំទាស់គ្នា ។ ក៏កាលមានអ្នកទ្រុស្តសីល ពាក្យសម្ដីដែលពោលនិយាយដល់សីល និងបុគ្គលដែលទ្រុស្តសីល (នោះ) រមែងជាពាក្យសម្ដីដែលពោលដោយលំបាក ព្រោះហេតុដូច្នោះ សីលកថា ក៏រមែងមិនមាន ។ សេចក្ដីសុខ ក៏មិនមាន ការប្រព្រឹត្តទៅ ក៏មិនមានរហូតដែរ ។ សូម្បីពាក្យសម្ដីដែលពោលដល់សមាធិ និងបញ្ញា ក៏មានន័យដូចគ្នានេះដែរ ។ ក៏ភិក្ខុ ២ រូបអ្នកមានសមាធិ រមែងពោលពណ៌នាអំពីគុណនៃសមាធិ, អ្នកមានបញ្ញា*

*ក៏រមែងពោលពណ៌នាអំពីគុណនៃបញ្ញា; គេទាំងពីរនោះ រមែងមិនស្គាល់ដល់ការឈានកន្លងរហូតអស់រាត្រី ឬរហូតថ្ងៃ ។*

*បទថា* **"សក្កត្វា គរុំ កត្វា"** *បានដល់ ធ្វើសក្ការៈ ឬធ្វើការគោរព ។*

*ពីរបទថា* **"អធិកោ ហោតិ"** *បានដល់ ជាអ្នកក្រៃលែង ។*

*បទថា* **"សីលក្ខន្ធំ"** *បានដល់ កងនៃសីល ។*

*បទថា* **"បរិបូរេស្សាមិ"** *សេចក្តីថា យើងអាស្រ័យបុគ្គលដែលមានសីល ដែលក្រៃលែងនោះ ហើយនឹងធ្វើសីលក្ខន្ធ ដែលមិនទាន់បរិបូណ៌ឲ្យបរិបូណ៌ឡើង ។*

*ក្នុងពាក្យថា* **"តត្ថ តត្ថ បញ្ញាយ អនុគ្គហេស្សាមិ"** *នេះ គប្បីជ្រាបសេចក្តីថា បុគ្គលវៀរធម៌មិនជាឧបការៈដែលមិនជាសប្បាយដល់សីលហើយ ទើបសេពធម៌មានឧបការៈ ដែលជាសប្បាយដល់សីល ឈ្មោះថា រមែងកាន់យកសីលក្ខន្ធក្នុងទីនេះ ដោយបញ្ញា ។ សូម្បីក្នុងសមាធិខន្ធ និងបញ្ញាខន្ធទាំងឡាយ ក៏មានន័យដូចគ្នានេះដែរ ៕*

---

## ពណ៌នាអំពីបុគ្គលដែលគួរខ្ពើមជាដើម

*បទថា* **"ជិគុច្ឆិតព្វោ"** *បានដល់ បុគ្គលដែលគេស្អប់ដូចលាមក ។*

បទថា **“អថ ខោ នំ”** កែជា **អថ ខោ អស្ស** = គ្រានោះឯង កិត្តិសព្ទ ក៏រមែងមាន ។

បទថា **“កិត្តិសទ្ទោ”** បានដល់ សំឡេងដែលនិយាយគ្នា ។

បណ្ឌិតគប្បីជ្រាបអ្នកទ្រុស្តសីល ដូចរណ្តៅលាមក ក្នុងបទថា **“ឯទ-មេទ”** នេះ ។ គប្បីជ្រាបបុគ្គលដែលទ្រុស្តសីល ដូចពស់គួរស្អប់ធ្លាក់ទៅក្នុងរណ្តៅលាមក ។ គប្បីឃើញភាវៈ គឺមិនយកតម្រាប់តាមបុគ្គលដែលសេពនឹងអ្នកទ្រុស្តសីលនោះ ដូចពស់ដែលបុគ្គលលើកឡើងអំពីរណ្តៅលាមក, សូម្បីគេលើកឡើងកាន់សរីរៈនៃបុរសដែលវាមិនចឹក ។ គប្បីជ្រាបការខូរខ្ចាយទៅនៃកិត្តិសព្ទលាមក របស់បុគ្គលដែលសេពគប់អ្នកទ្រុស្តសីល ដូចពស់ដែលមានសរីរៈប្រឡាក់លាមកហើយក៏ទៅ ។

បទថា **“តិន្ទុកាលាតំ”** បានដល់ ស្លឹកស្ងួតរបស់ដើមទន្លាប់ ។

បទថា **“ភិយ្យោ សោ មត្តាយ ចិច្ចិដាយតិ”** សេចក្តីថា ក៏ស្លឹកនៃដើមទន្លាប់នោះ កាលត្រូវគេអាំង សូម្បីតាមធម្មតារមែងមានសំឡេងផ្ទុះឡើង ព្ទចិដៈចិដៈ, អធិប្បាយថា កាលមានអ្វីៗ មកខ្ទប់ហើយ រមែងមានសំឡេងព្ទខ្លាំងឡើង ។

បទថា **“ឯវមេវ”** សេចក្តីថា បុគ្គលដែលចូលចិត្តក្រោធ សូម្បីតាមធម្មតារបស់ខ្លួន ក៏ជាអ្នកឃោរឃៅ ព្រោះគេមានចិត្តរវើរវាយ និង

រមែងប្រព្រឹត្តទៅដូច្នោះនោះឯង ។ មួយទៀត កាលអ្នកដទៃពោលពាក្យបន្តិចបន្តួច មនុស្សអ្នកតែងតែក្រោធនោះ ក៏ធ្វើសេចក្ដីឃោរឃៅ ព្រោះខ្លួនជាអ្នកមានសេចក្ដីវេរីរវាយធ្ងន់ឡើងថា "បុគ្គលនេះ រមែងពោលយ៉ាងនេះនិងបុគ្គលដែលមានឈ្មោះដូចគ្នានឹងយើងដែរ" ។

បទថា **"គូថកូបោ"** បានដល់ រណ្ដៅដែលពេញទៅដោយលាមក; ម្យ៉ាងទៀត បានដល់ គំនរនៃលាមកនោះឯង ។ ក៏បណ្ឌិតគប្បីជ្រាបការប្រៀបធៀបដោយសេចក្ដីឧបមាក្នុងពាក្យថា **"គូថកូបោ"** នេះ ដោយន័យមុននុ៎ះឯង, ព្រោះហេតុដូច្នោះ បុគ្គលបែបនេះ គឺបុគ្គលគប្បីព្រងើយកន្តើយមិនគួរសេពគប់ទេ, បុគ្គលដែលតែងតែក្រោធនោះ កាលអ្នកដទៃសេពគប់ច្រើនលើសទៅខ្លះ, ចូលទៅរកច្រើនលើសទៅខ្លះ រមែងក្រោធកាន់តែខ្លាំងណាស់ថែមទៀត; ទោះបីអ្នកដទៃចៀសចេញទៅ ក៏ក្រោធទៀតនោះឯងថា "ប្រយោជន៍អ្វី នឹងបុគ្គលនោះទៅ" ។ ព្រោះហេតុដូច្នោះ គេ (អ្នកក្រោធនោះ) បុគ្គលគប្បីព្រងើយកន្តើយ ហើយមិនគួរសេពគប់ (បង្កើតក្ដីស្រឡាញ់) ដូចភ្លើងឆេះចំបើង ។ សេចក្ដីនេះ មានពាក្យអធិប្បាយទុកយ៉ាងណា ? មានពាក្យអធិប្បាយថា អ្នកឯណាចូលទៅជិតភ្លើងឆេះចំបើងច្រើនលើសទៅ រមែងក្ដៅអន្ទះអន្ទែង សរីរៈរបស់ខ្លួន ក៏រមែងត្រូវភ្លើងឆេះ, អ្នកឯណា មិនថយឆ្ងាយចេញមក ក៏រមែងក្ដៅអន្ទះអន្ទែង,

*ភាពត្រជាក់រមែងមិនកើតដល់គេ; កាលអ្នកនោះ មិនចូលទៅជិត មិនចៀសចេញទៅសម្ទីងហើយ ដោយសេចក្ដី (នៅស្ងៀមព្រងើយ) ភាពត្រជាក់របស់អ្នកនោះរមែងមាន សូម្បីកាយគេ ក៏មិនត្រូវឆេះ, ព្រោះហេតុដូច្នោះ បុគ្គលដែលតែងតែក្រោធនោះ គឺបុគ្គលគប្បីនៅស្ងៀមព្រងើយ មិនសេពគប់ មិនគួរចូលទៅអង្គុយជិត ដូចភ្លើងឆេះចំបើងដូច្នោះឯង ។*

*បទថា* **“កល្យាណមិត្តា”** *បានដល់ មានមិត្តល្អ ។*

*បទថា* **“កល្យាណសហាយា”** *បានដល់ មានសម្លាញ់ល្អ ។*

*បទថា* **“សហាយា”** *បានដល់ អ្នកទៅព្រមគ្នា គឺត្រាច់ទៅជាមួយគ្នា ។*

*បទថា* **“កល្យាណសម្បវង្កា”** *បានដល់ អ្នករួមក្រុមក្នុងបុគ្គលល្អ អ្នកមានធម៌ចម្រើន, អធិប្បាយថា អ្នកមានចិត្តបង្អោនទៅ គឺត្រេកអរពេញចិត្តក្នុងមិត្តអ្នកមានកល្យាណធម៌នោះ ៕*

## ពណ៌នាអំពីបុគ្គលមានប្រក្រតីធ្វើឱ្យបរិបូណ៌ក្នុងសីលជាដើម

*បទថា* **“សីលេសុ បរិបូរិការិនោ”** *សេចក្ដីថា ព្រះអរិយសាវកទាំងឡាយនោះ ព្រោះភាវៈនៃលោកមិនបានឈានកន្លងមហាសីល សិក្ខាបទ* ***គឺអាបត្តិបារាជិក ៤*** *ដែលជាខាងដើមនៃមគ្គព្រហ្មចរិយៈ គឺជាអាទិព្រហ្មចរិយៈ និងព្រោះហេតុដែលលោកចេញចាកអាបត្តិតូចៗ ដែលបានត្រូវ, ព្រះ*

អរិយសាវកទាំងនោះ រមែងធ្វើសិក្ខាបទដែលខ្លួនគួរធ្វើឲ្យបរិបូណ៌ គឺឲ្យសម្បូណ៌ក្នុងសីលទាំងឡាយ, ព្រោះហេតុដូច្នោះ ព្រះអរិយសាវកទាំងនោះបណ្ឌិតហៅថា **“សីលេសុ បរិបូរិការិនោ** = អ្នកមានប្រក្រតីធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ” ។ មួយវិញទៀត ព្រោះហេតុដែលលោកនៅមានកាមរាគៈនិងព្យាបាទទាំងឡាយដែលជាសត្រូវដល់សមាធិ និងមោហៈដែលបិទបាំងនូវសច្ចធម៌ ជាសត្រូវដល់បញ្ញាមិនបាន លោកទាំងនោះ សូម្បីចម្រើននូវសមាធិនិងបញ្ញា ក៏រមែងធ្វើកិច្ចដែលបុគ្គលគប្បីធ្វើល្មមប្រមាណ សមគួរបានត្រឹមតែបំណែកខ្លះក្នុងសមាធិ និងបញ្ញាទាំងឡាយនោះ, ព្រោះហេតុដូច្នោះ ព្រះអរិយសាវកទាំងនោះ ទើបលោកហៅថា **“សមាធិស្មឹ បញ្ញាយ ច មត្តសោការិនោ** = អ្នកធ្វើល្មមប្រមាណក្នុងសមាធិ និងបញ្ញា” ។ បណ្ឌិតគប្បីជ្រាបសេចក្ដីសូម្បីក្នុងន័យទាំងពីរក្រៅអំពីនេះ ដោយឧបាយនេះចុះ ។

## សូម្បីក្នុងន័យទាំងពីរនេះ ន័យក្នុងព្រះសូត្រដទៃទៀត គឺ

ព្រះមានព្រះភាគទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងព្រះធម្មវិន័យនេះ ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ធ្វើល្មមប្រមាណក្នុងសមាធិ ធ្វើល្មមប្រមាណក្នុងបញ្ញា, ភិក្ខុនោះ នៅតែត្រូវ (អាបត្តិ) ក្នុង

*សិក្ខាបទតូច និងតូចបន្ទាប់[៧] ទាំងនោះខ្លះ នៅចេញចាក (អាបត្តិ) ខ្លះ ។ ហេតុនោះនឹងទៅជាអ្វី ។ ម្នាលភិក្ខុទាំងឡាយ តថាគតនៅតែមិនឲ្យឈ្មោះថា អភព្វក្នុងការត្រូវអាបត្តិហើយចេញចាកអាបត្តិនោះទេ ។ ពួកសិក្ខាបទណា ជាខាងដើមនៃមគ្គព្រហ្មចារ្យ សមគួរដល់មគ្គព្រហ្មចារ្យទី ៤, ភិក្ខុនោះ ជាអ្នកមានសីលដាប់មិនដាច់ផង, មានសីលតាំងនៅផង, សមាទានសិក្សាក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះ នៅតែបាន* ***សោតៈ*** *ព្រោះការអស់សំយោជនៈ ៣ មានសភាពជាអ្នកមិនបានធ្លាក់ចុះក្នុងអបាយ ជាអ្នកទៀងមានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល ។ល ។ ភិក្ខុនោះនៅតែបានសកទាគាមី ព្រោះអស់សំយោជនៈ ៣ ព្រោះតែស្រាលស្តើង* ***រាគៈ ទោសៈ*** *និង* ***មោហៈ*** *មកកាន់លោកនេះ ម្តងទៀត ក៏ធ្វើនូវទីបំផុតនៃទុក្ខបាន ។*

*ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល ធ្វើឲ្យបរិបូណ៌ក្នុងសមាធិ ធ្វើឲ្យល្មមប្រមាណក្នុងបញ្ញា ។ល ។ សមាទានសិក្សា*

---

[៧] បានដល់ សិក្ខាបទដ៏សេសទាំងឡាយ លើកលែងតែបរាជិក ៤ ចេញ ហៅថា តូច និង តូចបន្ទាប់ គឺសង្ឃាទិសេសជាសិក្ខាបទតូច, ថុល្លច្ច័យតូចបន្ទាប់; ថុល្លច្ច័យតូច, បាចិត្តិយៈតូចបន្ទាប់; បាចិត្តិយៈតូច, បាដិទេសនីយៈ ទុក្កដ និងទុព្ភាសិត ឈ្មោះថា តូចបន្ទាប់ (អដ្ឋកថា ព្រះសូត្រ ខាងលើ) នេះ ។

ក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះជាអនាគាមី ព្រោះអស់សំយោជនៈ ៣ ជាចំណែកខាងក្រោម មិនត្រឡប់មកកាន់លោកនេះទៀតឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល ធ្វើឲ្យបរិបូណ៌ក្នុងសមាធិ និងធ្វើឲ្យបរិបូណ៌ក្នុងបញ្ញា ភិក្ខុនោះនៅតែត្រូវ (អាបត្តិ) ក្នុងសិក្ខាបទតូច និងតូចបន្ទាប់នោះខ្លះ ។ល។ សមាទានសិក្សាក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះ នៅតែធ្វើឲ្យជាក់ច្បាស់ គឺជាអ្នកចូលដល់នូវការអស់ទៅនៃអាសវ-ក្កិលេសទាំងឡាយ (ព្រះអរហន្ត) ”[៨] ៕

---

## ពណ៌នាអំពីសាស្ដា ៣ ជំពូក

ពីរបទថា **“បរិញ្ញំ បញ្ញាបេតិ”** បានដល់ រមែងបញ្ញត្តការលះ និងការឈានកន្លង ។

បទថា **“តត្រ”** បានដល់ ក្នុងសាស្ដា ៣ ជំពូកនោះ ។

ពីរបទថា **“តេន ឧជ្ឈេញ្ញោ”** សេចក្ដីថា សាស្ដានោះ បណ្ឌិតគប្បីជ្រាបថា ជាអ្នកមានប្រក្រតីបាននូវរូបាវចរសមាបត្តិដោយបញ្ញត្តិនោះ ។ សូម្បីក្នុងវារៈទី ២ ក៏មានន័យដូចគ្នានេះដែរ ។

បទថា **“សម្មាសម្ពុទ្ធោ សត្ថា តេន ឧជ្ឈេញ្ញោ”** សេចក្ដីថា ព្រះសាស្ដា

---

[៨] អំ. តិក. ៤១ / ៣២៤ ។

អន្ទទី ៣ ជាព្រះសម្មាសម្ពុទ្ធនេះ បណ្ឌិតគប្បីជ្រាបដោយបញ្ញត្តិដែលមិនសាធារណៈដល់អន្យតិរ្ថិយនោះ ។ ពិតមែនហើយ ពួកអន្យតិរ្ថិយ កាលបើបញ្ញត្តការលះកាមទាំងឡាយ រមែងពោលអាងដល់រូបភព, កាលបើបញ្ញត្តការលះរូបទាំងឡាយ រមែងពោលអាងដល់អរូបភព, កាលបើបញ្ញត្តការលះវេទនាទាំងឡាយ រមែងពោលអាងដល់អសញ្ញាភព, កាលបើគេនឹងបញ្ញត្តដោយការពេញចិត្ត គប្បីបញ្ញត្តយ៉ាងនេះ ឈ្មោះថា រមែងមិនអាចដើម្បីបញ្ញត្តបានដោយប្រពៃឡើយ ។ ចំណែកព្រះសម្មាសម្ពុទ្ធជាម្ចាស់រមែងបញ្ញត្តការលះ (បហានបរិញ្ញា) កាមទាំងឡាយ ដោយអនាគាមិមគ្គ, រមែងបញ្ញត្តការលះរូប និងវេទនាទាំងឡាយ ដោយអរហត្តមគ្គ ។

បទថា **"ឥមេ តយោ សត្ថារោ"** សេចក្តីថា ជនទាំង ២ ជំពូកនេះ ជាសាស្តាខាងក្រៅព្រះពុទ្ធសាសនា និងព្រះសម្មាសម្ពុទ្ធជាម្ចាស់ ១ ជំពូក ព្រោះហេតុដូច្នោះ ក្នុងលោកនេះ ទើបមានព្រះសាស្តា ៣ ជំពូក ។

***ក្នុងនិទ្ទេសនៃសាស្តាពួកទី ២*** ពីរបទថា **"ទិដ្ឋេវ ធម្មេ"** បានដល់ក្នុងអត្តភាពនេះប៉ុណ្ណោះ ។

បទថា **"អត្តានំ សច្ចតោ ថេតតោ បញ្ញាបេតិ"** សេចក្តីថា រមែងបញ្ញត្តដោយសេចក្តីមានពិត ដោយភាពជារបស់ឋិតថេរថា "ឈ្មោះថាអត្តាជារបស់ទៀង ជារបស់ឋិតយូរ ជារបស់យ៉ាងពិតប្រាកដ" ។

បទថា **“អភិសម្បរាយញ្ច”** បានដល់ រមែងបញ្ញត្តក្នុងអត្តភាពសូម្បីដទៃទៀត ដូចគ្នានុ៎ះឯង ។ ពាក្យដ៏សេសក្នុងទីនេះ បណ្ឌិតគប្បីជ្រាបតាមសេចក្ដីនៃពាក្យដែលពោលទុកហើយដូច្នេះចុះ ៕

ចប់អដ្ឋកថាតិកនិទ្ទេស

ត្រឹមតែប៉ុណ្ណេះ

## ៤.អដ្ឋកថាចតុក្កនិទ្ទេស អធិប្បាយបុគ្គល ៤ ជំពូក

## ពណ៌នាអំពីបុគ្គលជាអសប្បុរសជាដើម

បទថា **“អសប្បុរិសោ”** បានដល់ បុរសអ្នកលាមក គឺបុរសអ្នកមិនមានធម៌ ។ គប្បីជ្រាបវិគ្រោះផ្សេងៗ ដូចតទៅ ៖

បុគ្គលឯណា រមែងញ៉ាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លងទៅ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **បាណាតិបាតី** = អ្នកញ៉ាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លងទៅ ។

បុគ្គលឯណា រមែងកាន់យកវត្ថុដែលម្ចាស់គេមិនបានឲ្យ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **អទិន្នាទាយី** = អ្នកកាន់យកវត្ថុដែលម្ចាស់គេមិនបានឲ្យ ។

*បុគ្គលឯណា រមែងប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា* **កាមេសុមិច្ឆាចារី** *= អ្នកប្រព្រឹត្តខុសក្នុងកាមទាំង-ឡាយ ។*

*បុគ្គលឯណា រមែងពោលពាក្យកុហក ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា* **មុសាវាទី** *= អ្នកពោលពាក្យកុហក ។*

*បុគ្គលឯណា រមែងតាំងនៅក្នុងសេចក្ដីប្រមាទដោយការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា* **សុរាមេរយ-មជ្ជប្បមាទដ្ឋាយី** *= អ្នកតាំងនៅក្នុងសេចក្ដីប្រមាទ ដោយការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ។*

*បទថា* **“បាណាតិបាតេ សមាទបេតិ”** *សេចក្ដីថា ខ្លួនឯងរមែងញុំាង សត្វមានជីវិតឲ្យធ្លាក់ចុះកន្លងទៅ ដោយប្រការណា រមែងញុំាងអ្នកដទៃឲ្យ ប្រកាន់យកការញុំាងសត្វដែលមានជីវិត ឲ្យធ្លាក់ចុះកន្លងទៅនោះ ដោយ ប្រការនោះ ។ សូម្បីក្នុងពាក្យទាំងឡាយដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។*

*ពីរបទថា* **“អយំ វុច្ចតិ”** *សេចក្ដីថា បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា* **អសប្បុរិសេន អសប្បុរិសតរោ** *= បុគ្គលជាអសប្បុរស ក្រៃលែងជាងអសប្បុរស ព្រោះហេតុដែលខ្លួន ប្រកបដោយភាពជាអ្នក ទ្រុស្តសីល ដែលខ្លួនធ្វើដោយខ្លួនឯងផង និងខ្លួនឯងក៏ជាទាយាទនៃកម្មពាក់*

កណ្ដាល ***អំពីកម្មដែលខ្លួនបបួលឱ្យអ្នកដទៃធ្វើផង*** ។

បទថា **“សប្បុរិសោ”** បានដល់ ឧត្តមបុរស គឺបុរសអ្នកខ្ពស់បំផុត ។

ពីរបទថា **“សប្បុរិសេន សប្បុរិសតរោ”** សេចក្ដីថា អ្នកប្រកបព្រម ដោយភាពជាអ្នកមានសីលល្អដែលខ្លួនឯងធ្វើហើយនោះផង និងព្រោះហេតុ ដែលខ្លួនជាទាយាទនៃកម្មពាក់កណ្ដាល អំពីកម្មដែលខ្លួនបបួលឲ្យអ្នកដទៃធ្វើ ផង ទើបឈ្មោះថា **ឧត្តមប្បុរិសេន ឧត្តមប្បុរិសតរោ** = អ្នកជាឧត្តមបុរស ក្រៃលែងជាងឧត្តមបុរស ៕

---

## ពណ៌នាអំពីបុគ្គលដែលលាមកជាដើម

បទថា **“បាបោ”** សេចក្ដីថា អ្នកប្រកបដោយបាប ១០ ប្រការ គឺ អកុសលកម្មបថ ១០ ប្រការ ។

បទថា **“កល្យាណោ”** សេចក្ដីថា អ្នកប្រកបដោយកល្យាណធម៌ ពោលគឺកុសលកម្មបថ ១០ ប្រការ ជាអ្នកបរិសុទ្ធ ជាអ្នកចម្រើន ។ ពាក្យ ដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលមែនពិត ព្រោះហេតុថា មានន័យ ដែលបានពោលទុកហើយ ក្នុងពេលមុននុ៎ះឯង ៕

---

## ពណ៌នាអំពីបុគ្គលមានធម៌លាមកជាដើម

ធម៌ដែលលាមករបស់បុគ្គលនោះ រមែងមាន ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **បាបធម្មោ** = អ្នកមានធម៌ដ៏លាមក ។ ធម៌ដ៏ល្អរបស់បុគ្គលនោះ រមែងមាន ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **កល្យាណធម្មោ** = អ្នកមានធម៌ដែលល្អ ។ ពាក្យដ៏សេសក្នុងទីនេះ មានសេចក្តីងាយស្រួលទាំងអស់ ៕

•••••••••••••••••

## ពណ៌នាអំពីបុគ្គលមានទោសជាដើម

បទថា **"សាវជ្ជោ"** បានដល់ មានទោស ។ ពីរបទថា **"សាវជ្ជេន កាយកម្មេន"** បានដល់ ដោយកាយកម្មដែលមានទោស មានបាណាតិបាតជាដើម ។ សូម្បីក្នុងបទទាំងឡាយក្រៅអំពីនេះ ក៏មានន័យដូចគ្នានេះដែរ ។

ពីរបទថា **"អយំ វុច្ចតិ"** សេចក្តីថា បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា **សាវជ្ជោ** = អ្នកមានទោស ព្រោះភាវៈនៃកម្មប្រកបដោយត្រៃទ្វារជារបស់មានទោស ដូចប្រទេសដែលពេញទៅដោយរបស់បដិកូលមានលាមក និងសាកសពជាដើម ។

ពីរបទថា **"សាវជ្ជេន ពហុលំ"** សេចក្តីថា កាយកម្មរបស់បុគ្គលឯណា មានទោសប៉ុណ្ណោះច្រើន ដែលមិនមានទោស មានតិច, បុគ្គលនោះ

*ឈ្មោះថា ប្រកបដោយកាយកម្មមានទោសច្រើន ដែលមិនមានទោស គឺមានតិច ទើបលោកហៅថា* **អប្បំ អនវជ្ជំ** *= កាយកម្មដែលមិនមានទោស គឺមានតិច ។ ក្នុងពាក្យទាំងឡាយក្រៅអំពីនេះ ក៏មានន័យដូចគ្នានេះដែរ ។*

***សួរថា*** *ក៏នរណាទៅដែលមានសភាពបែបនេះបាន ?*

*ឆ្លើយថា អ្នកឯណា រមែងសមាទានឧបោសថសីល រមែងបំពេញសីលក្នុងកាលខ្លះ តាមធម្មតារបស់អ្នកស្រុក ឬតាមធម្មតារបស់អ្នកនិគម អ្នកនោះឯង ឈ្មោះថា ប្រកបដោយកម្មដែលមានទោស ជាចំណែកច្រើន, ដែលមិនមានទោស ជាចំណែកតិច ។*

*ពីរបទថា* **"អយំ ទុច្ចតិ"** *សេចក្តីថា បុគ្គលនេះ គឺអ្នកបែបនេះ លោកហៅថា* **វជ្ជពហុលោ** *= អ្នកច្រើនដោយទោស ព្រោះហេតុដែលទោសនោះឯង ជារបស់មានច្រើន ព្រោះជាកម្មដែលប្រកបទុកដោយត្រៃទ្វារ ។*

*ដូចយ៉ាងថា ផ្កាឈើទាំងឡាយ មានពណ៌មិនស្អាត ទាំងមានក្លិនស្អុយ បុគ្គលធ្វើទុកឲ្យជាគំនរមាននៅក្នុងប្រទេសកន្លែងមួយ វត្ថុទាំងឡាយមានផ្កាំងសំពត់ជាដើម ដែលគេបោះទៅ គប្បីធ្លាក់ទៅលើគំនរផ្កាឈើដែលមានក្លិនស្អុយនោះ ក្នុងទីនោះៗ ធ្វើឲ្យមានក្លិនស្អុយ យ៉ាងណា, បុគ្គលនេះ គឺអ្នកយ៉ាងនេះ បណ្ឌិតគប្បីជ្រាបដូច្នោះដែរ ឬដូចយ៉ាងថា វត្ថុទាំងឡាយ មានផ្កាំងសំពត់ជាដើម ដែលគេធ្វើឲ្យជាគំនរ គប្បីមានក្នុងប្រទេសកន្លែងមួយ ផ្កា*

ឈើទាំងឡាយ មានផ្កាពុទ្រាជាដើម ដែលមានពណ៌មិនស្អាត មានក្លិនស្អុយ គប្បីធ្លាក់ទៅលើគំនរសំពត់នោះ ក្នុងទីនោះៗ យ៉ាងណា, បុគ្គលទី ៣ នេះ គឺអ្នកបែបនេះ បណ្ឌិតគប្បីជ្រាបដូច្នោះដែរ ។ តែថាបុគ្គលទី ៤ បណ្ឌិតគប្បីជ្រាបដូចថាសមាសដែលពេញដោយមធុរសទាំង ៤ ព្រោះកម្មដែលប្រកបដោយត្រៃទ្វារ ជារបស់រកទោសមិនបាន ។

បណ្ដាបុគ្គលទាំង ៤ ជំពូកនោះ គឺ

**១-សាវជ្ជោ** អ្នកមានទោស

**២-វជ្ជពហុលោ** អ្នកមានទោសច្រើន

**៣-អប្បសាវជ្ជោ** អ្នកមានទោសតិច

**៤-អនវជ្ជោ** អ្នកមិនមានទោស ។

បុគ្គលពួកទី ១ ចាត់ជាអន្ធពាលបុថុជ្ជន គឺបុថុជ្ជនអ្នកទាំងខ្វាក់ ទាំងល្ងង់ ។ ពួកទី ២ ចាត់ជាលោកិយបុថុជ្ជន អ្នកធ្វើកុសលក្នុងចន្លោះៗ ។ ពួក ទី ៣ បានដល់ ព្រះសោតាបន្ន ។ សូម្បីព្រះសកទាគាមី និងព្រះអនាគាមី ក៏សង្គ្រោះដោយបុគ្គលជំពូកទី ៣ ដែរ ។ ពួកទី ៤ បានដល់ព្រះខីណាស្រព ។

ពិតមែនហើយ ព្រះខីណាស្រពនោះ ឈ្មោះថា **អនវជ្ជោ** = អ្នកមិនមានទោសឡើយ សេចក្ដីនេះជាន័យរបស់អដ្ឋកថា ***អង្គុត្តរនិកាយ*** ៕

— — — — — — — -

## ពណ៌នាអំពីឧគ្ឃដិតញ្ញូបុគ្គលជាដើម

ការលើកញាណ គឺបញ្ញាឡើង ឈ្មោះថា **ឧគ្ឃដិតំ** = មានបញ្ញាវាងវៃ ក្នុងពាក្យថា ***ឧគ្ឃដិតញ្ញូ*** នេះ, អធិប្បាយថា រមែងដឹងត្រឹមតែធម៌ដែលលោកលើកចំណងជើងឡើង ដោយញាណសម្តែងប៉ុណ្ណោះ ។

បទថា **"សហ ឧទាហដវេលាយ"** បានដល់ ក្នុងការនាំចំណងជើងមកតាំងទុក គឺក្នុងខណៈត្រឹមតែនាំខទ្ទេសមកតាំងទុកប៉ុណ្ណោះ ។

បទថា **"ធម្មាភិសមយោ"** បានដល់ ការត្រាស់ដឹងសច្ចធម៌ទាំង ៤ ព្រមដោយញាណ គឺបញ្ញា ។

ពីរបទថា **"អយំ វុច្ចតិ"** សេចក្តីថា បុគ្គលនេះ ជាអ្នកអាចបញ្ជូនញាណ គឺបញ្ញាទៅតាមក្រសែនៃព្រះធម៌ទេសនា តាមដែលលោកតាំងបទមាតិកាដោយសង្ខេប មានន័យថា **"ចត្តារោ សតិបដ្ឋានា"** ជាដើម ហើយទើបកាន់យកព្រះអរហត្តបាន, ទើបលោកហៅអ្នកនេះថា **ឧគ្ឃដិតញ្ញូ** = អ្នកវាងវៃត្រឹមតែលើកមាតិកាធម៌ឡើងសម្តែងប៉ុណ្ណោះ ក៏ដឹងភ្លាម ។

បុគ្គលឯណា រមែងដឹងអត្ថដែលលោកអធិប្បាយធ្វើឲ្យពិស្តារនោះឯង ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា **វិបចិតញ្ញូ** = អ្នកដឹងអត្ថដែលលោកអធិប្បាយហើយ ។

*ពីរបទថា* **“អយំ ឧុច្ចតិ”** *សេចក្ដីថា បុគ្គលនេះ គឺអ្នកមានសមត្ថភាព អាចដើម្បីសម្រេចព្រះអរហត្ត ក្នុងកាលមានអ្នកដទៃតាំងបទមាតិកាទុកដោយសង្ខេប ហើយចែកសេចក្ដីដោយពិស្ដារ ទើបលោកហៅថា* **វិបចិតញ្ញូ** ៕

--------------

## វិគ្រោះសព្ទថា នេយ្យបុគ្គល

***ឧទ្ទេសាទីហិ នេតព្វោតិ*** **នេយ្យោ** *បុគ្គលឯណា ដែលអ្នកដទៃគប្បីណែនាំដោយបទទាំងឡាយ មានឧទ្ទេសជាដើម ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា* **នេយ្យោ** *អ្នកដែលបុគ្គលគប្បីណែនាំទៅបាន ។*

*ពីរបទថា* **“អនុបុព្វេន ធម្មាភិសមយោ”** *បានដល់ ការសម្រេចព្រះអរហត្តតាមលំដាប់ ។*

## វិគ្រោះសព្ទថា បទបរមបុគ្គល

***ព្យញ្ជនបទមេវ បរមំ អស្សាតិ*** **បទបរមោ** *បទនៃព្យញ្ជនៈប៉ុណ្ណោះជាយ៉ាងក្រៃលែងរបស់បុគ្គលនោះ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា* **បទបរមោ** *អ្នកមានបទយ៉ាងក្រៃលែង ។*

*បទថា* **“ន តាយ ជាតិយា ធម្មាភិសមយោ ហោតិ”** *អធិប្បាយថា បទបរមបុគ្គលនោះ មិនអាចដើម្បីនឹងធ្វើញាណ វិបស្សនា មគ្គ និងផលឲ្យកើតឡើង បានដោយអត្តភាពនោះ៕*

## ពណ៌នាអំពីបុគ្គលឆ្លើយបានត្រឹមត្រូវ តែមិនរហ័សរហួនជាដើម

*ញាណ គឺបញ្ញាក្តី ពាក្យសម្តីដែលតាំងឡើង ព្រោះញាណក្តី ហៅថា* **បដិភាណ** *គឺសេចក្តីវាងវៃក្នុងការឆ្លើយតប ។ បដិភាណនោះ ព្រះមាន-ព្រះភាគទ្រង់ព្រះបំណងយកក្នុងពាក្យថា* ***"យុត្តបដិភាណ"*** *នេះ ។*

*បដិភាណដែលសមគួរដល់ហេតុ និងសមគួរដល់ផល របស់បុគ្គលនោះមាន ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា* **យុត្តបដិភាណោ** *អ្នកមានបដិភាណដែលត្រឹមត្រូវ ។ បដិភាណមិនរហ័សរហួនរបស់បុគ្គលនោះមាន ព្រោះភាវៈនៃខ្លួនជាអ្នកមិនអាចដើម្បីឆ្លើយតបបញ្ហាបាន ដោយលឿនរហ័ស ក្នុងខណៈដែលគេសួរបញ្ហាភ្លាមៗ ព្រោះហេតុនោះ បុគ្គលនោះឈ្មោះថា* **នោមុត្តបដិភាណោ** *= អ្នកមានបដិភាណដែលមិនរហ័សរហួន ។ បុគ្គលដ៏សេស បណ្ឌិតគប្បីជ្រាបដោយន័យនេះចុះ ។*

*ក៏ក្នុងបុគ្គលទាំងនេះ* ***បុគ្គលជំពូកទី ១*** *ពិចារណាបញ្ហាអស់វេលាត្រឹមតែបន្តិចបន្តួច ហើយទើបសម្តែងបញ្ហាបានត្រឹមត្រូវនេះមែនពិត ដូច* ***ព្រះចូឡនាគត្ថេរ*** *អ្នកទ្រទ្រង់ព្រះត្រៃបិដក បានពោលថា ព្រះថេរៈនោះ ត្រូវគេសួរបញ្ហា លោកកំណត់បញ្ហាបានត្រឹមត្រូវ និងសមរម្យមែនពិត ។*

***បុគ្គលជំពូកទី ២*** *រមែងហាមបញ្ហាក្នុងចន្លោះដែលគេសួរនោះឯង ដោយពាក្យសម្តីយ៉ាងណាមួយ, សូម្បីលោកពិចារណាបញ្ហាហើយ ក៏នៅ*

ប៉ុន់ស្មានសេចក្ដីនៃបញ្ហាមិនបានត្រឹមត្រូវ ដូចព្រះតិស្សត្ថេរអ្នកឈ្លាស ត្រឹមតែនិកាយ ៤, ន័យថា ព្រះថេរៈនោះ ត្រូវគេសួរបញ្ហាហើយ សូម្បីរង់ចាំការអស់ទៅនៃបញ្ហារួចរាល់ហើយ លោកក៏ឆ្លើយតបបញ្ចូនៗ (ភ្លាមៗ) ទៅ, ក៏សេចក្ដីនៃពាក្យសម្ដីដែលលោកពិចារណាហើយ មែងមិនអនុលោមទៅតាមក្នុងទីណាៗ ឡើយ ។

***បុគ្គលជំពូកទី ៣*** លោកពិចារណាសេចក្ដីសមគួរដល់វេលានៃបញ្ហានុ៎ះឯង រមែងឆ្លើយពាក្យសួរក្នុងខណៈនោះឯង, ដូចព្រះចូឡាភយត្ថេរអ្នកទ្រទ្រង់ព្រះត្រៃបិដក; បានពុថា ព្រះថេរៈនោះ ត្រូវគេសួរបញ្ហាហើយ រមែងឆ្លើយបានដោយលឿនរហ័ស មានហេតុផលដែលត្រឹមត្រូវ និងសមរម្យផង ។

***បុគ្គលជំពូកទី ៤*** ត្រូវគេសួរបញ្ហាហើយ រមែងមិនពិចារណាបញ្ហាបានឲ្យត្រឹមត្រូវ ទាំងនៅមិនអាចដើម្បីនឹងហាមដោយពាក្យសម្ដីយ៉ាងណាមួយ ដូចជាបុគ្គលដែលលិចចុះក្នុងសេចក្ដីងងឹតអ័ព្ទដ៏ក្រៃលែង ដូចលោឡុទាយីភិក្ខុដែរ ៕

## ពណ៌នាអំពីបុគ្គលជាធម្មកថិក ៤ ជំពូក

ពីរបទថា **“អប្បញ្ច ភាសតិ”** សេចក្ដីថា រមែងពោលត្រឹមតែបន្តិចបន្តួច ដល់បរិស័ទដែលមកហើយ ។

បទថា **“អសហិតញ្ច”** សេចក្ដីថា ឯកាលពោល ក៏រមែងមិនពោលឲ្យសមរម្យដល់ហេតុ និងផល ។

បទថា **“បរិសា ចស្ស អកុសលា ហោតិ”** អធិប្បាយថា ក៏បរិស័ទដែលកំពុងអង្គុយប្រជុំគ្នាដើម្បីនឹងស្ដាប់ព្រះធម៌ ភិក្ខុជាធម្មកថិកនោះ រមែងមិនដឹងពាក្យពេចន៍ដែលគួរ និងមិនគួរ មានហេតុ ឬមិនមានហេតុ ល្អ ឬមិនល្អ ។

បទថា **“ឯវរូបោ”** សេចក្ដីថា អ្នកនេះ គឺព្រះធម្មកថិកអ្នកល្ងង់អ្នកមានជាតិយ៉ាងនោះ រមែងបានឈ្មោះថា ធម្មកថិករបស់បរិស័ទអ្នកល្ងង់ខ្លៅ អ្នកមានជាតិយ៉ាងនោះឯង ។ បណ្ឌិតគប្បីជ្រាបសេចក្ដីគ្រប់ៗបទ ដោយន័យនេះចុះ ។ ក៏ក្នុងព្រះធម្មកថិកនេះ ព្រះធម្មកថិក ២ ពួកប៉ុណ្ណោះ ឈ្មោះថា ជាព្រះធម្មកថិកដោយសភាវៈ, ចំណែកព្រះធម្មកថិកក្រៅអំពីនេះ លោកពោលទុកយ៉ាងនោះ ព្រោះនៅក្នុងចន្លោះនៃព្រះធម្មកថិកទាំងឡាយ ៕

## ពណ៌នាអំពីបុគ្គលប្រៀបដូចខលាហកៈ (ពពក) ៤ យ៉ាង

*បទថា* **“ខលាហកា** *= ដុំពពក”* ។

*បទថា* **“គជ្ជិតា** *= មេឃគំរាម (ផ្គរលាន់) ហើយ”* ។ *បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងសេចក្តីនេះថា ក៏ឈ្មោះថា មេឃគំរាមហើយ ភ្លៀងមិនធ្លាក់ រមែងជាបាប, ព្រោះថា មនុស្សទាំងឡាយគិតថា “កាលណាផ្គរលាន់ហើយ ភ្លៀងក៏នឹងធ្លាក់” ទើបនាំគ្នាយកពូជចេញសាបព្រោះ កាលបើភ្លៀងមិនធ្លាក់ ពូជដែលមាននៅក្នុងស្រែ ក៏វិនាសទៅក្នុងស្រែនុ៎ះឯង ។ ពូជដែលមាននៅក្នុងផ្ទះ ក៏វិនាសទៅក្នុងផ្ទះនុ៎ះឯង, ព្រោះហេតុដូច្នោះ គ្រានោះឯង ទុព្ភិក្ខភ័យរមែងមាន ទើបឈ្មោះថា* ***បាប*** *។*

*សូម្បីភាវៈដែលមេឃមិនមានផ្គរលាន់, តែភ្លៀងធ្លាក់ ក៏ជាបាបមែនពិត; ព្រោះថា មនុស្សទាំងឡាយរមែងធ្វើការសាបព្រោះពូជក្នុងស្រែទំនាបនោះឯង ដោយគិតថា “វេលានេះភ្លៀងនឹងរាំង” ពេលនោះ ភ្លៀងក៏ធ្លាក់ចុះមកបានញ៉ាំងពូជទាំងឡាយ ឲ្យដល់មហាសមុទ្រ, ក្នុងកាលនេះ ទុព្ភិក្ខភ័យ នោះឯងរមែងមាន ។ តែថា ភាវៈដែលផ្គរលាន់ហើយភ្លៀងធ្លាក់ រាប់ថា ជាសេចក្តីចម្រើន, ព្រោះថា ពេលនោះ ជាវេលាដែលមានភិក្ខារកបានងាយ ។ ភាវៈដែលមេឃមិនមានផ្គរលាន់ ភ្លៀងក៏មិនធ្លាក់ ឈ្មោះថា ជាបាបធ្ងន់មែនពិត ។*

បទថា **"ភាសិតា ហោតិ នោ កត្តា"** សេចក្ដីថា បុគ្គលដែលពោលថា "ឥឡូវនេះ ខ្ញុំនឹងបំពេញគន្ថធុរៈ ឬនឹងបំពេញវិបស្សនាធុរៈនោះឯង" តែថា មិនកាន់យកខទ្ទេស និងមិនចម្រើនកម្មដ្ឋានឡើយ ។

បទថា **"កត្តា ហោតិ នោ ភាសិតា"** សេចក្ដីថា បុគ្គលមិនពោលថា "ឥឡូវនេះ ខ្ញុំនឹងបំពេញគន្ថធុរៈ ឬនឹងបំពេញវិបស្សនាធុរៈ" , តែកាលដល់ពេលវេលាហើយ គេរមែងញុំាងប្រយោជន៍នោះឲ្យសម្រេច ។ បណ្ឌិតគប្បីជ្រាបបុគ្គលក្រៅអំពីនេះ ដោយន័យនេះចុះ; ក៏សុម្បីពាក្យទាំងអស់នោះ លោកពោលទុក សម្រាប់បុគ្គលដែលប្រគេនបច្ច័យប៉ុណ្ណោះ; ពិតណាស់ ទាយកម្នាក់និមន្តព្រះសង្ឃដោយពោលថា "ខ្ញុំនឹងប្រគេនទាន ក្នុងថ្ងៃនោះ" , លុះដល់វេលាហើយ ក៏មិនធ្វើ, អ្នកនេះរមែងសាបសូន្យចាកបុណ្យ; សូម្បីភិក្ខុសង្ឃ ក៏រមែងសាបសូន្យចាកលាភ (ប្រៀបបាននឹងផ្គរលាន់ឥតភ្លៀង) ។ ទាយកម្នាក់ទៀត មិននិមន្តព្រះសង្ឃទេ ដោយគិតថា "យើងនឹងធ្វើសក្ការៈហើយនឹងនាំភិក្ខុមក" គេរមែងមិនបានព្រះសង្ឃ ព្រោះព្រះសង្ឃទាំងអស់ត្រូវអ្នកដទៃនិមន្តទៅក្នុងទីដទៃអស់ហើយ, បុគ្គលនោះ រមែងសាបសូន្យចាកបុណ្យ; សូម្បីសង្ឃក៏សាបសូន្យចាកលាភនោះ (ប្រៀបបាននឹងភ្លៀងធ្លាក់មិនមានផ្គរលាន់) ។ ចំណែកទាយកមួយពួកទៀត និមន្តសង្ឃជាមុន

*ហើយចាត់ចែងសក្ការៈ ខាងក្រោយ ទើបថ្វាយទាន អ្នកនេះ ឈ្មោះថា រមែងធ្វើកិច្ចដែលត្រឹមត្រូវ (ប្រៀបបាននឹងផ្គរលាន់ភ្លៀងធ្លាក់) ។ មួយពួកទៀត សង្ស្រក៏មិននិមន្ត ទានក៏មិនប្រគេន អ្នកនេះ បណ្ឌិតគប្បីជ្រាបថា ជាបាបបុគ្គល (ប្រៀបបាននឹងផ្គរលាន់មិនមាន ភ្លៀងក៏មិនធ្លាក់) ៕*

- - - - - - - -

## ពណ៌នាអំពីបុគ្គលប្រៀបដូចកណ្ដុរ ៤ ជំពូក

*បទថា* **“គាធំ កត្តា នោ ចសិតា”** *សេចក្តីថា កណ្ដុរជំពូកទី ១ រមែងធ្វើរន្ធឲ្យជាទីនៅអាស្រ័យរបស់ខ្លួន, តែមិននៅក្នុងរន្ធនោះ ចេញទៅនៅក្នុងទីកន្លែងមួយនោះវិញ កាលបើដូច្នេះ វារមែងទៅកាន់អំណាចរបស់អមិត្ត មានសត្វឆ្មាជាដើម ។ បាលីខ្លះថា* **“ខត្តា** *= ជីក”ដូច្នេះក៏មាន ។*

*បទថា* **“ចសិតា នោ គាធំ កត្តា”** *សេចក្តីថា កណ្ដុរពួកទី ២ មិនធ្វើរន្ធនៅខ្លួនឯងទេ, តែទៅអាស្រ័យរន្ធដែលអ្នកដទៃធ្វើទុក កាលបើដូច្នេះក៏នៅឈ្មោះថា រក្សាជីវិតទុកបាន ។ កណ្ដុរជំពូកទី ៣ ធ្វើកិច្ចដើម្បីទាំង ២ យ៉ាង រមែងរក្សាជីវិតទុកបាន ។ កណ្ដុរជំពូកទី ៤ មិនធ្វើកិច្ចទាំង ២ យ៉ាង វារមែងដល់អំណាចរបស់អមិត្ត ។*

*ក៏បណ្ដាបុគ្គលទាំងឡាយ ដែលលោកឧបមាហើយ ដោយការប្រៀបធៀបនេះ បុគ្គលទី ១ រៀនពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា*

មានអង្គ ៩ ដូចកណ្ដុរដែលជីករន្ធសម្រាប់នៅជ្រៅ គឺកណ្ដុរនោះមិននៅក្នុងរន្ធជ្រៅដែលខ្លួនធ្វើទេ, តែទៅនៅក្នុងទីកន្លែងមួយផ្សេងទៀត រមែងទៅកាន់អំណាចរបស់អមិត្ត យ៉ាងណា, សូម្បីបុគ្គលនេះ បញ្ជូនញាណទៅដោយអំណាចនៃការសិក្សារៀនសូត្រ, តែមិនបានចាក់ធ្លុះសច្ចធម៌ទាំង ៤ ឡើយ, កាលបើប្រព្រឹត្តទៅដូច្នេះ ក្នុងកន្លែងលោកាមិសទាំងឡាយ គេរមែងទៅកាន់អំណាចរបស់អមិត្តទាំងឡាយ ពោលគឺមច្ចុមារ កិលេសមារ និងទេវបុត្តមារដូច្នោះ ។

បុគ្គលជំពូកទី ២ មិនរៀនពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដាមានអង្គ ៩ (គឺ ១.សុត្តៈ, ២.គេយ្យៈ, ៣.វេយ្យាករណៈ, ៤.គាថា, ៥.ឧទាន, ៦.ឥតិវុត្តកៈ, ៧.ជាតកៈ, ៨.អព្ភូតធម្មៈ, ៩.វេទល្លៈ) ប្រៀបដូចកណ្ដុរនោះ មិនធ្វើរន្ធនៅ គឺដូចយ៉ាងថា កណ្ដុរនោះអាស្រ័យនៅក្នុងរន្ធដែលកណ្ដុរដទៃជីកហើយ, វារមែងរក្សាជីវិតទុកបាន យ៉ាងណា; ភិក្ខុនេះស្ដាប់ធម្មកថារបស់អ្នកដទៃហើយ ក៏ចាក់ធ្លុះសច្ចធម៌ទាំង ៤, ឈានកន្លងអំណាចរបស់មារទាំង ៣ បានដូច្នោះ ។ បណ្ឌិតគប្បីជ្រាបការប្រៀបធៀបឧបមាសូម្បីក្នុងបុគ្គលទី ៣ និងទី ៤ ដោយន័យនេះចុះ ៕

## ពណ៌នាអំពីបុគ្គលប្រៀបដូចផ្លែស្វាយ ៤ ប្រភេទ

ពីរបទថា **“អាមំ បក្កវណ្ណី”** បានដល់ ផ្លែស្វាយខ្ចីខាងក្នុង, តែខាងក្រៅដូចស្វាយទុំ ។

ពីរបទថា **“បក្កំ អាមវណ្ណី”** បានដល់ ខាងក្នុងទុំ, តែខាងក្រៅដូចស្វាយខ្ចី ។ សូម្បីក្នុង ២ បទដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។ ក្នុងពាក្យប្រៀបធៀប ដោយផ្លែស្វាយនោះ គឺភាវៈនៃស្វាយមិនទុំ គឺជារបស់ខ្ចីយ៉ាងណា, សូម្បីក្នុងភាពនៃបុគ្គលជាបុថុជ្ជន ដូចស្វាយខ្ចី, ភាពជាព្រះអរិយៈក៏ដូចជាស្វាយទុំដូច្នោះ; បណ្ឌិតគប្បីជ្រាបការប្រៀបធៀប ដោយការឧបមាក្នុងបុគ្គលដែលលោកឧបមាហើយ ដោយន័យនេះថា ដូចជាស្វាយមានពណ៌ទុំហាក់ដូចជាស្វាយទុំ, ក្នុងស្វាយទាំងឡាយនោះ យ៉ាងណា; សូម្បីក្នុងបុគ្គលដែលជាព្រះអរិយៈទាំងឡាយ មានវណ្ណៈដែលទុំ គឺសេចក្ដីល្អ ដូចជាសេចក្ដីល្អរបស់ឥរិយាបថទាំងឡាយ មានការឈានទៅខាងមុខជាដើម ក៏ដូច្នោះដែរ ៕

•••••••••••••••••••••

## ពណ៌នាអំពីបុគ្គលប្រៀបដូចក្អម ៤ ប្រភេទ

បទថា **“កុម្ភោ** = ក្អម” ។

បទថា **“តុច្ឆោ”** បានដល់ ខាងក្នុងទំនេរ ។

បទថា **“បិហិតោ”** បានដល់ ក្អមដែលគេបិទមាត់តាំងទុក ។

បទថា **"ឬរោ"** បានដល់ ខាងក្នុងពេញ ។

បទថា **"ឱវដោ"** បានដល់ ក្អមដែលគេបើកមាត់តាំងទុក ។ ក៏ក្នុងបណ្ដាបុគ្គលដែលលោកឧបមាហើយក្នុងទីនេះ បណ្ឌិតគប្បីជ្រាបថា ឈ្មោះថាជាបុគ្គលទទេ ព្រោះវៀរចាកសារៈ គឺគុណសេចក្ដីល្អ ដែលមានខាងក្នុងនិងឈ្មោះថា ជាអ្នកបិទ ព្រោះភាពជាអ្នកស្អាតខាងក្រៅ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យដូចគ្នានេះដែរ ៕

---

## ពណ៌នាអំពីបុគ្គលប្រៀបដូចអន្លង់ទឹក ៤ កន្លែង

ក៏កាលបើទឹកជ្រៅប្រមាណត្រឹមជង្គង់ តែអន្លង់ទឹកមានផ្ទៃទឹកមិនប្រាកដ, ព្រោះមានពណ៌ទឹកដែលលាយគ្នា ឬព្រោះជាទឹកល្អក់ ឈ្មោះថាទឹករាក់មានស្រមោលជ្រៅ ។ ក៏សូម្បីទឹកជ្រៅប្រមាណ ៣ ឬ ៤ បុរស អន្លង់ទឹកមានផ្ទៃទឹកប្រាកដ ព្រោះជាទឹកថ្លា ទើបឈ្មោះថា ជាទឹកជ្រៅ មានស្រមោលរាក់ ។ បណ្ឌិតគប្បីជ្រាបអន្លង់ទឹកទាំងពីរក្រៅនេះ ព្រោះមានហេតុជាដែនកើតព្រមទាំង ២ ហេតុ ។ សូម្បីបុគ្គលដែលប្រកបដោយឥរិយាបថទាំងឡាយ មានការឈានទៅខាងមុខជាដើម ដែលដូចនឹងជម្រៅនៃគុណធម៌ទាំងឡាយ, តែព្រោះមានកិលេសក្រាស់ និងមិនមានគុណធម៌

*ដ៏ជ្រៅ ទើបឈ្មោះថា ដូចទឹករាក់, តែមានរស្មីដែលជ្រៅ* ***(ឧត្តានោ គម្ភីរោភាសោ នាម)*** *បុគ្គលដ៏សេស បណ្ឌិតគប្បីជ្រាបដោយន័យនេះចុះ ។*

..............................

## ពណ៌នាអំពីបុគ្គលប្រៀបដូចគោបម្រើ ៤ ពួក

*គប្បីជ្រាបគោបម្រើជាមុន, គោឯណាកាច គឺរមែងធ្វើហ្វូងរបស់ខ្លួនឲ្យខ្វាច, តែស្ងប់ស្ងៀមមានប្រក្រតីជាសុខក្នុងហ្វូងគោពួកដទៃ, គោនេះឈ្មោះថា ជាគោសាហាវឃោរឃៅក្នុងហ្វូងរបស់ខ្លួន, តែមិនឃោរឃៅក្នុងហ្វូងគោដទៃ; សូម្បីបុគ្គលក៏ដូចគ្នាដែរ, បៀតបៀនចាក់ដោតបរិស័ទរបស់ខ្លួន មានការស្រែកហៅដោយពាក្យសម្តីទ្រគោះបោះបោក, តែជាអ្នកស្ងប់ស្ងៀម ប្រព្រឹត្តបន្ទាបខ្លួនក្នុងបរិស័ទអ្នកដទៃ ឈ្មោះថា ដូចជាគោដែលឃោរឃៅ ក្នុងហ្វូងរបស់ខ្លួន, តែមិនឃោរឃៅក្នុងគោហ្វូងដទៃៗ ទេ; សូម្បីបុគ្គលដ៏សេស បណ្ឌិតគប្បីជ្រាបដោយន័យនេះចុះ ។ ក៏និទ្ទេសវារៈ ក្នុងពាក្យថា* **“ឧព្វេជិតា ហោតិ”** *នេះ បានដល់ ការប៉ះទង្គិច ការចាក់សៀត គឺការធ្វើអាការឲ្យធ្លាក់ទឹកចិត្តខ្វាចនេះឯង ។*

## ពណ៌នាអំពីបុគ្គលប្រៀបដូចអាសិរពិស ៤ ពួក

*គប្បីជ្រាបអាសិរពិសជាមុន, ពិសរបស់ពស់ឯណា រមែងរត់មក*

*ដោយរហ័ស គឺជ្រៀតចូលទៅដោយរហ័ស, តែមានពិសមិនសាហាវ ទាំងមិនបៀតបៀននៅយូរ ពិសរបស់ពស់នោះ ឈ្មោះថា មកហើយរហ័ស តែមានពិសមិនសាហាវទេ ។ ក្នុងបទទាំងពួងដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។ ឯការចែកបុគ្គល ក៏មានសេចក្ដីងាយស្រួលទាំងអស់ ៕*

---

## ពណ៌នាអំពីបុគ្គលពោលតិះដៀលមនុស្ស
## ដែលគួរតិះដៀលត្រឹមត្រូវតាមកាល ២ ឈ ២ ជាដើម

*បទថា* **“អននុវិច្ច”** *បានដល់ មិនពិចារណា គឺមិនសង្កេតមើល ។*

*បទថា* **“អបរិយោគាហេត្វា”** *បានដល់ មិនឲ្យកាន់យកនូវគុណទាំងឡាយ ដោយបញ្ញា ។*

*ពីរបទថា* **“ភូតំ តច្ឆំ”** *បានដល់ ក៏ឈ្មោះថា* ***ពិត*** *ព្រោះជារបស់មានមែន, ឈ្មោះថា* ***ជារបស់ពិត*** *ព្រោះជារបស់មិនវិបរិត (ក្លែងក្លាយ) ។*

*បទថា* **“កាលេន”** *បានដល់ តាមកាលដែលគួរ និងសមរម្យ ។*

*បទថា* **“តត្រ កាលញ្ញូ ហោតិ”** *សេចក្ដីថា ពាក្យនេះឯង លោកពោលទុកថា* **“កាលេន”** *។ ក៏បុគ្គលឯណា ជាកាលញ្ញូ គឺជាអ្នកស្គាល់កាល ដើម្បីប្រយោជន៍ដល់ការព្យាករណ៍បញ្ហានេះថា “កាលនេះ ពេលដែល*

ខ្ញុំត្រូវគេសួរបញ្ហាមិនគួរពោលឡើយ ក្នុងកាលនេះ គួរពោល" ព្រោះហេតុនេះ ទើបអ្នកនេះ ឈ្មោះថា រមែងពោលតាមកាល ។

ពីរបទថា **"ឧបេក្ខោ វិហរតិ"** បានដល់ ជាអ្នកតាំងនៅក្នុងឧបេក្ខាដែលមានភាពជាកណ្ដាល ។ ក្នុងពាក្យគ្រប់ ៗ បទដ៏សេស មានសេចក្ដីងាយស្រួលទាំងអស់ ៕

........................

## ពណ៌នាអំពីបុគ្គលចិញ្ចឹមជីវិត

## ដោយផលនៃសេចក្ដីព្យាយាម ៤ ល ៤ ជាដើម

អ្នកឯណា ឲ្យវេលាកន្លងទៅរហូតថ្ងៃ ដោយសេចក្ដីខស្បាហ៍ គឺសេចក្ដីព្យាយាមនោះឯង បានវត្ថុយ៉ាងណានីមួយដែលគ្រាន់តែជាផល ហូរចេញពីខស្បាហ៍ព្យាយាមនោះ ហើយសម្រេចការចិញ្ចឹមជីវិត, ក៏បុគ្គលអាស្រ័យសេចក្ដីព្យាយាមនោះហើយ មិនបានផលនៃបុណ្យយ៉ាងណាមួយតាមដែលលោកសំដៅយកបុគ្គលនោះ ហើយពោលពាក្យជាដើមថា **"យស្ស បុគ្គលស្ស ឧដ្ឋហតោ"** ។

បទថា **"តតូបរិនេខា"** បានដល់ ទេវតាទាំងឡាយ ខាងលើអំពីនោះមានពួកព្រហ្មជាដើម; ពិតមែនហើយ ឈ្មោះថា កិច្ច គឺការងារដោយ

សេចក្តីខិតខំខស្សហ៍ព្យាយាម រមែងមិនមានដល់ទេវៈទាំងនោះ ពួកទេវៈនោះ អាស្រ័យផលបុណ្ណោះរស់នៅ ។

ពាក្យថា **"បុញ្ញតោ ច"** នេះ ពោលសំដៅដល់ជនអ្នកមានបុណ្យ មានក្សត្រមហាសាល ព្រាហ្មណមហាសាល និងទេវតាទាំងឡាយ តាំងអំពីភូមិទេវតារហូតដល់ទេវតាជាន់និម្មានរតីជាទីបំផុត ។ ព្រោះថា ទេវតា និងមនុស្សទាំងនោះ សូម្បីទាំងអស់ រមែងសោយផលនៃសេចក្តីព្យាយាម និងផលនៃបុណ្យ, ចំណែកសត្វនរកទាំងឡាយ រមែងមិនអាចដើម្បីធ្វើអាជីពឲ្យកើតឡើង ដោយសេចក្តីព្យាយាមបានឡើយ, ទាំងអាជីពអ្វីៗ ដែលនឹងកើតឡើងដល់សត្វនរកទាំងនោះ ដោយផលនៃបុណ្យក៏មិនមាន ៕

## ពណ៌នាអំពីបុគ្គលមកងងឹត ទៅងងឹតជាដើម

បុគ្គលឯណាប្រកបដោយភាពងងឹតជាដើមថា កើតមកក្នុងត្រកូលថោកទាបជាដើម ព្រោះហេតុនោះ អ្នកនោះ ទើបឈ្មោះថា **តមោ** = អ្នកងងឹត ។ បុគ្គល ឈ្មោះថា **តមបរាយនោ** គឺអ្នកមានសេចក្តីងងឹតប្រព្រឹត្តទៅខាងមុខ ព្រោះការចូលដល់ភាពងងឹតក្នុងនរកទៀត ដោយទុច្ចរិតទាំងឡាយ មានកាយទុច្ចរិតជាដើម ។

*បទថា* **“នេសទកុលេ”** *បានដល់ ត្រកូលនាយព្រានម្រឹគជាដើម ។ ពាក្យថា* **“វេនកុលេ”** *បានដល់ ត្រកូលជាងត្បាញ ។ ពាក្យថា* **“បុក្កុស-កុលេ”** *បានដល់ ត្រកូលបុគ្គលដែលចាក់សំរាម ។ ពាក្យថា* **“កសិរវុត្តិកេ** *= មានសេចក្ដីក្រខ្សត់” ។ បទថា* **“ទុព្វណ្ណោ”** *បានដល់ អ្នកមានពណ៌សម្បុរដូចដង្កត់ឈើដែលត្រូវភ្លើងឆេះ ដូចបិសាចរមៀលលេងលើដីធូលី ។ បទថា* **“ទុទ្ទសិកោ”** *បានដល់ នរណាមួយឃើញ មិនជាទីចូលចិត្ត សូម្បីតែមាតាបង្កើតរបស់ខ្លួន ។ ពាក្យថា* **“ឱកោដិមកោ** *= ជាមនុស្សតឿ” ។ បទថា* **“កាណោ”** *បានដល់ មានភ្នែកខ្វាក់ម្ខាង ឬសងខាង ។ បទថា* **“កុណី”** *បានដល់ មានដៃពិការម្ខាង ឬសងខាង ។ បទថា* **“ខញ្ជោ”** *បានដល់ មានជើងពិការម្ខាង ឬសងខាង ។ បទថា* **“បក្ខហតោ”** *បានដល់ អ្នកត្រូវរោគកម្វាត់ទៅមួយចំណែក គឺជាអ្នកពិការអស់កម្លាំង ។*

*បទថា* **“បទីបេយ្យស្ស”** *បានដល់ ឧបករណ៍នៃប្រទីប មានប្រេងនិងចង្កៀងជាដើម ។*

*ក្នុងពាក្យថា* **“ឯវំ បុគ្គលោ តមោ ហោតិ តមបរាយណោ”** *នេះ លោកអធិប្បាយទុកថា បុគ្គលមួយពួកមិនឃើញពន្លឺខាងក្រៅ ធ្វើកាលៈ គឺស្លាប់ក្នុងផ្ទៃមាតានោះឯង ហើយកើតក្នុងអបាយទាំងឡាយ គេរមែងគ្រាប់*

ទៅរហូតកប្បទាំងអស់ ឈ្មោះថា **តមោ តមបរាយនោ** គឺបុគ្គលមកងងឹតទៅងងឹតនោះឯង និងគេនោះ គប្បីជាកុហកបុគ្គល គឺបុគ្គលដែលបោកបញ្ឆោត, ក៏ការកើតរបស់កុហកបុគ្គលនោះ មានសភាវៈបែបនេះ; ម្យ៉ាងទៀត ក្នុងអធិការនេះ លោកសម្ដែងការវិបត្តិនៃការមក និងវិបត្តិនៃបច្ច័យដែលកើតឡើងខាងដើមរបស់គេ ដោយពាក្យថា **"នីចេ កុលេ បច្ចា ជាតោ ហោតិ ចណ្ឌាលកុលេ វា** = អ្នកកើតមកហើយ ក្នុងត្រកូល ថោកទាបឬត្រកូលចណ្ឌាល" ជាដើម ។ លោកសម្ដែងនូវវិបត្តិនៃបច្ច័យរបស់កុហកបុគ្គលនោះ ដោយពាក្យថា **"ទលិទ្ទេ** = ខ្វះខាត" ជាដើម ។ លោកសម្ដែងនូវវិបត្តិនៃឧបាយជាគ្រឿងចិញ្ចឹមជីវិតរបស់គេ ដោយពាក្យជាដើមថា **"កសិរវុត្តិកេ** = អ្នករស់នៅដោយលំបាក" ។ លោកសម្ដែងនូវវិបត្តិនៃរូបរបស់គេដោយពាក្យថា " **ទុព្វណ្ណោ** = មានវណ្ណៈអន់" ជាដើម ។ លោកសម្ដែងសេចក្ដីប្រកបព្រមដោយហេតុនៃទុក្ខរបស់ គេដោយពាក្យជាដើមថា " **ពវ្ហាពាធោ** = មានអាពាធច្រើន" ។ លោកសម្ដែងនូវវិបត្តិដោយហេតុនៃសេចក្ដីសុខ និងនូវវិបត្តិនៃគ្រឿងឧបភោគ ដោយពាក្យជាដើមថា " **ន លាភី** = មិនមានលាភ" ។ លោកសម្ដែងការប្រកបហេតុនៃភាពងងឹត មានការងងឹតជាទីទៅខាងមុខ ដោយពាក្យជាដើមថា **"កាយេន ទុច្ចរិតំ** = មានកាយទុច្ចរិត" ជាដើម ។ លោកសម្ដែងការ

ចូលដល់ភាពផងផឹតក្នុងភពខាងមុខ ដោយពាក្យជាដើមថា **“កាយស្ស ភេទា** = ព្រោះកាយបែកធ្លាយ**”** ។ បណ្ឌិតគប្បីជ្រាបធម៌ចំណែកស ដោយន័យផ្ទុយគ្នានឹងពាក្យដែលពោលហើយ ។

ប្រការមួយទៀត ក្នុងអធិការនេះ លោកពោលពាក្យអធិប្បាយទុកថា បុគ្គលប្រកបដោយសេចក្ដីរុងរឿងមានការកើតខាងក្រោយ ព្រោះដល់ព្រម ដោយត្រកូល ៣ យ៉ាង គឺ ក្សត្រមហាសាល ព្រាហ្មណមហាសាល និង គហបតីមហាសាល ឈ្មោះថា **ជោតិ** = អ្នករុងរឿង គឺអ្នកមកភ្លឺ និង ឈ្មោះថា **ជោតិបរាយនោ** = អ្នកភ្លឺទៅខាងមុខ ព្រោះចូលដល់នូវភាព ជាអ្នកភ្លឺ គឺការកើតឡើងក្នុងភព (ឋាន) សួគ៌ ដោយសុចរិតទាំងឡាយ មានកាយសុចរិតជាដើម ។

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **“ខត្តិយមហាសាលកុលេ វា”** ជាដើម បទថា **“ខត្តិយមហាសាលា”** បានដល់ ក្សត្រអ្នកមានទ្រព្យដែល ជាសារៈច្រើន គឺថា ក្សត្រអ្នកដល់ព្រមដោយសារៈនៃសម្បត្តិច្រើន ។ ក៏ ក្សត្រឯណា មានព្រះរាជទ្រព្យយ៉ាងទាបប្រមាណមួយរយកោដិ ដែលជា ដើមទុន មានប្រយោជន៍ និងបានតាំងរណ្ដៅទ្រព្យទុក ៣ ឆ្នាំង ធ្វើឲ្យជា គំនរត្រង់កណ្ដាលផ្ទះ ដើម្បីប្រយោជន៍ដល់ការប្រើប្រាស់, ក្សត្រទាំងនោះ ឈ្មោះថា ***ខត្តិយមហាសាល*** ។ ព្រាហ្មណ៍ឯណា មានទ្រព្យជាដើមទុន

ប្រមាណ ៨០ កោដិ តាំងរណ្ដៅទ្រព្យទុកកន្លះឆ្នាំង សម្រាប់ប្រើប្រាស់ក្នុងផ្ទះ, ព្រាហ្មណ៍នោះ ឈ្មោះថា ***ព្រាហ្មណមហាសាល*** ។ គហបតីឯណា មានទុនទ្រព្យ ៤០ កោដិ តាំងរណ្ដៅទ្រព្យទុកមួយឆ្នាំង ធ្វើឲ្យជាគំនរត្រង់កណ្ដាលផ្ទះ ដើម្បីត្រូវការប្រើប្រាស់ក្នុងផ្ទះ គហបតីនោះ ឈ្មោះថា ***គហបតីមហាសាល,*** អធិប្បាយថា បុគ្គលដែលរុងរឿង គឺអ្នកមកក្លីនោះកើតក្នុងត្រកូលនៃជនទាំងនេះ ។

បទថា **“អឌ្ឍោ”** បានដល់ ភាពជាឥស្សរៈ ឈ្មោះថា មានទ្រព្យច្រើន ព្រោះមានទ្រព្យដែលជាដើមទុនមានប្រយោជន៍ច្រើន ។ ឈ្មោះថា មានភោគៈច្រើន ព្រោះគ្រឿងឧបភោគ មានភាជន៍ប្រាក់ជាដើមច្រើន ។ ឈ្មោះថា មានមាសប្រាក់ច្រើន ព្រោះមានមាស និងប្រាក់ដែលជាដើមទុនប្រមូលទុកច្រើនៗ ឈ្មោះថា មានឧបករណ៍នៃទ្រព្យជាគ្រឿងសប្បាយចិត្តគឺមានហេតុនៃសេចក្ដីត្រេកអរច្រើន ។ ឈ្មោះថា ***មានទ្រព្យ*** និង ***ធញ្ញាហារច្រើន*** ព្រោះមានវត្ថុទាំងឡាយ មានគោ និងទ្រព្យជាដើមផង មានធញ្ញាហារ ៧ ប្រភេទផង ដ៏ច្រើន ។

ពាក្យថា **“អភិរូបោ** = មានរូបស្អាត” ។

ពាក្យថា **“ទស្សនីយោ** = គួរទស្សនា” គឺសមគួរហើយដល់នរណាមួយ ដែលនឹងលះការផ្សារយ៉ាងដទៃ រួចសម្លឹងមើលសូម្បីរហូតថ្ងៃ ។

ពាក្យថា **“បាសាទិកោ”** នាំមកនូវសេចក្ដីជ្រះថ្លានៃចិត្ត ដោយការឃើញនោះឯង ។

ពាក្យថា **“បរមាយ** = ខ្ពស់បំផុត” ។

បទថា **“វណ្ណបោក្ខរតាយ”** បានដល់ វណ្ណៈនៃសរីរៈ, សរីរៈ លោកហៅថា **បោក្ខរំ** អធិប្បាយថា ព្រោះការដល់ព្រមដោយវណ្ណៈនៃសរីរៈនោះ ។

បទថា **“សមន្នាគតោ”** បានដល់ ចូលដល់ហើយ ។ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **“ឱណតោណតា”** ជាដើម ឈ្មោះថា អ្នកថោកទាប ព្រោះវៀរចាកសម្បត្តិក្នុងទិដ្ឋធម្មិកភព ឬក្នុងសម្បរាយិកភព អធិប្បាយថា ជាអ្នកថោកទាប គឺជាអ្នកលាមក ។ ឈ្មោះថា ***អ្នកខ្ពស់*** ព្រោះភាពជាសភាវៈផ្ទុយគ្នានឹងមនុស្សថោកទាបនោះ អធិប្បាយថា អ្នកខ្ពស់ គឺជាអ្នកលើស ។ ពាក្យដ៏សេសក្នុងទីនេះ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងពាក្យថា ***អ្នកងងឹត*** ជាដើម ។ ម្យ៉ាងទៀត បទថា **“ឱណតោណតោ”** សេចក្ដីថា ឥឡូវនេះ គឺជាតិនេះ ជាអ្នកថោកទាប សូម្បីតទៅ គឺជាតិតទៅខាងមុខ ក៏នឹងជាអ្នកថោកទាបដដែល ។ បទថា **“ឱណតុណ្ណតោ”** សេចក្ដីថា ជាតិនេះជាអ្នកថោកទាប, តែជាតិតទៅ នឹងជាអ្នកខ្ពស់ ។ បទថា **“ឧណតោណតោ”** សេចក្ដីថា ជាតិនេះជាអ្នកខ្ពស់, តែជាតិតទៅ នឹងជាអ្នកទាប ។ បទថា **“ឧណ្ណតុណ្ណតោ”** សេចក្ដីថា ជាតិនេះ ជាអ្នកខ្ពស់ សូម្បីជាតិតទៅ ក៏នឹងជាអ្នកខ្ពស់ទៀត ៕

## ពណ៌នាអំពីបុគ្គលប្រៀបដូចដើមឈើ ៤ ពួក

គប្បីជ្រាបដើមឈើស្រាយមានខ្លឹមជាបរិវារសិន៖

ដើមឈើចម្រើនជាទីបំផុតក្នុងព្រៃ ខ្លួនឯងគ្មានខ្លឹម តែបរិវារមានខ្លឹម ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យនេះ ក៏បណ្ដាបុគ្គលទាំងឡាយបណ្ឌិតគប្បីជ្រាបភាវៈនៃបុគ្គលដែលប្រៀបដូចដើមឈើគ្មានខ្លឹម ព្រោះវៀរចាកសារៈ គឺសីល និងគប្បីជ្រាបនូវភាវៈនៃបុគ្គលជាអ្នកប្រៀបដូចដើមឈើមានខ្លឹម ព្រោះប្រកបដោយសារៈ គឺសីល ៕

---

## ពណ៌នាអំពីបុគ្គលកាន់យករូបជាប្រមាណ ហើយជ្រះថ្លាក្នុងរូបជាដើម

បុគ្គលឯណា រមែងធ្វើរូបដែលសមគួរដល់សម្បត្តិឲ្យជាប្រមាណ ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **រូបប្បមាណោ** = អ្នកធ្វើរូបឲ្យជាប្រមាណ ។ បុគ្គលឯណា រមែងញុំាងសេចក្ដីជ្រះថ្លាឲ្យកើតក្នុងរូបដែលគួរដល់សម្បត្តិនោះ ដោយហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **រូបប្ប-សន្នោ** = អ្នកជ្រះថ្លាក្នុងរូប ។

បុគ្គលឯណា រមែងធ្វើសំឡេងដែលជាកិត្តិសព្ទឲ្យជាប្រមាណ ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **ឃោសប្បមាណោ** = អ្នកកាន់យក

សំឡេងជាប្រមាណ ។

វិនិច្ឆ័យក្នុងពាក្យថា **“អារោហំ ១”** ជាដើម ក៏ពាក្យថា **“អារោហំ”** បានដល់ ខ្ពស់ឡើងទៅ ។ ពាក្យថា **“បរិណាហំ”** បានដល់ មានរូបសម្បត្តិដែលសមរម្យដោយជុំវិញ ប្រាសចាកសេចក្ដីស្គម និងធាត់ ។ បទថា **“សណ្ឋានំ”** បានដល់ ភាពជារបស់គង់នៅដដែលនៃអវយវៈធំតូចទាំងឡាយ ក្នុងទីដែលគួរហើយ មានលក្ខណៈវែង ខ្លី និងមូលជាដើម ។ បទថា **“បារិបូរី”** បានដល់ មិនរខេករខាកនៃអវយវៈទាំងឡាយ មានប្រការតាមដែលពោលហើយ ឬភាពជាអ្នកបរិបូណ៌ដោយលក្ខណៈ ។ បទថា **“បរវណ្ណនាយ”** បានដល់ ព្រោះការពណ៌នាគុណដែលអ្នកដទៃថ្លែងចេញហើយក្នុងទីកំបាំង ។ បទថា **“បរថោមនាយ”** បានដល់ ការលើកតម្កើង ដែលអ្នកដទៃពោលទុកដោយអំណាចនៃការលើកសរសើរ មានការនិពន្ធចងគាថាទុកជាដើម ។ បទថា **“បរបសំសនាយ”** បានដល់ ការសរសើរគុណ ដែលអ្នកដទៃពោលចំពោះមុខ ។ បទថា **“បរវណ្ណហារិកាយ”** បានដល់ នាំការសរសើរគុណដែលអ្នកដទៃឲ្យប្រព្រឹត្តទៅ ដោយអំណាចនៃការសរសើរតៗ គ្នា ។ បទថា **“ចីវរលូខំ”** បានដល់ ភាវៈនៃចីវរជារបស់សៅហ្មង ដោយភាវៈមានពណ៌មិនល្អជាដើម ។ បទថា

**"បត្តលូខំ"** បានដល់ ភាវៈនៃភាជនៈជារបស់សៅហ្មង ដោយពណ៌ សណ្ឋាន និងគ្រោតគ្រាត ។ បទថា **"សេនាសនលូខំ"** បានដល់ ភាវៈនៃសេនាសនៈជារបស់សៅហ្មង ព្រោះវៀរចាកសម្បត្តិរបស់អ្នករំរែកជាដើម ។ បទថា **"ទិទិធំ"** បានដល់ មានប្រការផ្សេងៗ ដោយភាពជារបស់អចេលក៍ (តាបសអាក្រាត) ជាដើម ។ បទថា **"ទុក្ករការិកំ"** បានដល់ ការធ្វើសរីរៈខ្លួនឲ្យក្តៅក្រហាយ ។

**អបរោ នយោ** ន័យមួយទៀត ក៏បុគ្គល ៤ ជំពូកនេះ បុគ្គលដែលកាន់យកប្រមាណក្នុងរូបហើយជ្រះថ្លា ឈ្មោះថា **រូបប្បមាណោ** = អ្នកកាន់យករូបជាប្រមាណ ។ បទថា **"រូបប្បសន្នោ** = អ្នកជ្រះថ្លាក្នុងរូប បានដល់ជាការពោលដល់ភាពជារបស់បុគ្គលដែលកាន់យករូបជាប្រមាណនោះឯង ។ បុគ្គលដែលកាន់យកសំឡេងជាប្រមាណហើយជ្រះថ្លា ឈ្មោះថា **ឃោសប្បមាណោ** = អ្នកកាន់យកសំឡេងជាប្រមាណ ។ បុគ្គលដែលកាន់យកប្រមាណក្នុងចីវរដែលសៅហ្មង និងបាត្រដែលសៅហ្មង ហើយជ្រះថ្លា ឈ្មោះថា **លូខប្បមាណោ** = អ្នកកាន់យកសេចក្តីសៅហ្មងជាប្រមាណ ។ បុគ្គលអ្នកកាន់យកធម៌ជាប្រមាណហើយ ក៏ជ្រះថ្លា ឈ្មោះថា **ធម្មប្បមាណោ** = អ្នកកាន់យកធម៌ជាប្រមាណ ។ ពាក្យក្រៅអំពីនេះ ជាការពោលដល់ភាវៈនៃបុគ្គល ៤ ជំពូកទាំងនោះឯង ។

*ក៏សត្វលោកទាំងអស់បែងចែកជា ៣ ចំណែក, ដែលកាន់យករូបជាប្រមាណ ២ ចំណែក, ដែលមិនកាន់យក ១ ចំណែក ។ សត្វលោកទាំងអស់បែងចេញជា ៥ ចំណែក, ដែលកាន់យកសំឡេងជាប្រមាណមាន ៤ ចំណែក, ដែលមិនកាន់យកមាន ១ ចំណែក ។ សត្វលោកទាំងអស់បែងចេញជា ១០ ចំណែក, ដែលកាន់យកសេចក្ដីសៅហ្មងជាប្រមាណ មាន ៩ ចំណែក ដែលមិនកាន់យក មាន ១ ចំណែក ។ សត្វលោកទាំងអស់ បែងចែកជា ១០០.០០០ (មួយសែន) ចំណែក,* ***មានតែមួយចំណែកប៉ុណ្ណោះ ដែលកាន់យកធម៌ជាប្រមាណ****, ចំណែកដ៏សេសមិនកាន់យកធម៌ជាប្រមាណទេ, លោកសន្និវាសនេះ កាន់យកប្រមាណ ៤ យ៉ាងនេះ ដោយប្រការដូច្នេះ ។*

*ក្នុងលោកសន្និវាសមានប្រមាណ ៤ យ៉ាងនេះ អ្នកដែលមិនជ្រះថ្លាក្នុងព្រះពុទ្ធជាម្ចាស់ទាំងឡាយ មានប្រមាណតិច, ដែលជ្រះថ្លាមានច្រើន ។ ព្រោះថា បុគ្គលដែលកាន់យករូបជាប្រមាណ ឈ្មោះថា រូបដែលនាំមកនូវសេចក្ដីជ្រះថ្លាឲ្យក្រៃលែងជាងរូបរបស់ព្រះពុទ្ធជាម្ចាស់ មិនមានឡើយ ។*

*អ្នកដែលកាន់យកសំឡេងជាប្រមាណ ឈ្មោះថា សំឡេងដែលនាំមកនូវសេចក្ដីជ្រះថ្លាឲ្យក្រៃលែង ជាងសំឡេងប្រកាសកិត្តិគុណរបស់ព្រះពុទ្ធជាម្ចាស់ មិនមានឡើយ ។*

អ្នកដែលកាន់យកសេចក្តីសៅហ្មងជាប្រមាណ ឈ្មោះថា សេចក្តីសៅហ្មងដទៃ ដែលនាំមកនូវសេចក្តីជ្រះថ្លា ក្រៃលែងជាងសេចក្តីសៅហ្មងរបស់ព្រះពុទ្ធជាម្ចាស់ អ្នកលះសំពត់ទាំងឡាយដែលគេត្បាញក្នុងដែនកាសីលះភាជន៍មាសដែលមានតម្លៃច្រើន និងលះប្រាសាទ ដែលប្រកបដោយសម្បត្តិទាំងពួង ដ៏សមគួរដល់រដូវកាលទាំង ៣ ហើយ សេព (ប្រើ) សំពត់បង្សុកូល បាត្រដែលសម្រេចដោយសិលា និងសេនាសនៈ មានគល់ឈើជាដើម រមែងមិនមាន ។

អ្នកដែលកាន់យកធម៌ជាប្រមាណ ឈ្មោះថា គុណមានសីលជាដើមដទៃ ដែលនាំមកនូវសេចក្តីជ្រះថ្លាដ៏ក្រៃលែងជាងគុណ មានសីលជាដើមរបស់ព្រះតថាគត អ្នកមានសីលាទិគុណដែលមិនទូទៅក្នុងលោកនេះ រហូតទេវលោក រមែងមិនមាន, ដោយហេតុនេះ ព្រះមានព្រះភាគទ្រង់តាំងនៅហាក់ដូចជាកាន់យកលោកសន្និវាស មានប្រមាណ ៤ នេះ ដោយកណ្តាប់ព្រះហស្ត ៕

## ពណ៌នាអំពីបុគ្គលបដិបត្តិដើម្បីប្រយោជន៍ខ្លួនឯងជាដើម

វិនិច្ឆ័យក្នុងពាក្យថា អ្នកបដិបត្តិដើម្បីប្រយោជន៍ដល់ខ្លួនឯងជាដើម ៖

បទថា **"សីលសម្បន្នោ"** បានដល់ អ្នកដល់ព្រមហើយដោយសីល

គឺអ្នកសម្បូណ៌ដោយសីល ។ ក្នុងបុគ្គលដែលសម្បូណ៌ដោយសមាធិជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ក៏ក្នុងពាក្យថា ***អ្នកដល់ព្រមហើយដោយសីលជាដើម*** នោះ សីលព្រះមានព្រះភាគត្រាស់ទុកក្នុងលោកិយសីល និងលោកុត្តរសីល ។ សមាធិ និងបញ្ញាក៏ដូចគ្នា ។ ***វិមុត្តិ*** បានដល់ វិមុត្តិនៃអរហត្តផល ។ ***វិមុត្តិញ្ញាណទស្សនៈ*** បានដល់ បច្ចវេក្ខណញ្ញាណមាន ១៩ យ៉ាង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **"នោ បរំ"** ជាដើម ក៏បុគ្គលពោលនឹងអ្នកដទៃថា សូម្បីលោកក៏សមគួរដល់ព្រមដោយសីល, តែខ្លួនឯងសមាទានសីលដោយវិធីណា រមែងមិនបបួលដឹកនាំ មិនញ៉ាំងបុគ្គលដទៃ ឲ្យកាន់យកដោយវិធីនោះទេ, ក្នុងគ្រប់ៗ បទ ក៏មានន័យដូចគ្នាដែរ ។ ក៏បណ្ដាបុគ្គលទាំង ៤ ពួកនោះ បណ្ឌិតគប្បីជ្រាបថា ***បុគ្គលពួកទី ១*** ដូចព្រះថេរៈឈ្មោះថា **ពកុលៈ** ។ ***ពួកទី ២*** ដូច **ព្រះឧបនន្ទសក្យបុត្រ**, ***ពួកទី ៣*** ដូច **ព្រះសារីបុត្តត្ថេរ** និង **ព្រះមោគ្គល្លានត្ថេរ** ។ ***ពួកទី ៤*** ដូច **ព្រះទេវទត្ត** ៕

---

## ពណ៌នាអំពីបុគ្គលធ្វើខ្លួនឱ្យក្ដៅក្រហាយជាដើម

បុគ្គលឯណា រមែងទូន្មានខ្លួន គឺរមែងធ្វើខ្លួនឲ្យដល់នូវសេចក្ដីទុក្ខ ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **អត្តន្តបោ** = អ្នកធ្វើខ្លួនឲ្យក្ដៅក្រហាយ ។ ការប្រកបតាមក្នុងការញ៉ាំងខ្លួនឲ្យក្ដៅក្រហាយ ឈ្មោះថា

**អគ្គបរិភោគនានុយោគំ** ។

បទថា **"អចេលកោ"** បានដល់ អ្នកមិនស្លៀកសំពត់ គឺអ្នកអាក្រាតកាយ ។ បទថា **"មុត្តាចារោ** = អ្នកមានអាចារៈដែលលះបង់ចោលហើយ" ។ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **"ឧច្ចារកម្ម"** ជាដើម បានដល់ បុគ្គលដែលវៀរចាកអាចារៈ របស់កុលបុត្រអ្នកតាំងជីវិតនៅដោយការទំពាស៊ី គឺបរិភោគខច្ចារៈ និងបស្សាវៈ ។ បទថា **"ហត្ថាវ-លេខនោ"** សេចក្ដីថា កាលមានខច្ចារៈ (លាមក) ជាប់ដៃ ក៏យកអណ្ដាតលិទ្ធ ។ មួយវិញទៀត លោកសម្ដែងទុកថា បន្ទោបង់ខច្ចារៈហើយ ជាអ្នកមានសេចក្ដីសម្គាល់ថា "មានកំណាត់ឈើក្នុងដៃនោះឯង" ហើយ ក៏បរិភោគដោយដៃ ។ បានឮថា ជនពួកនោះ រមែងបញ្ញត្តកំណាត់ឈើថា ជាសត្វ, ព្រោះហេតុដូច្នោះ កាលគេ (អន្យតិរ្ថិយ) នឹងបំពេញបដិបទារបស់ជនទាំងនោះ ទើបធ្វើយ៉ាងនោះ ។

អ្នកណាដែលបុគ្គលដទៃពោលថា "លោកដ៏ចម្រើន ចូរលោកមកដើម្បីប្រយោជន៍ដល់ការទទួលភិក្ខា ក៏មិនមក ព្រោះហេតុដូច្នេះ អ្នកនោះទើបឈ្មោះថា **ន ឯហិ ភទន្តិកោ** ។ អ្នកណា សូម្បីដែលអ្នកដទៃពោលថា អ្នកដ៏ចម្រើន បើយ៉ាងនោះ ចូរលោកទៅឈរ ក៏មិនឈរ ព្រោះហេតុនោះ អ្នកនោះ ទើបឈ្មោះថា **នតិដ្ឋភទន្តិកោ"** ។ អន្យតិរ្ថិយទាំងឡាយ រមែង

*មិនធ្វើតាមពាក្យរបស់បុគ្គលនោះទាំង ២ យ៉ាង ដោយគិតថា “ពាក្យរបស់អ្នកនោះ នឹងជាកម្មដែលយើងធ្វើហើយ” ។ បទថា* **“អភិហដំ”** *បានដល់ភិក្ខាដែលគេកាន់យកមុន ហើយនាំមកឲ្យ ។ បទថា* **“ឧទ្ទិស កតំ”** *បានដល់ ភិក្ខាដែលគេប្រាប់យ៉ាងនេះថា “ភិក្ខានេះ គេធ្វើចំពោះលោក” ។ បទថា* **“និមន្តនំ”** *បានដល់ មិនត្រេកអរ និងមិនកាន់យក សូម្បីភិក្ខាដែលគេនិមន្តយ៉ាងនេះថា “ចូរលោកទៅកាន់ត្រកូល ឬថ្នល់ ឬក៏ស្រុកឈ្មោះនោះ” ។ បទថា* **“ន កុម្ភីមុខា”** *បានដល់ មិនទទួលភិក្ខាដែលបុគ្គលដួសអំពីឆ្នាំងហើយឲ្យ ។ បទថា* **“ន កឡោបិមុខា”** *សេចក្ដីថា ឆ្នាំង ឬកញ្ជ្រែង ឈ្មោះថា* **កឡោបិ** *= ភាជនៈ, គេរមែងមិនទទួលអាហារអំពីភាជនៈនោះ ដោយគិតថា “ព្រោះហេតុអ្វី ទើបយកវែកខ្ទប់ឆ្នាំងបាយ និងភាជនៈ” ។ បទថា* **“ន ឯឡកមន្តរំ”** *បានដល់ មិនទទួលភត្តដែលគេធ្វើធរណីទ្វារខណ្ឌហើយឲ្យ;* ***សួរថា*** *ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះគេគិតថា “បុគ្គលនេះគេអាស្រ័យយើងហើយ នឹងមានការធ្វើនូវចន្លោះខណ្ឌ” ។ សូម្បីក្នុងកំណាត់ឈើ និងអង្រែ ក៏មានន័យដូចគ្នានេះដែរ ។ បទថា* **“ទ្វិន្នំ”** *បានដល់ កាលបើមានមនុស្សពីរនាក់ កំពុងបរិភោគអាហារ មនុស្សម្នាក់ក្រោកឡើងហើយឲ្យភិក្ខា មិនព្រមទទួល ។* ***សួរថា*** *ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះ*

គេគិតថា "អន្តរាយសម្រាប់ដុំបាយនឹងមាន" ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **"ន គព្ភិនិយា"** ជាដើម, ក៏ទារកនៅក្នុងផ្ទៃរបស់ស្ត្រីមានគភ៌រមែងលំបាក ។ អន្តរាយនៃទឹកដោះរបស់ទារកអ្នកផឹក រមែងមាន ។ មិនព្រមទទួលភិក្ខាដោយគិតថា "អន្តរាយនៃសេចក្តីត្រេកអររមែងមានដល់ស្ត្រីអ្នកនៅកាន់ចន្លោះនៃបុរស" ។ បទថា **"ន សង្កិត្តីសុ"** បានដល់ ភត្តដែលត្រៀមគ្នាទុក ។ បានឮថា ក្នុងសម័យដែលមានភិក្ខារកបានដោយលំបាក ពួកសាវករបស់និគ្រន្ថទាំងឡាយ នាំគ្នាប្រមូលអង្ករជាដើម អំពីទីនោះៗ ដើម្បីប្រយោជន៍ដល់និគ្រន្ថទាំងឡាយ ហើយទើបចម្អិនបាយ; និគ្រន្ថអ្នកខក្រិដ្ឋមិនព្រមទទួលភិក្ខាអំពីទីនោះ ។ បទថា **"ន យត្ថ សា"** បានដល់ គេចិញ្ចឹមសុនខទុកក្នុងទីណាដោយតាំងចិត្តថា "យើងនឹងបានការចិញ្ចឹមជីវិត" មិនព្រមទទួលភិក្ខាដែលគេមិនឲ្យដល់សុនខ ហើយនាំមកក្នុងទីនោះ ។ ***សួរថា*** ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះគេគិតថា "អន្តរាយនៃដុំបាយរបស់សុនខនោះនឹងមាន" ។

បទថា **"សណ្ឌសណ្ឌចារិនី"** បានដល់ ការត្រាច់ទៅប្រជុំគ្នាជាពួកៗ, ក៏បើថា ពួកមនុស្សទាំងឡាយឃើញនិគ្រន្ថហើយ គេក៏ចូលទៅផ្ទះដើម្បីត្រូវ

ការភត្ត ដោយតាំងចិត្តថា "យើងនឹងថ្វាយភិក្ខាដល់និគ្រន្ថនេះ" , ក៏កាល បើមនុស្សទាំងនោះចូលទៅ ពួករុយដែលទំនៅត្រង់មាត់កញ្ចើជាដើម នាំគ្នា ហើរឡើងទៅ រមែងត្រាច់ទៅជាពួកៗ រមែងមិនទទួលភិក្ខា ដែលគេនាំមក អំពីកញ្ចើនោះ ។ **សួរថា** ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះគេគិតថា "ព្រោះអាស្រ័យយើង អន្តរាយនៃការគោចររបស់រុយទាំងឡាយ ទើប កើតមាន" ។ បទថា **"ថុសោទកំ"** បានដល់ ទឹកជ្រក់ដែលធ្វើដោយ គ្រឿងបម្រុងដោយស្រូវដំណើបគ្រប់ប្រភេទ, ក៏ក្នុងទីនេះ ទឹកសុរាប៉ុណ្ណោះ ចាត់ថាមានទោស, តែបុគ្គលនេះ មានសេចក្តីសម្គាល់សូម្បីក្នុងទឹកជ្រក់នោះ ថា មានទោស ។ បទថា **"ឯកាគារិកោ"** បានដល់ បានភិក្ខាក្នុងផ្ទះមួយខ្នង ប៉ុណ្ណោះ ហើយក៏ត្រឡប់ទៅ ។ បទថា **"ឯកាលោបិកោ"** បានដល់ គេ រមែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយបាយត្រឹមតែមួយពំនូតប៉ុណ្ណោះ ។ សូម្បីក្នុងពាក្យថា "ព្រៃ និងស្រុក" ជាដើម ក៏មានន័យដូចគ្នានេះដែរ ។

ពីរបទថា **"ឯកិស្សាបិ ទត្តិយា** = ថាសមួយ និងថាសតូចៗ មួយ" ឈ្មោះថា **ទត្តិ;** ក៏ជនទាំងឡាយ បញ្ចុះភិក្ខាដ៏លើសតាំងទុកក្នុងទីណា ។ បទថា **"ឯកាហិកំ** = ភត្តដែលគេថ្វាយមួយថ្ងៃ" ។ បទថា **"អឌ្ឍមាសិកំ"** បានដល់ ភត្តដែលគេថ្វាយមានកំណត់កន្លះខែ ។ បទថា **"បរិយាយភត្ត-**

**ភោជនំ"** បានដល់ ភត្តដែលគេបរិភោគតាមវារៈ, ការបរិភោគភត្តដែលគេនាំមកដោយវារៈនៃថ្ងៃយ៉ាងនេះ គឺតាមវារៈមួយថ្ងៃ ពីរថ្ងៃ ប្រាំពីរថ្ងៃ និងកន្លះខែ ។ បទថា **"សាកភក្ខោ"** បានដល់ មានបន្លែស្រស់ជាអាហារ ។ បទថា **"សាមាកភក្ខោ"** បានដល់ មានគ្រាប់ស្រូវមីយេជាអាហារ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **"និវារា** = ការហាម" ជាដើម គប្បីជ្រាបធញ្ញជាតិដែលដុះឡើងឯងក្នុងព្រៃមុន ។ បទថា **"ទទ្ទុលំ"** បានដល់ សំណល់ស្បែកដែលជាងស្បែកពន្លះចោលចេញ ។ ជ័រក្តី សារាយក្តី សូម្បីជ័រនៃដើមឈើ មានដើមកណិកាជាដើម ហៅថា **ហដំ** ។ បទថា **"កណំ** = កន្ទក់" ។ បទថា **"អាចាមោ"** បានដល់ បាយក្តាំងដែលជាប់នៅក្នុងឆ្នាំង ។ គេកាន់យកបាយទាំងនោះ ក្នុងទីដែលមនុស្សចោលហើយ ទើបទំពាស៊ី ។ អាចារ្យពួកខ្លះពោលថា គេបរិភោគទឹកបាយដូច្នេះខ្លះ ។ បទថា **"បិញ្ញាកា"** ជាដើម មានសេចក្តីប្រាកដជាក់ច្បាស់ហើយ ។ បទថា **"បវត្តផលភោជី** = អ្នកបរិភោគផ្លែឈើដែលជ្រុះខ្លួនឯង" ។

បទថា **"មសាកានិ"** បានដល់ សំពត់ដែលគេត្បាញប៉ាក់លាយគ្នា ។ បទថា **"ឆវទុស្សានិ"** បានដល់ សំពត់ដែលគេចោលហើយអំពីសាកសព ។ម្យ៉ាងទៀត សំពត់ដែលគេចាក់ក្រងធ្វើដោយដើមរៃទឹកជាដើម ។ បទថា

**“បំសុកូលានិ”** *បានដល់ សំណល់សំពត់ដែលគេចោលលើផែនដី ។ បទថា* **“តិរីដកានិ”** *បានដល់ សំពត់ដែលគេត្បាញដោយសម្បកឈើ ។ បទថា* **“អជិនំ”** *បានដល់ ស្បែកខ្លា (គឺសំពត់ដែលគេធ្វើដោយស្បែកខ្លា) ។ បទថា* **“អជិនក្ខិបំ”** *បានដល់ ស្បែកខ្លានោះឯង ដែលគេពុះត្រង់កណ្តាល ។ អាចារ្យពួកខ្លះពោលថា “សំពត់ស្បៀកដែលគេធ្វើដោយស្បែកខ្លា ព្រមទាំងក្រចក” ដូច្នេះខ្លះ ។ បទថា* **“កុសចីរំ”** *បានដល់ សំពត់ដែលគេក្រងធ្វើដោយស្បូវ, សូម្បីក្នុងសំពត់ដែលគេក្រងដោយសម្បកឈើ ផ្ទាំងឈើជាដើម ក៏មានន័យដូចគ្នានេះដែរ ។ បទថា* **“កេសកម្ពលំ”** *បានដល់ សំពត់កម្ពលដែលគេធ្វើដោយសក់មនុស្ស, ពាក្យដែលលោកពោលសំដៅយកទុកថា “ម្នាលភិក្ខុទាំងឡាយ សំពត់ទាំងឡាយនោះ ពួកណាដែលគេក្រងហើយ, សំពត់កម្ពលដែលធ្វើដោយសក់មនុស្ស តថាគតពោលថា ជារបស់គួររង្កៀសក្រៃលែងជាងសំពត់ទាំងនោះ” ។ បទថា* **“វាលកម្ពលំ”** *បានដល់ សំពត់កម្ពលដែលធ្វើដោយកន្ទុយសេះជាដើម ។ បទថា* **“ឧលូកបក្ខកំ”** *បានដល់ សំពត់ដែលគេក្រងធ្វើដោយស្លាបមៀម ។*

*បទថា* **“ឧព្ភដ្ឋកោ** *= អ្នកឈរនៅខាងលើ* **”** *។ បទថា* **“ឧក្កុដិកប្ប-ធានមនុយុត្តោ”** *សេចក្តីថា អ្នកប្រកបសេចក្តីព្យាយាមក្នុងការអង្គុយ*

ប្រយោជន៍, ពេលទៅក៏ជាអ្នកអន្ទុយប្រយោជន៍មែនទែន ហើយលោតទៅៗ ។ បទថា **"កណ្ដកាបស្សយិកោ"** សេចក្ដីថា ដោតចុះនូវស្នា ឬបន្លាស្រួចលើផែនដី ហើយក្រាលដោយស្បែកលើស្នា ឬបន្លាស្រួចនោះ ទើបធ្វើការឈរនិងការដើរជាដើម ។ បទថា **"សេយ្យំ"** បានដល់ សូម្បីពេលដេកក៏សម្រេចការដេកលើផ្ទាំងស្បែកដែលក្រាលនោះឯង ។ អ្នកនោះ ប្រកបការង្ងូតទឹកជាគ្រាទី ៣ ក្នុងវេលាត្រជាក់ (ង្ងូត ១ ថ្ងៃ ៣ ដង) ព្រោះហេតុនោះ អ្នកនោះ ឈ្មោះថា **សាយតតិយៈ** អ្នកប្រកបការង្ងូតទឹកជាគ្រាទី ៣ ក្នុងវេលាត្រជាក់ ។ អ្នកប្រកបសេចក្ដីព្យាយាមក្នុងការចុះង្ងូតទឹក ដោយតាំងចិត្តថា "យើងនឹងបណ្ដែតបាបមួយថ្ងៃ ៣ ដង គឺវេលាព្រឹក ១ ដង វេលាថ្ងៃត្រង់ ១ ដង និងវេលាល្ងាច ១ ដង" ។

បុគ្គលណា រមែងញុំាងបុគ្គលដទៃឲ្យក្ដៅក្រហាយ ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា **បរន្តបោ** = អ្នកញុំាងបុគ្គលដទៃឲ្យក្ដៅក្រហាយ, ការប្រកបសេចក្ដីព្យាយាម ដើម្បីញុំាងបុគ្គលដទៃឲ្យក្ដៅក្រហាយ ឈ្មោះថា **បរបរិតាបនានុយោគ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **"ឱរព្ភិកា** = អ្នកសម្លាប់ពពែ" ជាដើម ពពែ ឬកែះ លោកហៅថា **ឧរព្ភា,** បុគ្គលឯណារមែងសម្លាប់ពពែ ឬកែះ ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា **ឱរព្ភិកោ** = អ្នក

សម្លាប់ពពែ ឬកែះ ។ សូម្បីក្នុងពាក្យថា អ្នកសម្លាប់ដំរីជាដើម ក៏មានន័យដូចគ្នានេះដែរ ។ បទថា **“លុទ្ទោ = នាយព្រាន”** បានដល់ អ្នកទារុណ អ្នកកក្ខឡៈ (ឃោរឃៅ) ។ បទថា **“មច្ឆាឃាដកោ = អ្នកប្រមង់, អ្នកចាប់ត្រី”** ។ បទថា **“ពន្ធនាគារិកោ = អ្នករក្សាគុក”** ។ បទថា **“កុរូរកម្មន្តា = អ្នកមានការងាររដ៏គ្រោតគ្រាត”** ។ បទថា **“មុទ្ធាភិសិត្តោ”** បានដល់ អ្នកអភិសេកលើសីសៈដោយការអភិសេកជាក្សត្រិយ៍ ។ ពីរបទថា **“បុរត្ថិមេន នគរស្ស”** បានដល់ តាមទិសខាងកើតនៃព្រះនគរ ។ បទថា **“សណ្ឋាគារំ”** បានដល់ រោងបូជាយញ្ញ ។

ពីរបទថា **“ខុរាជិនំ និវាសេត្វា”** បានដល់ ស្លៀកដណ្តប់ស្បែកខ្លាព្រមទាំងក្រចក ។ បទថា **“សប្បិតេលេន”** បានដល់ ទឹកដោះថ្លា និងប្រេង, ក៏វៀរទឹកដោះថ្លាចេញហើយ ជ័រស្អិតយ៉ាងណាមួយដ៏សេស លោកហៅថា **តេលំ** = ប្រេង ។ បទថា **“កណ្ឌុវមានោ”** បានដល់ ព្រោះខ្លួនកាត់ក្រចកចេញ ទើបយកជ័រស្អិតអេះខ្នងក្នុងវេលាដែលគួរអេះ ។ បទថា **“អនន្តរហិតាយ”** បានដល់ គេមិនបានក្រាលគ្រឿងកម្រាលទុក ។ បទថា **“សរូបវច្ឆាយ”** បានដល់ កូនគោដែលដូចមេគោ, អធិប្បាយថា បានដល់ កូនគោដែលមានរូបយ៉ាងនេះ គឺបើមេគោស កូនគោក៏សដែរ, បើមេគោ

*លឿន ឬក្រហម សូម្បីកូនគោក៏មានសភាពដូច្នោះដែរ ។ បទថា* **“សោឯខមាហ”** *បានដល់ ព្រះរាជានោះ ត្រាស់យ៉ាងនេះ ។ បទថា* **“ខច្ចរា”** *បានដល់ កូនគោស្ទាវដែលមានកម្លាំង ឈានកន្លងភាវៈជាកូនគោតូច ។ សូម្បីក្នុងកូនគោញី ក៏មានន័យដូចគ្នានេះដែរ ។ បទថា* **“បរិហីសត្ថាយ”** *បានដល់ ដើម្បីប្រយោជន៍ដល់ការរុំព័ទ្ធរបង និងដើម្បីប្រយោជន៍ដល់ការក្រាលក្នុងទីយញ្ញភូមិ ។ ពីរបទថា* **“ឆិដ្ឋេខ ធម្មេ”** *បានដល់ ក្នុងអត្តភាពនេះឯង ។*

*តណ្ហា លោកហៅថា* **ឆាតំ** *= សេចក្ដីស្រេកឃ្លាន សេចក្ដីលំបាកក្នុងពាក្យថា* **“និច្ឆាតោ”** *នេះ តណ្ហា គឺសេចក្ដីស្រេកឃ្លាននោះ របស់បុគ្គលណាមិនមាន, ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា* **និច្ឆាតោ** *អ្នកមិនមានតណ្ហា គឺសេចក្ដីស្រេកឃ្លាន ។ ឈ្មោះថា អ្នករំលត់ស្និទ្ធហើយ ព្រោះកិលេសទាំងអស់ រលត់អស់ទៅហើយ ។ អ្នកណាជាអ្នកត្រជាក់ស្រេងកើតឡើង ព្រោះភាពជាអ្នកមិនមានកិលេស ជាគ្រឿងឲ្យក្ដៅក្រហាយខាងក្នុង ព្រោះហេតុនោះ អ្នកនោះ ទើបឈ្មោះថា* **សីតិភូតោ** *គឺអ្នកត្រជាក់ហើយ ។ អ្នកណាសេពសោយនូវសេចក្ដីសុខ ដែលកើតអំពី* ***ឈាន មគ្គផល*** និង ***ព្រះនិព្វាន*** *ព្រោះហេតុនោះ អ្នកនោះ ទើបឈ្មោះថា* **សុខ-បដិសំវេទី** *គឺអ្នកសេពសោយនូវសេចក្ដីសុខ ។*

ពីរបទថា **"ព្រហ្មភូតេន អត្តនា** = មានខ្លួនប្រសើរបំផុត ។ ក៏ដើម្បីនឹងសម្ដែងបុគ្គលដែលប្រសើរបំផុតនេះ ចាប់ផ្ដើមតាំងអំពីកាលឧប្បត្តិឡើងនៃព្រះពុទ្ធជាម្ចាស់ ទើបព្រះអង្គត្រាស់ពាក្យថា **"ឥធ តថាគតោ"** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **"តថាគតោ"** បណ្ឌិតគប្បីធ្វើការវិនិច្ឆ័យថា ព្រះមានព្រះភាគដែលទ្រង់ព្រះនាមថា **តថាគត** ដោយហេតុ ៨ ប្រការ គឺ

**១.** ***តថា អាគតោតិ*** **តថាគតោ** ព្រះមានព្រះភាគស្ដេចយាងមកហើយយ៉ាងនោះ គឺស្ដេចយាងមកដូចព្រះពុទ្ធ ព្រោះហេតុនោះ ទើបព្រះអង្គទ្រង់ព្រះនាមថា **តថាគត** ។

**២.** ***តថា គតោតិ*** **តថាគតោ** ព្រះមានព្រះភាគស្ដេចយាងទៅយ៉ាងនោះ ព្រោះហេតុនោះ ទើបព្រះអង្គទ្រង់ព្រះនាមថា **តថាគត** ។

**៣.** ***តថលក្ខណំ អាគតោតិ*** **តថាគតោ** ព្រះមានព្រះភាគយាងមកកាន់លក្ខណៈយ៉ាងនោះ ទើបព្រះអង្គទ្រង់ព្រះនាមថា **តថាគត** ។

**៤.** ***តថធម្មេ យាថាវតោ អភិសម្ពុទ្ធោតិ*** **តថាគតោ** ព្រះមានព្រះភាគត្រាស់ដឹងសច្ចធម៌ទាំងឡាយតាមពិត ព្រោះហេតុនោះ ទើបព្រះអង្គទ្រង់ព្រះនាមថា **តថាគត** ។

**៥.** ***តថទស្សិតាយ*** **តថាគតោ** ព្រះមានព្រះភាគទ្រង់ព្រះនាមថា

**តថាគត** ព្រោះមានប្រក្រតីឃើញយ៉ាងនោះ ។

**៦. *តថវាទិតាយ* តថាគតោ** ព្រះមានព្រះភាគព្រះនាមថា **តថាគត** ព្រោះមានប្រក្រតីត្រាស់យ៉ាងនោះ ។

**៧. *តថការិតាយ* តថាគតោ** ព្រះមានព្រះភាគព្រះនាមថា **តថាគត** ព្រោះមានប្រក្រតីធ្វើយ៉ាងនោះ ។

**៨. *អភិភវនដ្ឋេន* តថាគតោ** ព្រះមានព្រះភាគព្រះនាមថា **តថាគត** ព្រោះអត្ថថា ទ្រង់គ្របអំណាច ។

ពាក្យថា **"អរហំ សម្មាសម្ពុទ្ធោ"** ជាដើម ខ្ញុំឲ្យពិស្តារហើយក្នុងគម្ពីរវិសុទ្ធិមគ្គឯណោះ ។ ពីរបទថា **"តំ ធម្មំ"** បានដល់ រមែងស្តាប់ធម៌នោះដែលដល់ព្រមដោយពាក្យ មានប្រការតាមដែលពោលហើយ ។ បទថា **"គហបតិ"** សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងធម៌ជាមួយគហបតីមុន; ព្រោះហេតុអ្វី ? ព្រោះគេកម្ចាត់មានះបានហើយ និងព្រោះជាអ្នកមានកុសលដ៏ក្រាស់ ។ មែនពិត ជនចំនួនច្រើនដែលបួសមកពីខត្តិយត្រកូលអាស្រ័យពូជពង្សជាតិហើយប្រកាន់ខ្លួន, ដែលបួសមកអំពីត្រកូល ព្រាហ្មណ៍អាស្រ័យមន្តហើយ ក៏ប្រកាន់ខ្លួន, ពួកដែលមានត្រកូលទាបបួសហើយ ក៏មិនអាចតាំងនៅបាន ព្រោះភាវៈនៃខ្លួនមានជាតិត្រកូលទាប ។ ក៏ទារករបស់គហបតីទាំងឡាយ ធ្វើការងាររមានញើសហូរចេញអំពីរន្ធក្លៀកទាំង

សង់ខាង មានខ្នងទទឹកដោយទឹកប្រៃ (ញើស) ធ្វើការភ្ជួរដី គេមិនមានមានះ មិនមានសេចក្ដីក្រអែងក្រអោង ព្រោះមិនមានមានះក្រអឺតក្រទមដូច្នោះ, កូនគហបតីទាំងនោះ បួសហើយទើបមិនធ្វើមានះ មិនធ្វើការក្រអឺតក្រទម គេនឹងរៀនពុទ្ធវចនៈតាមកម្លាំង, ធ្វើការផ្សារនៅដោយវិបស្សនា រមែងអាចដើម្បីតាំងនៅក្នុងព្រះអរហត្តបាន ។ ក៏ឈ្មោះថា ជនអ្នកចេញចាកត្រកូលដែលក្រៅអំពីនេះ មកបួសមានមិនច្រើន, គហបតីប៉ុណ្ណោះ មានច្រើន ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគទ្រង់សម្ដែងធម៌ជាមួយនឹងគហបតីមុន ព្រោះគេជាអ្នកកម្ចាត់មានះ គឺការប្រកាន់ខ្លួនបានហើយ និងព្រោះគេ **មានកុសលដែលសន្សំមកច្រើនផង** ។

ពាក្យថា **"អញ្ញតរស្មឹ វា"** បានដល់ អ្នកកើតក្នុងត្រកូលណាមួយនៃត្រកូលទាំងឡាយ ដែលក្រៅអំពីនេះ ។ បទថា **"តថាគតេ សទ្ធំ បដិលភតិ"** សេចក្ដីថា អ្នកស្ដាប់ធម៌ដ៏បរិសុទ្ធហើយ បានចំពោះនូវសទ្ធាក្នុងព្រះតថាគត ជាធម្មសាមី គឺម្ចាស់របស់ធម៌ថា "ព្រះមានព្រះភាគអង្គនោះទ្រង់ជាព្រះសម្មាសម្ពុទ្ធហ្ន៎ !" ។ បទថា **"ឥតិ បដិសញ្ចិក្ខតិ"** បានដល់ រមែងពិចារណាយ៉ាងនេះ ។ ពីរបទថា **"សម្ពាធោ ឃរាវាសោ** = ការនៅគ្រប់គ្រងផ្ទះ ជាការចង្អៀតចង្អល់" សេចក្ដីថា ក៏បើស្វាមី និងភរិយាទាំងពីរនាក់ នៅគ្រប់គ្រងផ្ទះមានប្រមាណ ៦០ ហត្ថ ឬទាំងរយយោជន៍ សូម្បី

យ៉ាងនេះ, ឃរាវាស គឺការនៅគ្រប់គ្រងផ្ទះរបស់ស្វាមី និងភរិយានោះ ក៏ឈ្មោះថា ***ចង្អៀតចង្អល់មែនពិត*** ព្រោះអត្ថថា មានការប្រព្រឹត្តទៅជាមួយនឹងកិលេសដែលជាគ្រឿងទាក់ទាញ និងកិលេសជាគ្រឿងកង្វល់ចិត្ត ។ ពាក្យថា **"រជបថោ"** លោកពោលទុកក្នុង ***មហាអដ្ឋកថា*** ថា ជាឋាន គឺជាទីតាំងឡើងនៃធូលីមានរាគៈជាដើម, តែនឹងពោលថា "ជាផ្លូវមកនៃធូលី" ដូច្នេះខ្លះ ក៏គួរ ។

បព្វជ្ជា ឈ្មោះថា ***មានឱកាសដ៏ល្អ*** ព្រោះអត្ថថា មិនជាប់ ។ មែនពិត បុគ្គលដែលបួសហើយ សូម្បីនឹងនៅក្នុងប្រាសាទកែវ គឺផ្ទះកំពូលក្តី នៅក្នុងទីទាំងឡាយ មានវិមានជាដើម ដែលបិទបាំងល្អហើយ គឺមានទ្វារនិងបង្អួចដែលបិទស្និទ្ធល្អហើយក្តី ក៏មិនជាប់ជំពាក់វាក់វិនដែរ ព្រោះហេតុនោះ ទើបលោកពោលថា **"អព្ភោកាសោ បព្វជ្ជា** = បព្វជ្ជាមានឱកាសដ៏ល្អក្រៃលែង" ។

ម្យ៉ាងទៀត ***ឃរាវាស*** ឈ្មោះថា ចង្អៀតចង្អល់ ព្រោះមិនមានឱកាសក្នុងការកសាងកុសលតាមសប្បាយ ។ ការនៅគ្រប់គ្រងផ្ទះ ឈ្មោះថា ជាផ្លូវមកនៃធូលី ព្រោះជាទីសន្និបាត គឺការប្រជុំនៃធូលី គឺកិលេសទាំងឡាយ, ដូចស្ថានទីគំនរសំរាម ដែលបុគ្គលមិនបានបិទបាំងទុក បព្វជ្ជា ទើបឈ្មោះថា មានឱកាសដ៏ល្អក្រៃលែង ព្រោះមានឱកាសក្នុងការកសាងកុសលបាន តាម

សប្បាយ ។

ក្នុងពាក្យថា **“នយិទំ សុករំ ។ បេ ។ បព្វជេយ្យំ”** នេះ មានពាក្យពោលទុកដោយសង្ខេបដូចតទៅនេះ ៖ ព្រហ្មចរិយៈ គឺត្រៃសិក្ខានេះ ឈ្មោះថា បរិបូណ៌ហើយដោយសព្វគ្រប់ ព្រោះមិនធ្វើឲ្យខាតដាច់រហូតមួយថ្ងៃ ហើយអាចញុំាងចរិមកចិត្ត គឺចិត្តដួងទីបំផុតខាងចុងឲ្យដល់បាន ។ ព្រហ្មចរិយៈនេះ ឈ្មោះថា បរិសុទ្ធដោយសព្វគ្រប់ ព្រោះធ្វើមិនឲ្យសៅហ្មងដោយកិលេសមន្ទិលរហូតថ្ងៃមួយ ហើយក៏អាចញុំាងចរិមកចិត្តឲ្យដល់បាន ។ បទថា **“សង្ខលិខិតំ”** បានដល់ គប្បីប្រព្រឹត្តព្រហ្មចរិយៈឲ្យដូចជាស័ង្ខ ដែលគេខាត់ហើយ គឺឲ្យមានចំណែកប្រៀបដោយស័ង្ខដែលខាត់ល្អហើយ, ការប្រព្រឹត្តព្រហ្មចរិយៈនេះ បុគ្គលដែលនៅគ្រប់គ្រងផ្ទះមិនធ្វើបានងាយទេ, ការដែលបុគ្គលដែលនៅត្រង់កណ្ដាលផ្ទះ មិនអាចប្រព្រឹត្តព្រហ្មចរិយៈ ឲ្យបរិបូណ៌ ដោយសព្វគ្រប់បាន, បើដូច្នោះ មានតែយើងគប្បីកោរសក់កោរពុកមាត់ ពុកចង្កា ស្លៀកដណ្ដប់សំពត់ ឈ្មោះថា កាសាវៈ ព្រោះជាសំពត់ពណ៌លឿង ដែលជ្រលក់ដោយទឹកអម្ចត់ ដ៏សមគួរដល់បព្វជិតអ្នកប្រព្រឹត្តព្រហ្មចរិយៈហើយ ចេញចាកផ្ទះបួសជាបព្វជិតមិនមានផ្ទះ ។

ក៏ក្នុងអធិការនេះ កម្មមានកសិកម្ម និងពាណិជ្ជកម្មជាដើម ដែលជាប្រយោជន៍ដល់ការគ្រប់គ្រងផ្ទះ លោកហៅថា **“អគារិយំ** = អ្នកគ្រប់គ្រង

ផ្ទះ" ក៏កសិកម្មជាដើមនោះ មិនមានក្នុងបព្វជ្ជា ព្រោះហេតុដូច្នោះ បព្វជ្ជា បណ្ឌិតគប្បីជ្រាបថា **"អនាគារិយំ** = អ្នកមិនគ្រប់គ្រងផ្ទះ" ។ ការបួសនោះ ទើបជាអនាគារិយៈ ។ បទថា **"បព្វជេយ្យុំ"** បានដល់ គប្បីបដិបត្តិ ។ បទថា **"អប្បំ វា"** សេចក្តីថា គំនរភោគៈតិចជាងមួយពាន់ ឈ្មោះថា មានតិច, តាំងអំពីមួយពាន់ឡើងទៅ ឈ្មោះថា មានច្រើន ។ ញាតិនោះឯង ឈ្មោះថា ញាតិសាលោហិត ព្រោះអត្ថថា ជាប់ទាក់ទងគ្នា ញាតិនោះតិចជាង ២០ ឈ្មោះថា មានតិច, តាំងអំពី ២០ ឡើងទៅ ឈ្មោះថា មានច្រើន ។ ពីរបទថា **"ភិក្ខូនំ សិក្ខាសាជីវសមាបន្នោ"** សេចក្តីថា សិក្ខា ពោលគឺអធិសីលសិក្ខាណារបស់ភិក្ខុទាំងឡាយ រមែងមាន, ភិក្ខុអ្នកដល់ព្រមដោយសិក្ខានោះផង, ភិក្ខុទាំងនោះ រមែងរស់នៅរួមគ្នា គឺជាអ្នកនៅរួមរស់ជាមួយគ្នា ជាអ្នកមានការប្រព្រឹត្តស្មើគ្នា ភិក្ខុជាអ្នកដល់ព្រមហើយនូវសិក្ខាសាជីវៈ ពោលគឺសិក្ខាបទដែលព្រះមានព្រះភាគទ្រង់បញ្ញត្តទុកហើយនោះផង, ក្នុងសិក្ខាសាជីវៈណា ដោយភាវៈ គឺការសិក្សាក្នុងសិក្ខាសាជីវៈនោះ ព្រោះហេតុនោះ ទើបលោកឈ្មោះថា **ភិក្ខូនំ សិក្ខាសាជីវសមាបន្នោ** = អ្នកសម្បូណ៌ដោយសិក្ខាសាជីវៈរបស់ភិក្ខុទាំងឡាយ, អធិប្បាយថា ភិក្ខុជាអ្នកញុំាងសិក្ខាឲ្យបរិបូណ៌ផង មិនឈានកន្លងសាជីវៈផង ហើយចូលដល់នូវសិក្ខាសាជីវៈទាំង ២ យ៉ាងនោះ ៕

## ពណ៌នាអំពីបុគ្គលធ្វើខ្លួនឱ្យលំបាកលំបិនជាដើម

កថា គឺពាក្យ មានបាណាតិបាតជាដើម ក្នុងពាក្យទាំងឡាយ មានពាក្យថា **"បាណាតិបាតំ បហាយ"** ជាដើម ខ្ញុំឲ្យពិស្តារទុកក្នុងពេលមុននុ៎ះឯង ។

បទថា **"បហាយ"** បានដល់ លះភាពជាអ្នកទ្រុស្តសីលដែលបណ្ឌិតរាប់ព្រមហើយថា ចេតនាជាគ្រឿងញ៉ាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លងទៅនេះ ។

ពីរបទថា **"បដិវិរតោ ហោតិ"** សេចក្ដីថា ជាអ្នកវៀរហើយ គឺវៀរដាច់អំពីភាពជាអ្នកទ្រុស្តសីលនោះ ចាប់ផ្ដើមអំពីកាលជាទីលះហើយ ។

ពីរបទថា **"និហិតទណ្ឌោ និហិតសត្ថោ"** អធិប្បាយថា ឈ្មោះថាអ្នកមានកំណាត់ឈើ និងមានសស្ត្រាដែលដាក់ហើយ ព្រោះការមិនកាន់កំណាត់ឈើ ឬសស្ត្រា ដើម្បីត្រូវការបៀតបៀនសត្វដទៃ ឲ្យប្រព្រឹត្តទៅ ។ ក៏ក្នុងអធិការនេះ លើកវៀរទណ្ឌៈ គឺកំណាត់ឈើចេញហើយ សូម្បីឧបករណ៍ដ៏សេសទាំងអស់ បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា **សត្ថំ** គឺសស្ត្រា ព្រោះជាគ្រឿងបៀតបៀនសត្វទាំងឡាយ ។ ក៏ភិក្ខុកាន់យកវត្ថុឯណា គឺនឹងជាឈើច្រត់មនុស្សចាស់ ឬកាំបិតសម្រាប់សម្រួចឈើស្ទន់ ឬក៏កាំបិតតូច ធ្វើដំណើរទៅ វត្ថុនោះ មិនឈ្មោះថា **សស្ត្រា** ព្រោះមិនប្រព្រឹត្តទៅដើម្បីត្រូវការបៀតបៀនសត្វដទៃ ព្រោះហេតុដូច្នោះ ភិក្ខុទាំងឡាយនោះរមែង

ដល់នូវការរាប់ថា ជាអ្នកមានកំណាត់ឈើ និងសស្ត្រាដែលដាក់ចុះហើយមែនពិត ។

បទថា **"លជ្ជី"** បានដល់ អ្នកប្រកបដោយសេចក្ដីខ្មាស មានការរង្កៀសបាបជាលក្ខណៈ ។ បទថា **"ទយាបន្នោ"** បានដល់ អ្នកដល់នូវសេចក្ដីអាណិត គឺអ្នកមានចិត្តដែលប្រកបដោយមេត្តា ។ បទថា **"សព្វបាណភូតហិតានុកម្បី"** បានដល់ អ្នកអនុគ្រោះសត្វទាំងពួងដោយប្រយោជន៍ អធិប្បាយថា ឈ្មោះថា អ្នកមានចិត្តប្រកបដោយប្រយោជន៍ដល់សត្វទាំងពួង ព្រោះជាអ្នកដល់នូវសេចក្ដីអាណិតនោះ ។ បទថា **"វិហរតិ"** បានដល់ រមែងផ្លាស់ប្ដូរឥរិយាបថ គឺរមែងរក្សាអត្តភាព ។

អ្នកឯណា កាន់យកតែវត្ថុរបស់ដែលម្ចាស់គេឲ្យប៉ុណ្ណោះ ព្រោះហេតុនោះ អ្នកនោះ ទើបឈ្មោះថា **"ទិន្នាទាយី** = អ្នកកាន់យកចំពោះរបស់ដែលគេឲ្យ" ។ អ្នកឯណា បំណងយកវត្ថុដែលគេឲ្យ សូម្បីដោយចិត្តនោះឯង ព្រោះហេតុនោះ អ្នកនោះ ទើបឈ្មោះថា **ទិន្នបាដិកង្ខី** = អ្នកសង្ឃឹមតែរបស់ដែលគេឲ្យ ។ អ្នកឯណា រមែងលួច ហេតុនោះ អ្នកនោះ ទើបឈ្មោះថា **ថេនោ** = អ្នកលួច, ការមិនលួច ឈ្មោះថា **អថេនោ** ។ ឈ្មោះថា ***ជាអ្នកស្អាត*** ព្រោះភាវៈនៃខ្លួនមិនមែនជាចោរនោះឯង ។

បទថា **"អត្តនា** = អត្តភាព" មានពាក្យអធិប្បាយទុកថា ការធ្វើ

អត្តភាព មិនឲ្យជាអ្នកល្ងង់ គឺធ្វើឲ្យស្អាត ។ បទថា **“អព្រហ្មចរិយំ** = ប្រព្រឹត្តធម៌ដែលមិនប្រសើរ” ។ បុគ្គលឯណា រមែងប្រព្រឹត្តអាចារៈ គឺ ចរិយា ដែលល្អស្អាត ដ៏ប្រសើរបំផុត ព្រោះហេតុនោះ អ្នកនោះ ទើប ឈ្មោះថា **ព្រហ្មចារី** = អ្នកប្រព្រឹត្តធម៌ប្រសើរបំផុត ។ បទថា **“អារាចារី** = ប្រព្រឹត្តឃ្លាតឆ្ងាយអំពី ***ព្រហ្មចារ្យ*** ។

បទថា **“មេថុនា”** បានដល់ ***អសទ្ធម្ម*** ដែលដល់នូវការរាប់ថា ***“ជា មេថុន”*** ព្រោះភាវៈនៃ (វត្ថុ) ដែលបុគ្គលគប្បីសេពចំពោះ តាមរឿងរ៉ាវ នៃសត្វលោក ដែលបានឈ្មោះថា **មេថុនកា** គឺអ្នកសេពមេថុនធម្ម ព្រោះ ហាក់ដូចជាដោយអំណាចនៃការច្បាំងរបស់រាគៈដែលគ្របសង្កត់ចិត្ត ។ បទថា **“គាមធម្មា** = ធម៌របស់អ្នកស្រុក” ។

បុគ្គលឯណា រមែងនិយាយពាក្យពិត ហេតុនោះ អ្នកនោះ ទើប ឈ្មោះថា **សច្ចវាទី** = អ្នកនិយាយពាក្យពិត ។ អ្នកឯណាជាប់ត គឺ រមែងទទួលតវាចាសច្ចៈ ដោយវាចាសច្ចៈ ហេតុនោះ អ្នកនោះ ឈ្មោះថា **សច្ចសន្ធោ** = អ្នកទទួលតជាប់សច្ចៈ គេជាអ្នកទុក (ទប់) ចិត្តបាន អធិប្បាយ ថា មិននិយាយពាក្យកុហកក្នុងចន្លោះ, ក៏បុគ្គលឯណា គ្រាខ្លះនិយាយពាក្យ កុហក គ្រាខ្លះនិយាយពាក្យពិត ពាក្យរបស់អ្នកនោះ មិនតភ្ជាប់សេចក្តីពិត

ដោយសេចក្ដីពិត ព្រោះពាក្យរបស់គេខណ្ឌដោយសេចក្ដីកុហក ព្រោះហេតុនោះ គេទើបឈ្មោះថា អ្នកមិនទទួលតសច្ចៈ ជាអ្នកទុក (ទប់) ចិត្តមិនបាន ។ ក៏បុគ្គលនេះ មិនដូចអ្នកនោះទេ, គេមិនព្រមនិយាយពាក្យកុហក សូម្បីព្រោះហេតុនៃជីវិត រមែងទទួលចំពោះសេចក្ដីពិតដោយសេចក្ដីពិតប៉ុណ្ណោះ ព្រោះហេតុដូច្នោះ អ្នកនេះ ទើបឈ្មោះថា **សច្ចសន្ធោ** ។

បទថា **"ថេតោ** = អ្នកមាំមួន" អធិប្បាយថា អ្នកមានវាចាតាំងមាំ ។ បុគ្គលមួយពួកជាអ្នកមានវាចាដែលមិនតាំងមាំ ប្រៀបដូចនឹងសំពត់ដែលគេជ្រលក់ដោយល្មៀត, ដូចដង្គត់ឈើដែលគេបោះទុកក្នុងគំនរអង្កាម, ដូចកូនផ្លែឃ្លោក ដែលគេដាក់ទុកលើខ្នងសេះ ។ បុគ្គលមួយពួកមានវាចាមាំមួន ដូចស្នាមគំនូសដែលជាប់នៅនឹងផ្ទាំងថ្ម និងដូចសសរខឿនសូម្បីនឹងត្រូវកាត់ក្បាលដោយដាវ, គេក៏មិនពោលពាក្យជាពីរភាគ អ្នកនោះលោកហៅថា **ថេតោ** អ្នកមានវាចាមាំមួន ។

បទថា **"បច្ចយិកោ"** បានដល់ អ្នកមានវាចាគួរជឿ គឺបានដល់អ្នកដែលគួរជឿបាន ។ ក៏បុគ្គលខ្លះជាអ្នកជឿទុកចិត្តមិនបាន កាលនរណាមួយសួរថា "ពាក្យនេះនរណានិយាយ" ក៏ពោលថា "អ្នកនោះនិយាយ" គេរមែងដល់នូវវាទៈដែលនរណាមួយ គប្បីពោលថា "កុំជឿពាក្យសម្ដីរបស់គេ" ។ បុគ្គលមួយពួកជាអ្នកមានវាចាជឿបាន កាលនរណាមួយ សួរថា

“ពាក្យនេះ នរណានិយាយ” ក៏ពោលថា “អ្នកនោះនិយាយ” គេរមែងដល់នូវវាទៈដែលនរណាមួយ គប្បីពោលថា “ប្រសិនបើពាក្យរបស់អ្នកនោះពោលពាក្យនេះប៉ុណ្ណោះ កាន់យកជាប្រមាណបាន ឥឡូវនេះ ការសាកសួររមែងមិនមាន” ពាក្យនេះ ជាយ៉ាងនេះប៉ុណ្ណោះ ។

ពីរបទថា **“អវិសំវាទកោ លោកស្ស”** អធិប្បាយថា រមែងមិនឆបោកសត្វលោក ព្រោះភាវៈនៃខ្លួនមានប្រក្រតីពោលពាក្យសច្ចៈនោះ ។ ពីរបទថា **“ឥមេសំ ភេទាយ”** បានដល់ ដើម្បីការទម្លាយពួកជនដែលខ្លួនស្តាប់ក្នុងសំណាក់របស់ជនដែលគេពោលអំពីខាងនេះ ។

បទថា **“ភិន្នានំ វា សន្ធាតា”** បានដល់ ការចូលទៅរកកន្លែងចំណែកទីមួយៗ ក្នុងជនទាំងពីរចំណែក គឺអ្នកជាមិត្ត ឬអ្នករួមឧបជ្ឈាយ៍ជាដើម ដែលបែកសាមគ្គីគ្នាដោយហេតុយ៉ាងណាមួយ ហើយពោលថា “ការវិវាទគ្នានេះ មិនសមគួរដល់លោកទាំងឡាយអ្នកកើតក្នុងត្រកូលដូច្នេះ អ្នកជាពហុស្សូតយ៉ាងនេះ ហើយធ្វើការស្ម័គ្រចិត្តរួមសាមគ្គីគ្នាឲ្យមាំមួន” ។

បទថា **“អនុប្បទាតា”** បានដល់ អ្នកគាំទ្រសេចក្តីព្រមព្រៀងគ្នា អធិប្បាយថា ឃើញទាំងពីរនាក់មានសេចក្តីសាមគ្គីគ្នា ហើយពោលថា “ការណ៍នេះ សមរម្យដល់លោកអ្នកកើតក្នុងត្រកូលបែបនេះ អ្នកប្រកប

ដោយគុណទាំងឡាយបែបនេះ ហើយធ្វើឲ្យជាអ្នកមាំមួន” ។ សេចក្តីត្រេកអរទូទៅ ក្នុងជនអ្នកព្រមព្រៀងគ្នារបស់អ្នកនោះនៅមាន, ព្រោះហេតុនោះ អ្នកនោះ ទើបឈ្មោះថា **សមគ្គារាមោ** = អ្នកមានសេចក្តីត្រេកអរក្នុងជនអ្នកសាមគ្គីគ្នា អធិប្បាយថា ជនអ្នកព្រមព្រៀងគ្នាមិនមានក្នុងទីណា, គេរមែងមិនព្រមទៅសូម្បីដើម្បីនឹងនៅក្នុងទីនោះ ។ ព្រះបាលីថា **“សមគ្គ-ារាមោ”** ដូច្នេះ ពាក្យនេះមានសេចក្តីដូចគ្នា ។ បទថា **“សមគ្គរតោ”** បានដល់អ្នកត្រេកអរក្នុងជនអ្នកព្រមព្រៀងគ្នា អធិប្បាយថា គេលះជនអ្នកព្រមព្រៀងគ្នានោះ ហើយគេក៏មិនប្រាថ្នាសូម្បីនឹងទៅកាន់ទីដទៃឡើយ ។

អ្នកឯណា ឃើញក្តី ឮក្តី នូវជនអ្នកព្រមព្រៀងគ្នា ហើយរមែងត្រេកត្រអាល ព្រោះហេតុនោះ អ្នកនោះ ទើបឈ្មោះថា **សមគ្គនន្ទី** = អ្នកត្រេកអរក្នុងជនអ្នកព្រមព្រៀងគ្នា ។ បទថា **“សមគ្គករណី វាចំ ភាសិតា”** សេចក្តីថា វាចាឯណា រមែងធ្វើសត្វទាំងឡាយឲ្យជាអ្នកព្រមព្រៀងគ្នាប៉ុណ្ណោះ, គេរមែងពោលនូវវាចានោះ ដែលសម្តែងដល់គុណនៃសេចក្តីសាមគ្គីនោះឯងមិនពោលវាចាក្រៅអំពីនេះទេ ។

អ្នកឯណា រមែងពោលក្នុងកាលដែលសមគួរ ហេតុនោះ អ្នកនោះទើបឈ្មោះថា **កាលវាទី** = អ្នកមានប្រក្រតីពោលក្នុងកាល, អធិប្បាយថា គេកំណត់កាលដែលគួរដល់ពាក្យដែលខ្លួនគប្បីពោល ហើយទើបពោល ។

អ្នកឯណា រមែងពោលពាក្យដែលពិត គឺពាក្យដែលជាសភាវៈប៉ុណ្ណោះ ហេតុនោះ អ្នកនោះ ឈ្មោះថា **ភូតវាទី** = អ្នកមានប្រក្រតីពោលពាក្យពិត ។

អ្នកឯណា រមែងពោលពាក្យអាស្រ័យនូវប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍ក្នុងភពខាងមុខប៉ុណ្ណោះ ហេតុនោះ អ្នកនោះ ទើបឈ្មោះថា **អត្ថវាទី** = អ្នកមានប្រក្រតីពោលពាក្យដែលជាប្រយោជន៍ ។

អ្នកឯណា រមែងពោលពាក្យអាស្រ័យនូវលោកុត្តរធម៌ ៩ ប្រការ ហេតុនោះ អ្នកនោះ ទើបឈ្មោះថា **ធម្មវាទី** = អ្នកមានប្រក្រតីពោលតាមធម៌ ។

អ្នកឯណា រមែងពោលពាក្យអាស្រ័យសំវរវិន័យ និងបហានវិន័យ ព្រោះហេតុនោះ អ្នកនោះ ទើបឈ្មោះថា **វិនយវាទី** = អ្នកមានប្រក្រតីពោលវិន័យ ។

ឱកាសដែលជាទីតាំងរបស់វាចានោះ លោកហៅថា **និធានំ** ។ ឱកាសដែលជាទីតាំងរបស់វាចានោះមាន ព្រោះហេតុនោះ វាចានោះ ទើបឈ្មោះថា **និធានវតី** = វាចាមានល័ក្ខខ័ណ្ឌ អធិប្បាយថា ពោលវាចាសមគួរដល់ពាក្យដែលបុគ្គលគប្បីតាំងទុកក្នុងហឫទ័យ ។

បទថា **"កាលេន"** សេចក្តីថា ក៏គេគិតថា "យើងនឹងពោលវាចាដែលមានល័ក្ខខ័ណ្ឌ" សូម្បីការពោលវាចាបែបនេះហើយ គេរមែងមិនពោល

ដោយកាលដែលមិនសមគួរទេ, សំដៅសេចក្ដីថា ពិចារណាវេលាដ៏សមគួរ ហើយទើបពោល ។ បទថា **"សាបទេសំ"** បានដល់ ពាក្យសម្ដីមានឧបមា គឺបានដល់ពាក្យសម្ដីមានហេតុ ។ បទថា **"បរិយន្តវតី"** បានដល់ សម្ដែងការកំណត់ អធិប្បាយថា ការកំណត់វាចានោះ រមែងប្រាកដដោយវិធីណា, រមែងកំណត់ដោយវិធីនោះ ។ បទថា **"អត្ថសញ្ហិតំ"** សេចក្ដីថា ឈ្មោះថា ដល់ព្រមដោយប្រយោជន៍ដែលនរណាមួយ ចែកហើយ ដោយន័យសូម្បីមិនមែនតិច, ក៏មិនអាចនឹងកំណត់បាន ។ ម្យ៉ាងទៀត ឈ្មោះថា រមែងពោលវាចាដែលជាប្រយោជន៍ និងអនុគ្រោះ ព្រោះប្រកបទៅដោយប្រយោជន៍ដែលល្អ ដែលលោកអត្ថវាទីនោះ ពោលសេចក្ដីទុក ។ លោកអធិប្បាយទុកថា មិនលះចោលពាក្យម្យ៉ាង ហើយពោលពាក្យម្យ៉ាងទៀតឡើយ ។

បទថា **"ពីជគាមភូតគាមសមារម្ភា"** សេចក្ដីថា ការប្រាសចាក (ការទម្លាយ) ពីជគាម ៥ យ៉ាង គឺ

**១-មូលពីជំ** ពូជកើតអំពីឫស

**២-ខន្ធពីជំ** ពូជកើតអំពីដើម

**៣-ផលពីជំ** ពូជកើតអំពីផ្លែ

**៤-អគ្គពីជំ** ពូជកើតអំពីចុង

**៥-ពីជពីជំ** ពូជកើតអំពីពូជ និងការផ្ដាច់ (ទម្លាយ) ភូតគាមមាន

ស្មៅខៀវស្រស់ និងដើមឈើជាដើម យ៉ាងណាមួយ ។ អធិប្បាយថា បានដល់ ជាអ្នកវៀរចាកអំពីការទម្លាយដោយសភាវៈ មានការកាត់ និងការស្ងោរជាដើម ។

បទថា **“ឯកភត្តិកោ”** សេចក្ដីថា ភត្ត (បាយ) ២ យ៉ាង គឺភត្តសម្រាប់វេលាព្រឹក និងភត្តសម្រាប់វេលាល្ងាច ។ ក្នុងភត្ត ២ យ៉ាងនោះ ភត្តដែលបរិភោគក្នុងវេលាព្រឹក លោកកំណត់ត្រឹមវេលាថ្ងៃត្រង់, ភត្តដែលបរិភោគក្នុងវេលាល្ងាច លោកកំណត់ចាប់តាំងអំពីថ្ងៃត្រង់ទៅ រហូតដល់វេលាមុនអរុណរះ ព្រោះហេតុដូច្នោះ កាលភិក្ខុបរិភោគអាហារហើយអស់ ១០ ដង ត្រឹមវេលាថ្ងៃត្រង់ រមែងជាអ្នកឈ្មោះថា **“ឯកភត្តិកោ** = គឺអ្នកមានភត្តតែមួយ” ។ ពាក្យថា **“ឯកភត្តិកោ”** ដែលលោកពោលសំដៅយកភត្តដែលបរិភោគក្នុងវេលាព្រឹកនោះ ។ ការបរិភោគភត្តក្នុងវេលាយប់ ឈ្មោះថា **រត្តិ** ។ អ្នកឯណាវៀរចាកការបរិភោគភត្តក្នុងវេលាយប់នោះ ព្រោះហេតុនោះ អ្នកនោះ ទើបឈ្មោះថា **រត្តូបរតោ** = អ្នកវៀរចាកអំពីការបរិភោគភត្តក្នុងវេលាយប់ ។ ការបរិភោគភត្តតាំងអំពីវេលាថ្ងៃត្រង់កន្លងទៅហើយ រហូតដល់ព្រះអាទិត្យលិច ឈ្មោះថា **វិកាល-ភោជនំ** = ការបរិភោគភត្តក្នុងវេលាវិកាល គឺជាអ្នកវៀរចាកអំពីការបរិភោគភត្តក្នុងវេលាវិកាលនោះ ។

*ការមើលល្បែងជាសត្រូវ ដែលបដិបក្ខចំពោះព្រហ្មចរិយៈ ព្រោះមិនសមរម្យនឹងព្រះសាសនា, ព្រោះហេតុដូច្នោះ ការមើលល្បែងនោះទើបឈ្មោះថា* **វិសូកទស្សនំ** *= ការមើលល្បែងដែលជាសត្រូវចំពោះព្រហ្មចរិយៈ (***វិសូក** *= សត្រូវ,* **ទស្សនំ** *= ការមើល) ។ ការរាំច្រៀងនិងប្រគំតន្ត្រី ដោយអំណាចនៃការរាំរែកដោយខ្លួនឯង ឬឲ្យអ្នកដទៃរាំរែកជាដើមក្តី, ការមើល ការរាំជាដើម ដោយហោចទៅសូម្បីមើលការរាំរបស់បក្សី មានក្ងោកជាដើមក្តី, ក៏ចាត់ទុកជាសត្រូវចំពោះព្រហ្មចរិយៈ ព្រោះហេតុដូច្នោះ ការរាំជាដើមនោះ ទើបឈ្មោះថា* **នច្ចគីតវាទិតវិសូកទស្សនា** *= អំពីការរាំច្រៀង ប្រគំតន្ត្រី និងមើលនូវល្បែងដែលជាសត្រូវ ចំពោះព្រហ្មចរិយៈ ។ (***នច្ចះ** *= រាំ,* **គីតះ** *= ច្រៀង,* **វាទិតៈ** *= ប្រគំតន្ត្រី) ក៏ការដែលនឹងប្រកបការរាំជាដើមក្តី, ឲ្យអ្នកដទៃប្រកបក្តី, មើលល្បែងដែលគេប្រកបហើយក្តី មិនសមគួរដល់ភិក្ខុ និងភិក្ខុនីឡើយ* * ។

*គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា* **“មាលា”** *ជាដើម ។ បទថា* **“មាលា”** *បានដល់ ផ្កាឈើយ៉ាងណាមួយ ។ បទថា* **“គន្ធំ”** *បានដល់ គន្ធជាតិ*

---

* ពាក្យនេះលោកពោលដោយអម (បរិយាយ), តែដោយពិត ដោយត្រង់ (និប្បរិយាយ) មិនមែនតែភិក្ខុ និងភិក្ខុនីប៉ុណ្ណោះទេ សូម្បីសិក្ខមានា សាមណេរ និងសាមណេរី ក៏មិនគួរដែរ (ដីកា និងយោជនាព្រះវិន័យ) ។

យ៉ាងណាមួយ ។ បទថា **“ទិវេលេបនំ”** បានដល់ ការជ្រលក់ (ផាត់) ពណ៌ ។ ក្នុងអធិការនេះ បុគ្គលកាលប្រដាប់តុបតែងហើយ ឈ្មោះថា រមែងទ្រទ្រង់ទុក, កាលបើបុគ្គលធ្វើវត្ថុដែលខ្វះឲ្យបរិបូណ៌ ឈ្មោះថា រមែងប្រដាប់ ។ អ្នកត្រេកអរដោយរបស់ក្រអូបក្តី ដោយការលាបពណ៌ក្តី ឈ្មោះថា រមែងតុបតែង ។ ការធ្វើ លោកហៅថា **ឋាន** អធិប្បាយថា មហាជនរមែងធ្វើការសៀត គឺទ្រទ្រង់ផ្កាឈើជាដើមនោះ ដោយចេតនាជាគ្រឿងទ្រុស្តសីលណា, អ្នកមានសីលរមែងជាអ្នកវៀរចាកអំពីចេតនាជាគ្រឿងទ្រុស្តសីលនោះ ។ ទីដេកដែលខ្ពស់ហួសប្រមាណ លោកហៅថា **ឧច្ចាសយនំ** = ទីដេកខ្ពស់, ទីដេកមានគ្រឿងក្រាល ដោយវត្ថុដែលមិនសមគួរ លោកហៅថា **មហាសយនំ** = ទីដេកធំ, អ្នកមានសីល គប្បីវៀរចាកទីដេកនោះ ។

មាសសុទ្ធ ឈ្មោះថា **ជាតរូបំ** ។ កហាបណៈ ឈ្មោះថា **រជតំ** ។ កហាបណៈឯណា ដែលលោកហៅថា **លោហមាសកោ** គឺមាសកៈធ្វើដោយលោហៈ, **ជតុមាសកោ** គឺមាសកៈធ្វើដោយជ័រ, **ទារុមាសកោ** គឺមាសកៈធ្វើដោយឈើ; អធិប្បាយថា លោកជាអ្នកវៀរចាកការទទួលប្រាក់ និងមាសទាំង ២ យ៉ាងនោះ គឺមិនទទួលដោយខ្លួនឯង និងមិនឲ្យអ្នកដទៃទទួល

*ជំនួស, ទាំងមិនត្រេកអរប្រាក់ និងមាសដែលគេទុកដាក់ដើម្បីខ្លួន* * ។

*បទថា* **“អាមកធញ្ញបដិគ្គហណា”** *បានដល់ វៀរចាកការទទួលនូវធញ្ញជាតិឆៅ ៧ ប្រភេទ គឺ*

**១.សាលិ** *ស្រូវសាលី* **២.វីហិ** *ស្រូវខ្សាយ*

**៣.យវៈ** *ស្រូវដំណើប* **៤.គោធុមៈ** *ស្រូវស្រងែ*

**៥.កង្គុ** *ស្រូវមីយេ* **៦.វរកៈ** *ស្កួយ*

**៧.កុទ្រូសកៈ** *ស្មៅគែលលក* ។

*ក៏ការទទួលធញ្ញជាតិឆៅ ៧ ប្រភេទនោះ មិនគួរដល់ភិក្ខុទាំងឡាយប៉ុណ្ណោះក៏ទេ, សូម្បីការប៉ះពាល់វត្ថុទាំងនោះ ក៏មិនគួរដូចគ្នា ។ ក៏ក្នុងពាក្យថា* **“អាមកមំសបដិគ្គហណា”** *នេះ ការទទួលសាច់ឆៅ ក៏មិនគួរដល់ភិក្ខុទាំងឡាយ វៀរលែងព្រះមានព្រះភាគ ទ្រង់អនុញ្ញាតទុកដោយចំពោះប៉ុណ្ណោះ* ***ទាំងការប៉ះពាល់សាច់ឆៅ ក៏មិនគួរដែរ*** ។

*ក្នុងពាក្យថា* **“ឥត្ថីកុមារិកាបដិគ្គហណា”** *នេះ ស្រីដែលទៅកាន់ចន្លោះបុរស ឈ្មោះថា* **ឥត្ថី**, *ស្រីក្រៅអំពីនេះ ឈ្មោះថា* **កុមារិកា** *(ស្រីក្រមុំ);*

---

* សេចក្តីពិស្តារនៃបញ្ហានេះ អ្នកសិក្សាគប្បីជ្រាបនៅក្នុងគម្ពីរសមន្តប្បាសាទិកា ត្រង់និស្សគ្គិយកណ្ឌ កោសិយវគ្គទី ២ សិក្ខាបទទី ១៨ ។

ការទទួលទុកក្តី ការប៉ះពាល់ក្តី នូវស្ត្រីទាំងឡាយនោះ រមែងមិនគួរទាំងអស់ ។ ក្នុងពាក្យថា **"ទាសីទាសាបដិគ្គហណា"** នេះ ការទទួលស្ត្រី និងបុរសទាំងនោះ ទុកសម្រាប់ជាទាសី ទាសា រមែងមិនសមគួរ, ក៏កាលនរណាមួយពោលយ៉ាងនេះថា "ខ្ញុំព្រះករុណា សូមប្រគេនកប្បិយការកៈ គឺអ្នកឧបដ្ឋាក, ខ្ញុំព្រះករុណា សូមប្រគេនអារាមិក គឺអ្នកទទួលបម្រើក្នុងវត្ត" ដូច្នេះ, នឹងទទួលទុកក៏សមគួរ ។ ន័យដែលគួរ និងមិនគួរសូម្បីក្នុងសត្វទាំងឡាយមានពពែ និងចៀមជាដើម ក្នុងស្ថានទីទាំងឡាយ មានស្រែ និងសួនជាទីបំផុត បណ្ឌិតគប្បីពិចារណាដោយអំណាចនៃព្រះវិន័យចុះ ។

ក្នុងស្ថានទីទាំងនោះ ទីណាមានបុព្វណ្ណជាតិរីកលូតលាស់ល្អ ទីនោះឈ្មោះថា ***ទីស្រែ***, ក្នុងទីណា អបរណ្ណជាតិរមែងរីកលូតលាស់ល្អ ទីនោះឈ្មោះថា ***ចម្ការ*** ។ម្យ៉ាងទៀត បុព្វណ្ណជាតិ និងអបរណ្ណជាតិទាំង ២ រមែងរីកលូតលាស់ល្អក្នុងទីណា, ទីនោះ ឈ្មោះថា ***ស្រែ*** ។ ភូមិភាគដែលគេធ្វើហើយ ដើម្បីត្រូវការបុព្វណ្ណជាតិ និងអបរណ្ណជាតិ ឈ្មោះថា ***ចម្ការ*** ។ ក៏ក្នុងអធិការនេះ សូម្បីក្នុងទីបឹង និងត្រពាំងទឹកជាដើម ក៏លោកសង្គ្រោះចូលដោយការកាន់យកទីស្រែចម្ការជាប្រធាន ។

ការងាររបស់ទូត លោកហៅថា **ទូតេយ្យំ** អធិប្បាយថា ការកាន់យកសំបុត្រ ឬដំណឹងរបស់គ្រហស្ថទាំងឡាយហើយទៅក្នុងទីនោះៗ ។ ការ

*ទទួលបម្រើបន្តិចបន្តួចរបស់អ្នកបញ្ជូនសារទៅកាន់ស្រុកអ្នកដទៃ លោកហៅថា* **បហិណគមនំ** *= ការទទួលបម្រើបន្តិចបន្តួច (សំដៅដល់អ្នកបញ្ជូនដំណឹង), ការធ្វើកិច្ចទាំង ២ យ៉ាងនោះ ឈ្មោះថា* **អនុយោគោ** *= ការតាមប្រកប; ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបសេចក្តីក្នុងពាក្យនេះ យ៉ាងនេះថា* **"ទូតេយ្យបហិណគមនានំ អនុយោគោ** *= ការប្រកបទូតកម្ម និងការទទួលបម្រើ"* ។

*បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា* ***អ្នកកោងដោយភ្នែកជញ្ជីង*** *ជាដើម ។ បទថា* **"កូដំ** *= ការកោង"* *គឺការបោកបញ្ឆោត ។ បណ្តាការកោងទាំងនោះ ការកោងដោយភ្នែកជញ្ជីង មាន ៤ យ៉ាង គឺ*

**១.រូបកូដំ** *កោងដោយរូប*

**២.អង្គកូដំ** *កោងដោយអវយវៈ*

**៣.គហណកូដំ** *កោងដោយការកាន់យក*

**៤.បដិច្ឆន្នកូដំ** *កោងដោយវត្ថុដែលបិទបាំងទុក ។*

*ក្នុងការកោងទាំងនោះ បុគ្គលធ្វើគ្រឿងថ្លឹងទាំង ២ ឲ្យមានរូបភាពស្រដៀងគ្នា កាលនឹងកាន់យក រមែងកាន់យកនូវចំណែកច្រើន, កាលឲ្យរមែងឲ្យចំណែកតិច ឈ្មោះថា* **រូបកូដំ** *= កោងដោយរូប ។ បុគ្គលនឹងកាន់យកវត្ថុ ដោយប្រើដៃសង្កត់ភ្នែកជញ្ជីងទុក ក្នុងចំណែកខាងក្រោយ,*

កាលនឹងឲ្យ រមែងប្រើដៃសង្កត់ក្អែកដញ្ជីងទុកក្នុងចំណែកខាងដើម ឈ្មោះថា **អទ្ធកូដំ** = កោងដោយអវយវៈ ។ បុគ្គលកាលនឹងកាន់យក រមែងកាន់យកត្រង់ដើមខ្សែ, កាលនឹងឲ្យ ក៏រមែងចាប់កាន់យកត្រង់ចុងខ្សែ ឈ្មោះថា **គហណកូដំ** = កោងដោយការចាប់កាន់យក ។ បុគ្គលធ្វើក្អែកដញ្ជីងឲ្យប្រហោង ហើយដាក់លំអិតដែកទុកខាងក្នុង, កាលនឹងកាន់យកវត្ថុ រមែងធ្វើលំអិតដែកនោះ ទុកក្នុងចំណែកខាងក្រោយ, កាលឲ្យ ក៏ធ្វើលំអិតដែកនោះ ទុកក្នុងចំណែកខាងចុង ឈ្មោះថា **បដិច្ឆន្នកូដំ** = កោងដោយវត្ថុរបស់ដែលបិទបាំងទុក ។

ថាសដែលធ្វើដោយមាស លោកហៅថា **កំសោ** ។ ការឆបោកដោយថាសមាសនោះ ឈ្មោះថា **កំសកូដំ** ។ ***សួរថា*** ធ្វើយ៉ាងណា ? ឆ្លើយថា ជនទាំងឡាយ ធ្វើថាសមាសទុកមួយថាស ធ្វើរបស់ក្លែងក្លាយទុក ២-៣ បាទ តពីនោះ គេក៏ទៅកាន់ជនបទ ចូលទៅកាន់ត្រកូលស្តុកស្តម្ភណាមួយដែលមានទ្រព្យច្រើន ហើយនិយាយថា លោកទាំងឡាយ ចូរទិញថាសមាស ។ កាលនរណាមួយ សួរដល់តម្លៃ គេមានសេចក្តីប្រាថ្នាឲ្យតម្លៃស្មើគ្នា, តែវេលានោះ កាលបើជនទាំងនោះពោលថា តើខ្ញុំគប្បីជ្រាបភាពជាភាជនៈមាសរបស់ថាសទាំងនេះបានយ៉ាងណា ? ទើបគេយកថាសមាសត្រដុសចូលនឹងផ្ទាំងថ្ម ពោលថា លោកទាំងឡាយដកពិសោធន៍មុន ហើយ

ទើបកាន់យក រួចឲ្យថាសមាសទាំងអស់ គឺលក់ទាំងអស់ហើយ ក៏ទៅ ។

**មានក្ខជំ** = កោងដោយការវាស់រយៈពេល មាន ៣ យ៉ាង គឺ

**១.ហទយភេទ:** វាស់បែងចែកដោយការប្តូរចេញ

**២.សិខាភេទ:** វាស់បែងចែកដោយខាងចុង

**៣.រជ្ជុភេទ:** វាស់បែងចែកដោយខ្សែ ។

ក្នុងការវាស់ទាំងនោះ **ហទយភេទ:** ឈ្មោះថា ការវាស់បែងចែកដោយការប្តូរចេញ រមែងបានក្នុងវេលាដែលគេដួសទឹកដោះថ្លា និងប្រេងជាដើម ក៏កាលដែលបុគ្គលនឹងកាន់យកទឹកដោះថ្លាជាដើម ដោយខ្លួនឯងក៏និយាយថា លោកចូរចាក់តិចៗ ព្រោះគ្រឿងវាស់វាប្រហោង បែកខាងក្រោម ហើយក៏ឲ្យហូរចេញទៅក្នុងភាជនៈដែលត្រងទុកយ៉ាងច្រើន ទើបកាន់យក, កាលនឹងឲ្យអ្នកដទៃ ក៏បិទប្រហោងរន្ធនោះជិត ដើម្បីឲ្យពេញឆាប់រហ័ស ហើយក៏ឲ្យ ។ **សិខាភេទ:** ឈ្មោះថា ការវាស់បែងចែកដោយខាងចុង រមែងបានក្នុងកាលដួសល្ង និងអង្ករជាដើម, ក៏កាលនឹងកាន់យកវត្ថុរបស់នោះដោយខ្លួនឯង ក៏ឲ្យពូនកំពូលរបស់នោះតិចៗ ឲ្យកំពុងខ្ពស់ឡើងទៅហើយកាន់យក កាលនឹងឲ្យ ក៏ធ្វើឲ្យពេញដោយឆាប់រហ័ស ហើយចោះទម្លាយកំពូលចេញ ទើបឲ្យ ។ **រជ្ជុភេទ:** ឈ្មោះថា ការវាស់បែងចែកដោយខ្សែ រមែងប្រព្រឹត្តធ្វើ ក្នុងវេលាដែលវាស់ស្រែចម្ការ, ក៏បុគ្គល

ទាំងឡាយ កាលបើមិនបានទទួលសំណូក រមែងធ្វើការវាស់ស្រែសូម្បីមិនទូលំទូលាយ (លើស) ក៏ឲ្យទូលំទូលាយ (លើស) បាន ។

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យថា **“ឧក្កោដនំ”** ជាដើម ។ ការក្លែងធ្វើវត្ថុម្ចាស់របស់ទាំងឡាយ មិនឲ្យជាម្ចាស់របស់ ហើយក៏កាន់យកសំណូក ឈ្មោះថា **ឧក្កោដនំ** = ការកោង ។ ការបោកបញ្ឆោតអ្នកដទៃដោយឧបាយនោះៗ ឈ្មោះថា **វញ្ចនំ** = ការបោកបញ្ឆោត, ក្នុងរឿងទាំងអស់នោះ មានរឿងមួយជាឧទាហរណ៍ ដូចតទៅនេះ ៖

បានឮថា នាយព្រានម្រឹគម្នាក់ចាប់បានម្រឹគ និងកូនម្រឹគហើយ ដើរមកតាមផ្លូវ, មានអ្នកលេងភ្នាល់ម្នាក់និយាយនឹងព្រាននោះថា “នែលោកដ៏ចម្រើន ម្រឹគ និងកូនម្រឹគ តម្លៃប៉ុន្មាន ?” កាលនាយព្រានឆ្លើយថា “ម្រឹគតម្លៃ ២ កហាបណៈ, កូនម្រឹគ ១ កហាបណៈ” ដូច្នេះហើយ នាយអ្នកលេងភ្នាល់ ក៏ឲ្យប្រាក់មួយកហាបណៈ ហើយក៏ចាប់យកកូនម្រឹគទៅ, គ្រាទៅបានបន្តិច ហើយក៏ត្រឡប់មកវិញ និយាយថា “លោកដ៏ចម្រើន យើងមិនត្រូវការកូនម្រឹគទេ លោកចូរឲ្យមេម្រឹគដល់ខ្ញុំវិញ” ។ នាយព្រាននិយាយថា “បើយ៉ាងនោះ ចូរឲ្យខ្ញុំ ២ កហាបណៈ” ។ នាយអ្នកលេងភ្នាល់នោះនិយាយថា “អ្នកដ៏ចម្រើន ពីមុនខ្ញុំឲ្យ ១ កហាបណៈ មិនមែនឬ ?”

កាលនាយព្រានឆ្លើយថា ត្រូវហើយ លោកឲ្យខ្ញុំ ១ កហាបណៈដែរ ។ នាយអ្នកលេងភ្នាល់ ទើបនិយាយថា "ចូរលោកចាប់យកកូនម្រឹគនេះទៅវិញចុះ, ក៏កាលបើមានសេចក្តីយ៉ាងនោះ កហាបណៈនោះផង កូនម្រឹគមានតម្លៃ ១ កហាបណៈផង ក៏រួមជា ២ កហាបណៈ" ។ នាយព្រាននោះ ពិចារណាមើលថា "នាយអ្នកលេងភ្នាល់នេះ រមែងពោលដល់ហេតុគួរ" ហើយទើបទទួលយកកូនម្រឹគ និងបានឲ្យម្រឹគដល់អ្នកលេងភ្នាល់ទៅ នេះក៏ហៅថា **ឧញ្ចនំ** * = ការបោកបញ្ឆោតដែរ ។

ការធ្វើ **អបាមង្គំ** គឺធ្វើនូវវត្ថុមិនមែនខ្សែសង្វារ ថាជាសង្វារក្តី, ធ្វើវត្ថុមិនមែនកែវមណី ឲ្យដូចកែវមណីក្តី, ធ្វើមាសក្លែងក្លាយ ឲ្យដូចមាសពិតក្តី ហើយឆបោកដោយរបស់ក្លែងក្លាយនោះ ដោយអំណាចនៃការប្រកបដោយកលមាយា ឈ្មោះថា **និកតិ** = ការកាឡៃ ។ អ្នកប្រកបក្នុងការកោងឈ្មោះថា **សាចិយោគ** * , ក៏ពាក្យថា **សាចិយោគ** នេះ ជាឈ្មោះរបស់ការកោងដែលមានការទទួលទ្រព្យសម្បត្តិជាដើមនោះឯង ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបអធិការយ៉ាងនេះ គឺ

---

* ក្នុងទីដទៃទៀតលោកហៅថា ឧបាយកថា អទិន្នាទាន ។

* **សាចិយោគោតិ** កុដិលយោគោ ។

**-ឧក្កោដនសាចិយោគោ** អ្នកប្រកបការកោងដោយទទួលនូវទ្រព្យ-សម្បត្តិ ។

**-វញ្ចនសាចិយោគោ** អ្នកប្រកបការកោងដោយបោកបញ្ឆោត

**-និកតិសាចិយោគោ** អ្នកប្រកបការកោងដោយក្លែងបន្លំ ។

កេចិអាចារ្យពោលថា "ការសម្តែងរបស់ម្យ៉ាង ហើយផ្លាស់ប្តូររបស់ម្យ៉ាងទៀត ឈ្មោះថា **សាចិយោគ**" , ក៏ពាក្យថា **សាចិយោគ** នេះ លោកសង្គ្រោះដោយការបោកបញ្ឆោតនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **ឆេទនំ** ជាដើម ។ បទថា "**ឆេទនំ** = ការកាត់ដៃជាដើម" ។ បទថា "**វធោ** = ការសម្លាប់ឲ្យស្លាប់" ។ បទថា "**ពន្ធោ** = គ្រឿងចាប់ចងដោយខ្សែជាដើម" ។ បទថា "**វិបរាមោសោ** = ការវាយដណ្តើម" ។ ការវាយដណ្តើមនេះ មាន ២ យ៉ាង គឺ **ហិម-វិបរាមោសោ** = ការវាយដណ្តើម អាស្រ័យហិមៈ (ទឹកសន្សើម) ១, **គុម្ពវិបរាមោសោ** = ការវាយដណ្តើមអាស្រ័យគុម្ពឈើ ១ ។ ពិតមែនហើយ ក្នុងសម័យណាដែលទឹកសន្សើមធ្លាក់ ពួកអ្នកលេងទាំងឡាយបិទបាំងខ្លួនដោយទឹកសន្សើមដែលធ្លាក់ហើយ ទើបវាយដណ្តើមអ្នកដើរផ្លូវ ភាវៈដូច្នេះ ឈ្មោះថា **ហិមវិបរាមោសោ** ។ សម័យណា ពួកអ្នកលេងអាស្រ័យការកំបាំងខ្លួនដោយគុម្ពឈើ ហើយវាយដណ្តើមអ្នកដើរផ្លូវ ភាវៈដូច្នេះ

ឈ្មោះថា **គុម្ពវិលោបនាមោសោ** ។ ការបួន់កំហែងតាមផ្ទះ និងពួកអ្នកស្រុកជាដើម លោកហៅថា **អាលោបោ** = ការបួន់កំហែងយកទ្រព្យ ។ ការចូលទៅកាន់ស្រុកអ្នកដទៃ ដោយកិរិយាកាយវិការផ្លូវដីអាក្រក់ ហើយយកសស្ត្រាចាក់ត្រង់ទ្រូងមនុស្ស ក៏កាន់យកវត្ថុរបស់ដែលខ្លួនប្រាថ្នា ឈ្មោះថា **សហសាការោ** = ការសម្លុត ។ អ្នកមានសីលរមែងវៀរចាកនូវអំពើអាក្រក់មានការកាត់ដៃជាដើមនោះ ដោយប្រការដូច្នេះ ។

បទថា **"សោ សន្តុដ្ឋោ ហោតិ"** សេចក្តីថា លោកជាអ្នកប្រកបដោយសេចក្តីសន្តោសក្នុងបច្ច័យតាមមានតាមបាន ១២ យ៉ាង ក្នុងបច្ច័យ ៤ ។ បទថា **"កាយបរិហារិកេន** = ដោយបច្ច័យយ៉ាងណាមួយដែលត្រឹមតែជាគ្រឿងបរិហារកាយ" ។ បទថា **"កុច្ឆិបរិហារិកេន** = ដោយបច្ច័យត្រឹមតែជាគ្រឿងបរិហារផ្ទៃ" ។ ពីរបទថា **"សមាទាយេវ បក្កមតិ"** សេចក្តីថា លោកកាន់យកតែបរិក្ខារ ៨ គត់ ដែលជាបរិក្ខារសម្រាប់ភិក្ខុប៉ុណ្ណោះ ធ្វើឲ្យជាប់ដោយកាយ ហើយក៏ទៅ, លោកជាអ្នកមិនជាប់ជំពាក់ទាក់ទិនថា "វិហាររបស់យើង បរិវេណរបស់យើង ឧបដ្ឋាករបស់យើង" ទេ, លោកប្រើប្រាស់សេនាសនៈ ដែលជាដូវព្រៃ មានគល់ឈើ ដងព្រៃ ញកភ្នំ តាមដែលប្រាថ្នា ជាអ្នកឈរម្នាក់ឯង អង្គុយម្នាក់ឯង មិនមានមិត្ត ជាគម្រប់ពីរ ក្នុងឥរិយាបថទាំងពួង ដូចកូនសរដែល

ផុតពីខ្សែ ឬដូចដំរីចុះប្រេងជៀសចេញអំពីហ្វូងដូច្នោះ; លោករមែងដល់នូវភាពជាអ្នកដូចកុយរមាស ដែលលោកពណ៌នាពាក្យជាគាថាទុកយ៉ាងនេះថា ៖

**“ចាតុទ្ទិសោ អប្បដិឃោ ច ហោតិ**

**សន្តុស្សមានោ ឥតរីតរេន បរិស្សយានំ សហិតា អច្ឆម្ភី**

**ឯកោ ចរេ ខគ្គវិសាណកប្បោ**

ប្រែសេចក្តីថា ភិក្ខុជាអ្នកមិនទើសទាក់ ត្រាច់ទៅក្នុងទិសទាំង ៤ ។ លោកជាអ្នកសន្តោស ដោយបច្ច័យ តាមមាន តាមបាន, ជាអ្នកអត់ធន់ចំពោះអន្តរាយទាំងឡាយ ជាអ្នកមិនភ្ញាក់ញញើត តក់ស្លុត គប្បីជាអ្នកត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាសដូច្នោះ” ។

ឥឡូវនេះ ព្រះបរមសាស្តា កាលនឹងទ្រង់ញ៉ាំងសេចក្តីនោះ ឲ្យសម្រេចប្រយោជន៍ដោយពាក្យឧបមា ទើបត្រាស់ពាក្យថា **“សេយ្យថាបិ”** ជាដើម ។ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **“សេយ្យថាបិ”** ជាដើមនោះ ។ ពីរបទថា **“បក្ខី សកុណោ”** បានដល់ បក្សីប្រកបដោយស្លាប ។ បទថា **“ឌេតិ** = រមែងហើរទៅ” ។ ក៏ក្នុងអធិការនេះ មានសេចក្តីដោយសង្ខេបដូចតទៅនេះ ៖

ធម្មតាបក្សីទាំងឡាយដឹងថា ដើមឈើក្នុងប្រទេសនោះមានផ្លែទុំ ក៏នាំគ្នាហើរមកអំពីទិសផ្សេងៗ ហើយនាំគ្នាចឹកចោះទម្លាយ និងចឹកស៊ីផ្លែឈើ

ទាំងឡាយនៃដើមឈើនោះ ដោយក្រចក ស្លាប និងចំពុះមាត់ជាដើម ហើយ ទំពាស៊ី ។ ក៏សេចក្តីព្រួយបារម្ភរបស់បក្សីទាំងនោះថា "ផ្លែនេះនឹងមាន ប្រយោជន៍ដល់ពួកយើង ក្នុងថ្ងៃនេះ, ផ្លែនេះនឹងមានប្រយោជន៍ដល់ពួក យើងក្នុងថ្ងៃស្អែកនេះ" ដូច្នេះ រមែងមិនមាន ។ ក៏ពេលផ្លែឈើអស់ ហើយពួកបក្សី ក៏មិនបានខាវខាំងការពារដើមឈើនោះទុកឡើយ គឺសំដៅ សេចក្តីថា ពួកបក្សីទាំងនោះនឹងមិនយកស្លាប ឬក្រចក និងចំពុះមាត់ ប៉ះត្រូវដើមឈើ ដើម្បីត្រូវការរក្សាទីទុំះឯងទុកទេ ហ្វូងបក្សីដែលមិនព្រួយ បារម្ភក្នុងដើមឈើនោះ ក៏នឹងនាំគ្នាហើរទៅ, បក្សីណាប្រាថ្នានឹងទៅកាន់ ទិសភាគឯណា, បក្សីនោះ ក៏មានត្រឹមតែស្លាបប៉ុណ្ណោះជាភារៈ ហើយ ក៏ស្រវាហើរទៅ យ៉ាងណា; ភិក្ខុនេះ ក៏ដូច្នោះដែរ គឺជាអ្នកមិនជាប់ជំពាក់ មិនហួងហែង កាន់យកត្រឹមតែបរិក្ខារ ៨ ប៉ុណ្ណោះ ហើយក៏ជៀសចេញទៅ ដោយប្រការដូច្នេះ ។

បទថា **"អរិយេន** = មិនមានទោស" ។ បទថា **"អជ្ឈត្តំ** = ក្នុង អត្តភាពរបស់ខ្លួន" ។ បទថា **"អនវជ្ជសុខំ** = សេចក្តីសុខដែលប្រាស ចាកទោស" ។ បទថា **"សោ ចក្ខុនា រូបំ ទិស្វា"** អធិប្បាយថា ភិក្ខុនោះ ជាអ្នកប្រកបដោយសីលក្ខន្ធ ដែលមិនមានទោសនេះ ព្រោះឃើញរូប ដោយចក្ខុវិញ្ញាណ ។ សូម្បីក្នុងបទដ៏សេស ពាក្យឯណា ដែលខ្ញុំគប្បី

ពោលពាក្យទាំងអស់នោះ ខ្ញុំពោលហើយក្នុងពេលមុនន៉ុះឯង ។ បទថា **"អព្យាសេកសុខំ"** បានដល់ សេចក្ដីសុខដែលកិលេសទាំងឡាយមិនលេចស្រោច ។ ពាក្យនេះ លោកពោលថា "ជាសេចក្ដីសុខដែលមិនច្រឡូកច្រឡំ" ដូច្នេះខ្លះ ។ ពិតមែនហើយ សេចក្ដីសុខក្នុងឥន្ទ្រិយសំវរៈឈ្មោះថា ជាសេចក្ដីសុខដែលមិនច្រឡូកច្រឡំ ព្រោះប្រព្រឹត្តទៅដោយហេតុត្រឹមតែអារម្មណ៍ដែលខ្លួនឃើញហើយជាដើម ក្នុងអារម្មណ៍ទាំងឡាយ ដែលខ្លួនឃើញហើយ ។ បទថា **"សោ អភិក្កន្តេ បដិក្កន្តេ"** អធិប្បាយថា ភិក្ខុនោះ ប្រកបដោយសេចក្ដីសង្រួមឥន្ទ្រិយទាំងឡាយ ដែលមានចិត្តជាទីប្រាំមួយ រមែងជាអ្នកធ្វើសម្បជញ្ញៈដោយអំណាចនៃសតិសម្បជញ្ញៈក្នុងទីទាំងឡាយ ៧ មានការឈានទៅខាងមុខ និងត្រឡប់ថយក្រោយជាដើមនេះ ។ បណ្ដាពាក្យទាំងនោះ ពាក្យឯណាដែលខ្ញុំគប្បីពោល ពាក្យនោះខ្ញុំពោលទុកហើយក្នុងឈានវិភង្គ * ។

***សួរថា*** ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្ដែងធម៌អ្វីទុកដោយពាក្យជាដើមថា **"សោ ឥមិនា ច"** ដូច្នេះ ?

ឆ្លើយថា ព្រះអង្គទ្រង់សម្ដែងបច្ចយសម្បត្តិ គឺការដល់ព្រមដោយ

---

* អដ្ឋកថាព្រះអភិធម្ម ទុតិយភាគ ៧ ។

*បច្ច័យ របស់ភិក្ខុអ្នកនៅក្នុងព្រៃដោយបច្ច័យទាំង ៤ នេះ គឺ **សីលក្ខន្ធ ១, ឥន្ទ្រិយសំវរៈ ១, សតិសម្បជញ្ញៈ ១** និង **សេចក្ដីសន្ដោស ១** មិនមានដល់ភិក្ខុណា, ការនៅក្នុងព្រៃ ក៏មិនសម្រេចប្រយោជន៍ដល់ភិក្ខុនោះឡើយ; សំដៅសេចក្ដីថា ភិក្ខុនោះនឹងត្រូវដល់នូវភាពជាអ្នកដែលបុគ្គលណាមួយគប្បីតិះដៀល ដោយពោលប្រៀបនឹងសត្វតិរច្ឆាន និងព្រានព្រៃ ។ ទេវតាអ្នកអាស្រ័យនៅក្នុងព្រៃ រមែងប្រកាសពាក្យឲ្យបានឮសំឡេងដែលគួរភ័យខ្លាចថា "នឹងមានប្រយោជន៍អ្វី ដោយការនៅព្រៃរបស់អ្នកលាមកបែបនេះ" ពួកមនុស្សទាំងឡាយនឹងនាំគ្នាយកដៃស្ទាបអង្អែលក្បាលធ្វើអាការឲ្យលោកគេចចេញទៅ, ភាពមិនមានយសរបស់លោករមែងខ្ចរខ្ចាយទៅថា ភិក្ខុឈ្មោះនោះ ចូលទៅនៅក្នុងព្រៃហើយ សាងកម្មដ៏លាមកយ៉ាងនេះៗ, ក៏បច្ច័យទាំង ៤ នេះ មានហើយដល់ភិក្ខុណា, ការនៅក្នុងព្រៃ ក៏រមែងសម្រេចប្រយោជន៍ដល់ភិក្ខុនោះ; ព្រោះថា កាលលោកពិចារណាឃើញសីលរបស់ខ្លួន កាលបើមិនឃើញការពព្រុស ពពាលត្រឹមតែម្យ៉ាង លោកក៏ញុំាងបីតិ និងបាមោជ្ជៈ ឲ្យកើតឡើងហើយ ក៏ពិចារណាបីតិនោះ ដោយការអស់ទៅ សូន្យទៅ រមែងឈានចុះកាន់ភូមិនៃព្រះអរិយៈ ។ ពួកទេវតាទាំងឡាយ ដែលស្ថិតនៅក្នុងព្រៃ មានចិត្តជារបស់ខ្លួន មានចិត្តរីករាយ រមែងពោលសរសើរគុណ ដោយហេតុនេះ*

*យសរបស់ភិក្ខុនោះ រមែងរីកផ្សាយចេញទៅ ដូចតំណក់ប្រេងដែលបុគ្គលដាក់ចូលទៅក្នុងទឹក រមែងរីកផ្សាយចេញទៅដូច្នោះដែរ ។*

*បទថា* **“ទិទិត្តំ”** *ជាដើម មានសេចក្តីដូចពាក្យដែលខ្ញុំពោលទុកក្នុងពេលមុននុ៎ះឯង ។ ពាក្យឯណាដែលគួរពោលក្នុងស្ថានទីមានប្រមាណប៉ុណ្ណេះថា* **“សោ ឯវំ សមាហិតេ ចិត្តេ ។បេ។ យថាកម្មូបគេ សត្តេ បជានាតិ”** *ដូច្នេះ ពាក្យទាំងអស់នោះ ខ្ញុំពោលទុកហើយក្នុងវិសុទ្ធិមគ្គនុ៎ះឯង ។ បណ្ឌិតគប្បីជ្រាបចតុត្ថជ្ឈានចិត្ត ដែលជាបាទនៃវិបស្សនាក្នុងពាក្យថា* **“សោ ឯវំ សមាហិតេ ចិត្តេ”** *នៃតតិយវិជ្ជា គឺវិជ្ជាទី ៣ បានដល់ អាសវក្ខយញ្ញាណ ។ បទថា* **“អាសវានំ ខយញ្ញាណាយ”** *បានដល់ ដើម្បីប្រយោជន៍ដល់ព្រះអរហត្តមគ្គញ្ញាណ ។ ក៏អរហត្តមគ្គដែលញ៉ាំងអាសវក្កិលេសឲ្យវិនាស លោកហៅថា* **“អាសវានំ ខយោ** *= ធម៌ជាទីអស់ទៅនៃអាសវៈទាំងឡាយ”* ។

*ពិតមែនហើយ ឈានក្នុងអរហត្តមគ្គញ្ញាណនោះ លោកហៅថា* **“អាសវានំ ខយោ”** *ព្រោះជាធម៌ដែលរាប់បញ្ចូលក្នុងអរហត្តមគ្គនេះ ។ បទថា* **“ចិត្តំ អភិនិន្នាមេតិ”** *បានដល់ វិបស្សនាចិត្តរបស់គេរមែងឈានទៅខាងមុខ ។*

ក្នុងពាក្យទាំងឡាយ មានពាក្យថា **“សោ ឥទំ ទុក្ខំ”** ជាដើម បណ្ឌិតគប្បីជ្រាបសេចក្ដីយ៉ាងនេះថា ៖

ភិក្ខុរមែងដឹងទូទៅ គឺរមែងចាក់ធ្លុះទុក្ខសច្ច សូម្បីទាំងអស់ តាមសេចក្ដីពិត ដោយការចាក់ធ្លុះលក្ខណៈព្រមទាំងរសថា **“ឯត្តកំ ទុក្ខំ ន ឥតោ ភិយ្យោ** = ទុក្ខមានប្រមាណប៉ុណ្ណេះ មិនក្រៃលែងទៅជាងនេះឡើយ” ។ ក៏ភិក្ខុរមែងដឹងទូទៅ គឺរមែងចាក់ធ្លុះតណ្ហាដែលជាដែនកើតនៃទុក្ខនោះ តាមសេចក្ដីពិត ដោយការចាក់ធ្លុះលក្ខណៈព្រមទាំងរសថា **“អយំ ទុក្ខសមុទយោ** = សភាវធម៌នេះ ជាដែនកើតនៃទុក្ខ” ។ ភិក្ខុរមែងដឹងទូទៅ គឺរមែងចាក់ធ្លុះនូវព្រះនិព្វាន ដែលជាទីដល់នូវសេចក្ដីរំលត់ គឺមិនប្រព្រឹត្តទៅរបស់ធម៌សូម្បីទាំងពីរពួកនោះ តាមសេចក្ដីពិត ដោយការចាក់ធ្លុះលក្ខណៈព្រមទាំងរសថា **“អយំ ទុក្ខនិរោធោ** = សភាវធម៌នេះ ជាទីរលត់ទុក្ខ” ។ ក៏ភិក្ខុរមែងដឹងទូទៅ គឺរមែងចាក់ធ្លុះអរិយមគ្គដែលជាសម្បាបកហេតុនៃព្រះនិព្វាននោះ តាមសេចក្ដីពិត ដោយការចាក់ធ្លុះលក្ខណៈព្រមទាំងរសថា **“អយំ ទុក្ខនិរោធគាមិនីបដិបទា** = សភាវធម៌នេះ ជាខបដិបត្តិឲ្យដល់នូវសេចក្ដីរលត់ទុក្ខ” ។ ព្រះមានព្រះភាគលុះទ្រង់សម្ដែងសច្ចៈទាំងឡាយ ដោយសរុបយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់នឹងសម្ដែងសច្ចៈយ៉ាងបរិយាយ

*ដោយអំណាចនៃកិលេស ទើបព្រះអង្គត្រាស់ពាក្យជាដើមថា* **“ឥមេ អាសវា”** *។*

*បទថា* **“តស្ស ឯវំ ជានតោ ឯវំ បស្សតោ”** *សេចក្តីថា ព្រះភគវារមែងត្រាស់ប្រយោជន៍ដែលដល់ទីបំផុត ព្រមដោយវិបស្សនាដល់ភិក្ខុនោះ អ្នកដឹងយ៉ាងនេះ អ្នកឃើញយ៉ាងនេះ ។ បទថា* **“កាមាសវា”** *បានដល់ (រមែងផុត) អំពីកាមាសវៈ ។ ព្រះមានព្រះភាគទ្រង់សម្តែងខណៈនៃមគ្គ ដោយបទថា* **“វិមុច្ចតិ** *= កំពុងរួចផុត”* *នេះ ។ ទ្រង់សម្តែងខណៈនៃផលដោយបទថា* **“វិមុត្តស្មឹ** *= រួចផុតហើយ”* *នេះ ។ ក៏ចិត្តក្នុងខណៈនៃមគ្គ ឈ្មោះថា* ***កំពុងរួចផុត****, ចិត្តក្នុងខណៈនៃផល ឈ្មោះថា* ***រួចផុតហើយ*** *។ រមែងទ្រង់សម្តែងញាណក្នុងបច្ចវេក្ខណៈ ដោយពាក្យថា* **“វិមុត្តស្មឹ វិមុត្តមីតិ ញាណំ”** *នេះ កាលបើចិត្តរួចផុតហើយ ក៏ដឹងថា ចិត្តរួចផុតហើយ, ទ្រង់សម្តែងភូមិនៃបច្ចវេក្ខណញ្ញាណនោះ ដោយពាក្យថា* **“ខីណា ជាតិ”** *ជាដើម ។ ក៏ព្រះខីណាស្រពនោះ កាលពិចារណាដោយញាណនោះ រមែងដឹងច្បាស់ថា “ជាតិរបស់អញអស់ហើយ” ។ បទថា* **“វុសិតំ”** *បានដល់ នៅហើយ គឺនៅចប់ហើយ គឺថាធ្វើហើយ ប្រព្រឹត្តសម្រេចកិច្ចហើយ អធិប្បាយថា សម្រេចកិច្ចរួចរាល់ហើយ ។ បទថា*

**“ព្រហ្មចរិយំ”** បានដល់ មគ្គព្រហ្មចរិយៈ ។

ក៏ព្រះសេក្ខបុគ្គល ៧ ជំពូក និងកល្យាណបុថុជ្ជន ឈ្មោះថា រមែង នៅប្រព្រឹត្តព្រហ្មចរិយៈ, ព្រះខីណាស្រព ឈ្មោះថា មានការប្រព្រឹត្ត ព្រហ្មចរិយៈចប់ហើយ ព្រោះហេតុដូច្នោះ កាលព្រះខីណាស្រពលោក ពិចារណាការប្រព្រឹត្តព្រហ្មចរិយៈរបស់លោក រមែងដឹងច្បាស់ថា ព្រហ្មចរិយៈ យើងប្រព្រឹត្តចប់ហើយ ។ ពីរបទថា **“កតំ ករណីយំ”** អធិប្បាយថា សូម្បីកិច្ច ១៦ យ៉ាង ក្នុងសច្ចៈទាំង ៤ ដែលព្រះខីណាស្រពធ្វើឲ្យសម្រេច ហើយ ដោយអំណាចនៃបរិញ្ញាកិច្ច បហានកិច្ច សច្ឆិកិរិយាកិច្ច និងភាវេតព្វ-កិច្ច ដោយមគ្គទាំង ៤ ។ ពិតមែនហើយ កល្យាណបុថុជ្ជនជាដើម កំពុង ធ្វើកិច្ចនោះ, តែព្រះខីណាស្រពធ្វើកិច្ចនោះ ស្រេចហើយ ព្រោះហេតុដូច្នោះ កាលព្រះខីណាស្រពពិចារណាករណីយកិច្ចរបស់ខ្លួន លោករមែងដឹងច្បាស់ ថា **“កតំ ករណីយំ** = ករណីកិច្ចយើង ធ្វើស្រេចហើយ” ។ បទថា **“នាបរំ ឥត្ថត្តាយ”** សេចក្តីថា ព្រះខីណាស្រព រមែងដឹងច្បាស់ថា “ឥឡូវ នេះ កិច្ចដោយការចម្រើនមគ្គដទៃទៀត រមែងមិនមាន និងដោយការ ចម្រើនកិច្ចក្នុងទីនេះ ឬដោយការចម្រើនកិច្ច ១៦ យ៉ាង ឬថាដោយការ អស់កិលេសក៏ដោយ”៕

## ពណ៌នាអំពីបុគ្គលមានរាគៈជាដើម

*វិនិច្ឆ័យក្នុងពាក្យទាំងឡាយ មានពាក្យថា* ***"អ្នកមានរាគៈ"*** *ជាដើម ៖*

*បទថា* **"អប្បហីនោ"** *សេចក្តីថា អ្នកប្រហាររាគៈមិនទាន់បាន ដោយវិក្ខម្ភនប្បហាន ឬដោយតទង្គប្បហាន ។*

---

## ពណ៌នាអំពីបុគ្គលបានចេតោសមថៈខាងក្នុង ៗ ល ៗ ជាដើម

*វិនិច្ឆ័យក្នុងពាក្យទាំងឡាយ មានពាក្យថា* **"លាភី ហោតិ"** *ជាដើម ៖*

*បទថា* **"លាភី** *= អ្នកមានប្រក្រតីបាន" គឺបានចំពោះហើយតាំងនៅ ។ ពីរបទថា* **"អជ្ឈត្តំ ចេតោសមថស្ស"** *បានដល់ ចេតោសមថៈដែលកើតឡើងក្នុងចិត្តរបស់ខ្លួន ពោលគឺប្រព្រឹត្តទៅខាងក្នុងរបស់ខ្លួនឯង ។ បទថា* **"អធិបញ្ញាធម្មវិបស្សនាយ"** *សេចក្តីថា ដោយវិបស្សនា គឺអធិបញ្ញាដែលប្រព្រឹត្តទៅដោយអំណាចនៃអនិច្ចលក្ខណៈជាដើម ក្នុងធម្មក្ខន្ធទាំងឡាយ ។ បទថា* **"រូបសហាគតានំ"** *បានដល់ រូបាវចរសមាធិដែលមានរូបនិមិត្តជាអារម្មណ៍ ។ បទថា* **"អរូបសហាគតានំ"** *បានដល់ អរូបសមាបត្តិដែលមិនមានរូបនិមិត្តជាអារម្មណ៍ ។ ក៏ក្នុងអធិការនេះ គប្បីជ្រាបថា បុគ្គលពួកទី ១ បានដល់ បុថុជ្ជនអ្នកមានសមាបត្តិ ៨, បុគ្គលពួកទី ២*

បានដល់ ព្រះអរិយសាវកដែលជាសុក្ខវិបស្សកៈ, បុគ្គលពួកទី ៣ បានដល់ ព្រះអរិយសាវកដែលបានសមាបត្តិ ៨, បុគ្គលពួកទី ៤ បានដល់ លោកិយ-បុថុជ្ជន ។

---

## ពណ៌នាអំពីបុគ្គលទៅតាមក្រសែជាដើម

វិនិច្ឆ័យក្នុងពាក្យថា **"អនុសោតគាមី"** គឺអ្នកទៅតាមក្រសែជាដើម ៖

បទថា **"អនុសោតគាមី"** គប្បីជ្រាបថា បានដល់ បុថុជ្ជនអ្នកទៅតាមក្រសែ គឺវដ្តៈ អ្នកលិចចុះក្នុងក្រសែ គឺវដ្តៈ ។ បទថា **"បដិសោតគាមី"** គឺអ្នកទៅបញ្ច្រាសក្រសែ ។ បទថា **"បដិសោតគាមី"** នេះ ជាឈ្មោះរបស់លោកអ្នកមិនទៅតាមក្រសែ, គឺទៅបញ្ច្រាសក្រសែ ។ បទថា **"បាបញ្ច កម្មំ ន ករោតិ"** បានដល់ អ្នកមិនឈានកន្លងបញ្ញត្តិហើយធ្វើបាប ។ បទថា **"សហាបិ ទុក្ខេន សហាបិ ទោមនស្សេន"** សេចក្តីថា កាលបើកិលេសដែលជាបរិយុដ្ឋាននៅមាន រមែងធ្វើកម្មដ៏លាមក សូម្បីដោយទុក្ខទោមនស្សដែលកើតឡើង ។ បទថា **"បរិបុណ្ណំ"** បានដល់ បណ្តាសិក្ខាទាំង ៣ មិនឆកល្ហក សូម្បីត្រឹមតែមួយ៉ាង ។ បទថា **"បរិសុទ្ធំ"** បានដល់ មិនមានឧបក្កិលេស ។ បទថា **"ព្រហ្មចរិយំ** = ប្រព្រឹត្តធម៌ដែល

ប្រសើរបំផុត ។ ព្រះសោតាបន្ន និងព្រះសកទាគាមី ព្រះមានព្រះភាគ ត្រាស់ទុកដោយវារៈនេះ ។

***សួរថា*** បុគ្គលទាំងនេះ នៅស្រែកយំប្រព្រឹត្តព្រហ្មចរិយៈឬ ?

ឆ្លើយថា ត្រូវហើយ លោកទាំងនេះ ឈ្មោះថា ស្រែកយំប្រព្រឹត្តព្រហ្មចរិយៈ ដោយអំណាចនៃកិលេស ។

សូម្បីភិក្ខុដែលជាបុថុជ្ជនសម្បូណ៌ដោយសីល ព្រះមានព្រះភាគក៏ទ្រង់សង្គ្រោះចូលក្នុងបទថា **"ព្រហ្មចរិយំ"** នេះ ដូចគ្នាដែរ ។ បទថា **"ឋិតត្តោ"** បានដល់ អ្នកមានការតាំងខ្លួននៅបានជាសភាវៈ, ក៏ព្រះអនាគាមីឈ្មោះថា តាំងខ្លួននៅបានជាសភាវៈ ព្រោះលោកជាអ្នកមានចិត្តមិនញាប់ញ័រដោយកាមរាគៈ និងព្យាបាទ, ថែមទាំងជាអ្នកមិនវិលត្រឡប់មកកាន់លោកនេះ ជាធម្មតា ។ បទថា **"តិណ្ណោ"** បានដល់ អ្នកឆ្លងកាត់ក្រសែនៃតណ្ហា ។ បទថា **"បារគតោ"** បានដល់ អ្នកដល់ត្រើយ គឺព្រះនិព្វាន ។ ពីរបទថា **"ថលេ តិដ្ឋតិ"** បានដល់ ឈរនៅលើគោក គឺអរហត្តផល និងសមាបត្តិផល ។ បទថា **"ចេតោវិមុត្តិំ"** បានដល់ ផលសមាធិ ។ បទថា **"បញ្ញាវិមុត្តិំ"** បានដល់ ផលញ្ញាណ ។ ពីរបទថា **"អយំ វុច្ចតិ"** សេចក្តីថា ព្រះខីណាស្រពអ្នកឆ្លងកាត់ក្រសែតណ្ហាទៅហើយ ដល់ត្រើយគឺព្រះនិព្វាន ឈរនៅលើគោក គឺអរហត្តផល និងសមាបត្តិផល លោក

ហៅថា **"ជាព្រាហ្មណ៍"** ។ ក៏ព្រះខីណាស្រពនេះ ឈ្មោះថា ជាព្រាហ្មណ៍ ព្រោះលោកជាអ្នកមានបាបដែលបណ្តេតចេញទៅហើយ ៕

---

## ពណ៌នាអំពីបុគ្គលមានសុតៈតិចជាដើម

វិនិច្ឆ័យក្នុងពាក្យថា **"អ្នកបានស្តាប់តិច"** ជាដើម ៖

បទថា **"អប្បកំ សុតំ ហោតិ"** សេចក្តីថា **សុតៈ** គឺការស្តាប់ ការរៀន ក្នុងនវង្គសត្ថុសាសន៍មានចំណែកខ្លះ គឺមានបន្តិចបន្តួចប៉ុណ្ណោះ ។ បទថា **"ន អត្ថមញ្ញាយ ន ធម្មញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ"** សេចក្តីថា ជាអ្នកចេះបាលី អដ្ឋកថា ហើយបដិបត្តិធម៌ ដែលជាខបដិបត្តិខាងដើម ដ៏សមគួរដល់លោកុត្តរធម៌ រមែងមិនមានដល់គេឡើយ ។ ក្នុងបទទាំងពួង បណ្ឌិតគប្បីជ្រាបសេចក្តីដោយន័យនេះចុះ ៕

.....................................

## ពណ៌នាអំពីបុគ្គលជាសមណៈ មិនកម្រើកញាប់ញ័រជាដើម

វិនិច្ឆ័យក្នុងបទថា **"សមណមចលោ"** ជាដើម ៖

បទថា **"សមណមចលោ"** កែជា **សមណអចលោ** = សមណៈអ្នកមិនកម្រើកញាប់ញ័រ, អក្សរ **ម** ធ្វើការភ្ជាប់បទទុក អធិប្បាយថា បុគ្គលជាសមណៈ ជាអ្នកមិនកម្រើកញាប់ញ័រ គឺជាសមណៈអ្នកមានចិត្ត

*មាំមួន ។ ពីរបទថា* **“អយំ ទុច្ចតិ”** *សេចក្ដីថា ព្រះសោតាបន្ននេះលោកហៅថា* **“សមណមចលោ”** *ព្រោះលោកជាអ្នកតាំងមាំ ដោយសទ្ធា* ***(អចលសទ្ធា)*** *ដែលជាហេតុមាំមួនកើតហើយក្នុងព្រះពុទ្ធសាសនា ។ ចំណែកព្រះសកទាគាមី ព្រះអង្គត្រាស់ថា* **“សមណបទុមោ”** *គឺសមណៈផ្កាឈូកធំ ព្រោះកិលេសដែលជាគ្រឿងគ្រេកអរនៅមាន ។ លោកពោលពាក្យអធិប្បាយទុកថា “ក៏ឈ្មោះថា អត្ថនៃ* ***បទុម*** *សព្ទ ក្នុងពាក្យថា* **‘សមណបទុមោ’** *នេះថា មានសេចក្ដីគ្រេកអរជាអត្ថ (រត្តត្ថោ)”* ។ *ព្រះអនាគាមីព្រះមានព្រះភាគត្រាស់ថា* **“សមណបុណ្ឌរីកោ”** *គឺសមណៈឈូកស ព្រោះលោកមិនមានកិលេសជាគ្រឿងគ្រេកអរ ពោលគឺកាមរាគៈ លោកអធិប្បាយថា “ក៏ឈ្មោះថា អត្ថនៃ* ***បុណ្ឌរីក*** *សព្ទ ក្នុងពាក្យថា* **‘សមណបុណ្ឌរីកោ’** *នេះថា មានសេចក្ដីស្អាតជាអត្ថ” ។ ព្រះខីណាស្រព ព្រះអង្គត្រាស់ហៅឈ្មោះថា* ***សមណសុខុមាល*** *ក្នុងសមណៈទាំងឡាយ ព្រោះភាពជាអ្នកមិនមានកិលេសទាំងឡាយ ដែលធ្វើសេចក្ដីរឹងប៉ឹង ។ ក៏ព្រះខីណាស្រពនេះ ឈ្មោះថា ជាសមណៈអ្នកសុខុមាលដោយពិត ព្រោះអត្ថថា លោកជាអ្នកមានទុក្ខតិច ៕*

ចប់ចតុក្កនិទ្ទេសត្រឹមតែប៉ុណ្ណោះ

## ៥.អដ្ឋកថាបញ្ចកនិទ្ទេស អធិប្បាយបុគ្គល ៥ ជំពូក

*បទថា* **"តត្រ"** *បានដល់ បុគ្គលដែលលោកលើកឡើងសម្តែងទុកក្នុងពេលមុន ដោយន័យជាដើមថា* **"អារព្ភតិ ច វិប្បដិសារី ច ហោតិ"** *នោះ ។ បទថា* **"យ្វាយំ"** *កាត់បទជា* **យោ អយំ** *។* ***អារព្ភ****សព្ទ ក្នុងពាក្យថា* **"អារព្ភតិ"** *នេះ រមែងប្រព្រឹត្តទៅក្នុងអត្ថថា កម្ម គឺការធ្វើ ១, ក្នុងកិរិយា គឺកិច្ច ១, ក្នុងហិង្សនៈ គឺការបៀតបៀន ១ និងក្នុងអាបត្តិវីតិក្កមៈ គឺការកន្លងអាបត្តិ ១ ។*

*ពិតយ៉ាងនេះមែន* ***អារព្ភ****សព្ទនេះ មានមកក្នុងអត្ថថា* **កម្ម** *ក្នុងពាក្យថា* **"យំ កិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ អារព្ភបច្ចយា** *= ទុក្ខយ៉ាងណាមួយកើតឡើង ទុក្ខទាំងអស់ មានកម្មជាបច្ច័យ" ។*

***អារព្ភ****សព្ទនេះ មានមកក្នុងអត្ថថា* **កិរិយា** *ក្នុងពាក្យថា* **"មហាយញ្ញា មហារម្ភា ន តេ ហោន្តិ មហប្ផលា** *= យញ្ញធំ ជាកិរិយាដែលធំ, តែយញ្ញទាំងនោះ មិនមានផលច្រើនឡើយ ។*

***អារព្ភ****សព្ទនេះ មានមកក្នុងអត្ថថា* **ហិឝ្សនៈ** *គឺការបៀតបៀន ក្នុងពាក្យថា* **"សមណគោតមំ ឧទ្ទិស្ស បាណំ អារព្ភតិ** *= រមែងសម្លាប់សត្វឧទ្ទិសចំពោះសមណគោតម" នេះ ។*

***អារម្ភ*** *សព្ទនេះ មានមកក្នុងអត្ថថា* **វីរិយៈ** *គឺសេចក្ដីព្យាយាម ក្នុងពាក្យថា* **“អារម្ភថ និក្កមថ យុញ្ជថ ពុទ្ធសាសនេ** *= អ្នកទាំងឡាយ ចូរប្រារព្ធសេចក្ដីព្យាយាម ចូរព្យាយាម ចូរប្រកបធុរៈក្នុងព្រះពុទ្ធសាសនា”* *នេះ ។*

***អារម្ភ****សព្ទនេះ មានមកក្នុងអត្ថថា* **វិហេឋនៈ** *គឺការផ្ដាច់ទម្លាយ ក្នុងពាក្យថា* **“ពីជគាមភូតគាមសមារម្ភា បដិវិរតោ ហោតិ** *= ភិក្ខុវៀរចាកអំពីការផ្ដាច់ពីជគាម និងភូតគាម”* *នេះ ។*

***អារម្ភ****សព្ទនេះ មានមកក្នុងអត្ថថា* ***អាបត្តិវីតិក្កមៈ*** *គឺការកន្លងអាបត្តិរបស់ភិក្ខុ ក្នុងពាក្យថា* **“អារម្ភតិ វិប្បដិសារី ហោតិ** *= ភិក្ខុត្រូវអាបត្តិរមែងជាអ្នកក្ដៅក្រហាយ”* *នេះ ។ ព្រោះហេតុដូច្នោះ ទើបមានសេចក្ដីក្នុងទីនេះថា “ភិក្ខុរមែងត្រូវអាបត្តិដោយអំណាចនៃការកន្លងអាបត្តិផង និងរមែងជាអ្នកក្ដៅក្រហាយ ព្រោះត្រូវអាបត្តិនោះ ជាបច្ច័យផង” ។*

*បទថា* **“ចេតោវិមុត្តិ”** *បានដល់ ផលសមាធិ ។ បទថា* **“បញ្ញាវិមុត្តិ”** *បានដល់ ផលញ្ញាណ ។ បទថា* **“យថាភូតំ នប្បជានាតិ”** *បានដល់ រមែងមិនដឹងតាមសេចក្ដីពិត ព្រោះខ្លួនជាអ្នកនៅមិនសម្រេចគុណវិសេស ។ បទថា* **“យត្ថស្ស”** *កាត់បទជា* **យត្ថ** + **អស្ស** *= របស់បុគ្គលនោះ មានក្នុងទីណា ។ អធិប្បាយថា អកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ*

ដល់បុគ្គលនេះ រមែងរលត់ទៅដោយមិនសល់ ព្រោះដល់ឋានណា ។

***សួរថា*** ក៏អកុសលធម៌ទាំងនោះ ដល់ឋានអ្វីហើយ ទើបរលត់ទៅដោយមិនមានសល់ ?

*ឆ្លើយថា* ដល់ឋានគឺអរហត្តមគ្គ ទើបរលត់ទៅដោយមិនមានសល់ ។

ក៏អកុសលធម៌ដ៏លាមក របស់លោកអ្នកសម្រេចអរហត្តផលហើយ ឈ្មោះថា រលត់ទៅហើយដោយមិនមានសល់, សូម្បីកាលបើមានសេចក្ដីយ៉ាងនេះ ផលចិត្តប៉ុណ្ណោះ គប្បីជ្រាបថា លោកពោលហើយដោយអំណាចនៃមគ្គក្នុងទីនេះ ។

បទថា **“អារម្ភជា”** បានដល់ កើតអំពីការកន្លងអាបត្តិ ។ បទថា **“វិប្បដិសារជា”** បានដល់ កើតអំពីសេចក្ដីក្ដៅក្រហាយ ។ បទថា **“បវឌ្ឍន្តិ”** បានដល់ អាសវៈទាំងឡាយ រមែងចម្រើនដោយការកើតឡើងញយៗ ។ បទថា **“សាធុ”** បានដល់ សេចក្ដីល្អដែលកើតអំពីការសូមអង្វរករ ។ មានពាក្យអធិប្បាយដែលលោកពោលទុកដូច្នេះថា លោកអ្នកមានអាយុ ក៏កម្មដែលភ្ញាំងភ្ញាត់មាននៅត្រឹមណា សូម្បីចិត្តជាយ៉ាងនោះនៅមាន កាលបើមានសេចក្ដីយ៉ាងនោះ ខ្ញុំសូមអង្វរលោកអ្នកមានអាយុ សូមលោកអ្នកមានអាយុ លះអាសវៈដែលកើតអំពីការត្រូវអាបត្តិ ដោយការសម្ដែងអាបត្តិរបស់ភិក្ខុអ្នកគួរសម្ដែង, ដោយការចេញចាកអាបត្តិ របស់

ភិក្ខុអ្នកគួរចេញចាកអាបត្តិ ដោយការធ្វើឲ្យច្បាស់នូវអាបត្តិរបស់ភិក្ខុអ្នកគួរធ្វើឲ្យច្បាស់ ហើយបន្ទោបង់នូវអាសវៈទាំងឡាយ ដែលកើតអំពីសេចក្ដីក្ដៅក្រហាយ ដោយការពិចារណាដល់ភាវៈដែលខ្លួនតាំងនៅក្នុងចំណែកនៃសេចក្ដីបរិសុទ្ធិ ហើយចូរនាំនូវអាសវៈទាំងឡាយចេញ រួចចូរញុំាងវិបស្សនាចិត្តនិងវិបស្សនាបញ្ញាឲ្យចម្រើនចុះ ។

បទថា **"អមុនា បញ្ចមេន បុគ្គលេន"** បានដល់ បុគ្គលជាព្រះខីណាស្រពជាទី ៥ នោះ ។ ពីរបទថា **"សមសមោ ភវិស្សតិ"** អធិប្បាយថា អ្នកដែលព្រះខីណាស្រពគប្បីឲ្យឱវាទយ៉ាងនេះថា "នឹងជាអ្នកស្មើគ្នាដោយលោកុត្តរគុណនោះឯង" ។ បទថា **"អាបជ្ជតិ ន វិប្បដិសារី ហោតិ"** បានដល់ ភិក្ខុអ្នកត្រូវអាបត្តិ ។ ក៏ដើម្បីនឹងសម្ដែងអាបត្តិនោះ ទើបស្វែងរកភិក្ខុអ្នកចូលចិត្ត (សភាគ) គ្នា ព្រោះហេតុដូច្នោះ ទើបលោកមិនជាអ្នកក្ដៅក្រហាយ ។

អដ្ឋកថាចារ្យបានពោលពាក្យអធិប្បាយទុកក្នុងគម្ពីរអដ្ឋកថា អង្គុត្តរនិកាយថា "លោករមែងជាអ្នកមិនក្ដៅក្រហាយ ព្រោះចេញចាកអាបត្តិបានហើយ" ។ បទថា **"នាបជ្ជតិ វិប្បដិសារី ហោតិ"** បានដល់ ភិក្ខុអ្នកមិនត្រូវអាបត្តិ, តែព្រោះលោកជាអ្នកមិនឈ្លាសក្នុងវិនយបញ្ញត្តិ ជាអ្នកមានការសម្គាល់អនាបត្តិថា ជាអាបត្តិ ទើបមានវិប្បដិសារី គឺក្ដៅក្រហាយ ។

*តែក្នុង* ***អដ្ឋកថា អង្គុត្តរនិកាយ*** *អធិប្បាយថា ភិក្ខុត្រូវអាបត្តិមួយដង ចេញចាកអាបត្តិនោះហើយ ខាងក្រោយមិនត្រូវអាបត្តិអ្វីៗ ឡើយ ក៏ពិតមែនហើយ, ប៉ុន្តែថា លោកក៏មិនអាចដើម្បីនឹងផុតអំពីវិប្បដិសារីបានឡើយ ។ បទថា* **"ន អាបជ្ជតិ ន វិប្បដិសារី ហោតិ"** *សេចក្ដីថា ទាំងមិនត្រូវអាបត្តិ ទាំងមិនក្ដៅក្រហាយ ។*

***សួរថា*** *ក៏បុគ្គលដែលមិនត្រូវអាបត្តិ និងមិនក្ដៅក្រហាយនោះ តើយ៉ាងណា ?*

*ឆ្លើយថា បុគ្គលដែលមានសេចក្ដីព្យាយាមដែលលះបង់ហើយ ។ អធិប្បាយថា ក៏បុគ្គលដែលមានសេចក្ដីព្យាយាមលះបង់ហើយនោះ សូម្បីជាអ្នកមានសីលបរិសុទ្ធ រមែងមិនបំពេញឧបដិបត្តិដោយការគិតថា "ប្រយោជន៍អ្វីចំពោះយើង ដោយការបរិនិព្វានក្នុងពុទ្ធកាលនេះ យើងនឹងបរិនិព្វានក្នុងសម័យនៃព្រះមេត្តេយ្យសម្មាសម្ពុទ្ធជាម្ចាស់ក្នុងអនាគតកាលវិញ" ។ សូម្បីអ្នកដែលនរណាៗ គប្បីឲ្យឱវាទថា "អ្នកមានអាយុ ជាអ្នកប្រមាទដើម្បីប្រយោជន៍អ្វី ?" ក៏ឈ្មោះថា គតិរបស់បុថុជ្ជនជារបស់មិនពិតប្រាកដឡើយ, លោកអ្នកមានអាយុ តើនរណានឹងអាចដឹងថា បុគ្គលគប្បីបានឬមិនបាននូវភាពជាអ្នកមានមុខ ចំពោះព្រះមេត្តេយ្យសម្មាសម្ពុទ្ធជាម្ចាស់ ព្រោះហេតុដូច្នោះ ចូរលោកចម្រើនវិបស្សនា ដើម្បីដល់ព្រះអរហត្តចុះ ។*

ពាក្យដ៏សេស បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងបទទាំងពួងនុ៎ះឯង ៕

---

## ពណ៌នាអំពីបុគ្គលឱ្យហើយមើលងាយជាដើម

ភិក្ខុមួយរូបមានបុណ្យច្រើន រមែងជាអ្នកមានប្រក្រតីបានបច្ច័យ ៤ មានចីវរប្បច្ច័យជាដើមហើយ រមែងសួរដោយអើពើ នឹងភិក្ខុរូបដទៃដែលមានបុណ្យតិច, លោកនោះ កាលបើភិក្ខុដែលមានបុណ្យច្រើនសួរហើយញយៗ ទើបទទួលបច្ច័យទាំងឡាយ មានចីវរប្បច្ច័យជាដើមទៅ ពេលនោះភិក្ខុអ្នកមានបុណ្យច្រើន ក្រោធនឹងភិក្ខុអ្នកមានបុណ្យតិច នោះបន្តិច, ប្រាថ្នានឹងឲ្យលោកកើតសេចក្តីអៀនប្រៀន ទើបពោលថា "ភិក្ខុនេះ មិនបានបច្ច័យទាំងឡាយ មានចីវរប្បច្ច័យជាដើម តាមធម្មតារបស់ខ្លួនទេ លុះត្រាតែអាស្រ័យយើងទើបបាន" ។ បុគ្គលនេះ ទើបឈ្មោះថា ***ឱ្យហើយមើលងាយ*** ។

ក៏បុគ្គលម្នាក់ កាលអាស្រ័យនៅនឹងបុគ្គលម្នាក់ ២-៣ ឆ្នាំ តែងធ្វើសេចក្តីគោរពក្នុងបុគ្គលនោះ តាំងពីកាលមុន, តមកខាងក្រោយ កាលបើវេលាកន្លងទៅៗ ក៏មិនធ្វើសេចក្តីគោរពកោតក្រែង គឺមិនក្រោកឡើងអំពីអាសនៈខ្លះ មិនទៅកាន់ទីបម្រើខ្លះ បុគ្គលនេះ ឈ្មោះថា រមែងមើលងាយដោយការនៅរួមគ្នា ។

បទថា **"អារធយន្ត្រមុខោ"** បានដល់ អ្នកជឿងាយតាំងពីដើម អធិប្បាយថា អ្នកមានសេចក្ដីសម្គាល់ដែលតាំងទុកហើយ ក្នុងពាក្យដំបូងប៉ុណ្ណោះ ។ ពីរបទថា **"អធិមុច្ចិតា ហោតិ"** បានដល់ ភាពជាអ្នកមានសទ្ធា ។ ក្នុងពាក្យថា **"អធិមុច្ចិតា ហោតិ"** នេះ មានន័យដូចតទៅ ៖

បុគ្គលម្នាក់ពោលដល់ភិក្ខុអ្នកមានសមណសារុប្បនោះឯងថា "ភិក្ខុនេះ មិនមានសមណសារុប្បទេ" អ្នកនោះ លុះស្ដាប់ពាក្យនោះហើយជឿយ៉ាងមាំមួន គឺជឿដល់ទីបំផុត សូម្បីភិក្ខុអ្នកចូលចិត្តគ្នារូបដទៃពោលថា "ភិក្ខុនេះ មានសមណសារុប្ប" ក៏មិនជឿស្ដាប់ពាក្យរបស់ភិក្ខុនោះឡើយ, គេពោលអះអាងថា "ភិក្ខុរូបនោះ ប្រាប់ខ្ញុំថា 'ភិក្ខុរូបនេះ មិនមានសមណសារុប្បទេ' ទើបជឿពាក្យសម្ដីរបស់ភិក្ខុរូបមុនប៉ុណ្ណោះ" ។ សូម្បីបុគ្គលដទៃទៀត រមែងពោលដល់ភិក្ខុអ្នកមានសីលថា ជាអ្នកមិនមានសីល លោកជឿពាក្យរបស់អ្នកនោះហើយ សូម្បីភិក្ខុដទៃទៀត ពោលថា "ភិក្ខុនេះ មិនមានសមណសារុប្ប មិនគួរចូលទៅកាន់សំណាក់របស់លោក" ដូច្នេះ លោកមិនជឿកាន់យកពាក្យរបស់អ្នកនោះឡើយ រមែងជឿស្ដាប់ពាក្យសម្ដីរបស់ភិក្ខុមុនប៉ុណ្ណោះ ។ បុគ្គលដទៃទៀត រមែងប្រកាន់ពាក្យសម្ដីដែលអ្នកដទៃពោលដល់សេចក្ដីល្អខ្លះ សេចក្ដីអាក្រក់ខ្លះនោះឯង ។ សូម្បីបុគ្គលនេះ ឈ្មោះថា អ្នកមានសេចក្ដីជឿកាន់យកដែលតាំងទុក អធិប្បាយថា អ្នក

មានសេចក្ដីជឿដែលតាំងទុកនេះ ស្ដាប់ពាក្យណាៗ រមែងជាអ្នកមានសេចក្ដីជឿកាន់យកដែលតាំងទុកក្នុងពាក្យនោះៗ ។

បទថា **"លោលោ"** សេចក្ដីថា ឈ្មោះថា ជាអ្នកស្មាក់ស្មើរ គឺអ្នកញញើតអឹមអៀម ព្រោះភាពនៃខ្លួនជាអ្នកញញើតអឹមអៀម ដោយភាពជាអ្នកមិនមានសទ្ធាជាដើម ព្រោះហេតុមានសទ្ធាជាដើម ជាធម្មជាតិតាំងនៅរយៈកាលបន្តិចបន្តួច ។ បទថា **"ឥត្តរសទ្ធោ"** បានដល់ អ្នកមានសទ្ធាតិច គឺមានសទ្ធាមិនបរិបូណ៌ ។ សូម្បីក្នុងពាក្យដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។ បុគ្គលដែលមានសទ្ធាដែលមិនពិតប្រាកដនេះ រមែងប្រព្រឹត្តទៅដោយអំណាចនៃការសេពគប់ញយៗ ក្នុងអធិការនេះ ។ ឈ្មោះថា សេចក្ដីស្រឡាញ់ នឹងជាធម្មជាតិដែលកើតអំពីសទ្ធាក្ដី អំពីតណ្ហាក្ដី ក៏គួរ ។ សេចក្ដីជ្រះថ្លា ក៏គឺការជ្រះថ្លាដែលកើតអំពីសទ្ធានោះឯង ។ បទថា **"ឯវំ បុគ្គលោ លោលោ ហោតិ"** សេចក្ដីថា បុគ្គលនេះ ឈ្មោះថា អ្នកមិននឹងធឹង ព្រោះភាពនៃខ្លួនជាអ្នកមានសទ្ធាបន្តិចបន្តួចជាដើម អធិប្បាយថា បុគ្គលដែលមិននៅនឹងនួននេះ ជាអ្នកមានឋានៈដែលមិនតាំងមាំ ដូចសំពត់ដែលជ្រលក់ដោយល្មៀត, ដូចបង្គោលដែលបោះទុកក្នុងគំនរអង្កាម, ដូចផ្លែឃ្លោកដែលគេដាក់ទុកលើខ្នងសេះ, រមែងជ្រះថ្លាដោយកាលមួយភ្លែត, រមែងក្រោធដោយកាលមួយភ្លែត, សំដៅសេចក្ដីថា មួយភ្លែតស្រឡាញ់

*មួយភ្លែតស្អប់ ។ បទថា* **“មន្ទា មោមូហា”** *សេចក្ដីថា បុគ្គលឈ្មោះថា* ***ល្ងង់*** *ព្រោះមិនមានញាណ (អញ្ញាណ), ឈ្មោះថា* ***ល្ងង់*** *ព្រោះភាពជាអ្នកមិនឈ្លាស អធិប្បាយថា អ្នកវង្វេងវង្វាន់ច្រើន ៕*

---

# ពណ៌នាអំពីបុគ្គល
# ប្រៀបដូចអ្នកចម្បាំងជាអាជីព ៥ ជំពូក

*វិនិច្ឆ័យក្នុងបុគ្គលដែលប្រៀបដូចអ្នកចម្បាំងជាអាជីព ៖*

*បទថា* **“យោធាជីវា”** *បានដល់ បុគ្គលអ្នកចូលទៅអាស្រ័យ ការច្បាំងចិញ្ចឹមជីវិត ហើយរស់នៅ ។ បទថា* **“រជគ្គំ”** *បានដល់ គំនរធូលីដែលហុយឡើងអំពីផែនដី ដែលដំរីសេះជាដើម ជាន់ញាំញី ។ បទថា* **“ន សន្ថម្ភតិ”** *បានដល់ កាលបើរឹងប៉ឹងហើយរមែងមិនអាច ដើម្បីនឹងតាំងមាំបាន ។ ពីរបទថា* **“សហតិ រជគ្គំ”** *សេចក្ដីថា អ្នកចម្បាំងពួកខ្លះ សូម្បីឃើញគំនរធូលីដែលហុយឡើងទៅអំពីផែនដី ដែលដំរីសេះជាដើមជាន់ញាំញីនៅអត់ធន់បាន ។ បទថា* **“ធជគ្គំ”** *បានដល់ កំពូលទង់ទាំងឡាយ ដែលគេលើកឡើងលើខ្នង ដំរី សេះ ឬរថ ។ បទថា* **“ឧស្សារណំ”** *បានដល់ សំឡេងហ៊ោធំរបស់ដំរី សេះ រថ និងពលនិកាយ ។ បទថា* **“សម្បហារេ”** *បានដល់ កាលបើការប្រហារ សូម្បីមានប្រមាណតិចដែលមកដល់ហើយ ។*

បទថា **"ហញ្ញតិ"** បានដល់ រមែងក្តៅក្រហាយ គឺដល់ការរំដើបរំជួល ។ បទថា **"ព្យាបជ្ជតិ"** បានដល់ រមែងដល់ការវិបត្តិ គឺរមែងលះភាពជាប្រក្រតី ។ ពីរបទថា **"សហតិ សម្បហារំ"** សេចក្តីថា អ្នកចម្បាំងអាជីពនោះ សូម្បីត្រូវប្រហារពីរបីដង នៅអត់ធន់ គឺនៅអត់ធន់បាន ។ ពីរបទថា **"តះមេវ សង្គាមសីសំ"** បានដល់ ទីនោះៗ ឯង ជាទីតាំងបន្ទាយប្រយុទ្ធដែលមានជ័យ ។ បទថា **"អជ្ឈាវសតិ"** បានដល់ រមែងនៅគ្រប់គ្រងប្រមាណ ៧ ថ្ងៃ ។ ***សួរថា*** ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះត្រូវការរក្សាខេត្តប្រហាររបស់ជនដែលបានប្រហារទៅហើយ ដើម្បីជ្រាបសេចក្តីផ្សេងគ្នារបស់កម្មដែលជនធ្វើហើយ ទើបឲ្យឋានន្តរ និងដើម្បីត្រូវការសោយសេចក្តីសុខ គឺភាពជាធំ ។ ឥឡូវនេះ កិច្ចដោយភាពជាអ្នកចម្បាំងអាជីពរបស់ព្រះសាស្តាមិនមានទេ, តែដើម្បីនឹងសម្តែងបុគ្គល ៥ ជំពូក ក្នុងព្រះសាសនានេះ ទើបព្រះអង្គត្រាស់ពាក្យថា **"ឯវមេវ"** ជាដើម ។

បណ្តាបទទាំងនោះ បទថា **"សំសីទតិ"** បានដល់ លិចនៅ គឺរមែងធ្លាក់ទៅក្នុងមិច្ឆាវិតក្កៈ ។ បទថា **"ន សក្កោ ព្រហ្មចរិយំ សន្តានេតុំ"** សេចក្តីថា រមែងមិនអាចដើម្បីរក្សាការប្រព្រឹត្តព្រហ្មចរិយៈឲ្យជាប់រហូត តទៅបាន ។ ពីរបទថា **"សិក្ខាទុព្វល្យំ អាវិកត្វា"** បានដល់ ប្រកាសភាពនៃសិក្ខាជាសភាពមានកម្លាំងខ្សោយ ។ បទថា **"កិមស្ស រជគ្គស្មឹ"**

សេចក្តីថា លោកពោលថា ឈ្មោះថា ចុងធូលីរបស់បុគ្គលនោះ ដោយយ៉ាងណា ? ។ បទថា **"អភិរូបា** = រូបស្អាត ។ បទថា **"ទស្សនីយា"** បានដល់ គួរនឹងមើល ។ បទថា **"បាសាទិកា"** បានដល់ នាំសេចក្តីជ្រះថ្លាមកកាន់ចិត្តដោយការឃើញនោះឯង ។ បទថា **"បរមាយ"** បានដល់ ខ្ពស់បំផុត ។ បទថា **"វណ្ណបោក្ខរតាយ"** បានដល់ ដោយវណ្ណៈនៃសរីរៈ និងសណ្ឋាននៃអវយវៈ ។ បទថា **"ឱសហតិ** * **"** បានដល់ រមែងអត់ធន់ ។ បទថា **"ឧល្លបតិ** = រមែងពោល" ។ បទថា **"ឧជ្ជគ្ឃតិ"** បានដល់ ទះដៃហើយសើចចំអក ។ បទថា **"ឧប្បណ្ឌេតិ"** បានដល់ រមែងពោលពាក្យចំអកចំអន់ ។ បទថា **"អភិនិសីទតិ"** បានដល់ អ្នកឈ្នះហើយអង្គុយក្នុងសម្នាក់ ឬក្នុងអាស្រមជាមួយគ្នា ។ សូម្បីក្នុងបទទី ២ ក៏មានន័យដូចគ្នានេះដែរ ។ បទថា **"អជ្ឈោត្ថរតិ"** បានដល់ រមែងក្រាលលាត ។ ពីរបទថា **"វិនិវេឋេត្វា** * **វិនិមោចេត្វា"** បានដល់ ផ្លាស់ប្ដូរដោះចេញ និងយកដៃរបស់គេចេញអំពីទីដែលមាតុគ្រាមចាប់ហើយ ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយស្រួលទាំងអស់ ៕

---

* បាលីថា ឱសហតិ ។

* វិនិវេថេត្វា ។

## ពណ៌នាអំពីភិក្ខុកាន់បិណ្ឌបាតជាវត្ត ៥ ជំពូក

*វិនិច្ឆ័យក្នុងភិក្ខុអ្នកកាន់បិណ្ឌបាតជាវត្ត គឺអ្នកកាន់ការឆាន់ភត្តាហារដែលបានមកអំពីការបិណ្ឌបាត ៖*

*ពីរបទថា* **“មន្ទត្តា មោមូហត្តា”** *បានដល់ រមែងមិនស្គាល់ការសមាទាន និងមិនស្គាល់អានិសង្ស ។ អធិប្បាយថា ក៏ភិក្ខុអ្នកកាន់បិណ្ឌបាតជាវត្តដោយការមិនចេះនោះឯង ព្រោះភាពជាមនុស្សល្ងង់ ។ ពីរបទថា* **“បាបិច្ឆោ ឥច្ឆា បកតោ”** *សេចក្តីថា ជនទាំងឡាយនឹងធ្វើសក្ការៈដោយបច្ច័យបួន ដល់យើងអ្នកកាន់បិណ្ឌបាតជាវត្ត ដោយគិតថា* **“សតោ អយំ បិណ្ឌបាតិកោ** *= ភិក្ខុនេះ ជាអ្នកកាន់បិណ្ឌបាតជាវត្ត” ។ ភិក្ខុអ្នកតាំងអាជីវៈនៅដោយសេចក្តីប្រាថ្នាដ៏លាមកយ៉ាងនេះថា ៖*

*“ក៏ជនទាំងឡាយនឹងលើកសរសើរយើង ដោយគុណទាំងឡាយថា ភិក្ខុនេះ ជាអ្នកមានសេចក្តីខ្មាស មានសេចក្តីប្រាថ្នាតិចជាដើម” និងត្រូវសេចក្តីប្រាថ្នាដ៏លាមកនោះ គ្របសង្កត់ហើយ ទើបកាន់បិណ្ឌបាតជាវត្ត ។ ក៏ភិក្ខុនោះរមែងត្រាច់ទៅបិណ្ឌបាត ដោយភាពជាអ្នកឆ្កួត ឈ្មោះថា អ្នកកាន់បិណ្ឌបាតជាវត្ត ព្រោះឆ្កួត គឺសេចក្តីរវើរវាយរាយមាយនៃចិត្ត ។ បទថា* **“ខណ្ឌិតំ”** *សេចក្តីថា ភិក្ខុពិចារណាថា “ធម្មតាបិណ្ឌបាតិកធុតង្គ*

នេះ ព្រះពុទ្ធជាម្ចាស់ទាំងឡាយ និងសាវករបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ពណ៌នាគុណ គឺសរសើរទុក” ដូច្នេះ ហើយទើបកាន់បិណ្ឌបាតជាវត្ត ។ ក្នុងពាក្យថា **“អបរិច្ចិំ ឯទ និសព្វាយ”** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ គឺភិក្ខុអ្នកកាន់បិណ្ឌបាតជាវត្តគិតថា “យើងនឹងជាអ្នកប្រាថ្នាតិច, ព្រោះហេតុនេះ អង្គនៃបិណ្ឌបាតិកធុតង្គរបស់យើងនេះ នឹងប្រព្រឹត្តទៅដើម្បីភាពជាអ្នកប្រាថ្នាតិច, យើងនឹងជាអ្នកសន្តោស, ព្រោះហេតុនេះ អង្គនៃបិណ្ឌបាតិកធុតង្គរបស់យើងនេះ នឹងប្រព្រឹត្តទៅដើម្បីសេចក្តីសន្តោស, យើងនឹងជាអ្នកជុសខាត់កិលេសទាំងឡាយ, ព្រោះហេតុនេះ អង្គនៃបិណ្ឌបាតិកធុតង្គរបស់យើងនេះ នឹងប្រព្រឹត្តទៅដើម្បីសេចក្តីជុសខាត់កិលេស” ។ បទថា **“ឥទមត្ថិតំ”** សេចក្តីថា អាស្រ័យសេចក្តីត្រូវការដោយឧបដិបត្តិដែលស្អាតនេះ ឬអាស្រ័យសេចក្តីត្រូវការ ដោយហេតុត្រឹមតែបិណ្ឌបាតនេះ អធិប្បាយថា អាស្រ័យភាវៈ គឺការញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយវត្ថុយ៉ាងណាមួយតាមតែនឹងបាន ។ បទថា **“អគ្គោ”** បានដល់ អ្នកចម្រើនបំផុត ។ ពាក្យដ៏សេស ជាវេវចនៈរបស់ពាក្យថា **“អគ្គោ”** នេះ ។ បទថា **“គាវា ខីរំ”** សេចក្តីថា ធម្មតាទឹកដោះ រមែងកើតអំពីគោ វៀរមេគោចេញហើយ ក៏មិនមាន ។ សូម្បីក្នុងពាក្យថា **“ខីរម្ហា ទធិ”** ជាដើម ក៏មានន័យដូចគ្នានេះដែរ ។ បទថា **“ឯវមេវ”** អធិប្បាយថា ទឹកដោះប្រភេទថ្លាលើសជាងបញ្ចគោរសទាំងនេះ យ៉ាងណា,

*បណ្តាភិក្ខុអ្នកកាន់ការបិណ្ឌបាតជាវត្តទាំង ៥ ជំពូកនេះ ភិក្ខុណាអាស្រ័យភាពជាអ្នកប្រាថ្នាតិចជាដើម ហើយកាន់បិណ្ឌបាតជាវត្ត ភិក្ខុនេះ ជាអ្នកលើស ជាអ្នកចម្រើនបំផុត ជាប្រមុខ ជាអ្នកខ្ពស់បំផុត និងប្រសើរបំផុត ក្នុងភិក្ខុអ្នកកាន់បិណ្ឌបាតជាវត្តទាំងនោះ ដូច្នោះដែរ ។*

*ក៏បណ្តាភិក្ខុអ្នកកាន់បិណ្ឌបាតជាវត្ត ៥ ជំពូកពួកនេះ ដែលកាន់បិណ្ឌបាតជាវត្តពិតប្រាកដ មាន ២ ជំពូក, ដែលមិនកាន់ មាន ៣ ជំពូក; បណ្ឌិតគប្បីជ្រាបជន ៣ ជំពូកនេះថា ជាអ្នកកាន់បិណ្ឌបាតជាវត្តត្រឹមតែឈ្មោះប៉ុណ្ណោះ ។*

## ពណ៌នាអំពីភិក្ខុកាន់ការហាមភត្ត ដែលគេនាំមកប្រគេនខាងក្រោយជាវត្តជាដើម

*សូម្បីភិក្ខុអ្នកកាន់ការហាមភត្ត ដែលគេនាំមកប្រគេនខាងក្រោយជាវត្តជាដើម ក៏មានន័យដូចគ្នានេះដែរ ។*

ចប់អដ្ឋកថាបញ្ហកនិទ្ទេស

ត្រឹមតែប៉ុណ្ណោះ

## ៦.អដ្ឋកថាឆក្កនិទ្ទេស អធិប្បាយបុគ្គល ៦ ជំពូក

បទថា **"តត្រ"** បានដល់ បណ្ដាបុគ្គលទាំងនោះ ។ បទថា **"សម្មា-សម្ពុទ្ធោ តេន ទដ្ឋព្វោ"** សេចក្ដីថា បុគ្គលទាំងនោះ បណ្ឌិតគប្បីជ្រាបថា ជាព្រះសព្វញ្ញុពុទ្ធ ព្រោះព្រះសព្វញ្ញុតញ្ញាណនោះ គឺព្រះអង្គឲ្យកើតឡើង ដោយព្រះអង្គឯង មិនមាននរណាៗ ជាអាចារ្យ នេះចាត់ជាពួកទី ១ ។ សូម្បីក្នុងពាក្យថា **"បច្ចេកសម្ពុទ្ធោ តេន"** ជាដើម បណ្ឌិតគប្បីជ្រាប វិនិច្ឆ័យដូចតទៅ ៖

បុគ្គលទាំងនោះ បណ្ឌិតគប្បីជ្រាបថា ជាព្រះបច្ចេកសម្ពុទ្ធ ព្រោះ បច្ចេកសម្ពោធិញ្ញាណនោះ នេះចាត់ជាពួកទី ២ ។ បុគ្គលទាំងនោះ បណ្ឌិត គប្បីជ្រាបថា ***ជាព្រះអគ្គសាវក គឺព្រះសារីបុត្រ និងព្រះមោគ្គល្លាន*** ព្រោះ សាវកបារមីញាណនោះ នេះចាត់ជាពួកទី ៣ ។ បុគ្គលទាំងនោះ បណ្ឌិត គប្បីយល់ឃើញថា ព្រះអរហន្តទាំងឡាយ ព្រោះការធ្វើនូវទីបំផុតនៃទុក្ខ នោះ នេះចាត់ជាពួកទី ៤ ។ បុគ្គលទាំងនោះ បណ្ឌិតគប្បីយល់ឃើញថា ជាព្រះអនាគាមី ព្រោះមិនមកកាន់លោកនេះទៀត នេះចាត់ជាពួកទី ៥ ។ បុគ្គលទាំងនោះ បណ្ឌិតគប្បីយល់ឃើញថា ***ជាព្រះសោតាបន្ន និងព្រះ សកទាគាមី*** ព្រោះមកកាន់លោកនេះ នេះចាត់ជាពួកទី ៦ ។ រួមជា ៦ ជំពូកដូច្នេះឯង ៕

ចប់អដ្ឋកថាឆក្កនិទ្ទេស ត្រឹមតែប៉ុណ្ណោះ

## ៧.អដ្ឋកថាសត្តកនិទ្ទេស អធិប្បាយបុគ្គល ៧ ជំពូក

បទថា **“សកឹ និមុគ្គោ”** សេចក្តីថា បុគ្គលខ្លះលិចចុះហើយអស់មួយវារៈ ។ បទថា **“ឯកន្តកាឡកេហិ”** បានដល់ ដោយធម៌ គឺនិយតមិច្ឆាទិដ្ឋិទាំងឡាយ គឺនត្ថិកវាទ និងអកិរិយវាទដែលខ្មៅម្យ៉ាងប៉ុណ្ណោះ ។ បទថា **“ឯវំ បុគ្គលោ”** សេចក្តីថា បុគ្គលលិចចុះអស់មួយវារៈដោយហេតុនេះ គឺដោយនិយតមិច្ឆាទិដ្ឋិនេះហើយ ក៏លិចទៅយ៉ាងនុ៎ះឯង ។ អាចារ្យពួកខ្លះពោលថា “ក៏ឈ្មោះថា ចេញចាកភពរបស់និយតមិច្ឆាទិដ្ឋិនោះ រមែងមិនមាន” អណ្តាតភ្លើង គឺសត្វនរកទាំងឡាយមាននៅខាងក្រោមនោះឯង ដូចសាស្តាទាំងឡាយ មានមក្ខលិគោសាលជាដើម ។ បទថា **“សាហុ សទ្ធា កុសលេសុ ធម្មេសុ”** សេចក្តីថា រមែងងើបឡើងក្នុងកុសលធម៌ទាំងឡាយ ដោយគិតថា “ឈ្មោះថា សទ្ធា ជាលទ្ធិដែលល្អ” ដូច្នេះ បុគ្គលនោះ ឈ្មោះថា រមែងងើបឡើងដោយកុសលធម៌មានប្រមាណប៉ុណ្ណោះនោះឯង ។ សូម្បីក្នុងពាក្យថា **“សាធុ ហិរិ** = សេចក្តីខ្មាសជាលទ្ធិដែលល្អ” ជាដើម ក៏មានន័យដូចគ្នានេះដែរ ។ បទថា **“ហាយតិ៎ះមេវ”** សេចក្តីថា អ្នកនោះរមែងស្រៀមម្យ៉ាងប៉ុណ្ណោះ ដូចទឹកដែលចាក់ចុះក្នុងភក់ ។ បទថា **“ឯវំ បុគ្គលោ”** សេចក្តីថា ក៏និយតមិច្ឆាទិដ្ឋិបុគ្គលនោះ ងើបឡើង

អស់មួយវារៈ ដោយអំណាចនៃសទ្ធាជាដើមទាំងនេះថា **“ឯខំ សាហុ សទ្ធា** = សទ្ធាជាសេចក្ដីល្អយ៉ាងនេះ” ក៏នឹងលិចចុះ ព្រោះសេចក្ដីសាបសូន្យចាកធម៌ មានសទ្ធាជាដើមនោះឯង ដូចព្រះទេវទត្តជាដើម ។

សេចក្ដីសង្ខេបថា ព្រះទេវទត្តសូម្បីធ្វើសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើតហើយ ក៏សាបសូន្យចាកគុណវិសេសទាំងនោះ ព្រោះភាពជាបដិបក្ខចំពោះព្រះពុទ្ធជាម្ចាស់ទៀត ទើបធ្វើលោហិតុប្បាទកម្ម និងសង្ឃភេទកម្ម, កាលបើកាយបែកធ្លាយ ទើបកើតក្នុងនរកដោយវារៈចិត្តទី ២ ព្រះកោកាលិកៈ ដាក់ទោសព្រះអគ្គសាវកទាំងពីរ ទើបកើតក្នុងបទុមនរក ។

បទថា **“នេវ ហាយតិ នោ វឌ្ឍតិ”** សេចក្ដីថា ក្នុងវេលាដែលមិនសាបសូន្យក្ដី ក្នុងវេលាដែលសាបសូន្យក្ដី សទ្ធាក៏មិនថយចុះ និងមិនចម្រើន ។ ក៏ហេតុទាំងពីរនោះ បណ្ឌិតគប្បីសម្ដែងដោយអាគារិកបុគ្គល គឺគ្រហស្ថ និងអនាគារិកបុគ្គល គឺបព្វជិត សូម្បីទាំងពីរជាឧទាហរណ៍ ៖

ក៏គ្រហស្ថខ្លះ ក្នុងវេលាដែលខ្លួនមិនសាបសូន្យចាកសទ្ធា ទើបឲ្យចាត់ចែងបក្ខិកភត្ត ឬសលាកភត្ត ឬក៏សំពត់ងូតទឹកភ្លៀង ។ គ្រហស្ថនោះក្នុងកាលដែលសាបសូន្យចាកសទ្ធាខាងក្រោយ រមែងនៅត្រឹមតែបក្ខិកភត្តជាដើម ឲ្យប្រព្រឹត្តទៅ សទ្ធាក៏មិនចម្រើន ។

ចំណែកបព្វជិត ក្នុងវេលាដែលមិនសាបសូន្យខាងដើម រមែងរៀន

យកខទ្មេស បុធុតគ្គ សូម្បីវេលាដែលសាបសូន្យចាកការដល់ព្រមដោយបញ្ញា ពលៈ និងវីរិយៈ ក៏ធ្វើឲ្យក្រែលែងជាងនោះមិនបាន ។ បទថា **“ឯខំ បុគ្គលោ”** សេចក្តីថា បុគ្គលយ៉ាងនេះ ឈ្មោះថា ងើបឡើងហើយឈប់នៅ ព្រោះការតាំងនៅនៃធម៌ទាំងឡាយ មានសទ្ធាជាដើម ។

បទថា **“ឧម្មុជ្ជិត្វា ខិបស្សតិ ខិលោកេតិ”** សេចក្តីថា ព្រះសោតាបន្ន ឈ្មោះថា ក្រឡេកមើលមគ្គដែលជាទីទៅខាងលើ ឬទិសដែលគួរនឹងទៅ ព្រោះការងើបឡើងអំពីអន្លង់ទឹក គឺវដ្តៈ ។ បទថា **“ឧម្មុជ្ជិត្វា បតរតិ”** សេចក្តីថា ព្រះសកទាគាមីបុគ្គលងើបឡើងអំពីអន្លង់ទឹក គឺវដ្តៈហើយជាអ្នកឈានទៅខាងមុខ ចំពោះទិសដែលនឹងគប្បីទៅ ព្រោះភាពនៃខ្លួនមានកិលេសស្តួចស្តើង ទើបឈ្មោះថា រមែងឆ្លងផុតទៅបាន ។ បទថា **“បតិគាធប្បត្តោ ហោតិ”** សេចក្តីថា ព្រះអនាគាមីបុគ្គលងើបឡើងអំពីអន្លង់ គឺវដ្តៈហើយ ក្រឡេកមើលទិសដែលនឹងទៅហើយ ក៏ឆ្លងទៅដល់ទីកន្លែងមួយដែលជាទីពឹង ទើបឈប់នៅ រមែងមិនត្រឡប់មក ។ បទថា **“តិណ្ណោ បារង្គតោ ថលេ តិដ្ឋតិ”** សេចក្តីថា ព្រះខីណាស្រពលោកឆ្លងអន្លង់ទឹក គឺកិលេសទាំងអស់ ដល់ច្រាំងនោះហើយ រមែងជាអ្នកឈ្មោះថា ឈរនៅលើគោក គឺព្រះនិព្វាន ។ ក៏បុគ្គល ៧ ជំពូកនេះ លោកសម្តែងការឧបមាទុក ដោយអន្លង់ទឹកជាឧទាហរណ៍ដូច្នេះ ៖

បានឮថា នាយជន្សពាណិជ គឺអ្នកជំនួញ ៧ នាក់ ដើរផ្លូវឆ្ងាយដល់ស្ទឹង (ទឹក) ពេញច្រាំងក្នុងចន្លោះផ្លូវ បណ្ដាអ្នកជំនួញទាំងនោះ អ្នកជំនួញទី ១ ជាអ្នកខ្លាចទឹក សាកល្បងចុះមុនហើយ ក៏បោះពួយចុះអំពីកំពង់ទឹកជាទីឆ្លងកាត់នោះឯង មិនអាចនឹងងើបឡើងទៀត ទើបគេធ្លាក់ទៅជាចំណីរបស់ត្រី និងអណ្ដើកក្នុងស្ទឹងនោះឯង ។ អ្នកជំនួញទី ២ បោះពួយចុះហើយ ក្នុងទីជាទីឆ្លងកាត់ ទើបឡើងមកម្ដង ហើយក៏លិចចុះទៀត មិនអាចដើម្បីនឹងងើបឡើងបាន ទើបគេជាចំណីរបស់ត្រី និងអណ្ដើកក្នុងស្ទឹងនោះដូចគ្នា ។ អ្នកជំនួញទី ៣ បោះពួយចុះ ហើយងើបឡើងឈប់នៅត្រង់កណ្ដាលស្ទឹងមិនអាចដើម្បីនឹងទៅត្រើយនោះ មិនអាចនឹងមកច្រាំងនេះបានទេ ។ អ្នកជំនួញទី ៤ បោះពួយចុះហើយងើបឡើង ឈប់នៅ ក្រឡេកមើលកំពង់ទឹកជាទីឆ្លងកាត់ទៅ ។ អ្នកជំនួញទី ៥ បោះពួយចុះហើយងើបឡើងឈប់ ក្រឡេកមើលកំពង់ទឹកជាទីឆ្លងកាត់ហើយទើបឆ្លងកាត់ទៅ ។ អ្នកជំនួញទី ៦ បោះពួយចុះហើយ ងើបឡើងឆ្លងកាត់ទៅដល់ត្រើយនោះ ទើបឈប់នៅក្នុងទឹកត្រឹមចង្កេះ ។ អ្នកជំនួញទី ៧ បោះពួយចុះហើយ ។ ល ។ ដល់ច្រាំងនោះ ហើយងូតទឹកជម្រះខ្លួនដោយលំអិតក្រអូបជាដើម ស្លៀកដណ្ដប់សំពត់ដ៏ប្រសើរ លាបផាត់ដោយរបស់ក្រអូប ប្រដាប់ផ្កាឧប្បលខៀវជាដើម ហើយប្រដាប់ដោយគ្រឿងអលង្ការប្រភេទនានា ទើបចូលទៅកាន់មហានគរ ឈានឡើងកាន់ប្រាសាទ បរិភោគភោជនដ៏ឧត្ដម ។

ក្នុងសេចក្ដីនោះ បណ្ឌិតគប្បីជ្រាបពាក្យឧបមាដូច្នេះ គឺ

បុគ្គល ៧ ជំពូកទាំងនេះ ប្រៀបដូចអ្នកជំនួញ ៧ នាក់នោះ, វដ្ដៈ ប្រៀបដូចស្ទឹង, ការលិចចុះក្នុងវដ្ដៈរបស់និយតមិច្ឆាទិដ្ឋិ បណ្ឌិតគប្បីជ្រាបថា ដូចនឹងការលិចចុះ ក្នុងកំពង់ទឹកជាទីឆ្លងកាត់របស់អ្នកជំនួញដែលខ្លាចទឹក, អ្នកទី ១ ងើបឡើងដោយហេតុត្រឹមតែការកើតឡើងនៃសទ្ធាជាដើម ហើយលិចចុះ ព្រោះសេចក្ដីសាបសូន្យចាកសទ្ធាជាដើមនោះ ដូចនឹងអ្នកជំនួញដែលងើបឡើងម្ដងហើយ ក៏លិចចុះទៅក្នុងស្ទឹង ។ ព្រះសោតាបន្នក្រឡេកមើលនូវផ្លូវដែលខ្លួនគប្បីទៅ ឬផ្លូវដែលគួរនឹងទៅ ដូចជាអ្នកជំនួញដែលងើបឡើងអំពីទឹកក្រឡេកមើលនូវកំពង់ទឹកជាទីឆ្លងកាត់ ។ ព្រះសកទាគាមី ឈ្មោះថាកំពុងឆ្លងកាត់ទៅ ព្រោះភាពនៃខ្លួនជាអ្នកមានកិលេសស្ដួចស្ដើង ប្រៀបដូចជាអ្នកជំនួញដែលកំពុងឆ្លងកាត់ទៅ ។ ព្រះអនាគាមី ឈ្មោះថា ឈប់នៅ ព្រោះជាអ្នកមិនត្រឡប់មកកាន់កាមលោកនេះ ដូចជាអ្នកជំនួញដែលឆ្លងកាត់ទៅ ហើយឈរនៅត្រង់ទឹកត្រឹមចង្កេះ ។ ព្រះខីណាស្រពអ្នកជាព្រាហ្មណ៍ អ្នកឈានឆ្លងកាត់ឱឃៈទាំង ៤ ហើយ ឈរនៅលើគោក គឺព្រះនិព្វាន បណ្ឌិតគប្បីជ្រាបថា ប្រៀបដូចអ្នកជំនួញដែលងូតទឹកជម្រះរាងកាយ ឲ្យស្អាតហើយឆ្លងឡើងច្រាំងនោះ ឈរនៅលើគោក ។ បណ្ឌិតគប្បីជ្រាបថា កាលដែលព្រះខីណាស្រពលោកចូលផលសមាបត្តិ ដែលមាន

*និព្វានជាអារម្មណ៍ ហើយញុាំងកាលឲ្យកន្លងទៅ ដូចជាអ្នកជំនួញដែលឈរនៅលើ គោកហើយចូលទៅកាន់ព្រះនគរ ឈានឡើងកាន់ប្រាសាទដ៏ប្រសើរហើយ ក៏បរិភោគអាហារដ៏ឧត្តម ។ ព្រះអរិយបុគ្គលទាំងឡាយមានឧភតោភាគវិមុត្តបុគ្គលជាដើម ខ្ញុំចង្អុលបង្ហាញទុកហើយ ក្នុងពេលមុននុ៎ះឯង ៕*

ចប់អដ្ឋកថាសត្តកនិទ្ទេស

ត្រឹមតែប៉ុណ្ណោះ

## ៨-៩.អដ្ឋកថាអដ្ឋកនិទ្ទេស និងនវកនិទ្ទេស

## អធិប្បាយបុគ្គល ៨ និង ៩ ជំពូក

*សូម្បីក្នុងនិទ្ទេសនៃបុគ្គល ៨ និងបុគ្គល ៩ ជំពូក បណ្ឌិតគប្បីជ្រាបដោយន័យដែលខ្ញុំពោលទុកហើយ ក្នុងពេលក្រោយនុ៎ះឯង ៕*

ចប់អដ្ឋកថាអដ្ឋកនិទ្ទេស និងនវកនិទ្ទេស

ត្រឹមតែប៉ុណ្ណោះ

## ១០.អដ្ឋកថាទសកនិទ្ទេស អធិប្បាយបុគ្គល ១០ ជំពូក

*ពាក្យថា* **“ឥធ”** *បានដល់ ក្នុងកាមាវចរភូមិ ។ ក៏ព្រះអរិយបុគ្គលទាំងឡាយ មានសត្តក្ខត្តុំបរមបុគ្គលជាដើម ដែលនៅក្នុងកាមាវចរភូមិ លោករមែងសម្រេចក្នុងកាមាវចរភូមិនុ៎ះឯង បានសេចក្តីថា ការសម្រេចព្រះអរហត្តក្តី ការសម្រេចអនុបាទិសេសនិព្វានក្តី រមែងមានក្នុងអត្តភាពដែលលោកកើតនៅក្នុងកាមាវចរភូមិនុ៎ះឯង ។*

*បទថា* **“ឥធ វិហាយ”** *អធិប្បាយថា ព្រះអនាគាមីបុគ្គលលោកលះអត្តភាពក្នុងកាមាវចរភូមិនេះហើយ ទើបសម្រេចជាព្រះអរហន្ត ក្នុងអត្តភាពជាន់សុទ្ធាវាសភូមិ ។ ក៏ព្រះអនាគាមី ៥ ប្រភេទ មានអន្តរាបរិនិព្វាយីជាដើម លោកសម្រេចអនាគាមិផលក្នុងកាមភូមិនេះ, កាលបើចុតិចាកកាមភូមិហើយ ក៏កើតឡើងក្នុងសុទ្ធាវាសភូមិ ទើបសម្រេចព្រះអរហត្ត និងអនុបាទិសេសនិព្វានធាតុ ។ ព្រោះហេតុនោះ ទើបព្រះអង្គត្រាស់ថា* **“ឥមេសំ បញ្ចន្នំ ឥធ វិហាយ និដ្ឋា** *= ព្រះអនាគាមីទាំង ៥ ជំពូកនេះ លះអត្តភាពក្នុងកាមាវចរភូមិនេះហើយ ទើបនឹងសម្រេចព្រះអរហត្ត ក្នុងសុទ្ធាវាសភូមិ” ជាដើម ៕*

ចប់អដ្ឋកថាទសកនិទ្ទេស

ត្រឹមតែប៉ុណ្ណោះ

## និគមគាថា

*ក៏ដោយពាក្យមានប្រមាណប៉ុណ្ណេះ ៖*

*ព្រះសាស្តាដែលរកបុគ្គលក្នុងលោកប្រៀបមិនបាន ទ្រង់សម្តែងហើយនូវគម្ពីរ បុគ្គលប្បញ្ញត្តិ ណា ដោយមិនបានសង្ខេបពេកក្នុងទីនៅនៃទេវតាឋានត្រៃត្រិង្ស ខ្ញុំកាន់យកអដ្ឋកថានៃគម្ពីរនោះ ដែលលោកតែងសង្ខេបទុកដោយភាសាអ្នកកោះសីហឡៈ និងអដ្ឋកថាដែលមានមកទាំងឡាយ ដោយមិនសេសសល់ ។*

*សេចក្តីណាៗ ដែលលោកចែកទុកល្អហើយ មិនខ្វាត់ខ្វាយ មាននៅក្នុងគម្ពីរណាៗ ខ្ញុំលះសេចក្តីដែលពិស្តារហួសកំណត់ ហើយទើបកាន់យកសេចក្តីនោះអំពីគម្ពីរនោះៗ ។*

*ក៏ពាក្យឯណា ដែលខ្ញុំពោលទុកហើយក្នុងបករណ៍ វិសុទ្ធិមគ្គ ខ្ញុំមិនបាននាំមកពោលក្នុងទីនេះទៀតទេ, នឹងបានតែងគម្ពីរអដ្ឋកថា បុគ្គលប្បញ្ញត្តិនេះ ទុកដោយសេចក្តីដែលមិនសង្ខេបពេក និងមិនពិស្តារលើសលប់ពេកទេ ។*

*បានតែងទុកដោយបែបផែនមានប្រមាណ ៧ ភាណវារៈ ដើម្បីសេចក្តីតាំងមាំនៃព្រះសទ្ធម្មរហូតអស់កាលយូរ ។*

*មួយទៀត កុសលធម៌ឯណាដែលខ្ញុំសម្រេច (កសាង) ហើយ ដោយតេជកុសលផលបុណ្យនោះ សូមឱ្យសត្វទាំងឡាយ ក្រឡេកមើលព្រះសទ្ធម្មដែលសុខុមជ្រាលជ្រៅ ជាសិរីមង្គល ដោយធម្មចក្ខុដ៏បរិសុទ្ធផងចុះ ៚*

ចប់បុគ្គលប្បញ្ញត្តិបករណ៍

# កថាវត្ថុបករណ៍

## អារម្ភកថា

*ព្រះសម្មាសម្ពុទ្ធ ព្រះអង្គជាសាស្តារបស់សត្វលោក ព្រមទាំងទេវ-លោក ព្រះអង្គរកបុគ្គលដទៃប្រៀបមិនបាន ដែលពួកទេវតាលើកសរសើរហើយ ទ្រង់គង់ប្រថាប់ក្នុងទេវលោក ។ ព្រះអង្គទ្រង់ជាអ្នកឈ្លាសក្នុងបញ្ញត្តិទាំងពួង ទ្រង់ជាឧត្តមបុគ្គលក្នុងលោក លុះត្រាស់សម្តែងគម្ពីរ* បុគ្គលប្បញ្ញត្តិ *ដែលសម្តែងដល់បញ្ញត្តិចប់រួចហើយ ទើបទ្រង់សម្តែងកថា-វត្ថុប្បករណ៍ ដែលពោលអំពីរឿងផ្សេងៗ មានរឿងបុគ្គលជាដើមឯណាទុកហើយ ដោយសង្ខេប ។*

*ឥឡូវនេះ លំដាប់នៃការសំវណ្ណនាសេចក្តីដែលព្រះមានព្រះភាគទ្រង់តាំងទុកហើយ ក្នុងសុរាល័យទេវលោក ដោយការផ្តើមតាំងទុកត្រឹមតែចំណងជើងនោះឯង ដែលព្រះមោគ្គលីបុត្តតិស្សត្ថេរ ចែកហើយក្នុងមនុស្សលោកនោះ ដល់ព្រមហើយ ព្រោះហេតុដូច្នោះ ខ្ញុំនឹងពណ៌នាកថាវត្ថុប្ប-ករណ៍នោះ, សូមអ្នកទាំងឡាយ មានចិត្តតាំងមាំ ផ្ចង់ (ស្មារតី) ស្តាប់ព្រះសទ្ធម្មនោះចុះ ៕*

ចប់អារម្ភកថា

# និទានកថា

*សេចក្ដីសង្ខេបថា ក្នុងទីបំផុតនៃការសម្ដែងយមកប្បាដិហារ្យ ព្រះសាស្ដាយាងទៅចាំព្រះវស្សាលើបណ្ឌុកម្ពលសិលាសនៈ ត្រង់គល់បារិច្ឆត្តកៈក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី (កាយសក្ខី) ត្រាស់ហើយនូវព្រះអភិធម្មកថាដល់ទេវបរិស័ទ, លុះទ្រង់សម្ដែងបករណ៍ធម្មសង្គណី បាន ១០០ ឆ្នាំ ពួកភិក្ខុវជ្ជីបុត្រ ក៏សម្ដែងវត្ថុ ១០ ប្រការ ដែលខុសពីព្រះធម្មវិន័យ គឺ*

*១-ភិក្ខុទុកអំបិលសល់ក្នុងក្ឆាក់ សម្រាប់ឆាន់នឹងអាហារ ឃើញថា* ***សមគួរ*** *។*

*២-ភិក្ខុឆាន់អាហារ កាលថ្ងៃជ្រេ ២ ធ្នាប់ ឃើញថា* ***សមគួរ*** *។*

*៣-ភិក្ខុហាមភត្តហើយ ចូលទៅក្នុងលង្វែកស្រុកហើយឆាន់ភត្តដែលមិនធ្វើវិន័យកម្មមុន ឬមិនជារបស់សល់ពីភិក្ខុឈឺ ឃើញថា* ***សមគួរ*** *។*

*៤-ភិក្ខុនៅក្នុងអាវាសមួយជាមួយគ្នា នឹងធ្វើសង្ឃកម្មបែកគ្នា ឃើញថា* ***សមគួរ*** *។*

*៥-ភិក្ខុធ្វើឧបោសថមិនរង់ចាំឆន្ទានុមតិ ឃើញថា* ***សមគួរ*** *។*

*៦-បដិបត្តិដែលឧបជ្ឈាយាចារ្យធ្លាប់ប្រព្រឹត្តមក ខុសត្រូវយ៉ាងណា*

*បើប្រព្រឹត្តតាម ឃើញថា **សមគួរ** ។*

*៧-ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ ដែលនៅមិនទាន់ក្លាយជាទឹកដោះជូរ ឃើញថា **សមគួរ** ។*

*៨-ភិក្ខុផឹកសុរាតិចៗ ឃើញថា **សមគួរ** ។*

*៩-ភិក្ខុប្រើសំពត់និសីទនៈ ដែលមិនមានជាយ ឃើញថា **សមគួរ** ។*

*១០-ភិក្ខុទទួល ឬត្រេកអរចំពោះប្រាក់ និងមាស ដែលគេទុកដាក់ដើម្បីខ្លួន ឃើញថា **សមគួរ** ។*

*ព្រះយសត្ថេរជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា* **កាកណ្ឌកៈ** *ស្តាប់វត្ថុ ១០ ប្រការនោះហើយ បានកាន់យកព្រះបាទ **អសោករាជ** ដែលជាឱរសរបស់ព្រះបាទ* **សុសុនាគៈ** *ធ្វើជាសម្លាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ រូប ក្នុងចំនួនភិក្ខុ ១.២០០០០០ (១២ សែន) រូប ញាំញីវត្ថុទាំង ១០ ប្រការនេះ ហើយក៏លើកសរីរៈ គឺព្រះធម៌វិន័យឡើងសង្គាយនា ។*

*ក៏ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ រូប ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយ គំរាមសម្កុតហើយ គឺតិះដៀលហើយ ទើបស្វែងរកបក្សពួក, គ្រាបានបក្សពួកជាអ្នកទុព្វល (មានកម្លាំងខ្សោយ) ដែលសមគួរដល់ខ្លួន ក៏ចាត់តាំងសំណាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា* **មហាសង្ឃិកៈ** *= ពួកច្រើន,*

ត្រកូលអាចារ្យ ២ ពួកដទៃទៀតកើតឡើង គឺគោកុលិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកអំពីត្រកូលអាចារ្យមហាសង្ឃិកៈនោះ ។ ត្រកូលអាចារ្យ ២ ពួកដទៃទៀត គឺបញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ បែកចេញមកអំពីនិកាយគោកុលិកៈ ។ អាចរិយវាទដទៃទៀត ឈ្មោះថា ចេតិយវាទ កើតឡើងហើយ ក្នុងចន្លោះ និកាយពហុលិយៈនោះឯង ។ ក្នុងសតវត្សទី ២ គឺក្នុងព្រះពុទ្ធសករាជ ២០០ ឆ្នាំ ត្រកូលអាចារ្យទាំង ៥ កើតឡើងអំពីត្រកូលអាចារ្យមហាសង្ឃិកៈ ដោយប្រការដូច្នេះ ។ ត្រកូលអាចារ្យទាំង ៥ នោះ រួមនឹងមហាសង្ឃិកៈដើម ១ ត្រូវជា ៦ ត្រកូល ។

ក្នុងសតវត្សទី ២ នោះឯង អាចរិយវាទទាំង ២ គឺមហិសាសកៈ និងវជ្ជីបុត្តកៈកើតឡើង បែកចេញមកអំពីថេរវាទ ។ បណ្តាអាចរិយវាទទាំង ២ នោះ អាចរិយវាទទាំង ៤ គឺ ***ធម្មុត្តរិយៈ ១, ភទ្រយានិកៈ ១, ឆន្នាគារិកៈ ១ និងសមិតិយៈ ១*** កើតឡើង ព្រោះបែកចេញមកអំពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងសតវត្សទី ២ នោះឯង អាចរិយវាទ ២ ពួក គឺ ***សព្វត្ថិកវាទៈ និងធម្មគុត្តិកៈ*** កើតឡើងទៀត ព្រោះបែកចេញមកអំពីត្រកូលអាចារ្យមហិសាសកៈ ។ និកាយ ឈ្មោះថា **កស្សបិកៈ** កើតឡើងទៀត ព្រោះបែកចេញមកអំពីត្រកូលសព្វត្ថិកវាទៈ ។ កាលនិកាយកស្សបិកៈទាំងឡាយ

បែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយ ឈ្មោះថា សំកន្តិកៈដទៃទៀត កើតឡើង, កាលនិកាយសំកន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទៈ ក៏កើតឡើង ។ អាចរិយវាទទាំង ១១ និកាយនេះ កើតឡើងហើយ ព្រោះបែកចេញមកអំពីថេរវាទយ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទទាំង ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ត្រូវជា ១២ និកាយ ។

ក្នុងសតវត្សទី ២ គឺក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទ គឺលទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយ ដែលបែកមកអំពីថេរវាទទាំងនេះ និងនិកាយអាចរិយវាទ ៦ ដែលបែកចេញមកអំពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយដូច្នេះឯង ។

ពាក្យថា ***និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី*** ជាឈ្មោះរបស់និកាយដែលពោលមកហើយទាំងអស់នោះឯង ។ ក៏បណ្តានិកាយទាំង ១៨ នោះ និកាយ ១៧ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបំបែកគ្នាមក, ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នាទេ ។

រឿងរ៉ាវនេះ លោកបានពោលទុក ក្នុង ***ទីបវង្ស*** ថា ៖

***១.ភិក្ខុដ៏លាមកទាំងឡាយ គឺវជ្ជីបុត្រជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយកម្ចាត់ចេញហើយ តមក បានពួកដទៃ ទើបតាំងគណាចារ្យថ្មី ។***

*២.ភិក្ខុ* * *ទាំងនោះ មានប្រមាណមួយហ្មឺនរូប បានប្រជុំគ្នា រួបរួម គឺធ្វើការចងក្រងព្រះធម្មវិន័យ ព្រោះហេតុដូច្នោះ ការចងក្រងព្រះធម្មវិន័យនេះ លោកហៅថា "មហាសង្គីតិ ៗ*

---

* ១.ភិក្ខុប្រមាណ ១ ហ្មឺនរូបទាំងនោះ ក្នុងទីនេះសំដៅយកភិក្ខុវជ្ជីបុត្រ, តែក្នុងទីខ្លះ លោកពោលថា ជាភិក្ខុពួកព្រះមហាទេវៈដែលឱ្យកំណើតនិកាយមហាសង្ឃិកវាទី បរាវនៈ បំប្រួញថា ព្រះមហាទេវៈជាបុត្រអ្នកលក់គ្រឿងក្រអូបក្នុងដែនអវន្តី លោកឧបសម្បទក្នុងក្រុងបាដលី ដែនមគធៈ ជាអ្នករៀនព្រះត្រៃបិដកបែកធ្លុះធ្លាយ ថ្ងៃមួយដល់វារៈដែលលោកសម្តែងបាដិមោក្ខ លោកបាន ស្នើសុំសេចក្តីយល់ឃើញ ៥ ខ ចំពោះទីប្រជុំសង្ឃដូច្នេះ :

១.ព្រះអរហន្តអាចត្រូវមារទាក់ទាញឱ្យកើតការលំបាកក្នុងសេចក្តីយល់សប្តិបាន

២.ព្រះអរហន្តនៅមានអញ្ញាណៈ

៣.ព្រះអរហន្តនៅមានសេចក្តីសង្ស័យ

៤.ព្រះអរហន្តនឹងត្រូវដឹងថា ខ្លួនបានមគ្គ និងផល ត្រូវអាស្រ័យអ្នកដទៃទៀត

៥.មគ្គ និងផលកើតឡើងត្រូវអាស្រ័យបញ្ចេញពាក្យថា ទុក្ខំហ្ន៎ៗ ។

ខសេចក្តីស្នើសុំរបស់លោកនេះ ពួកខ្លះមិនឃើញផង ទើបធ្វើសង្ឃកម្មមិនបាន គ្រាជ្រាប ដល់ព្រះបាទកាលាសោករាជៗ ក៏ស្តេចមកហាមមិនឱ្យកើតការបែកខ្ញែកគ្នា ទើបព្រះមហាទេវៈ ពន្យល់ ដោយឱ្យរម្ងាប់អធិករណ៍ តាមមតិរបស់ប្រជុំសង្ឃ ក្នុងទីបំផុត ខាងព្រះមហាទេពឈ្នះ ព្រោះមានគ្នាច្រើន ខាងដែលមិនឃើញផងនោះ ជាខាងថេរវាទ្យ តមក ពួកមហាទេពបានចាត់ការ ធ្វើសង្គីតិ ដោយសង្ឃពួកធំ ទើបហៅថា មហាសង្គីតិ និងតមកទៀត និកាយនេះ កើតការបែកបាក់ គ្នាទៀត ។

*ការចងក្រងធំ” ។*

*៣.ភិក្ខុទាំងឡាយអ្នកធ្វើមហាសង្គីតិ បានធ្វើការជំទាស់ ទុកក្នុងព្រះសាសនា ទម្លាយសង្គាយនាដើម ហើយធ្វើការរួបរួមធម៌វិន័យទុកម្យ៉ាងទៀត ។*

*៤.ភិក្ខុទាំងនោះ បានសរសេររចនាព្រះសូត្រដែលសង្គាយនាទុកហើយ ឱ្យជាយ៉ាងដទៃ ទម្លាយអត្ថ និងធម៌ ក្នុងព្រះវិន័យ ក្នុងនិកាយទាំង ៥ ផង ។*

*៥.មួយទៀត ភិក្ខុទាំងនោះ សូម្បីមិនដឹងនូវធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងទុកហើយ ដោយបរិយាយ និងនិប្បរិយាយ មិនចេះអត្ថដែលព្រះមានព្រះភាគទ្រង់ណែនាំទុកហើយ និងទាំងមិនស្គាល់អត្ថដែលគួរណែនាំ ។*

*៦.ភិក្ខុពួកនោះៗ បានកំណត់អត្ថទុកជាយ៉ាងដទៃ អំពីអត្ថដែលព្រះមានព្រះភាគត្រាស់ទុកដោយសំដៅយកតែម្យ៉ាង បានញ៉ាំងអត្ថច្រើន ឱ្យវិនាសទៅ ព្រោះឆាយា (ស្រមោល) នៃព្យញ្ជនៈ* * ។

---

* បាលីថា **“ព្យញ្ជនច្ឆាយាយ”** មានសេចក្តីចំណាំជាពីរន័យ គឺព្យញ្ជនៈ + ឆាយា ក៏បាន, ព្យញ្ជនៈ + អច្ឆាយាយៈ ក៏បាន; ន័យដំបូង ព្រោះស្រមោលនៃព្យញ្ជនៈ ឬព្រោះរូបនៃ (ត)

*៧.ភិក្ខុទាំងនោះ លះចោលព្រះសូត្រខ្លះ និងព្រះវិន័យខ្លះ ដែលជ្រាលជ្រៅចេញ ហើយតែងព្រះសូត្របដិរូប និង ព្រះវិន័យបដិរូបធ្វើឱ្យជាយ៉ាងដទៃ ។*

*៨.គម្ពីរបរិវារអត្ថុទ្ធារៈក្តី អភិធម្មទាំង ៦ បករណ៍ក្តី បដិ-សម្ភិទានិទ្ទេសក្តី ជាតកចំណែកខ្លះក្តី ។*

*៩.គម្ពីរមានប្រមាណប៉ុណ្ណេះ ត្រូវភិក្ខុទាំងនោះ ចែកទុក ផ្សេងៗ គ្នា ហើយតែងឱ្យជាយ៉ាងដទៃទាំងនាម លិង្គ បរិក្ខារ និងអាកប្បករណីយៈ ។*

*១០.ភិក្ខុជាប្រធានគណៈ អ្នកមានវាទៈដែលបែកគ្នា ហើយ អ្នកធ្វើមហាសង្គីតិទាំងនោះ បាននាំគ្នាលះចោល នូវ ប្រក្រតីភាពនោះចេញ ហើយតែងឱ្យជាយ៉ាងដទៃ ។*

*១១.ក៏ដោយការរៀនដូចភិក្ខុទាំងនោះ បានមានលទ្ធិបែកគ្នា ច្រើនឡើង និងខាងក្រោយអំពីកាលនោះមក បានកើត រឿងបែកគ្នាឡើង ក្នុងមហាសង្ឃិកៈនោះ ដូចនេះ គឺ*

*១២.ភិក្ខុមហាសង្ឃិកៈបានបែកគ្នាជា ២ ពួក គឺជាគោកុលិកៈ*

---

ព្យញ្ជនៈ, ន័យក្រោយ ប្រែថា ព្រោះមិនមានព្យញ្ជនៈ ព្រោះមិនមានរូបនៃព្យញ្ជនៈ ព្រោះមិនភ្លឺ រុងរឿង ក្នុងព្យញ្ជនៈ ព្រោះមិនឈ្លាសក្នុងព្យញ្ជនៈ ។

មួយពួក និងជាឯកព្យោហារិកៈមួយពួក; តមកទៀត និកាយគោកុលិកៈបែកចេញជា ២ ពួក គឺ

១៣.ជានិកាយពហុស្សុតិកៈមួយពួក និងជានិកាយបញ្ញត្តិ មួយពួក; តែនិកាយចេតិយៈនោះ បែកចេញមកអំពីពួក មហាសង្គីតិ (បង្កើត) បានជាមួយពួកទៀត ។

១៤.ក៏និកាយទាំងអស់ ៥ នេះ មានមូលមកអំពីពួកធ្វើ មហាសង្គីតិ ដែលទម្លាយអត្ថ និងធម៌, និងទម្លាយការ សង្គ្រោះធម៌វិន័យខ្លះ ។

១៥.ភិក្ខុទាំងនោះ លះចោលគម្ពីរខ្លះ និងធ្វើឱ្យជាយ៉ាងដទៃ ទាំងនាម លិង្គ បរិក្ខារ និងអាកប្បករណីយៈ ។

១៦.មួយទៀត ក្នុងថេរវាទអ្នកបរិសុទ្ធ ពួកភិក្ខុអ្នកលះចោល ប្រក្រតីភាព និងធ្វើឱ្យជាយ៉ាងដទៃនោះ បានកើតការ បែកគ្នាឡើងទៀតដូចនេះ គឺ

១៧.ជាមហិសាសកៈមួយពួក ជាវជ្ជីបុត្តកៈមួយពួក, សម្រាប់ ពួកវជ្ជីបុត្តកៈនោះ បានបំបែកចេញទៅជា ៤ ពួកទៀត គឺ

១៨.ធម្មុត្តរិកៈ ១, ភទ្រយានិកៈ ១, ឆន្នាគារិកៈ ១ និង សមិតិយៈ ១; ក្នុងកាលតមក ពួកមហិសាសកៈបំបែក

គ្នាជា ២ ពួកទៀត គឺ

១៩.ជាពួកសព្វត្ថិកវាទៈ និងធម្មគុត្តវាទៈ, សម្រាប់សព្វត្ថិក-វាទៈបានបែកចេញជានិកាយកស្សបិកៈ; តមក និកាយកស្សបិកៈបំបែកជានិកាយសំកន្តិកវាទៈ ។

២០.តមកទៀត សំកន្តិកវាទៈបែកគ្នាជាសុត្តវាទី១ បានបំបែកគ្នា មកដោយលំដាប់ដូច្នេះ វាទៈ គឺនិកាយទាំង ១១ និកាយនេះ បែកចេញអំពីថេរវាទទាំងអស់ ។

២១.ភិក្ខុទាំងនោះ ទម្លាយទាំងអត្ថ ទាំងធម៌ ធ្វើការរួបរួមទាំងអត្ថ ទាំងធម៌ទុកខ្លះ និងបានបោះបង់ចោលគម្ពីរខ្លះ ទាំងធ្វើឱ្យជាយ៉ាងដទៃ ។

២២.រហូតទាំងនាម លិង្គ បរិក្ខារ និងអាកប្បករណីយៈ បាននាំគ្នាលះចោលភាពជាប្រក្រតីចេញហើយ ។

២៣.និកាយដែលបែកខ្ញែកគ្នា មាន ១៧ និកាយ, និកាយដែលមិនបែកខ្ញែកគ្នា មាន ១ និកាយ គឺថេរវាទ រួមនិកាយ ទាំងអស់ត្រូវជា ១៨ និកាយ; ម្យ៉ាងទៀត លោកហៅថា ត្រកូលអាចារ្យ ១៨ ត្រកូល ។

២៤.ពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រីដ៏បរិសុទ្ធបរិបូណ៌ មិន

លើស មិនខ្វះ ជាគោលមាំទាំខ្ពង់ខ្ពស់ របស់ថេរវាទ ទាំងឡាយ ហាក់ដូចជាដើមឈើធំ ឈ្មោះថា និគ្រោធ ដូច្នោះ ។

២៥.និកាយដ៏សេស គឺក្រៅពីថេរវាទ កើតឡើងហើយ ហាក់ដូចជាបញ្ញើក្អែក កើតនៅត្រង់ដើមឈើ, និកាយដែលបែកគ្នាមកទាំង ១៧ និកាយនេះ មិនមែនក្នុង ១ រយឆ្នាំដំបូងទេ, តែក្នុងចន្លោះ ២ រយឆ្នាំ គឺខាងក្នុងព្រះពុទ្ធសករាជ ២០០ ឆ្នាំ បានកើតឡើងហើយ ក្នុងសាសនារបស់ព្រះជិនស្រី ដោយប្រការដូច្នេះឯង ។

មួយទៀត សូម្បីអាចរិយវាទ ៦ ដទៃទៀត គឺ

១.ហេមវតិកៈ ២.រាជសិរិកៈ

៣.សិទ្ធត្ថិកៈ ៤.បុព្វសេលិយៈ

៥.អបរសេលិយៈ ៦.វាជិរិយៈ ។

កើតឡើងហើយក្នុងកាលដទៃៗ ទៀត អាចរិយវាទទាំងនេះ ព្រះគន្ថរចនាចារ្យ លោកមិនមានបំណងនឹងពោលទុកក្នុងទីនេះទេ ៕

# ព្រះរាជាទ្រទ្រង់ធម៌

*ក៏ព្រះរាជាដែលតាំងនៅក្នុងធម៌ ព្រះនាមថា* ***ព្រះបាទអសោក*** *ព្រះអង្គមានសទ្ធាដែលបានចំពោះហើយ ក្នុងព្រះពុទ្ធសាសនានៃនិកាយ អាចរិយ-វាទទាំង ១៨ និកាយ ដែលមានមកក្នុងកាលមុន ទើបទ្រង់លះបង់ព្រះរាជទ្រព្យ ៥ សែនៗ រៀងរាល់ថ្ងៃ គឺដើម្បីបូជាព្រះពុទ្ធជាម្ចាស់ ១ សែន, ដើម្បីបូជាព្រះធម៌ ១ សែន, ដើម្បីបូជាព្រះសង្ឃ ១ សែន, ដើម្បីអាចារ្យរបស់ព្រះអង្គ ឈ្មោះថា និគ្រោធត្ថេរ ១ សែន និងដើម្បីឲ្យសម្រេចប្រយោជន៍ ពីថ្នាំរក្សារោគត្រង់ទ្វារទាំងបួន ១ សែនទៀត; បានឲ្យលាភសក្ការៈដ៏ច្រើន ប្រព្រឹត្តទៅក្នុងព្រះពុទ្ធសាសនា ។ អន្យតិរ្ថិយទាំងឡាយ គឺអ្នកបួសក្រៅព្រះពុទ្ធសាសនា បានសាបសូន្យចាកលាភសក្ការៈយ៉ាងខ្លាំង, មិនបានអ្វីឡើយ ដោយហោចទៅសូម្បីតែអាហារ ឬសំពត់សម្រាប់បិទបាំងរាងកាយ ក៏ខ្វះខាតដែរ, កាលបើពួកគេត្រូវការលាភសក្ការៈហើយ ទើបនាំគ្នាទៅបួសក្នុងសំណាក់ភិក្ខុទាំងឡាយ ហើយក៏សម្តែងទិដ្ឋិ គឺសេចក្តីយល់ឃើញរបស់ខ្លួនៗ ថា "នេះជាធម៌, នេះជាវិន័យ, នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា" ដូច្នេះ ។ សូម្បីកាលគេទាំងនោះ មិនបានបព្វជ្ជាតាមបំណង គេក៏នាំគ្នាកោរសក់ ស្លៀកដណ្តប់សំពត់កាសាវពស្ត្រដោយខ្លួនឯងតែម្តង ហើយនាំគ្នាត្រាច់ទៅក្នុងវិហារទាំងឡាយ និងបាន*

*ចូលទៅកាន់កណ្ដាលជំនុំសង្ឃ ក្នុងកាលជាទីធ្វើនូវឧបោសថកម្មជាដើម ។ ពួកអន្យតិរ្ថិយទាំងនោះ សូម្បីត្រូវភិក្ខុសង្ឃគិះដៀលហើយ ដោយធម៌ ដោយវិន័យ និងដោយសត្ថុសាសន៍ គឺពាក្យទូន្មានរបស់ព្រះសាស្ដា ក៏មិនអាចតាំងនៅក្នុងឧបដិបត្តិដែលសមគួរដល់ព្រះធម៌វិន័យបាន, ត្រឡប់ជាញុំាងការរឹករវរនៃមន្ទិល និងចម្រូងចម្រាសជាច្រើន ឲ្យកើតឡើងក្នុងព្រះពុទ្ធសាសនា គឺពួកខ្លះ ក៏បម្រើភ្លើង, ពួកខ្លះក៏អាំងខ្លួន ក្នុងសេចក្ដីក្ដៅ ៥ យ៉ាង, ពួកខ្លះ ក៏ងើយមុខតាមមើលព្រះអាទិត្យជាដរាប, ពួកខ្លះ ក៏គិតប៉ុនប៉ងថា យើងនឹងទម្លាយធម៌ និងវិន័យរបស់ពួកលោកផ្សេងៗ” ក៏នាំគ្នាព្យាយាមហើយ ដោយអាការនោះៗ ។ ក្នុងកាលនោះ ព្រះភិក្ខុសង្ឃមិនព្រមធ្វើឧបោសថ និងបវារណាកម្មរួមជាមួយពួកអន្យតិរ្ថិយទាំងនោះឡើយ ។ ក្នុងអសោការាម ដាច់ឧបោសថកម្មទៅដល់ ៧ ឆ្នាំ ។ សូម្បីព្រះរាជាទ្រង់ព្យាយាមហើយ ដោយសេចក្ដីប្រាថ្នាថា “យើងនឹងឲ្យសង្ឃធ្វើឧបោសថកម្មដោយព្រះរាជអាជ្ញា” ដូច្នេះ ក៏មិនអាចដើម្បីនឹងធ្វើបាន ។ កាលបើពួកភិក្ខុមិនមែនតិច ត្រូវអាមាត្រជាមនុស្សពាល អ្នកយល់ឃើញខុសប្រហារជីវិតហើយ ភាពក្ដៅក្រហាយ ក៏បានកើតដល់ព្រះរាជាអ្នកទ្រទ្រង់ធម៌ ។ ព្រះអង្គជាអ្នកប្រាថ្នាដើម្បីនឹងរម្ងាប់សេចក្ដីក្ដៅក្រហាយនោះ និងការរឹករវរមន្ទិលដែលកើតឡើងក្នុងព្រះសាសនានោះ, ទើបត្រាស់សួរសង្ឃថា*

"នរណាហ្ន៎ ជាអ្នកអាចក្នុងទីនេះ" , ទ្រង់ស្តាប់ថា "បពិត្រមហារាជ ព្រះមោគ្គលីបុត្តតិស្សត្ថេរ" ដូច្នេះ ទ្រង់បានទទួលបញ្ជាឲ្យព្រះមោគ្គលីបុត្ត-តិស្សត្ថេរ ដែលទើបនិមន្តមកអំពីអហោគង្គាបព៌តតាមពាក្យរបស់សង្ឃ បានជាអ្នកអស់សេចក្តីសង្ស័យ ដោយអានុភាព របស់ព្រះថេរៈដែលសម្តែងឥទ្ធិបាដិហារ្យ ទើបត្រាស់សួរសេចក្តីមិនពេញចិត្តរបស់ព្រះអង្គ បានញុំាងវិប្បដិសារីឲ្យស្ងប់រម្ងាប់អស់ហើយ ។ សូម្បីព្រះថេរៈ ក៏គង់នៅជាមួយនឹងព្រះរាជាក្នុងព្រះរាជឧទ្យាននោះឯង ហើយបានញុំាងព្រះរាជាឲ្យសិក្សាលទ្ធិសម័យរហូត ៧ ថ្ងៃ៕

---

## ក្រុសលោបាយជ្រើសរើសយកលទ្ធិដែលជាធម្មវាទី

ព្រះរាជាមានលទ្ធិដែលទ្រង់សិក្សាស្រេចហើយ ក៏និមន្តភិក្ខុសង្ឃទាំងឡាយ ឲ្យមកប្រជុំគ្នាក្នុងអសោការាមក្នុងថ្ងៃទី ៧ ហើយទ្រង់ទទួលបញ្ជាឲ្យបាំងវាំងននជាកំពែងជុំវិញ និងទ្រង់ប្រថាប់អង្គុយខាងក្នុងកំពែងវាំងនន ទ្រង់ឲ្យរួបរួមភិក្ខុទាំងឡាយ ដែលមានលទ្ធិដូចគ្នា ឲ្យនៅជាពួកៗ និងត្រាស់ឲ្យភិក្ខុចូលទៅគាល់ត្រង់កន្លែងមួយពួកៗ ហើយទ្រង់ត្រាស់សួរថា **"ភន្តេ កឹវាទី សម្មាសម្ពុទ្ធោ** = ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់មានវាទៈយ៉ាងណា ?" ។

លំដាប់នោះ ពួកសស្សតវាទី គឺអ្នកមានវាទៈថា អត្តា និងលោក

ទៀត ក៏ទូលថា "ព្រះសម្មាសម្ពុទ្ធជាម្ចាស់ មានវាទៈថា អត្តា និងលោកទៀត" ដូច្នេះ ។

ពួកឯកច្ចសស្សតទិដ្ឋិ គឺពួកដែលមានសេចក្តីយល់ឃើញថា ទៀងខ្លះ ក៏ទូលថា "ព្រះសម្មាសម្ពុទ្ធជាម្ចាស់ មានវាទៈថា ទៀងខ្លះ" ។

ពួកអន្តានន្តិកទិដ្ឋិ គឺពួកដែលមានសេចក្តីយល់ឃើញថា លោកមានទីបំផុត ក៏មាន, មិនមានទីបំផុត ក៏មាន បានទូលថា "ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់មានវាទៈថា 'លោកមានទីបំផុត និងមិនមានទីបំផុត" ។

ពួកអមរាវិក្ខេបិកាទិដ្ឋិ គឺពួកអ្នកមានសេចក្តីយល់ឃើញថា មានវាទៈបម្រះចេញបាន មិនស្លាប់ខ្លួន ក៏ទូលថា "ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់មានវាទៈបម្រះចេញបាន មិនស្លាប់ខ្លួន" ។

ពួកអធិច្ចសមុប្បន្និកទិដ្ឋិ គឺពួកដែលមានសេចក្តីយល់ឃើញថា អត្តា និងលោកកើតឡើងឯង ក៏ទូលថា "ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់មានវាទៈថា អត្តា និងលោកកើតឡើងឯង" ។

ពួកសញ្ញីវាទ គឺពួកដែលមានសេចក្តីយល់ឃើញថា អត្តាមានសញ្ញា ក៏ទូលថា "ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់មានវាទៈថា អត្តាមានសញ្ញា" ។

ពួកអសញ្ញីវាទ គឺពួកដែលមានសេចក្តីយល់ឃើញថា អត្តាមិនមាន

សញ្ញា ក៏ទូលថា "ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់មានវាទៈថា អត្តាមិនមាន
សញ្ញា" ។

ពួកនេវសញ្ញីនាសញ្ញីវាទ គឺពួកដែលមានសេចក្ដីយល់ឃើញថា អត្តា
មានសញ្ញា ក៏មិនមែន, មិនមានសញ្ញា ក៏មិនមែន ក៏ទូលថា "ព្រះសម្មា-
សម្ពុទ្ធជាម្ចាស់ ទ្រង់មានវាទៈថា អត្តាមានសញ្ញា ក៏មិនមែន មិនមានសញ្ញា
ក៏មិនមែន" ។

ពួកឧច្ឆេទទិដ្ឋិ គឺពួកដែលមានសេចក្ដីយល់ឃើញថា ដាច់សូន្យ ក៏ទូល
ថា "ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់មានវាទៈថា ដាច់សូន្យ" ។

ពួកទិដ្ឋធម្មនិព្វានវាទ គឺពួកដែលមានសេចក្ដីយល់ឃើញថា និព្វាន
មានក្នុងទិដ្ឋធម៌ (បច្ចុប្បន្ន) ក៏ទូលថា "ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់មាន
វាទៈថា និព្វានមានក្នុងបច្ចុប្បន្ន" ។ ពួកដែលមានវាទៈថា និព្វានមានក្នុង
បច្ចុប្បន្ន ឬនិព្វាន បច្ចុប្បន្ននេះ ពួកគេរមែងបញ្ញត្តស័ព្ទថា និព្វានបច្ចុប្បន្ន
ជាធម៌យ៉ាងក្រៃលែង របស់សត្វដែលប្រាកដ ដោយហេតុ ៥ ប្រការ គឺ

១. សមណៈ ឬព្រាហ្មណ៍ពួកខ្លះ មានទិដ្ឋិថា "អត្តភាពនេះ, ត្រូវ
ប្រកបព្រមដោយកាមគុណទាំង ៥ ទើបបានដល់និព្វានបច្ចុប្បន្ន
ដែលជាធម៌យ៉ាងក្រៃលែងបាន" ។

២. ពួកខ្លះមានទិដ្ឋិថា "អត្តភាពដែលសម្រេចបឋមជ្ឈាន ទើបបានដល់

និញ្វានបច្ចុប្បន្ន ដែលជាធម៌យ៉ាងក្រៃលែងបាន" ។

៣. ពួកខ្លះមានទិដ្ឋិថា "អត្តភាពដែលសម្រេចទុតិយជ្ឈាន ទើបបានដល់និញ្វានបច្ចុប្បន្ន ដែលជាធម៌យ៉ាងក្រៃលែងបាន" ។

៤. ពួកខ្លះមានទិដ្ឋិថា "អត្តភាពដែលសម្រេចតតិយជ្ឈាន ទើបបានដល់និញ្វានបច្ចុប្បន្ន ដែលជាធម៌យ៉ាងក្រៃលែងបាន" ។

៥. ពួកខ្លះមានទិដ្ឋិថា "អត្តភាពដែលសម្រេចចតុត្ថជ្ឈាន មិនមានសុខនិងទុក្ខ មានតែឧបេក្ខាដែលជាហេតុឲ្យសតិបរិសុទ្ធ ទើបបានដល់និញ្វានបច្ចុប្បន្នដែលជាធម៌យ៉ាងក្រៃលែងបាន" ។

ព្រះរាជាទ្រង់ជ្រាបថា "ពួកនេះពិតជាអន្យតិរ្ថិយ, មិនមែនជាភិក្ខុទេ" ដូច្នេះ ព្រោះព្រះអង្គទ្រង់បានសិក្សាលទ្ធិមកពីមុនរួចហើយ ទើបទ្រង់ព្រះរាជទានសំពត់សដល់ពួកអន្យតិរ្ថិយទាំងនោះ ហើយឲ្យសឹកចេញទៅ ។ អន្យតិរ្ថិយទាំងអស់ដែលសឹកចេញទៅ មានដល់ទៅ ៦០.០០០ នាក់ ។

ព្រះរាជាត្រាស់ទទួលបញ្ជាឲ្យពួកភិក្ខុដទៃចូលគាល់ ហើយទ្រង់សួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់មានវាទៈ យ៉ាងណា ?" សូមថ្វាយព្រះពរ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ជាវិភជ្ជវាទី, កាលបើភិក្ខុទាំងឡាយ ទូលយ៉ាងនេះហើយ ទើបព្រះរាជាត្រាស់សួរព្រះមោគ្គលីបុត្តតិស្សត្ថេរថា "ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ជាវិភជ្ជវាទីឬ ?"

ព្រះថេរៈទូលថា “ មែនហើយ មហាបពិត្រ” ។

លំដាប់នោះ ព្រះរាជាទទួលបញ្ញាថា បពិត្រលោកម្ចាស់ដ៏ចម្រើន ឥឡូវនេះ ព្រះសាសនាបរិសុទ្ធហើយ, សូមភិក្ខុសង្ឃធ្វើឧបោសថចុះ ទ្រង់ព្រះរាជទានអារក្ខា ហើយស្តេចយាងចូលកាន់ព្រះនគរ ។ ព្រះសង្ឃ ក៏បានព្រមព្រៀងប្រជុំគ្នាធ្វើឧបោសថ ។ ក្នុងសន្និបាតនោះ មានភិក្ខុសង្ឃដល់ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រូប ៕

## ព្រះមោគ្គល្លីបុត្តតិស្សត្ថេរសម្តែងកថាវត្ថុ

ព្រះមោគ្គល្លីបុត្តតិស្សត្ថេរ កាលបើនឹងហាមវត្ថុទាំងឡាយ ដែលកើតឡើងហើយក្នុងគ្រានោះ និងរឿងដែលនឹងកើតឡើង ក្នុងកាលតទៅ ទើបចែកមាតិកា ដែលព្រះតថាគតទ្រង់តាំងទុកហើយ ដោយអំណាចនៃអត្ថន័យដែលព្រះសាស្តាទ្រង់ប្រទានទុក ហើយក៏នាំព្រះសូត្រ ១.០០០ គឺព្រះសូត្រ ៥០០ សូត្រ សម្រាប់សកវាទៈរបស់ខ្លួន និងព្រះសូត្រ ៥០០ សូត្រ សម្រាប់បរវាទៈ គឺវាទៈរបស់អ្នកដទៃ ហើយបានពោលកថាវត្ថុប្ប-ករណ៍ ដែលមានលក្ខណៈដ៏ទូលំទូលាយ ញាំញីបរប្បវាទ គឺការទាស់ទែងឬការជំទាស់របស់អ្នកដទៃនេះ ក្នុងសមាគមនោះ ។

លំដាប់នោះ លោកបានជ្រើសរើសយកភិក្ខុសង្ឃទាំងឡាយ អ្នក

*ទ្រទ្រង់បរិយត្តិ គឺព្រះត្រៃបិដក និងបែកធ្លាយក្នុងបដិសម្ភិទាញាណចំនួន ១.០០០ រូប ក្នុងចំនួនភិក្ខុ ៦.០០០.០០០ រូប ធ្វើតតិយសង្គីតិ គឺការចងក្រងព្រះធម្មវិន័យក្នុងគ្រាទី ៣ ជម្រះលាងមន្ទិលក្នុងព្រះសាសនា ដូចព្រះមហាកស្សបត្ថេរ និងព្រះយសត្ថេរ សង្គាយនាព្រះធម្មវិន័យដូច្នោះដែរ ។*

*ក្នុងបិដកទាំង ៣ នោះ កាលបើលោកសង្គាយនាព្រះអភិធម្មបិដក លោកបានយកកថាវត្ថុប្បករណ៍នេះឡើង សង្គ្រោះតាមន័យដែលលោកបានភាសិត (សម្ដែង) ទុកហើយ ។*

**តេន វុត្តំ** *ដោយហេតុនោះ ទើបព្រះគន្ថរចនាចារ្យពោលទុកថា ៖*

***ព្រះសម្មាសម្ពុទ្ធ ព្រះអង្គជាសាស្ដារបស់លោក ព្រមទាំងទេវលោក ព្រះអង្គឈ្លាស ក្នុងបញ្ញត្តិទាំងពួង ជាបុគ្គលដ៏ខ្ពង់ខ្ពស់ ទ្រង់បានសម្ដែងកថាវត្ថុប្បករណ៍ ដោយសេចក្ដីជារឿងនៃកថាទាំងឡាយ មានបុគ្គលកថាជាដើមឯណា ទុកដោយសង្ខេប, ឥឡូវនេះ ដល់លំដាប់នៃការសំវណ្ណនាកថាវត្ថុប្បករណ៍ ដែលព្រះមានព្រះភាគទ្រង់តាំងទុកហើយ ដោយការតាំងទុកត្រឹមតែមាតិកាក្នុងសុរាល័យទេវលោក ដែលព្រះមោគ្គល្លីបុត្តតិស្សត្ថេរចែកទុកក្នុងមនុស្សលោកនោះ, ព្រោះហេតុដូច្នោះ ខ្ញុំនឹងពណ៌នាគម្ពីរនោះ, សូមអ្នកទាំងឡាយ មានចិត្តជាសមាធិ ត្រងត្រាប់ស្ដាប់រសនៃព្រះសទ្ធម្មនោះចុះ ៕***

ចប់និទានកថា

# ១.បុគ្គលកថា

## ១.សុទ្ធសច្ចិកត្ថ

### ពណ៌នាអំពីអនុលោមបញ្ចកៈ ( និគ្គហៈទី ១)

### ពណ៌នាអំពីបុគ្គលពោលពាក្យថា សច្ចិកត្ថ ជាមុនសិន

*បណ្ដាពាក្យទាំងនោះ ពាក្យថា "លោកដឹងបុគ្គលបានដោយសច្ចិកត្ថបរមត្ថឬ ?" នេះ ជាពាក្យសួរ ។*

*ពាក្យថា* **"អាមន្តា"** *នេះ ជាពាក្យឆ្លើយយល់ព្រម ។*

***សួរថា*** *ក៏ពាក្យសួរដែលពោលថា "លោកនៅដឹងបុគ្គលបានដោយសច្ចិកត្ថបរមត្ថ" និងពាក្យយល់ព្រមដែលពោលថា* **"អាមន្តា"** *នេះ ជាពាក្យរបស់នរណា ?*

*ឆ្លើយថា ពាក្យសួរ និងពាក្យយល់ព្រមនេះ នរណាមួយ ក៏មិនគួរនឹងពោលថា ជាពាក្យរបស់បុគ្គលផ្សេងឡើយ, ព្រោះថា ក្នុងបករណ៍នេះ ព្រះមានព្រះភាគទ្រង់តាំងមាតិកា គឺគោលធម៌ទុកសម្រាប់ជាបែបផែន ដើម្បីលាងជម្រះលទ្ធិដែលយល់ឃើញខុសទាំងឡាយមានប្រការផ្សេងៗ ។ ព្រះមោគ្គលីបុត្តតិស្សត្ថេរ លោកតាំងមាតិកានេះ តាមន័យដែលព្រះសាស្ដាទ្រង់ប្រទានទុករួចហើយ ក៏ចែកសេចក្ដីដែលព្រះសាស្ដា ទ្រង់សម្ដែងទុកមក*

នោះ ៗ ចំណែកវាទមគ្គ គឺគន្លងនៃវាទៈដែលព្រះសាស្ដាទ្រង់សម្ដែងប្រាប់ទុកក្នុងបករណ៍នេះ មានប្រមាណប៉ុនណា, ព្រះថេរៈលោកមិនបានសម្ដែងវាទមគ្គ ដែលជាពាក្យពេចន៍វិវាទគ្នានឹងវាទៈ ដោយវាទៈមានប្រមាណប៉ុណ្ណោះដែរ; ក៏កាលបើមានសេចក្ដីដូច្នេះ ដើម្បីប្រយោជន៍ដល់ការកំណត់ចំណាំអត្ថនៃពាក្យពេចន៍ទាំងនោះ បានដោយងាយ ខ្ញុំ (ព្រះពុទ្ធឃោសាចារ្យ) នឹងសម្ដែងវិភាគ គឺការចែកសេចក្ដីយ៉ាងនេះ គឺជាពាក្យសួររបស់សកវាទី ១, ជាពាក្យឆ្លើយរបស់បរវាទី ១, ជាពាក្យសួររបស់បរវាទី ១ និងជាពាក្យឆ្លើយតបរបស់សកវាទី ១ ហើយនឹងពណ៌នាសេចក្ដីដូចតទៅ ៖

ក៏ពាក្យថា **"បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមដ្ឋេន"** នេះ ជាពាក្យសួររបស់សកវាទី ។ ដោយពាក្យសួរនោះ លោកសម្ដែងថា ជនឯណាជាបុគ្គលវាទី មានសេចក្ដីយល់ឃើញយ៉ាងនេះថា បុគ្គលមាន បណ្ឌិតគួរសួរជនទាំងអស់នោះ យ៉ាងនេះ ៖

***សួរថា*** ជនឯណាជាបុគ្គលវាទី គឺអ្នកមានវាទៈថា បុគ្គលមានដោយពិតប្រាកដ ?

ឆ្លើយថា ពួកភិក្ខុវជ្ជីបុត្តកៈ ភិក្ខុនិកាយសមិតិយៈក្នុងព្រះពុទ្ធសាសនា

*និងអន្យតិត្ថិយជាច្រើន ខាងក្រៅព្រះពុទ្ធសាសនា* * ។

*បណ្ដាពាក្យថា* **“បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមដ្ឋេន”** *ទាំងអស់នោះ ពាក្យថា* **“បុគ្គលោ** = *បុគ្គល”* *បានដល់ អត្តា សត្វ និងជីវៈ ។ ពាក្យថា* **“ឧបលព្ភតិ”** *លោកអធិប្បាយថា អ្នកចូលដល់ហើយរមែងដឹងបាន គឺរមែងដឹងបានដោយបញ្ញា ។ ពាក្យថា* **“សច្ចិកដ្ឋោ”** *ក្នុងពាក្យថា* **“សច្ចិកដ្ឋបរមដ្ឋេន”** *នេះ បានដល់ អត្ថដ៏ពិត ដែលបណ្ឌិតមិនគប្បីកាន់យកដោយអាការដែលមិនពិត, ដូចថ្ងៃបណ្ដើរកូនដែលជាកលមាយាជាដើម ។ ពាក្យថា* **“បរមដ្ឋោ”** *បានដល់ អត្ថដ៏ឧត្តម ដែលបណ្ឌិតមិនគប្បីកាន់យកដោយអំណាចនៃពាក្យដែលនិយាយតៗ គ្នាមកជាដើម, អធិប្បាយថា សកវាទីសួរថា ប្រភេទនៃធម៌ ៥៧ យ៉ាង ដែលព្រះមានព្រះភាគទ្រង់សម្ដែងទុកដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ និងឥន្ទ្រិយ ២២ ដោយអត្ថទាំងពីរ គឺសច្ចិកដ្ឋៈ និងបរមដ្ឋៈនោះថា លោកនៅដឹងបុគ្គលបានដោយសច្ចិកដ្ឋ-បរមដ្ឋ ដូចនៅដឹងរូបបរមត្ថឬជាដើមខាងមុខ, ប្រភេទនៃធម៌នោះ បណ្ឌិតរមែងនៅដឹងបុគ្គលបាន តាមសេចក្ដីយល់ឃើញរបស់លោកដូច្នោះឬ ?*

---

* ទាំងពីរនិកាយនេះ មានសេចក្ដីយល់ថា បុគ្គលមានដោយបរមត្ថ ដោយអធិប្បាយថា បុគ្គលរបស់គេមិនមែនខន្ធ ៥ មិនក្រៅពីខន្ធ ៥ ដូចមិនមែនភ្នក់ភ្លើង, តែមិនក្រៅពីភ្នក់ភ្លើង ខុសគោលអនត្តារបស់ព្រះពុទ្ធសាសនា លទ្ធិនេះត្រូវព្រះមោគ្គល្លីបុត្តតិស្សត្ថេរវាយប្រហារច្រើនជាងលទ្ធិដទៃៗ ។

បរវាទីឆ្លើយយល់ព្រមថា “ **អាមន្តា** = មែន ឬត្រូវហើយ” ក៏ពាក្យយល់ព្រមដែលមានមកក្នុងទីផ្សេងៗ លោកប្រើពាក្យ “**អាម ភន្តេ** = ករុណាមែន” និងប្រើពាក្យថា “ **អាម** = មែន” ជាដើម, តែក្នុងព្រះអភិធម្មនេះ ពាក្យយល់ព្រមលោកប្រើពាក្យថា “**អាមន្តា** = មែន ឬត្រូវហើយ” ។

អធិប្បាយក្នុងពាក្យថា “**អាមន្តា**” តទៅ ៖

ក៏បរវាទីបុគ្គល គឺអ្នកមានវាទៈថា បុគ្គលមានការកាន់យកព្រះសូត្រដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា “បុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍ស្រោចស្រង់ដល់ខ្លួនមាន” ហើយទើបប្រកាន់យកសេចក្ដីយល់ឃើញថា ព្រះមានព្រះភាគ ព្រះអង្គជាសច្ចវាទី ព្រះអង្គមានវាទៈដែលរកទោសមិនបាន រមែងមិនទ្រង់សម្ដែងធម៌ ដោយសមត្ថភាពនៃពាក្យដែលបានទទួលស្ដាប់តៗ គ្នាមក ក៏ព្រោះហេតុដែលព្រះអង្គទ្រង់ធ្វើលោកនេះ ព្រមទាំងទេវលោក ឲ្យជាក់ច្បាស់ដោយព្រះអង្គឯង ហើយប្រកាសសាសនា ព្រោះហេតុនោះ ពាក្យថា បុគ្គលណាដែលព្រះមានព្រះភាគត្រាស់ទុកថា “បុគ្គលអ្នកប្រតិបត្តិដើម្បីប្រយោជន៍ឃឹតយោងដល់ខ្លួនមាន” ដូច្នេះ បុគ្គលនោះ

ត្រូវមានដោយសច្ចិកដ្ឋ និងបរមដ្ឋ* ដូច្នោះ ទើបឆ្លើយទទួលថា **អាមន្តា** = មែន ។ ពេលនោះ សកវាទីពោលមិនឲ្យឱកាសដល់បរវាទីអ្នកមានសំអាង ដែលភ្ញាំងភ្ញាត់ដូច្នោះ ទើបពោលថា សភាវៈណាមានអត្ថដ៏ពិត ជាបរមត្ថ រមែងមាន លោកនៅដឹងបុគ្គលនោះ បានដោយអត្ថដ៏ពិត និងអត្ថយ៉ាងខ្ពស់នោះ ដែរឬ ?

គប្បីជ្រាបអធិប្បាយ ក្នុងពាក្យថា **សច្ចិកត្ថ** និង **បរមត្ថ** តទៅ ៖

ប្រភេទនៃធម៌ ៥៧ យ៉ាង មានរូបជាដើម ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយថា "ធម៌ណាមានបច្ច័យ មិនមានបច្ច័យ ជាសង្ខតៈ ជាអសង្ខតៈ ជារបស់ទៀង មិនទៀង មាននិមិត្ត មិនមាននិមិត្ត ធម៌ទាំងនោះ បណ្ឌិតមិនគប្បីកាន់យកដោយសម្មតិសច្ច និងមិនគប្បីកាន់យកតាមពាក្យនិយាយតៗ គ្នាមកទេ" ជាដើម ។ ប្រភេទនៃធម៌ ៥៧ យ៉ាងនេះឯង ឈ្មោះថា **សច្ចិកត្ថ** ព្រោះភាវៈនៃខ្លួន គឺសភាវៈនីមួយៗ នោះ ជាសភាវៈមានពិតមែន និងបានឈ្មោះថា **បរមត្ថ** ព្រោះការប្រចក្សច្បាស់ដោយខ្លួនឯង គឺដល់តួសភាវៈនោះ ដោយមិនត្រូវជឿតាមពាក្យនិយាយតៗ គ្នាទេ ។

---

* ពាក្យថា **សច្ចិកដ្ឋ** និង **បរមត្ថ** ពោលដោយអត្ថហើយ ក៏ដូចគ្នា, ផ្សេងគ្នាតែព្យញ្ជនៈ គឺសំដៅដល់ចិត្ត ចេតសិក រូប និងនិព្វាន ។ ចំណែកពាក្យថា **បុគ្គល** ត្រឹមតែជាឧបាទានប្បញ្ញត្តិប៉ុណ្ណោះ ។

ព្រះសកវាទីចាប់យកសេចក្ដីទាំងពីរយ៉ាងនេះ ទើបសួរបញ្ជាក់ថា សភាវធម៌ណា ដែលជាសច្ចិកដ្ឋ និងបរមត្ថមាន លោកនៅដឹងសភាវធម៌នោះ ដោយសច្ចិកដ្ឋ និងបរមត្ថនោះឬ ?

ពាក្យថា **"តតោ"** ជាតតិយាវិភត្តិ ព្រោះហេតុដូច្នោះ ក្នុងទីនេះ ទើបអធិប្បាយថា លោកនៅដឹងបុគ្គលនោះ បានដោយសច្ចិកដ្ឋបរមត្ថនោះឬ ? ត្រង់នេះ លោកអធិប្បាយទុកថា សកវាទីសួរថា សភាវធម៌ណាជាសច្ចិកដ្ឋ តាមអាការដែលផ្សេងដោយលក្ខណៈ មានរុប្បនលក្ខណៈ * ជាដើម ឬដែលផ្សេងដោយសភាវធម៌ មានធម៌ដែលមានបច្ច័យតាក់តែងជាដើម លោកនៅដឹងបុគ្គលនោះ បានដោយអាការនោះឬ ?

ត្រង់ពាក្យថា ***មិនគប្បីពោលទេ*** នេះ ជាពាក្យមើលងាយរបស់ព្រះបរវាទី អធិប្បាយថា ពេលបរវាទីនោះ មិនប្រាថ្នាពាក្យដែលសកវាទីនោះពោល គឺមិនឃើញផង ទើបពោលបដិសេធពាក្យព្រះបាលីថា **"ន ហេវំ វត្តព្វេ"** នេះ ចែកបទជា **"ន ហិ ឯវំ វត្តព្វេ"** ឬជា **"នហេ ឯវំ"** ដូច្នេះក៏គួរ; បទទាំងពីរនោះ ក៏ប្រែថា ***មិនគប្បីពោលយ៉ាងនេះទេ*** ដូចគ្នា ។

---

* ពាក្យថា **លក្ខណៈ** មានច្រើនយ៉ាងដូចជា : **រុប្បនលក្ខណៈ** បានដល់ លក្ខណៈដែលវិនាសទៅ ព្រោះវិរោធិប្បច្ច័យជាដើម; **បច្ចត្តលក្ខណៈ** បានដល់ លក្ខណៈដែលមានចំពោះខ្លួន; **សាមញ្ញ-លក្ខណៈ** បានដល់ លក្ខណៈដែលស្មើគ្នា មានសេចក្ដីមិនទៀងជាដើម ។

ត្រង់ពាក្យថា ***ចូរលោកដឹងនិគ្គហៈ គឺសេចក្ដីខុសឆ្គងចុះ*** ជាពាក្យរបស់សកវាទី, អធិប្បាយថា សកវាទីពោលថា លោកពោលយល់ព្រមបញ្ហាមុនថា ***"មែន"*** , តែត្រឡប់បដិសេធក្នុងបញ្ហាក្រោយថា មិនគប្បីពោលយ៉ាងនោះទេ ពាក្យមុនមិនសមជាមួយនឹងពាក្យក្រោយ, ព្រោះហេតុនោះ ចូរលោកទទួលនូវកំហុសនោះចុះ គឺចូរទទួលនូវកំហុសទៅ កាលសកវាទីឲ្យបរវាទីទទួលនិគ្គហៈយ៉ាងនេះហើយ ឥឡូវនេះ ពេលនឹងធ្វើនិគ្គហៈនោះឲ្យប្រាកដ ដោយអំណាចនៃ **ឋបនា** គឺការតាំង, **បាបនា** គឺការឲ្យដល់ និង **អារោបនា** គឺការលើកឡើង, អំពីអនុលោមប្បដិលោម ទើបពោលពាក្យថា ***ប្រសិនបើបុគ្គល*** ជាដើម ។

បណ្ដាពាក្យទាំងអស់នោះ ពាក្យថា "ប្រសិនបើ លោកនៅដឹងថាបុគ្គល" អធិប្បាយថា បើលោកនៅដឹងបុគ្គលបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ។ ត្រង់ពាក្យថា **"ហញ្ចិ បុគ្គលោ ឧបលព្ភតិ"** ជាដើមនេះ ឈ្មោះថា ***អនុលោមឋបនា*** ព្រោះជាលក្ខណៈនៃការឲ្យដល់និគ្គហៈ និងការលើកនិគ្គហៈឡើងពីការតាំងទុករបស់បរវាទី ។ ត្រង់ពាក្យថា **"តេន វត រេ"** ជាដើម ឈ្មោះថា ***អនុលោមប្បាបនា*** ព្រោះនិគ្គហៈដែលលោកឲ្យដល់ហើយ ក្នុងចំណែកនៃអនុលោម ។ បណ្ដាពាក្យទាំងអស់នោះ ពាក្យថា **"តេន"** ជា

ពាក្យសម្តែងដល់ហេតុ ។ ពាក្យថា **“ខត”** ជាពាក្យសម្តែងដល់សេចក្តីជឿនោះ ។ ពាក្យថា **“រេ”** ជាពាក្យសម្រាប់ហៅ ។ លោកអធិប្បាយ ពាក្យថា **“តេន ខត រេ ខត្តព្វេ”** នេះទុកថា ម្នាលអ្នកមានមុខរីករាយ ដ៏ចម្រើន ព្រោះហេតុនោះ ទើបខ្ញុំពោលពាក្យនោះពិត ។ ត្រង់ពាក្យថា **“យំ តត្ថ វទេសិ”** ជាដើម ឈ្មោះថា ***អនុលោមារោបនា*** ព្រោះនិគ្គហៈ លោកលើកឡើងហើយក្នុងចំណែកនៃអនុលោម ។ ឯបទថា **“មិច្ឆា”** ក្នុងបទទីបំផុតនៃអនុលោមនោះ អ្នកសិក្សាគប្បីនាំពាក្យថា **“ឥទន្តេ”** មកប្រកបទុកខាងមុខនៃពាក្យថា **“មិច្ឆា”** នោះ ។ ក៏ក្នុងពាក្យនេះ លោកអធិប្បាយថា “នេះជាកំហុសរបស់លោក” ត្រង់សេចក្តីនេះ មានក្នុងព្រះបាលីខាងមុខនុ៎ះហើយ ។ ត្រង់ពាក្យថា **“នោ ចេ បន ខត្តព្វេ”** ជាដើម ឈ្មោះថា ***បដិលោមឋបនា*** ព្រោះជាលក្ខណៈនៃការឲ្យដល់ និងការលើកនិគ្គហៈឡើងពីបដិលោម ព្រោះលោកតាំងទុកក្នុងពាក្យបដិសេធថា ***មិនគប្បីពោលយ៉ាងនោះទេ*** ។ ត្រង់ពាក្យថា **“នោ ខត រេ”** ជាដើម ឈ្មោះថា ***បដិលោមប្បាបនា*** ព្រោះនិគ្គហៈដែលលោកឲ្យដល់ហើយ ក្នុងចំណែកនៃបដិលោម ។ ត្រង់ពាក្យថា **“យំ តត្ថ វទេសិ”** ជាដើមទៀត ឈ្មោះថា ***បដិលោមារោបនា*** ព្រោះលោកលើកនិគ្គហៈក្នុងផ្នែកនៃបដិលោមឡើង ។ បទថា **“មិច្ឆា”** សូម្បីក្នុង

ទីបំផុតនេះ ក៏គប្បីនាំពាក្យថា **"តទនេ្ត"** មកទុកខាងមុខដូចគ្នា ។ ក្នុងទីទាំងឡាយដែលមានសភាពយ៉ាងនេះ សូម្បីខាងមុខ ក៏មានន័យដូចគ្នានេះដែរ ។

បណ្ឌិតគប្បីសរុបសេចក្ដីផ្ដើមពីដំបូងក្នុងពាក្យថា **"ហញ្ចិ មុគ្គលោ ។ ល ។ សច្ចិកដ្ឋបរមដ្ឋេន"** នោះ ដូចតទៅនេះ ៖

បើថា លោកនៅដឹងបុគ្គលបានដោយសច្ចិកដ្ឋ និងបរមត្ថមែន ដោយហេតុនោះឯង ទើបពោលថា ខ្ញុំនៅដឹងបុគ្គលនោះ បានដោយសច្ចិកត្ថ-បរមត្ថនោះ ។ ក៏លោកពោលពាក្យណា ក្នុងបញ្ហាដំបូងនោះឯងថា ខ្ញុំនៅដឹងបុគ្គលបានដោយសច្ចិកត្ថបរមត្ថ, តែក្នុងបញ្ហាទីពីរ លោកមិនពោលថា "សភាវធម៌ណា ជាសច្ចិកត្ថបរមត្ថ ខ្ញុំនៅដឹងបុគ្គលនោះបាន ដោយសភាវៈនោះ" ។ ពាក្យថា **"តទនេ្ត មិច្ឆា"** បានដល់ ជាការតាំង ការឲ្យដល់ និងការលើកឡើងតែអនុលោម ដូចពណ៌នាមកពីមុននេះ ។

ឯបរវាទីមិនបានពោលក្នុងបញ្ហាទីពីរថា "ខ្ញុំនៅដឹងបុគ្គលនេះ បានដោយអត្ថដ៏ពិត និងអត្ថយ៉ាងខ្ពស់នោះ" ។ ក្នុងបញ្ហាដំបូង ក៏មិនគួរពោលយល់ព្រមដូចគ្នា ។ ក្នុងបញ្ហាដំបូងនុ៎ះឯង លោកពោលថា ខ្ញុំនៅដឹងបុគ្គលដោយសច្ចិកដ្ឋ និងបរមត្ថ, តែក្នុងបញ្ហាទីពីរ មិនពោលថា "ខ្ញុំនៅដឹងបុគ្គលនោះ បានដោយសច្ចិកដ្ឋ និងបរមត្ថនោះ" ដូច្នេះទេ, ពាក្យថា **"តទនេ្ត**

**មិច្ឆា"** បានដល់ ការតាំង ការឲ្យដល់ ការលើកឡើងពីបដិលោមយ៉ាងនេះ ។

ពាក្យថា ***"រមែងដឹង"*** ជាដើម ឈ្មោះថា អនុលោមបញ្ចកៈ ព្រោះជាពាក្យដែលលោកពោលដល់ **និគ្គហៈ** ពោលដល់ **បាបនា** និង **អារោបនា** ពីអនុលោម និងបដិលោម ៤ រួមត្រូវជា ៥ ដោយប្រការដូច្នេះ ។ ក្នុងធម៌ទាំងអស់នោះ **និគ្គហៈ** លោកធ្វើទុកពីរយ៉ាង គឺនិគ្គហៈមួយធ្វើ ដោយ **បាបនា** និង **អារោបនា** ពីអនុលោម, និគ្គហៈមួយផ្សេងទៀត ធ្វើដោយបាបនា និងអារោបនាពីបដិលោម ។ ម្យ៉ាងទៀត ឈ្មោះថា និគ្គហៈមួយនេះ អាស្រ័យវាទៈដំបូងថា "លោកនៅដឹងបុគ្គលបានក្នុងបញ្ហានៃពាក្យថា 'លោកចូរដឹងនិគ្គហៈ" ដូច្នេះនុ៎ះឯង ហើយទើបលើកនិគ្គហៈដំបូងឡើង ដោយអាការពីរយ៉ាង ព្រោះហេតុដូច្នោះ និគ្គហៈនេះ ទើបឈ្មោះថា ជានិគ្គហៈទី ១, សម្រាប់និគ្គហៈទី ២ នោះ បរវាទីជាអ្នកធ្វើ ជាមួយនឹងសកវាទី ព្រោះអាស្រ័យលេសន័យថា លោកមិនដឹងបុគ្គល ។ល។ ដែលនឹងមានមកខាងមុខ ៕

## ចប់អនុលោមបញ្ចកៈ

## ពណ៌នាអំពីបដិកម្មចតុក្កៈ ពួក ៤ នៃការធ្វើតប

ឥឡូវនេះ សកវាទីរមែងយល់ព្រមពាក្យដើម ព្រោះនៅដឹងបុគ្គលមិនបាន ដោយបរមត្ថសច្ច ក៏ពិតមែនហើយ, ក៏ប៉ុន្តែថា ក្នុងបញ្ហាក្រោយលោកក៏បដិសេធដោយអំណាចនៃសម្មតិសច្ច ឬដោយអំណាចនៃមិស្សក-សច្ច ។ តែបរវាទីអាស្រ័យវាទៈលេសន័យត្រឹមតែថា "រមែងដឹងមិនបានទេ" ដូច្នេះ ទើបធ្វើតប គឺធ្វើនិគ្គហកម្មដែលសកវាទីធ្វើដល់ខ្លួនវិញ ហើយពោលថា ចូរលោកទទួលដឹងបដិកម្ម គឺការធ្វើតប ដូចការបន្ទោសតបរបស់អ្នកស្ដីបន្ទោស ដោយពាក្យថា "លោកទទួលពាក្យមុនហើយ ខាងក្រោយលោកបដិសេធ" ។ ឥឡូវនេះ និគ្គហៈដែលសកវាទីធ្វើការតាំងវាទៈទុកក្នុងអនុលោម និងបដិលោម ដោយវិធីណា បរវាទីនោះ ពេលនឹងធ្វើបដិកម្មនោះ ឲ្យប្រាកដដោយវិធីនោះ ទើបពោលពាក្យថា ***"ប្រសិនបើបុគ្គល"*** ជាដើម ។ ខនោះ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងពេលក្រោយនុ៎ះឯង ។ ក៏ក្នុងសេចក្ដីនេះ ឈ្មោះថា **ឋបនា** ព្រោះការតាំងទុកនូវចំណែករបស់បរវាទីដែលគ្រាន់តែជាពាក្យតាំងទុកប៉ុណ្ណោះ ដើម្បីបញ្ជាក់ថា នេះជាទោសរបស់លោក មិនបានធ្វើនិគ្គហៈ ឬបដិកម្មឲ្យប្រាកដ, តែការធ្វើឲ្យប្រាកដដល់សកវាទីនោះ រមែងមាន ដោយ ***ពាបនា*** ផង ដោយ ***អារោបនា*** ផង

ព្រោះហេតុដូច្នោះ ខនេះ ទើបឈ្មោះថា បដិកម្មចតុក្កៈ ព្រោះបដិកម្ម គឺការធ្វើតប ឬការធ្វើដែលលោកធ្វើហើយដោយអាការ ៤ យ៉ាងវិញ ដោយអំណាចនៃឋាបនា និងអារោបនាពីអនុលោម និងបដិលោម មានប្រការដូច្នេះ ។ គប្បីជ្រាបចតុក្កៈពួក ៤ ដូចពណ៌នាមកនេះ ៕

ចប់បដិកម្មចតុក្កៈ

— — –

## ពណ៌នាអំពីនិគ្គហចតុក្កៈ ពួក ៤ នៃការសង្កត់សង្កិន

កាលធ្វើបដិកម្មយ៉ាងនេះហើយ ឥឡូវនេះ បរវាទីណាដែលត្រូវសកវាទីធ្វើនិគ្គហៈក្នុងអនុលោមបញ្ចកៈដល់ខ្លួន បានអាស្រ័យវាទៈដែលមានលេសន័យនោះឯង ត្រង់បញ្ហានោះ សម្ដែងសេចក្ដីមិនយល់ព្រម ដោយពោលពាក្យជាដំបូងថា **“ត្វះញ្ច បន មញ្ញសិ”** ដូច្នេះ ។ បណ្ដាពាក្យទាំងអស់នេះ ពាក្យថា **“ត្វញ្ច បន មញ្ញសិ** = ក៏លោកនៅអះអាង” ។

ពាក្យថា ***“គប្បីពោល”*** នេះ លោកពោលសំដៅយកពាក្យយល់ព្រមថា ***“មែន”*** ក្នុងបច្ចនិកៈ ។ ឯពាក្យថា ***“មិនគប្បីពោលទេ”*** នេះ លោកពោលសំដៅយកពាក្យជំទាស់ គឺពាក្យបដិសេធថា ***“មិនគប្បីពោលយ៉ាងនោះទេ”*** ; ពាក្យថា **“តេន ត្វំ តត្ថ”** បានដល់ ដោយហេតុនោះ លោក

*នោះឯង រមែងមានក្នុងគំនិតចូលចិត្តដែលដឹងមិនបាន ។ ពាក្យថា **"ពោលយល់ព្រម"** បានដល់ យល់ព្រមថា **"យ៉ាងនេះមែន"** ។ ពាក្យថា **"គប្បីនិគ្គហៈយ៉ាងនេះ"** សេចក្ដីថា ពេលជំទាស់ដោយពាក្យថា **"មិនគប្បីពោលទៀតទេ ឈ្មោះថា គប្បីនិគ្គហៈយ៉ាងនេះ"** ។ ពាក្យថា **"ព្រោះដូច្នោះ ទើបយើងនិគ្គហៈលោក"** សេចក្ដីថា ពេលនោះ ពួកយើងរមែងនិគ្គហៈនូវលោកដែលគួរដល់ការនិគ្គហៈមែនពិត ។ ពាក្យថា **"លោកជាអ្នកដែលយើងនិគ្គហៈល្អហើយ"** សេចក្ដីថា លោកឈ្មោះថា ជាអ្នកដែលយើងនិគ្គហៈត្រឹមត្រូវហើយ ព្រោះជានិគ្គហៈតាមមតិរបស់ខ្លួន ។*

*បរវាទីនោះ លុះសម្ដែងនូវភាវៈដែលខ្លួនគប្បីនិគ្គហៈយ៉ាងនេះហើយ ឥឡូវនេះ ពេលនឹងនិគ្គហៈសកវាទីនោះ ទើបពោលពាក្យថា **"ប្រសិនបើ"** ជាដើម ។*

*បណ្ដាពាក្យទាំងអស់នោះ បណ្ឌិតគប្បីជ្រាប* **ឋបនា បាបនា** *និង* **អារោបនា** *ដោយន័យដែលពោលហើយ ក្នុងគ្រាក្រោយនុ៎ះឯង ។ ក៏ក្នុងបទជាទីបំផុត ពាក្យថា **"នេះជាកំហុសរបស់លោក"** អធិប្បាយថា ពាក្យរបស់លោកនេះខុស ។ ត្រង់នេះ ឈ្មោះថា* **និគ្គហចតុក្កៈ** *ព្រោះបរវាទីធ្វើនិគ្គហៈដោយអាការ ៤ យ៉ាង ដោយវាទៈដែលមានលេសន័យ ៕*

## ពណ៌នាអំពីឧបនយនចតុក្កៈ ពួក ៤ នៃការបន្ទោនទៅ

*ពេលបរវាទីធ្វើនិគ្គហៈយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្ដែងថា "បើនិគ្គហៈដែលយើងធ្វើដល់លោកនេះ ជានិគ្គហៈខុសនោះ, និគ្គហៈឯណាដែលលោកធ្វើហើយដល់ខ្ញុំ ក្នុងអនុលោមបញ្ចកៈ នាពេលក្រោយ, និគ្គហៈនុ៎ះក៏ជានិគ្គហៈខុសដែរ" ដូច្នេះ ទើបពោលពាក្យជាដើមថា "ប្រសិនបើ និគ្គហៈដែលយើងធ្វើដល់លោកនេះ ជានិគ្គហៈខុសមែន" ។ ក្នុងសេចក្ដីនេះអធិប្បាយថា បើវាទៈនេះ ជាវាទៈដែលយើងនិគ្គហៈខុសមែន ។ ម្យ៉ាង-ទៀតថា បើនិគ្គហៈដែលយើងធ្វើដល់លោកនេះ ជានិគ្គហៈខុសមែន ។ ត្រង់សេចក្ដីថា* ***"លោកចូរយឹងដូចគ្នានោះឯង ក្នុងនិគ្គហៈដែលលោកបានធ្វើដល់យើង"*** *សេចក្ដីថា និគ្គហៈដែលលោកធ្វើហើយ ដល់យើងក្នុងពេលមុនសូម្បីក្នុងនិគ្គហៈនុ៎ះ លោកចូរដឹងនិគ្គហៈនោះៗ ផង ។*

*ឥឡូវនេះ និគ្គហៈឯណាដែលសកវាទីធ្វើហើយដល់បរវាទីនោះ ក្នុងពេលក្រោយ ទើបបរវាទីសម្ដែងនូវពាក្យនោះ ដោយពាក្យជាដើមថា* ***"គប្បីពោល"*** *ដូច្នេះ កាលនឹងបន្ទោនទៅនូវនិគ្គហៈនោះ មិនឲ្យមាននិគ្គហៈទៀត ទើបពោលពាក្យជាដើមថា " ក៏យើងអ្នកបដិញ្ញាយ៉ាងនេះ ដោយបដិញ្ញាដែលលោកមិនគប្បីនិគ្គហៈយ៉ាងនេះ ក្នុងពាក្យថា* **" នោ ច មយំ តយា**

**គត្ថ ហេតាយ បដិញ្ញាយ”** ជាដើមនេះ អធិប្បាយថា និគ្គហៈនោះ លោកធ្វើដល់យើង ជានិគ្គហៈខុសហេតុទេ, ព្រោះហេតុនោះ ក្នុងអនុលោម-បញ្ចកៈនោះ ទើបយើងយល់ព្រមយ៉ាងនេះ ដោយពាក្យបដិញ្ញានោះថា **“អាមន្តា** = មែន” ទោះយើងពោលពាក្យបដិសេធថា “មិនគួរពោលយ៉ាងនោះទៀតទេ” ដូច្នេះ ក៏ត្រូវលោកនិគ្គហៈយ៉ាងនេះថា ចូរលោកទទួលដឹងនិគ្គហៈនោះទៅ, សូម្បីលោកនិគ្គហៈយើង ដែលជាអ្នកមិនគួរនិគ្គហៈយ៉ាងនេះ, ក៏ពួកយើងត្រូវលោកនិគ្គហៈខុសហើយ ។

ឥឡូវនេះ បរវាទីនោះ អាស្រ័យនិគ្គហៈឯណាដែលបានពោលថា “ពួកយើងជាអ្នកដែលលោកនិគ្គហៈខុសហើយ” ដូច្នេះ ដើម្បីសម្ដែងនិគ្គហៈដែរនោះ ទើបពោលពាក្យថា **“ហញ្ចិ បុគ្គលោ ។ បេ ។ តេនហេ មិច្ឆា”** ជាដើម នេះឈ្មោះថា **ឧបនយនចតុក្កៈ** ព្រោះនិគ្គហៈដែលបរវាទីនោះបង្អោនទៅហើយដោយ ***ឋាបនា*** និង ***អារោបនា ៤*** អំពីអនុលោម និងបដិលោម ដូចពណ៌នាមកដូច្នេះ ៕

## ចប់ឧបនយនចតុក្កៈ

## ពណ៌នាអំពីនិគ្គមចតុក្កៈ

## ពួក ៤ នៃនិគ្គម គឺសរុបនិគ្គហៈទី ១-៨

ឥឡូវនេះ ឈ្មោះថា **និគ្គមចតុក្កៈ** មានពាក្យថា ***"យើងមិនគប្បីត្រូវនិគ្គហៈយ៉ាងនេះទេ"*** ជាដើម ។ ក្នុងសេចក្ដីថា ***"យើងមិនគប្បីត្រូវនិគ្គហៈយ៉ាងនេះទេ"*** បើសេចក្ដីនៃនិគ្គហៈនេះ ជានិគ្គហៈខុសដែលយើងឲ្យសម្រេចហើយមែនពិត, លោកក៏មិនគប្បីនិគ្គហៈយើងយ៉ាងនេះឡើយ ។ ពាក្យថា ***"ដោយហេតុនោះឯង"*** អធិប្បាយថា ដោយហេតុនោះ និគ្គហៈនេះជានិគ្គហៈខុស ព្រោះហេតុដូច្នោះ លោកទើបតែនិគ្គហៈឯណានឹងយើងថា "បើបុគ្គល ។ល។ នេះជាកំហុសរបស់លោក" ដូច្នេះ ការនិគ្គហៈរបស់លោកនេះខុស ។ ត្រង់សេចក្ដីថា ***"ដោយហេតុនោះឯង និគ្គហៈដែលលោកធ្វើហើយ"*** អធិប្បាយថា និគ្គហៈណាដែលលោកធ្វើហើយ, និគ្គហៈនោះជាការធ្វើដែលមិនល្អព្រោះហេតុណា; ជាសេចក្ដីខុសដោយហេតុនោះឯង ។ បដិកម្មណាដែលយើងធ្វើហើយ បដិកម្មនោះឯង យើងធ្វើល្អហើយ ។ ក៏ការញ៉ាំងកថាមគ្គឲ្យសម្រេចនេះ លោកធ្វើហើយ ធ្វើល្អហើយ ដោយអំណាចនៃបដិកម្មចតុក្កៈជាដើម ។ ត្រង់សេចក្ដីនេះ គប្បីជ្រាបថា ឈ្មោះថាអនុលោមបច្ចនិកបញ្ចកៈដែលលោកបញ្ចប់ហើយ ដោយអំណាចនៃបដិកម្ម

*និគ្គហៈ ឧបនយនៈ និងនិគ្គមចតុក្កៈទាំងឡាយ មានពាក្យថា **"ដឹងមិនបាន"** ជាដើម នៃអនុលោមបញ្ចកៈ មានពាក្យថា **"រមែងដឹងបុគ្គលជាដើម"** ដោយប្រការដូច្នេះឯង ៕*

ចប់និគ្គមចតុក្កៈ

ចប់និគ្គហៈទី ១

## ២.ឱកាសសច្ចិកត្ថ

### ពណ៌នាអំពីបច្ចនីកបញ្ចកៈពួក ៥ នៃបច្ចនីកៈ (និគ្គហៈទី ២)

*ពេលជ័យជម្នះដំបូងរបស់សកវាទី ដែលនៅមានប្រមាណប៉ុនណា, សេចក្ដីឈ្នះរបស់បរវាទីដោយវាទៈដែលមានលេសន័យក៏ដោយ ជាពាក្យធម្មតាក៏ដោយ ក៏មានប្រមាណប៉ុណ្ណោះ ។ ព្រោះហេតុដូច្នេះ គ្រាការឈ្នះដំបូងរបស់បរវាទី ក៏មានអឺចឹង, ការឈ្នះរបស់សកវាទី ដោយធម៌តាមសេចក្ដីពិត ក៏មានដូច្នោះដែរ ដើម្បីបញ្ជាក់នូវការកើតឡើងនៃវាទៈដូច្នេះ ទើបលោកផ្ដើមបច្ចនិកានុលោមបញ្ចកៈដោយពាក្យថា **"រមែងស្គាល់ដឹងបុគ្គលមិនបាន"** ជាដើម ។ ក្នុងបច្ចនិកៈនេះ ជាពាក្យសួររបស់បរវាទី ។ ពាក្យយល់ព្រមរបស់សកវាទី សំដៅយកសច្ចិកដ្ឋបរមត្ថ ដែលផ្សេងដោយរូបជាដើម ។ ពាក្យសួរបញ្ជាក់របស់បរវាទីទៀតថា "សភាវៈណាជាសច្ចិកត្ថ*

*សំដៅយកសម្មតិសច្ចសុទ្ធ ឬសម្មតិសច្ចដែលលាយដោយបរមត្ថ” ។ ពាក្យបដិសេធរបស់សកវាទីថា “មិនគួរពោលយ៉ាងនោះទេ” ព្រោះសច្ចិកត្ថបរមត្ថនោះ នរណាៗ មិនគួរពោលថា ដឹងមិនបានដោយអំណាចនៃសម្មតិសច្ចៈ ឬព្រោះការសាកសួរបុគ្គលដោយសច្ចៈទាំងពីរហើយ ។ ពាក្យថា* ***“ចូរលោកទទួលដឹងនិគ្គហៈ”*** *ដូច្នេះជាដើម ទោះបីដោយជាពាក្យធម្មតាថា លោកបដិសេធនូវពាក្យដែលលោកយល់ព្រមហើយ ជារបស់បរវាទី ។ គប្បីជ្រាបថា និគ្គហៈទីពីរអាស្រ័យវាទៈទីពីរថា “លោកមិនដឹងបុគ្គល” ដោយប្រការដូច្នេះ ។ បរវាទីលើកនិគ្គហៈឡើងហើយដោយលេសន័យនោះ ដូចពណ៌នាមកដូច្នេះ ៕*

**ចប់បច្ចនីកបញ្ចកៈ**

\- - - - - -

**បរមត្ថទីបនី**

**អដ្ឋកថាព្រះអភិធម្មបិដក**

**ឈ្មោះ បញ្ចបករណ៍**

**តតិយភាគ ៩**

**ចប់**

បោះពុម្ពលើកទី ២

រក្សាសិទ្ធិ (ហាមថតចម្លង)